ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រមងអត្ថបទច្បាប់

ឆ្នាំ ២០២៤

រៀបរៀង និងចងក្រងដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងបណ្ណសារជាតិ

មាតិកា

ព្រះរាជក្រម

២៣-៣-២០២៤	-ព្រះរាជក្រម នស/រកម/០៣២៤/០០១ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារសម្រាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងម៉ារ៉ាកេសស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីបញ្ចូលកិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធនជលផល	១
២៣-៣-២០២៤	-ព្រះរាជក្រម នស/រកម/០៣២៤/០០២ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី ការដឹកជញ្ជូនតាមផ្លូវទឹក	២១
២០-៨-២០២៤	-ព្រះរាជក្រម នស/រកម/០៨២៤/០០៣ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញា ស្តីពី ឯកភាវូបនីយកម្មនៃវិធានមួយចំនួនពាក់ព័ន្ធនឹងការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាស	១០១
២១-១១-២០២៤	-ព្រះរាជក្រម នស/រកម/១១២៤/០០៤ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី និរាករណ៍ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការជំរុញ និងសម្រួលពាណិជ្ជកម្មតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម	១៤៥
២២-១១-២០២៤	-ព្រះរាជក្រម នស/រកម/១១២៤/០០៥ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី ប្រព័ន្ធទឹកកខ្វក់	១៤៨
២២-១១-២០២៤	-ព្រះរាជក្រម នស/រកម/១១២៤/០០៦ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃកិច្ចព្រមព្រៀងស្តីពី ការទទួលយកបទប្បញ្ញត្តិបច្ចេកទេសរួមនៃអង្គការសហប្រជាជាតិសម្រាប់យានយន្ត បរិក្ខារ និងគ្រឿងបន្លាស់ដែលអាចបំពាក់និង/ឬប្រើប្រាស់ទៅលើយានយន្ត និងលក្ខខណ្ឌសម្រាប់ការទទួលស្គាល់ទៅវិញទៅមកនៃការផ្តល់អនុលោមភាពដោយឈរលើមូលដ្ឋាននៃបទបញ្ញត្តិអង្គការសហប្រជាជាតិ	១៨៤
១២-១២-២០២៤	-ព្រះរាជក្រម នស/រកម/១២២៤/០០៧ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣	២៧២
១២-១២-២០២៤	-ព្រះរាជក្រម នស/រកម/១២២៤/០០៨ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥	៣៤០

ព្រះរាជក្រម

នស/រកម/០៣២៤/ ០០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារសម្រាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងម៉ារ៉ាកេសស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីបញ្ចូលកិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធនជលផល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

១/២

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើពិធីសារសម្រាប់ធ្វើវិសោធនកម្ម កិច្ចព្រមព្រៀងម៉ារ៉ាកេសស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីបញ្ចូលកិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធនជលផល

មាត្រា១ .-

អនុម័តយល់ព្រមលើពិធីសារសម្រាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងម៉ារ៉ាកេសស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីបញ្ចូលកិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធនជលផល ដែលបានអនុម័តដោយសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី១២ នៃអង្គការពាណិជ្ជកម្មពិភពលោក នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស នាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

មាត្រា២ .-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ។

មាត្រា៣ .-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ១៤កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០២៤

ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាស់បញ្ជាប់

ប្រមុខរដ្ឋស្តីទី

ពរល.២៤០៣.២៥៧

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឌិត ទីណា

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រីប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

២/២

កិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធនជលផល

សេចក្តីសម្រេចថ្នាក់រដ្ឋមន្ត្រី ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២

សន្និសីទថ្នាក់រដ្ឋមន្ត្រី

បានឃើញកថាខណ្ឌទី១ មាត្រា១០ នៃកិច្ចព្រមព្រៀងម៉ារ៉ាកេសស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក (កិច្ចព្រមព្រៀងWTO)។

ដោយរំលឹកឡើងវិញនូវអាណត្តិដែលបានផ្តល់ជូនសមាជិក នាសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី១១ របស់អង្គការ WTO ឆ្នាំ២០១៧ នៅទីក្រុង Buenos Aires ដែលបានចែងថា សន្និសីទថ្នាក់រដ្ឋមន្ត្រីបន្ទាប់គួរអនុម័តកិច្ចព្រមព្រៀងស្តីពីវិធានគ្រប់ជ្រុងជ្រោយនិងមានប្រសិទ្ធភាព ក្នុងការហាមឃាត់ទម្រង់ជាក់លាក់នៃការឧបត្ថម្ភធនជលផលដែលរួមចំណែកដល់ការនេសាទហួសសមត្ថភាពនិងលើសកម្រិត និងលុបបំបាត់ការឧបត្ថម្ភធនលើការនេសាទខុសច្បាប់ គ្មានរបាយការណ៍និងគ្មានបញ្ញត្តិ(IUU) ដោយទទួលស្គាល់ថា ប្រព្រឹត្តកម្មពិសេសនិងដោយឡែកដែលមានលក្ខណៈសមស្របនិងប្រសិទ្ធភាពសម្រាប់សមាជិកដែលជាប្រទេសកំពុងអភិវឌ្ឍនិងអភិវឌ្ឍតិចតួចជាផ្នែកសំខាន់នៃការចរចានេះ។

បានសម្រេចដូចតទៅ៖

១- ពិធីសារសម្រាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងWTO ដែលភ្ជាប់មកជាមួយសេចក្តីសម្រេចនេះ ត្រូវបានអនុម័តនិងដាក់ជូនសមាជិកដើម្បីទទួលយក។

២- ពិធីសារនេះត្រូវបើកចំហសម្រាប់ការទទួលយកពីបណ្តាសមាជិក។

៣- ពិធីសារនេះត្រូវចូលជាធរមានដោយអនុលោមតាមបទប្បញ្ញត្តិនៃកថាខណ្ឌទី៣ មាត្រាX នៃកិច្ចព្រមព្រៀងWTO។

៤- ទោះបីមានចែងក្នុងមាត្រា៩.៤ នៃកិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធនជលផលក៏ដោយ ក្រុមចរចាផ្នែកច្បាប់ត្រូវបន្តការចរចាលើបញ្ហាដែលនៅសេសសល់ ដូចបានកំណត់ដោយឯកសារWT/MIN(21)/W/5 និងWT/MIN(22)/W/20 ក្នុងគោលបំណងផ្តល់អនុសាសន៍ដល់សន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី១៣របស់អង្គការWTO សម្រាប់បទប្បញ្ញត្តិបន្ថែមដើម្បីសម្រេចបាននូវកិច្ចព្រមព្រៀងមានលក្ខណៈគ្រប់ជ្រុងជ្រោយស្តីពីការឧបត្ថម្ភធនជលផល រួមទាំងតាមរយៈវិធានបន្ថែមចំពោះទម្រង់ជាក់លាក់នៃការឧបត្ថម្ភធនជលផលដែលរួមចំណែកដល់ការនេសាទហួសសមត្ថភាពនិងលើសកម្រិត ដោយទទួលស្គាល់ថា ប្រព្រឹត្តកម្មពិសេសនិងដោយឡែកដែលមានលក្ខណៈសមស្របនិងមានប្រសិទ្ធភាព សម្រាប់សមាជិកដែលជាប្រទេសកំពុងអភិវឌ្ឍនិងអភិវឌ្ឍតិចតួច ជាផ្នែកសំខាន់នៃការចរចានេះ។

ឯកសារភ្ជាប់
ពិធីសារសម្រាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងម៉ារ៉ាកេស ស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីបញ្ចូល កិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធនជលផល

សមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក

បានឃើញសេចក្តីសម្រេចនៃសន្និសីទថ្នាក់រដ្ឋមន្ត្រី ក្នុងឯកសារWT/MIN(22)/33 - WT/L/1144 ដែលបានអនុម័តស្របតាមកថាខណ្ឌទី១ មាត្រាX នៃកិច្ចព្រមព្រៀងម៉ារ៉ាកេសស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក(កិច្ចព្រមព្រៀង WTO)។

បានព្រមព្រៀងដូចតទៅៈ

១- នៅពេលពិធីសារនេះចូលជាធរមានស្របតាមកថាខណ្ឌទី៤ ឧបសម្ព័ន្ធ១Aនៃកិច្ចព្រមព្រៀងWTO នឹងត្រូវធ្វើវិសោធនកម្ម ដើម្បីបញ្ចូលកិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធនជលផល ដែលមានចែងក្នុងឧបសម្ព័ន្ធនៃពិធីសារនេះ នៅបន្ទាប់ពីកិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធននិងវិធានការពន្ធប៉ះប៉ូវ។

២- គ្មានខដាក់លក្ខខណ្ឌណាមួយ ត្រូវបានបង្កើតឡើងក្នុងបទប្បញ្ញត្តិនៃពិធីសារនេះឡើយ។

៣- ពិធីសារនេះត្រូវបើកចំហសម្រាប់ការទទួលយកពីបណ្តាសមាជិក។

៤- ពិធីសារនេះនឹងចូលជាធរមានស្របតាមកថាខណ្ឌទី៣ មាត្រាX នៃកិច្ចព្រមព្រៀងWTO[១]។

៥- ពិធីសារនេះត្រូវតែតម្កល់ទុកនៅអគ្គនាយកនៃអង្គការWTO ដែលអគ្គនាយកត្រូវផ្តល់ជូនភ្លាមៗនូវច្បាប់ចម្លងនិងការជូនដំណឹងអំពីការទទួលយកនៃសមាជិកនីមួយៗ ដោយអនុលោមតាមកថាខណ្ឌទី៣។

៦- ពិធីសារនេះត្រូវចុះបញ្ជិកាដោយអនុលោមតាមបទប្បញ្ញត្តិនានាដូចមានចែងក្នុងមាត្រា១០២ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។

ធ្វើនៅទីក្រុងហ្សឺណែវ នាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ជាភាសាអង់គ្លេស១ច្បាប់ បារាំង១ច្បាប់ និងអេស្ប៉ាញ ១ច្បាប់ ដែលមានតម្លៃគតិយុត្តស្មើគ្នា។

---

[១] ... ណាងនៃការគណនាការទទួលស្គាល់ក្រោមមាត្រាX : 3 នៃកិច្ចព្រមព្រៀងWTO លិខិតូបករណ៍នៃការទទួលយកដោយសហភាពអឺរ៉ុបផ្ទាល់ និងសម្រាប់ ... ភាពអឺរ៉ុបត្រូវរាប់ជា ជាការទទួលយកដោយសមាជិកស្មើនឹងចំនួនសមាជិកនៃសហភាពអឺរ៉ុបដែលជាសមាជិករបស់WTO។

២/៩

ឧបសម្ព័ន្ធ
កិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធនជលផល

មាត្រា១ .- វិសាលភាព

កិច្ចព្រមព្រៀងនេះអនុវត្តចំពោះការឧបត្ថម្ភធនដូចមានអត្ថន័យចែងក្នុងមាត្រា១.១ នៃកិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធននិងវិធានការពន្ធប៉ះប៉ូវ(កិច្ចព្រមព្រៀងSCM) ដោយមានលក្ខណៈជាក់លាក់ដូចមានចែងក្នុងមាត្រា២នៃកិច្ចព្រមព្រៀងនោះ ចំពោះការនេសាទសមុទ្រនិងសកម្មភាពពាក់ព័ន្ធការនេសាទសមុទ្រ[១ ២ ៣]។

មាត្រា២ .- និយមន័យ

សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ៖

ក- «ត្រី» សំដៅដល់ធនធានជលផលសមុទ្រមានជីវិតគ្រប់ប្រភេទ ទោះបីជាកែច្នៃឬមិនកែច្នៃក៏ដោយ។

ខ- «ការនេសាទ» សំដៅដល់ការស្វែងរក ការទាក់ទាញ ការកំណត់ទីតាំង ការចាប់ ការដកហូត ឬការប្រមូលផលត្រី ឬសកម្មភាពណាមួយដែលអាចពឹងទុកដោយសមហេតុផល ដែលនាំទៅរកការទាក់ទាញ ការកំណត់ទីតាំង ការចាប់ ការដកហូត ឬការប្រមូលផលត្រី។

គ- «សកម្មភាពពាក់ព័ន្ធនឹងការនេសាទ» សំដៅដល់ប្រតិបត្តិការទាំងឡាយណាដែលផ្តល់ការគាំទ្រឬការរៀបចំសម្រាប់ការនេសាទ រួមទាំងការឡើងផែ ការវេចខ្ចប់ ការកែច្នៃ ការផ្ទេរ ឬការដឹកជញ្ជូនត្រី រួមទាំងការផ្គត់ផ្គង់នៃបុគ្គលិក ប្រេងឥន្ធនៈ ឧបករណ៍ និងការផ្គត់ផ្គង់ផ្សេងទៀតនៅសមុទ្រ។

ឃ- «នាវា» សំដៅដល់នាវា កប៉ាល់ប្រភេទផ្សេងទៀត ឬទូកដែលប្រើ រៀបចំសម្រាប់ប្រើ ឬបំណងនឹងប្រើសម្រាប់ការនេសាទ និងសកម្មភាពពាក់ព័ន្ធនឹងការនេសាទ។

ង- «ប្រតិបត្តិករ» សំដៅដល់ម្ចាស់នាវាឬបុគ្គលណាម្នាក់ ដែលទទួលបន្ទុក ឬដឹកនាំ ឬគ្រប់គ្រងនាវា។

មាត្រា៣ .- ការឧបត្ថម្ភធនដែលរួមចំណែកដល់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ[៤]

៣.១- សមាជិកមិនត្រូវផ្តល់ឬរក្សាទុកការឧបត្ថម្ភធនណាមួយដល់នាវាឬប្រតិបត្តិករ[៥] ដែលធ្វើការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ(នេបប) ឬសកម្មភាពពាក់ព័ន្ធការនេសាទដែលគាំទ្រដល់ការនេសាទនេបប។

---

[១] សម្រាប់ភាពប្រាកដប្រជា វារីវប្បកម្មនិងការនេសាទទឹកសាបមិនត្រូវបានបញ្ចូលក្នុងវិសាលភាពនៃកិច្ចព្រមព្រៀងនេះទេ។

[២] សម្រាប់ភាពប្រាកដប្រជា ការបង់ប្រាក់រវាងរដ្ឋាភិបាលនិងរដ្ឋាភិបាលក្រោមកិច្ចព្រមព្រៀងក្នុងការឱ្យធ្វើនេសាទ មិនត្រូវចាត់ទុកថាជាការឧបត្ថម្ភធនក្នុងអត្ថន័យដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះទេ។

[៣] សម្រាប់ភាពប្រាកដប្រជា ជាគោលបំណងនៃកិច្ចព្រមព្រៀងនេះ ការឧបត្ថម្ភធនមួយត្រូវចាត់ជាបន្ទុករបស់រដ្ឋសមាជិកដែលផ្តល់វា ដោយមិនគិតពីទង់ជាតិឬការចុះបញ្ជីនាវាណាមួយដែលពាក់ព័ន្ធឬសញ្ជាតិរបស់អ្នកទទួលឡើយ។

[៤] "ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ(នេបប)" សំដៅដល់សកម្មភាពដែលមានចែងក្នុងកថាខណ្ឌទី៣ នៃផែនការសកម្មភាពអន្តរជាតិ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ ដែលត្រូវបានអនុម័តដោយអង្គការស្បៀងអាហារនិងកសិកម្ម(FAO) នៃអង្គការសហប្រជាជាតិក្នុងឆ្នាំ២០០១ ។

[៥] សម្រាប់គោលបំណងនៃមាត្រា៣ ពាក្យ "ប្រតិបត្តិករ" សំដៅដល់ប្រតិបត្តិករដែលមានចែងក្នុងមាត្រា២ ចំណុច "ង" នៅពេលមានការនេសាទខុសច្បាប់ពាក់ព័ន្ធនឹងនេបប។ សម្រាប់ភាពប្រាកដប្រជា ការហាមឃាត់លើការផ្តល់ឬរក្សាទុកការឧបត្ថម្ភធនដល់ប្រតិបត្តិករដែលពាក់ព័ន្ធការនេសាទនេបប អនុវត្តចំពោះការឧបត្ថម្ភធនដែលផ្តល់សម្រាប់ការនេសាទ និងសកម្មភាពពាក់ព័ន្ធការនេសាទនៅសមុទ្រ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

៣.២- សម្រាប់គោលបំណងនៃមាត្រា៣.១ នាវាឬប្រតិបត្តិករត្រូវចាត់ទុកថាបានចូលរួមក្នុងការនេសាទIUU ក្នុងករណីការកំណត់ដោយមានអំណះអំណាងថាបានចូលរួម ត្រូវបានធ្វើដោយតួអង្គណាមួយដូចខាងក្រោម[៦][៧]៖

ក- សមាជិកជារដ្ឋម្ចាស់ឆ្នេរ ចំពោះសកម្មភាពទាំងឡាយដែលកើតឡើងក្នុងតំបន់យុត្តាធិការរបស់រដ្ឋនោះ។
ខ- សមាជិកជារដ្ឋម្ចាស់ទង់ជាតិ ចំពោះសកម្មភាពនាវាដែលបំពាក់ទង់ជាតិរបស់រដ្ឋនោះ។
គ- អង្គការឬស្ថាប័នគ្រប់គ្រងជលផលថ្នាក់តំបន់ពាក់ព័ន្ធ(RFMO/A) ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីដែលកំណត់ដោយRFMO/A និងច្បាប់អន្តរជាតិពាក់ព័ន្ធ រួមទាំងតាមរយៈការជូនដំណឹងទាន់ពេលវេលានិងការផ្តល់ព័ត៌មានពាក់ព័ន្ធ ចំពោះតំបន់និងប្រភេទត្រីស្ថិតក្រោមដែនសមត្ថកិច្ចរបស់RFMO/A។

៣.៣- ក- ការកំណត់ដោយមានអំណះអំណាងថាបានចូលរួម[៨]ដូចមានចែងក្នុងមាត្រា៣.២ សំដៅដល់ការរកឃើញជាស្ថាពរដោយសមាជិកនិង/ឬការដាក់ក្នុងបញ្ជីជាស្ថាពរដោយRFMO/A កំណត់ថាជានាវាឬប្រតិបត្តិករបានចូលរួមក្នុងការនេសាទIUU។

ខ- សម្រាប់គោលបំណងនៃមាត្រា៣.២ក ការហាមឃាត់ដូចមានចែងក្នុងមាត្រា៣.១ត្រូវអនុវត្ត នៅពេលដែលការកំណត់ដោយសមាជិកជារដ្ឋម្ចាស់ឆ្នេរបានធ្វើឡើងដោយផ្អែកលើព័ត៌មានជាក់លាក់ និងសមាជិកជារដ្ឋម្ចាស់ឆ្នេរបានផ្តល់ដល់រដ្ឋម្ចាស់ទង់ជាតិនិងសមាជិកដែលផ្តល់ការឧបត្ថម្ភធន ក្នុងករណីត្រូវបានស្គាល់ ដោយផ្អែកតាមលក្ខខណ្ឌដូចខាងក្រោម៖

(i) ការជូនដំណឹងទាន់ពេលវេលា តាមរយៈបណ្តាញសមស្រប អំពីនាវាឬប្រតិបត្តិករដែលត្រូវបានឃាត់ទុកជាបណ្តោះអាសន្ន ដោយរង់ចាំការស៊ើបអង្កេតបន្ថែមលើករណីនៃការចូលរួមការនេសាទIUU ឬអំពីរដ្ឋម្ចាស់ឆ្នេរដែលបានផ្តួចផ្តើមការស៊ើបអង្កេតលើករណីការធ្វើនេសាទIUU រួមទាំងការយោងលើព័ត៌មានជាក់ស្តែងពាក់ព័ន្ធ ច្បាប់ជាធរមាន បទប្បញ្ញត្តិ នីតិវិធីរដ្ឋបាល ឬវិធានការពាក់ព័ន្ធផ្សេងទៀតណាមួយ។
(ii) ការផ្តល់ឱកាសសម្រាប់ការផ្លាស់ប្តូរនូវព័ត៌មានពាក់ព័ន្ធ[៩] មុនធ្វើការកំណត់ ដើម្បីឱ្យព័ត៌មានទាំងនោះត្រូវបានយកមកពិចារណាជាមូលដ្ឋានសម្រាប់ការកំណត់ចុងក្រោយអំពីការចូលរួមការនេសាទIUU។ សមាជិកជារដ្ឋម្ចាស់ឆ្នេរ អាចបញ្ជាក់អំពីបែបបទនិងរយៈពេលនៃការផ្លាស់ប្តូរព័ត៌មាន។
(iii) ការជូនដំណឹងអំពីការកំណត់ចុងក្រោយ និងការដាក់ទណ្ឌកម្មណាមួយ រួមទាំងរយៈពេលនៃទណ្ឌកម្មប្រសិនបើអាច។

សមាជិកជារដ្ឋម្ចាស់ឆ្នេរ ត្រូវជូនដំណឹងទៅគណៈកម្មាធិការអំពីការកំណត់ចុងក្រោយ ដូចមានចែងក្នុងមាត្រា៩.១ (ក្នុងកិច្ចព្រមព្រៀងនេះ ហៅថា «គណៈកម្មាធិការ»)។

៣.៤- សមាជិកដែលផ្តល់ការឧបត្ថម្ភធន ត្រូវផ្អែកលើលក្ខណៈ ស្ថានទម្ងន់ និងការប្រព្រឹត្តដដែលៗនៃការនេសាទIUU ដែលប្រព្រឹត្តដោយនាវាឬប្រតិបត្តិករ ពេលដែលធ្វើការកំណត់រយៈពេលនៃការហាមឃាត់ណាមួយ ដូចមានចែងក្នុងមាត្រា៣.១។ ការហាមឃាត់ដូចមានចែងក្នុងមាត្រា៣.១ ត្រូវបានអនុវត្ត យ៉ាងហោចណាស់មានពេលវេលាស្មើនឹងការ

[៦] មាត្រានេះមិនមានន័យក្នុងការផ្តល់កាតព្វកិច្ចដល់រដ្ឋសមាជិកធ្វើការផ្តួចផ្តើមការស៊ើបអង្កេតការនេសាទIUUឬធ្វើការកំណត់ការនេសាទIUU នោះទេ។

[៧] មាត្រានេះមិនមានន័យប៉ះពាល់ដល់សមត្ថកិច្ចរបស់អង្គភាពដែលមានក្នុងបញ្ជីលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធ ឬផ្តល់សិទ្ធិថ្មីដល់អង្គភាពទាំងនោះក្នុងការកំណត់ការនេសាទIUU នោះទេ។

[៨] មាត្រានេះមិនមានន័យក្នុងការពន្យារឬប៉ះពាល់ដល់សុពលភាពឬការអនុវត្តច្បាប់នៃការកំណត់ការនេសាទIUUនោះទេ។

[៩] ដោយឡែក អាចរួមបញ្ចូលនូវឱកាសក្នុងការសន្ទនាឬការផ្លាស់ប្តូរព័ត៌មានជាលាយលក្ខណ៍អក្សរ ប្រសិនបើត្រូវបានស្នើសុំដោយរដ្ឋម្ចាស់ទង់ជាតិឬរដ្ឋសមាជិកដែលផ្តល់ការឧបត្ថម្ភធន។

៤/៩

១៥

ដាក់ទណ្ឌកម្ម[១០] ដែលស្ថិតនៅជាធរមាន កើតចេញពីការកំណត់លើការចូលរួមIUU ឬយ៉ាងហោចណាស់មានពេលវេលាស្មើនឹងការដាក់នាវាឬប្រតិបត្តិករក្នុងបញ្ជីរបស់អង្គការឬស្ថាប័នគ្រប់គ្រងជលផលថ្នាក់តំបន់(RFMO/A) ដោយរើសយកមួយណាដែលមានរយៈពេលវែងជាង។

៣.៥- សមាជិកដែលផ្តល់ការឧបត្ថម្ភធន ត្រូវជូនដំណឹងអំពីវិធានការដែលបានដាក់ចេញ ដូចមានចែងក្នុងមាត្រា៣.១ ដល់គណៈកម្មាធិការ ដោយអនុលោមតាមមាត្រា៨.៣។

៣.៦- នៅពេលដែលសមាជិកជារដ្ឋម្ចាស់កំពង់ផែ ជូនដំណឹងដល់សមាជិកដែលផ្តល់ការឧបត្ថម្ភធន ដោយមានមូលដ្ឋានច្បាស់លាស់ក្នុងការជឿជាក់ថា នាវាដែលកំពុងចតនៅកំពង់ផែនៃរដ្ឋនោះបានចូលរួមធ្វើនេសាទIUU សមាជិកដែលផ្តល់ការឧបត្ថម្ភធននោះត្រូវពិចារណាលើព័ត៌មានដែលទទួលបាន និងត្រូវចាត់វិធានការសមស្របចំពោះការឧបត្ថម្ភធនរបស់ខ្លួន។

៣.៧- សមាជិកនីមួយៗត្រូវមានច្បាប់ បទប្បញ្ញត្តិ និង/ឬនីតិវិធីរដ្ឋបាលជាធរមាន ដើម្បីធានាថាការឧបត្ថម្ភធនដែលមានចែងក្នុងមាត្រា៣.១ រួមទាំងការឧបត្ថម្ភធនដែលមានស្រាប់ក្នុងពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន មិនត្រូវបានផ្តល់ឬរក្សាទុកឡើយ។

៣.៨- ក្នុងរយៈពេល២ឆ្នាំ គិតចាប់ពីថ្ងៃកិច្ចព្រមព្រៀងនេះចូលជាធរមាន ការឧបត្ថម្ភធនដែលត្រូវបានផ្តល់ឬរក្សាទុកដោយសមាជិកជាប្រទេសកំពុងអភិវឌ្ឍនិងប្រទេសអភិវឌ្ឍតិចតួច(LDC) នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ(EEZ)របស់ខ្លួន នឹងត្រូវបានលើកលែងចំពោះសកម្មភាពនានាផ្អែកតាមមាត្រា៣.១ និងមាត្រា១០ នៃកិច្ចព្រមព្រៀងនេះ។

មាត្រា៤ .- ការឧបត្ថម្ភធនលើការនេសាទលើសកម្រិតផលស្តុក

៤.១- សមាជិកមិនត្រូវផ្តល់ឬរក្សាទុកការឧបត្ថម្ភធនដល់ការធ្វើនេសាទឬសកម្មភាពពាក់ព័ន្ធការនេសាទ ដែលទាក់ទងនឹងការនេសាទលើសកម្រិតផលស្តុកឡើយ។

៤.២- សម្រាប់គោលបំណងនៃមាត្រានេះ ផលស្តុកត្រីត្រូវបាននេសាទលើសកម្រិតក្នុងករណីដែលផលស្តុកនេះត្រូវបានទទួលស្គាល់ដោយរដ្ឋម្ចាស់ឆ្នេរចំពោះការនេសាទស្ថិតនៅក្នុងដែនយុត្តាធិការរបស់ខ្លួន ឬដោយRFMO/Aចំពោះតំបន់និងប្រភេទស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយផ្អែកលើភស្តុតាងវិទ្យាសាស្ត្រល្អបំផុត។

៤.៣- ទោះបីមានចែងក្នុងមាត្រា៤.១ក៏ដោយ សមាជិកអាចផ្តល់ឬរក្សាទុកការឧបត្ថម្ភធនរបស់ខ្លួនដូចមានចែងក្នុងមាត្រា៤.១ ក្នុងករណីមានការឧបត្ថម្ភធនឬវិធានការផ្សេងៗត្រូវបានអនុវត្តដើម្បីស្តារផលស្តុកត្រីឱ្យមាននិរន្តរភាពផ្នែកជីវសាស្ត្រ[១១]។

៤.៤- ក្នុងរយៈពេល២ឆ្នាំ គិតចាប់ពីថ្ងៃដែលកិច្ចព្រមព្រៀងចូលជាធរមាន ការឧបត្ថម្ភធនដែលផ្តល់ឬរក្សាទុកដោយសមាជិកជាប្រទេសកំពុងអភិវឌ្ឍនិងប្រទេសអភិវឌ្ឍតិចតួច(LDC)នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ(EEZ)របស់ខ្លួន នឹងត្រូវបានលើកលែងចំពោះសកម្មភាពនានាផ្អែកតាមមាត្រា៤.១ និងមាត្រា១០ នៃកិច្ចព្រមព្រៀងនេះ។

មាត្រា៥ .- ការឧបត្ថម្ភធនផ្សេងទៀត

៥.១- សមាជិកមិនត្រូវផ្តល់ឬរក្សាទុកការឧបត្ថម្ភធនដល់ការធ្វើនេសាទឬសកម្មភាពពាក់ព័ន្ធការនេសាទ ដែលស្ថិតនៅក្រៅ

[១០] កាលបញ្ចប់ទណ្ឌកម្មមានចែងក្នុងច្បាប់ឬនីតិវិធីរបស់អាជ្ញាធរដែលបានធ្វើការកំណត់ដូចមានចែងក្នុងមាត្រា៣.២។

[១១] សម្រាប់គោលបំណងនៃកថាខណ្ឌនេះ និរន្តរភាពផ្នែកជីវសាស្ត្រ សំដៅដល់កម្រិតដែលកំណត់ដោយរដ្ឋម្ចាស់ឆ្នេរដែលមានដែនយុត្តាធិការលើតំបន់ដែលការនេសាទឬសកម្មភាពពាក់ព័ន្ធការនេសាទកំពុងកើតឡើង ដោយប្រើចំណុចយោងដូចជាទិន្នផលនិរន្តរភាពអតិបរមា(MSY) ឬចំណុចយោងផ្សេងទៀត ស្របជាមួយនឹងទិន្នន័យផលនេសាទ[illegible] ឬដោយRFMO/A ពាក់ព័ន្ធចំពោះតំបន់និងប្រភេទសត្វក្រោមដែនសមត្ថកិច្ច។

ដែនយុត្តាធិការនៃម្ចាស់ទង់ជាសមាជិក ឬម្ចាស់ទង់មិនមែនជាសមាជិក ឬនៅក្រៅដែនសមត្ថកិច្ចរបស់RFMO/A ពាក់ព័ន្ធ។

៥.២- សមាជិកត្រូវយកចិត្តទុកដាក់ជាពិសេសនិងមានការប្រុងប្រយ័ត្នខ្ពស់ នៅពេលផ្តល់ការឧបត្ថម្ភធនដល់នាវាដែលមិនបំពាក់ទង់ជាតិរដ្ឋសមាជិកនោះ។

៥.៣- សមាជិកត្រូវយកចិត្តទុកដាក់ជាពិសេសនិងមានការប្រុងប្រយ័ត្នខ្ពស់ នៅពេលផ្តល់ការឧបត្ថម្ភធនដល់ការនេសាទ ឬសកម្មភាពពាក់ព័ន្ធការនេសាទទាក់ទាក់នឹងផលស្តុកត្រីដែលមិនបានដឹងពីស្ថានភាព។

មាត្រា៦ .- បទប្បញ្ញត្តិជាក់លាក់សម្រាប់សមាជិកជាប្រទេសអភិវឌ្ឍតិចតួច(LDC)

សមាជិកត្រូវមានការប្រុងប្រយ័ត្នខ្ពស់ ក្នុងការលើកនូវបញ្ហានានាដែលពាក់ព័ន្ធនឹងសមាជិកដែលជាប្រទេសអភិវឌ្ឍតិចតួច(LDC) និងការរកដំណោះស្រាយត្រូវពិចារណានូវស្ថានភាពជាក់លាក់របស់សមាជិកLDCដែលពាក់ព័ន្ធ ប្រសិនបើមាន។

មាត្រា៧ .- ជំនួយបច្ចេកទេសនិងការកសាងសមត្ថភាព

ជំនួយបច្ចេកទេសនិងការកសាងសមត្ថភាព ត្រូវផ្តល់ជូនដល់សមាជិកជាប្រទេសកំពុងអភិវឌ្ឍ រួមទាំងសមាជិកជាLDC ក្នុងគោលបំណងអនុវត្តវិធានការក្រោមកិច្ចព្រមព្រៀងនេះ។ ដើម្បីគាំទ្រជំនួយនេះ យន្តការផ្តល់មូលនិធិដោយស្ម័គ្រចិត្តរបស់អង្គការWTO ត្រូវបង្កើតឡើងក្រោមកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិពាក់ព័ន្ធ ដូចជាអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ(FAO) និងមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម។ ការចូលរួមវិភាគទានរបស់សមាជិកWTO ចំពោះយន្តការនេះ ត្រូវផ្អែកតាមគោលការណ៍ស្ម័គ្រចិត្តទាំងស្រុង និងមិនត្រូវប្រើប្រាស់ធនធានថវិកាជាប្រចាំឡើយ។

មាត្រា៨ .- ការជូនដំណឹងនិងតម្លាភាព

៨.១- ដោយមិនប៉ះពាល់ដល់មាត្រា២៥ នៃកិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធននិងវិធានការពន្ធប៉ះប៉ូវ(SCM) និងដើម្បីពង្រឹងការជូនដំណឹងអំពីការឧបត្ថម្ភធនជលផល ព្រមទាំងជំរុញការឃ្លាំមើលប្រកបដោយប្រសិទ្ធភាពលើការអនុវត្តការប្តេជ្ញាចិត្តចំពោះការឧបត្ថម្ភធនជលផល សមាជិកនីមួយៗត្រូវ៖

ក- ផ្តល់នូវព័ត៌មានដែលជាផ្នែកនៃការជូនដំណឹងជាប្រចាំអំពីការឧបត្ថម្ភធនជលផល ដូចមានចែងក្នុងមាត្រា២៥ នៃកិច្ចព្រមព្រៀង SCM[១២][១៣] នូវប្រភេទនៃការនេសាទដែលទទួលបានការឧបត្ថម្ភធន។

ខ- តាមលទ្ធភាពដែលធ្វើទៅបាន ផ្តល់នូវព័ត៌មានដែលជាផ្នែកនៃការជូនដំណឹងជាប្រចាំអំពីការឧបត្ថម្ភធនជលផល ដូចមានចែងក្នុងមាត្រា២៥ នៃកិច្ចព្រមព្រៀងSCM ដូចខាងក្រោម៖

(i) ស្ថានភាពផលស្តុកត្រីដែលទទួលបានការឧបត្ថម្ភធនក្នុងការនេសាទ (ឧ. ការនេសាទលើសកម្រិត ការនេសាទកម្រិតនិរន្តរភាពអតិបរមា ឬការនេសាទក្រោមកម្រិត) ចំណុចយោងដែលបានប្រើ និងថាតើផលស្តុកត្រូវបានចែករំលែក[១៤] ជាមួយសមាជិកផ្សេងទៀត ឬត្រូវបានគ្រប់គ្រងដោយRFMO/A។

(ii) វិធានការគ្រប់គ្រងនិងអភិរក្សដែលមានស្រាប់សម្រាប់ផលស្តុកត្រីពាក់ព័ន្ធ។

---

[១២] សម្រាប់គោលបំណងនៃមាត្រា៨.១ សមាជិកត្រូវផ្តល់ព័ត៌មានបន្ថែមលើព័ត៌មានទាំងឡាយដូចមានចែងក្នុងមាត្រា២៥ នៃកិច្ចព្រមព្រៀងSCM និងដូចមានចែងក្នុងកម្រងសំណួរដែលប្រើប្រាស់ដោយគណៈកម្មាធិការSCM ឧទាហរណ៍ G/SCM/6/Rev.1 ។

[១៣] សម្រាប់រដ្ឋសមាជិកជាប្រទេសអភិវឌ្ឍតិចតួចនិងប្រទេសកំពុងអភិវឌ្ឍ ដែលផលនេសាទសមុទ្រប្រចាំឆ្នាំមានមិនលើសពី០,៨ភាគរយនៃទិន្នផលនេសាទសមុទ្រសរុបទូទាំងសកលលោក ដូចដែលទិន្នន័យថ្មីបំផុតរបស់អង្គការFAOដែលបានបោះពុម្ពផ្សាយ និងចែកចាយដោយលេខាធិការដ្ឋានWTOនោះទេ ហើយការជូនដំណឹង[illegible]បន្ថែមនៅក្នុងអនុកថាខណ្ឌនេះ អាចត្រូវបានធ្វើឡើងរៀងរាល់បួនឆ្នាំម្តង។

[១៤] [illegible]ក្រុមភ្នា- សំដៅដល់ផលស្តុកដែលមាននៅក្នុងEEZs របស់រដ្ឋម្ចាស់ទង់ពីរឬច្រើន ឬរដ្ឋពីរនៅក្នុងEEZ និងតំបន់មួយទៀតនៅក្រៅតែតភ្ជាប់ពីវា។

៦/៩

១៣៥

(iii) សមត្ថភាពនាវានេសាទដែលបានទទួលការឧបត្ថម្ភធន។

(iv) ឈ្មោះនិងលេខអត្តសញ្ញាណនាវានេសាទនិងនាវាដែលទទួលបានផលប្រយោជន៍ពីការឧបត្ថម្ភធន។

(v) ទិន្នន័យផលចាប់តាមប្រភេទឬក្រុមប្រភេទនៃសកម្មភាពនេសាទដែលទទួលបានការឧបត្ថម្ភធន[១៨]។

៨.២- សមាជិកនីមួយៗត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាប្រចាំឆ្នាំ ទៅគណៈកម្មាធិការ អំពីបញ្ជីឈ្មោះនាវានិងប្រតិបត្តិករដែលបានកំណត់ថាបានចូលរួមការនេសាទIUU។

៨.៣- ក្នុងកំឡុងពេល១ឆ្នាំនៃកិច្ចព្រមព្រៀងចូលជាធរមាន សមាជិកនីមួយៗត្រូវជូនដំណឹងដល់គណៈកម្មាធិការ អំពីវិធានការដែលមានស្រាប់ឬបានអនុវត្ត សម្រាប់ជានាដល់ការអនុវត្តនិងការគ្រប់គ្រងកិច្ចព្រមព្រៀង រួមទាំងដំណើរការនៃការអនុវត្តការហាមឃាត់ ដូចមានចែងក្នុងមាត្រា៣ មាត្រា៤ និងមាត្រា៥។ សមាជិកនីមួយៗត្រូវជូនដំណឹងជាបន្ទាន់ទៅគណៈកម្មាធិការ អំពីការផ្លាស់ប្តូរណាមួយចំពោះវិធានការខាងលើនិងវិធានការថ្មីៗក្នុងការអនុវត្តការហាមឃាត់ដូចមានចែងក្នុងមាត្រា៣។

៨.៤- ក្នុងកំឡុងពេល១ឆ្នាំនៃកិច្ចព្រមព្រៀងចូលជាធរមាន សមាជិកនីមួយៗត្រូវផ្តល់ជូនគណៈកម្មាធិការ នូវការបរិយាយអំពីការគ្រប់គ្រងធនធានជលផលរបស់ខ្លួន ដោយយោងតាមច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរដ្ឋបាលដែលពាក់ព័ន្ធកិច្ចព្រមព្រៀងនេះ និងត្រូវជូនដំណឹងជាបន្ទាន់ទៅគណៈកម្មាធិការ អំពីការផ្លាស់ប្តូរណាមួយ។ សមាជិកអាចបំពេញកាតព្វកិច្ចដោយផ្តល់តំណអេឡិចត្រូនិកភ្ជាប់ទៅគេហទំព័រផ្លូវការរបស់ខ្លួន ឬគេហទំព័រផ្លូវការផ្សេងទៀតដែលបញ្ចូលនូវព័ត៌មានទាំងនោះ។

៨.៥- សមាជិកអាចស្នើសុំព័ត៌មានបន្ថែមពីសមាជិកដែលបានជូនដំណឹង ពាក់ព័ន្ធនឹងការជូនដំណឹងនិងព័ត៌មានដូចមានចែងក្នុងមាត្រានេះ។ សមាជិកដែលបានជូនដំណឹងត្រូវឆ្លើយតបនឹងសំណើនេះឱ្យបានលឿនតាមការដែលអាចធ្វើទៅបានជាលាយលក្ខណ៍អក្សរនិងមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ ប្រសិនបើសមាជិកណាមួយចាត់ទុកថា ការជូនដំណឹងឬព័ត៌មានដូចមានចែងក្នុងមាត្រានេះមិនត្រូវបានផ្តល់ សមាជិកដែលស្នើនោះអាចលើកឡើងអំពីបញ្ហានេះ ទៅកាន់សមាជិកដែលត្រូវជូនដំណឹងឬគណៈកម្មាធិការ។

៨.៦- ក្រោយពេលកិច្ចព្រមព្រៀងចូលជាធរមាន សមាជិកត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការអំពី RFMO/A ដែលខ្លួនជាភាគី។ ការជូនដំណឹងនេះត្រូវមានយ៉ាងហោចណាស់នូវអត្ថបទនៃលិខិតូបករណ៍ក្នុងការចូលជាភាគីនៃRFMO/A តំបន់និងប្រភេទត្រីស្ថិតក្រោមសមត្ថកិច្ចអង្គការនោះ ព័ត៌មានស្តីពីស្ថានភាពនៃផលស្តុកត្រីស្ថិតក្រោមការគ្រប់គ្រង ការបរិយាយអំពីវិធានការគ្រប់គ្រងនិងអភិក្រម បទប្បញ្ញត្តិនិងនីតិវិធីពាក់ព័ន្ធនឹងការកំណត់ការនេសាទIUU និងបញ្ជីបច្ចុប្បន្នកម្មនៃនាវានិង/ឬប្រតិបត្តិករដែលបានកំណត់ថាបានចូលរួមការនេសាទIUU។ ការជូនដំណឹងនេះអាចត្រូវបានផ្តល់ដោយសមាជិកនីមួយៗឬដោយសមាជិកជាក្រុម[១៩]។ រាល់ការផ្លាស់ប្តូរព័ត៌មាន ត្រូវជូនដំណឹងជាបន្ទាន់ទៅគណៈកម្មាធិការ។ លេខាធិការដ្ឋាននៃគណៈកម្មាធិការត្រូវរក្សានូវបញ្ជីនៃRFMO/A ដែលបានជូនដំណឹងស្របតាមមាត្រានេះ។

៨.៧- សមាជិកទទួលស្គាល់ថា ការជូនដំណឹងអំពីវិធានការនេះនឹងមិនធ្វើបុរេវិនិច្ឆ័យអំពី (ក) ស្ថានភាពផ្លូវច្បាប់នៅក្រោមកិច្ចព្រមព្រៀងGATT ១៩៩៤ កិច្ចព្រមព្រៀងSCM ឬកិច្ចព្រមព្រៀងនេះ (ខ) ផលប៉ះពាល់នៃវិធានការក្រោមកិច្ចព្រមព្រៀងSCM ឬ(គ) ចរិតនៃវិធានការនោះផ្ទាល់។

៨.៨- បទប្បញ្ញត្តិនៃមាត្រានេះគ្មានការតម្រូវឱ្យផ្តល់នូវព័ត៌មានសម្ងាត់នោះទេ។

---

[១៨] សម្រាប់ការនេសាទពហុប្រភេទ សមាជិកអាចផ្តល់ទិន្នន័យនេសាទដែលពាក់ព័ន្ធនិងអាចរកបានផ្សេងទៀត។

[១៩] [illegible]នេះអាចត្រូវបានបំពេញដោយការផ្តល់នូវតំណអេឡិចត្រូនិកភ្ជាប់ទៅកាន់គេហទំព័រជូនដំណឹងរបស់សមាជិក ឬគេហទំព័រផ្លូវការសមស្របផ្សេងទៀត [illegible]នេះ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៧/៩

មាត្រា៩ .- ការរៀបចំស្ថាប័ន

៩.១- ត្រូវបានបង្កើតគណៈកម្មាធិការស្ដីពីការឧបត្ថម្ភធនជលផល ដែលមានសមាសភាពមកពីតំណាងនៃសមាជិកនីមួយៗ។ គណៈកម្មាធិការត្រូវបោះឆ្នោតជ្រើសរើសប្រធាននិងត្រូវប្រជុំយ៉ាងតិចពីរដងក្នុងមួយឆ្នាំ ព្រមទាំងកោះប្រជុំតាមសំណើរបស់សមាជិកណាមួយ ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃកិច្ចព្រមព្រៀង។ គណៈកម្មាធិការត្រូវអនុវត្តការទទួលខុសត្រូវដូចបានចែងក្នុងកិច្ចព្រមព្រៀងនេះឬផ្តល់ឱ្យដោយសមាជិក និងត្រូវផ្តល់ឱកាសឱ្យសមាជិកធ្វើការពិគ្រោះយោបល់លើបញ្ហាណាមួយដែលទាក់ទងនឹងប្រតិបត្តិការនៃកិច្ចព្រមព្រៀងឬការសម្រេចឱ្យបាននូវគោលបំណងរបស់កិច្ចព្រមព្រៀង។ លេខាធិការដ្ឋាននៃអង្គការWTO ត្រូវដើរតួជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការ។

៩.២- គណៈកម្មាធិការត្រូវពិនិត្យរាល់ព័ត៌មានដែលបានផ្តល់ ដូចមានចែងក្នុងមាត្រា៣ មាត្រា៨ និងមាត្រា៩ យ៉ាងតិចពីរឆ្នាំម្តង។

៩.៣- គណៈកម្មាធិការត្រូវពិនិត្យឡើងវិញនូវការអនុវត្តនិងប្រតិបត្តិការនៃកិច្ចព្រមព្រៀងនេះជារៀងរាល់ឆ្នាំ ដោយពិចារណាលើគោលបំណងនៃកិច្ចព្រមព្រៀង។ គណៈកម្មាធិការត្រូវជូនដំណឹងជារៀងរាល់ឆ្នាំ ទៅក្រុមប្រឹក្សាពាណិជ្ជកម្មទំនិញអំពីការវិវត្តនានាក្នុងកំឡុងពេលពិនិត្យឡើងវិញ។

៩.៤- មិនលើសពីប្រាំឆ្នាំ បន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាននិងរៀងរាល់បីឆ្នាំម្តង គណៈកម្មាធិការត្រូវពិនិត្យឡើងវិញ នូវប្រតិបត្តិការនៃកិច្ចព្រមព្រៀង ដើម្បីកំណត់រាល់ការកែតម្រូវចាំបាច់ក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិការនៃកិច្ចព្រមព្រៀង ដោយពិចារណាលើគោលបំណងដែលបានចែង។ ក្នុងករណីសមស្រប គណៈកម្មាធិការអាចដាក់សំណើទៅក្រុមប្រឹក្សាពាណិជ្ជកម្មទំនិញ ក្នុងការធ្វើវិសោធនកម្មអត្ថបទនៃកិច្ចព្រមព្រៀង ដោយផ្អែកលើបទពិសោធដែលទទួលបានពីការអនុវត្ត។

៩.៥- គណៈកម្មាធិការត្រូវរក្សាទំនាក់ទំនងឱ្យបានជិតស្និទ្ធជាមួយអង្គការFAO និងជាមួយអង្គការអន្តរជាតិពាក់ព័ន្ធផ្សេងទៀតក្នុងការគ្រប់គ្រងវិស័យជលផល រួមទាំងRFMO/Aពាក់ព័ន្ធ។

មាត្រា១០ .- ការដោះស្រាយវិវាទ

១០.១- បទប្បញ្ញត្តិមាត្រាXXII និងXXIII នៃកិច្ចព្រមព្រៀងGATT១៩៩៤ ដូចមានចែងនិងដាក់ឱ្យអនុវត្តតាមវិធានដោះស្រាយវិវាទ(DSU) ត្រូវអនុវត្តសម្រាប់ការពិគ្រោះយោបល់និងការដោះស្រាយវិវាទក្នុងកិច្ចព្រមព្រៀងនេះ លើកលែងតែមានការចែងផ្សេងពីនេះ[១៧]។

១០.២- ដោយមិនប៉ះពាល់កថាខណ្ឌទី១ បទប្បញ្ញតិនៃមាត្រា៤ នៃកិច្ចព្រមព្រៀងSCM[១៨] ត្រូវអនុវត្តសម្រាប់ការពិគ្រោះយោបល់និងការដោះស្រាយវិវាទ ដែលកើតឡើងពីការអនុវត្តមាត្រា៣ មាត្រា៤ និងមាត្រា៥ នៃកិច្ចព្រមព្រៀងនេះ។

មាត្រា១១ .- អវសានប្បញ្ញត្តិ

១១.១- លើកលែងបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា៣និងមាត្រា៤ កិច្ចព្រមព្រៀងនេះមិនរារាំងសមាជិកណាមួយពីការផ្តល់ឧបត្ថម្ភធន ដើម្បីស្តារពីគ្រោះមហន្តរាយ[១៩] ក្នុងករណីដែលការឧបត្ថម្ភធននោះ៖

---

[១៧] កថាខណ្ឌ១ខនិង១គ នៃមាត្រា XXIII នៃGATT ១៩៩៤ និងមាត្រា២៦ នៃDSU មិនត្រូវអនុវត្តចំពោះការដោះស្រាយវិវាទក្រោមកិច្ចព្រមព្រៀងនេះទេ។

[១៨] សម្រាប់គោលបំណងនៃមាត្រានេះ ពាក្យ «ការឧបត្ថម្ភធនដែលត្រូវបានហាមឃាត់» នៅក្នុងមាត្រា៤ នៃកិច្ចព្រមព្រៀងSCM សំដៅដល់ការឧបត្ថម្ភធនដែលត្រូវបានហាមឃាត់ក្នុងមាត្រា៣ មាត្រា៤ ឬមាត្រា៥ នៃកិច្ចព្រមព្រៀងនេះ។

[១៩] [illegible] ប្រជា បទប្បញ្ញតិនេះមិនអនុវត្តចំពោះវិបត្តិសេដ្ឋកិច្ចឬហិរញ្ញវត្ថុទេ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក- មានកម្រិតត្រឹមតែដើម្បីស្តារពីគ្រោះមហន្តរាយជាក់លាក់ណាមួយ។

ខ- មានកម្រិតត្រឹមតែទីតាំងភូមិសាស្ត្រដែលរងផលប៉ះពាល់។

គ- មានពេលវេលាកំណត់ច្បាស់លាស់ និង

ឃ- ក្នុងករណីការឧបត្ថម្ភធននោះសម្រាប់ការកសាងឡើងវិញ មានកម្រិតត្រឹមតែដើម្បីស្តារឡើងវិញការធ្វើនេសាទ និង/ឬនាវាដែលរងផលប៉ះពាល់ ឱ្យដូចស្ថានភាពមុនគ្រោះមហន្តរាយកើតឡើង។

១១.២- ក- កិច្ចព្រមព្រៀងនេះ រួមទាំងសេចក្តីសម្រេច អនុសាសន៍ និងសេចក្តីវិនិច្ឆ័យណាមួយក្នុងកិច្ចព្រមព្រៀងនេះ មិនអាចប្រើជាមូលដ្ឋានច្បាប់ក្នុងការអនុវត្តដើម្បីការទាមទារដែនអធិបតេយ្យឬការកំណត់ព្រំដែនសមុទ្រណាមួយឡើយ។

ខ- អង្គជំនុំជម្រះដែលបានបង្កើតដូចមានចែងក្នុងមាត្រា១០ នៃកិច្ចព្រមព្រៀងនេះ មិនត្រូវធ្វើសេចក្តីសម្រេចណាមួយ ដែលតម្រូវឱ្យអង្គជំនុំជម្រះប្រើប្រាស់សេចក្តីសម្រេចនោះក្នុងការទាមទារដែនអធិបតេយ្យឬការកំណត់ព្រំដែនសមុទ្រឡើយ[២០]។

១១.៣- គ្មានបទប្បញ្ញត្តិណាមួយក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយឬអនុវត្តធ្វើឱ្យប៉ះពាល់ដល់សមត្ថកិច្ចដែនយុត្តាធិការ សិទ្ធិ និងកាតព្វកិច្ចនៃសមាជិកណាមួយ ដូចមានចែងក្នុងច្បាប់អន្តរជាតិ រួមទាំងច្បាប់ស្តីពីសមុទ្រផងដែរ[២១]។

១១.៤- លើកលែងមានការចែងផ្សេងពីនេះ គ្មានបទប្បញ្ញត្តិណាមួយក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយដោយតម្រូវឱ្យសមាជិកណាមួយជាប់កាតព្វកិច្ចក្រោមវិធានការ ឬសេចក្តីសម្រេចរបស់RFMO/A ឬទទួលស្គាល់RFMO/Aណាមួយ ដែលសមាជិកមិនមែនជាភាគី ឬមិនមែនជាភាគីសហការឡើយ។

១១.៥- កិច្ចព្រមព្រៀងនេះមិនត្រូវកែប្រែឬមោឃភាពនូវសិទ្ធិនិងកាតព្វកិច្ចណាមួយ ដែលមានចែងក្នុងកិច្ចព្រមព្រៀង SCM ឡើយ។

មាត្រា១២ .- ការបញ្ចប់កិច្ចព្រមព្រៀងក្នុងករណីវិធានគ្រប់ជ្រុងជ្រោយមិនត្រូវបានអនុម័ត

ប្រសិនបើវិធានគ្រប់ជ្រុងជ្រោយមិនត្រូវបានអនុម័ត ក្នុងរយៈពេល៤ឆ្នាំបន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន កិច្ចព្រមព្រៀងនឹងត្រូវបញ្ចប់ភ្លាមៗ លើកលែងតែមានការសម្រេចចិត្តផ្សេងទៀតពីអគ្គក្រុមប្រឹក្សា។

---

[២០] វិធានកំណត់នេះក៏ត្រូវអនុវត្តចំពោះមជ្ឈត្តករដែលត្រូវបានបង្កើតឡើងស្របតាមមាត្រា២៥ នៃDSU។

[២១] រួមទាំងវិធាន និងនីតិវិធីរបស់RFMO/As។

៥/៥

WORLD TRADE ORGANIZATION

WT/MIN(22)/33
WT/L/1144

22 June 2022

(22-4789) Page: 1/9

Ministerial Conference
Twelfth Session
Geneva, 12-15 June 2022

AGREEMENT ON FISHERIES SUBSIDIES

MINISTERIAL DECISION OF 17 JUNE 2022

The *Ministerial Conference*;

Having regard to paragraph 1 of Article X of the Marrakesh Agreement Establishing the World Trade Organization (the "WTO Agreement");

Recalling the mandate given to Members at the Eleventh WTO Ministerial Conference in 2017 in Buenos Aires that the next Ministerial Conference should adopt an agreement on comprehensive and effective disciplines that prohibits certain forms of fisheries subsidies that contribute to overcapacity and overfishing, and eliminates subsidies that contribute to IUU-fishing recognizing that appropriate and effective special and differential treatment for developing country Members and least developed country Members should be an integral part of these negotiations.

Decides as follows:

1. The Protocol amending the WTO Agreement attached to this Decision is hereby adopted and submitted to the Members for acceptance.

2. The Protocol shall hereby be open for acceptance by Members.

3. The Protocol shall enter into force in accordance with the provisions of paragraph 3 of Article X of the WTO Agreement.

4. Notwithstanding Article 9.4 of the Agreement on Fisheries Subsidies, the Negotiating Group on Rules shall continue negotiations based on the outstanding issues in documents WT/MIN(21)/W/5 and WT/MIN(22)/W/20 with a view to making recommendations to the Thirteenth WTO Ministerial Conference for additional provisions that would achieve a comprehensive agreement on fisheries subsidies, including through further disciplines on certain forms of fisheries subsidies that contribute to overcapacity and overfishing, recognizing that appropriate and effective special and differential treatment for developing country Members and least developed country Members should be an integral part of these negotiations.

ATTACHMENT

PROTOCOL AMENDING THE MARRAKESH AGREEMENT ESTABLISHING THE WORLD TRADE ORGANIZATION

AGREEMENT ON FISHERIES SUBSIDIES

Members of the World Trade Organization;

Having regard to the Decision of the Ministerial Conference in document WT/MIN(22)/33 – WT/L/1144 adopted pursuant to paragraph 1 of Article X of the Marrakesh Agreement Establishing the World Trade Organization ("the WTO Agreement");

Hereby agree as follows:

1. Annex 1A to the WTO Agreement shall, upon entry into force of this Protocol pursuant to paragraph 4, be amended by the insertion of the Agreement on Fisheries Subsidies, as set out in the Annex to this Protocol, to be placed after the Agreement on Subsidies and Countervailing Measures.

2. No reservations may be made in respect of any of the provisions of this Protocol.

3. This Protocol is hereby open for acceptance by Members.

4. This Protocol shall enter into force in accordance with paragraph 3 of Article X of the WTO Agreement.[1]

5. This Protocol shall be deposited with the Director-General of the World Trade Organization who shall promptly furnish to each Member a certified copy thereof and a notification of each acceptance thereof pursuant to paragraph 3.

6. This Protocol shall be registered in accordance with the provisions of Article 102 of the Charter of the United Nations.

Done at Geneva this seventeenth day of June two thousand and twenty-two, in a single copy in the English, French and Spanish languages, each text being authentic.

---

[1] For the purposes of calculation of acceptances under Article X:3 of the WTO Agreement, an instrument of acceptance by the European Union for itself and in respect of its Member States shall be counted as acceptance by a number of Members equal to the number of Member States of the European Union which are Members to the WTO.

ANNEX

AGREEMENT ON FISHERIES SUBSIDIES

ARTICLE 1: SCOPE

This Agreement applies to subsidies, within the meaning of Article 1.1 of the Agreement on Subsidies and Countervailing Measures (SCM Agreement) that are specific within the meaning of Article 2 of that Agreement, to marine wild capture fishing and fishing related activities at sea.[1, 2, 3]

ARTICLE 2: DEFINITIONS

For the purpose of this Agreement:

(a) "fish" means all species of living marine resources, whether processed or not;

(b) "fishing" means searching for, attracting, locating, catching, taking or harvesting fish or any activity which can reasonably be expected to result in the attracting, locating, catching, taking or harvesting of fish;

(c) "fishing related activities" means any operation in support of, or in preparation for, fishing, including the landing, packaging, processing, transshipping or transporting of fish that have not been previously landed at a port, as well as the provisioning of personnel, fuel, gear and other supplies at sea;

(d) "vessel" means any vessel, ship of another type or boat used for, equipped to be used for, or intended to be used for, fishing or fishing related activities;

(e) "operator" means the owner of a vessel, or any person, who is in charge of or directs or controls the vessel.

---

[1] For greater certainty, aquaculture and inland fisheries are excluded from the scope of this Agreement.

[2] For greater certainty, government-to-government payments under fisheries access agreements shall not be deemed to be subsidies within the meaning of this Agreement.

[3] For greater certainty, for the purposes of this Agreement, a subsidy shall be attributable to the Member conferring it, regardless of the flag or registry of any vessel involved or the nationality of the recipient.

ROYAUME DU CAMBODGE ✻ LE MINISTRE DU PALAIS ROYAL

ARTICLE 3: SUBSIDIES CONTRIBUTING TO ILLEGAL, UNREPORTED AND UNREGULATED FISHING[4]

3.1 No Member shall grant or maintain any subsidy to a vessel or operator[5] engaged in illegal, unreported and unregulated (IUU) fishing or fishing related activities in support of IUU fishing.

3.2 For purposes of Article 3.1, a vessel or operator shall be considered to be engaged in IUU fishing if an affirmative determination thereof is made by any of the following[6,7]:

(a) a coastal Member, for activities in areas under its jurisdiction; or

(b) a flag State Member, for activities by vessels flying its flag; or

(c) a relevant Regional Fisheries Management Organization or Arrangement (RFMO/A), in accordance with the rules and procedures of the RFMO/A and relevant international law, including through the provision of timely notification and relevant information, in areas and for species under its competence.

3.3 (a) An affirmative determination[8] under Article 3.2 refers to the final finding by a Member and/or the final listing by an RFMO/A that a vessel or operator has engaged in IUU fishing.

(b) For purposes of Article 3.2(a), the prohibition under Article 3.1 shall apply where the determination by the coastal Member is based on relevant factual information and the coastal Member has provided to the flag State Member and, if known, the subsidizing Member, the following:

(i) timely notification, through appropriate channels, that a vessel or operator has been temporarily detained pending further investigation for engagement in, or that the coastal Member has initiated an investigation for, IUU fishing including reference to any relevant factual information, applicable laws, regulations, administrative procedures, or other relevant measures;

(ii) an opportunity to exchange relevant information[9] prior to a determination, so as to allow such information to be considered in the final determination. The coastal Member may specify the manner and time period in which such information exchange should be carried out; and

(iii) notification of the final determination, and of any sanctions applied, including, if applicable, their duration.

The coastal Member shall notify an affirmative determination to the Committee provided for in Article 9.1 (referred to in this Agreement as "the Committee").

---

[4] "Illegal, unreported and unregulated (IUU) fishing" refers to activities set out in paragraph 3 of the *International Plan of Action to Prevent, Deter and Eliminate Illegal, Unreported and Unregulated Fishing* adopted by the UN Food and Agriculture Organization (FAO) in 2001.

[5] For the purpose of Article 3, the term "operator" means the operator within the meaning of Article 2(e) at the time of the IUU fishing infraction. For greater certainty, the prohibition on granting or maintaining subsidies to operators engaged in IUU fishing applies to subsidies provided to fishing and fishing related activities at sea.

[6] Nothing in this Article shall be interpreted to obligate Members to initiate IUU fishing investigations or make IUU fishing determinations.

[7] Nothing in this Article shall be interpreted as affecting the competence of the listed entities under relevant international instruments or granting new rights to the listed entities in making IUU fishing determinations.

[8] Nothing in this Article shall be interpreted to delay, or affect the validity or enforceability of, an IUU fishing determination.

[9] For example, this may include an opportunity to dialogue or for written exchange of information if requested by the flag State or subsidizing Member

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

3.4 The subsidizing Member shall take into account the nature, gravity, and repetition of IUU fishing committed by a vessel or operator when setting the duration of application of the prohibition in Article 3.1. The prohibition in Article 3.1 shall apply at least as long as the sanction[10] resulting from the determination triggering the prohibition remains in force, or at least as long as the vessel or operator is listed by an RFMO/A, whichever is the longer.

3.5 The subsidizing Member shall notify the measures taken pursuant to Article 3.1 to the Committee in accordance with Article 8.3.

3.6 Where a port State Member notifies a subsidizing Member that it has clear grounds to believe that a vessel in one of its ports has engaged in IUU fishing, the subsidizing Member shall give due regard to the information received and take such actions in respect of its subsidies as it deems appropriate.

3.7 Each Member shall have laws, regulations and/or administrative procedures in place to ensure that subsidies referred to in Article 3.1, including such subsidies existing at the entry into force of this Agreement, are not granted or maintained.

3.8 For a period of 2 years from the date of entry into force of this Agreement, subsidies granted or maintained by developing country Members, including least-developed country (LDC) Members, up to and within the exclusive economic zone (EEZ) shall be exempt from actions based on Articles 3.1 and 10 of this Agreement.

ARTICLE 4: SUBSIDIES REGARDING OVERFISHED STOCKS

4.1 No Member shall grant or maintain subsidies for fishing or fishing related activities regarding an overfished stock.

4.2 For the purpose of this Article, a fish stock is overfished if it is recognized as overfished by the coastal Member under whose jurisdiction the fishing is taking place or by a relevant RFMO/A in areas and for species under its competence, based on best scientific evidence available to it.

4.3 Notwithstanding Article 4.1, a Member may grant or maintain subsidies referred to in Article 4.1 if such subsidies or other measures are implemented to rebuild the stock to a biologically sustainable level.[11]

4.4 For a period of 2 years from the date of entry into force of this Agreement, subsidies granted or maintained by developing country Members, including LDC Members, up to and within the EEZ shall be exempt from actions based on Articles 4.1 and 10 of this Agreement.

ARTICLE 5: OTHER SUBSIDIES

5.1 No Member shall grant or maintain subsidies provided to fishing or fishing related activities outside of the jurisdiction of a coastal Member or a coastal non-Member and outside the competence of a relevant RFMO/A.

5.2 A Member shall take special care and exercise due restraint when granting subsidies to vessels not flying that Member's flag.

5.3 A Member shall take special care and exercise due restraint when granting subsidies to fishing or fishing related activities regarding stocks the status of which is unknown.

---

[10] Termination of sanctions is as provided for under the laws or procedures of the authority having made the determination referred to in Article 3.2.

[11] For the purpose of this paragraph, a biologically sustainable level is the level determined by a coastal Member having jurisdiction over the area where the fishing or fishing related activity is taking place, using reference points such as maximum sustainable yield (MSY) or other reference points, commensurate with the data available for the fishery; or by a relevant RFMO/A in areas and for species under its competence

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ARTICLE 6: SPECIFIC PROVISIONS FOR LDC MEMBERS

A Member shall exercise due restraint in raising matters involving an LDC Member and solutions explored shall take into consideration the specific situation of the LDC Member involved, if any.

ARTICLE 7: TECHNICAL ASSISTANCE AND CAPACITY BUILDING

Targeted technical assistance and capacity building assistance to developing country Members, including LDC Members, shall be provided for the purpose of implementation of the disciplines under this Agreement. In support of this assistance, a voluntary WTO funding mechanism shall be established in cooperation with relevant international organizations such as the Food and Agriculture Organization of the United Nations (FAO) and International Fund for Agricultural Development. The contributions of WTO Members to the mechanism shall be exclusively on a voluntary basis and shall not utilize regular budget resources.

ARTICLE 8: NOTIFICATION AND TRANSPARENCY

8.1 Without prejudice to Article 25 of the SCM Agreement and in order to strengthen and enhance notifications of fisheries subsidies, and to enable more effective surveillance of the implementation of fisheries subsidies commitments, each Member shall

(a) provide the following information as part of its regular notification of fisheries subsidies under Article 25 of the SCM Agreement[12,13]: type or kind of fishing activity for which the subsidy is provided;

(b) to the extent possible, provide the following information as part of its regular notification of fisheries subsidies under Article 25 of the SCM Agreement[12,13]:

(i) status of the fish stocks in the fishery for which the subsidy is provided (e.g. overfished, maximally sustainably fished, or underfished) and the reference points used, and whether such stocks are shared[14] with any other Member or are managed by an RFMO/A;

(ii) conservation and management measures in place for the relevant fish stock;

(iii) fleet capacity in the fishery for which the subsidy is provided;

(iv) name and identification number of the fishing vessel or vessels benefitting from the subsidy; and

(v) catch data by species or group of species in the fishery for which the subsidy is provided.[15]

8.2 Each Member shall notify the Committee in writing on an annual basis of a list of vessels and operators that it has affirmatively determined as having been engaged in IUU fishing.

---

[12] For the purpose of Article 8.1, Members shall provide this information in addition to all the information required under Article 25 of the SCM Agreement and as stipulated in any questionnaire utilized by the SCM Committee, for example G/SCM/6/Rev.1.

[13] For LDC Members, and developing country Members with an annual share of the global volume of marine capture production not exceeding 0.8 per cent as per the most recent published FAO data as circulated by the WTO Secretariat, the notification of the additional information in this subparagraph may be made every four years.

[14] The term "shared stocks" refers to stocks that occur within the EEZs of two or more coastal Members, or both within the EEZ and in an area beyond and adjacent to it.

[15] For multispecies fisheries, a Member instead may provide other relevant and available catch data.

8.3 Each Member shall, within one year of the date of entry into force of this Agreement, inform the Committee of measures in existence or taken to ensure the implementation and administration of this Agreement, including the steps taken to implement prohibitions set out in Articles 3, 4 and 5. Each Member shall also promptly inform the Committee of any changes to such measures thereafter, and new measures taken to implement the prohibitions set out in Article 3.

8.4 Each Member shall, within one year of the date of entry into force of this Agreement, provide to the Committee a description of its fisheries regime with references to its laws, regulations and administrative procedures relevant to this Agreement, and promptly inform the Committee of any modifications thereafter. A Member may meet this obligation by providing to the Committee an up-to-date electronic link to the Member's or other appropriate official web page that sets out this information.

8.5 A Member may request additional information from the notifying Member regarding the notifications and information provided under this Article. The notifying Member shall respond to that request as quickly as possible in writing and in a comprehensive manner If a Member considers that a notification or information under this Article has not been provided, the Member may bring the matter to the attention of such other Member or to the Committee.

8.6 Members shall notify to the Committee in writing, upon entry into force of this Agreement, any RFMO/A to which they are parties. This notification shall consist of, at least, the text of the legal instrument instituting the RFMO/A, the area and species under its competence, the information on the status of the managed fish stocks, a description of its conservation and management measures, the rules and procedures governing its IUU fishing determinations, and the updated lists of vessels and/or operators that it has determined as having been engaged in IUU fishing. This notification may be presented either individually or by a group of Members.[16] Any changes to this information shall be notified promptly to the Committee. The Secretariat to the Committee shall maintain a list of RFMO/As notified pursuant to this Article.

8.7 Members recognize that notification of a measure does not prejudge (a) its legal status under GATT 1994, the SCM Agreement, or this Agreement; (b) the effects of the measure under the SCM Agreement; or (c) the nature of the measure itself.

8.8 Nothing in this Article requires the provision of confidential information.

ARTICLE 9: INSTITUTIONAL ARRANGEMENTS

9.1 There is hereby established a Committee on Fisheries Subsidies composed of representatives from each of the Members. The Committee shall elect its own Chair and shall meet not less than twice a year and otherwise as envisaged by relevant provisions of this Agreement at the request of any Member. The Committee shall carry out responsibilities as assigned to it under this Agreement or by the Members and it shall afford Members the opportunity of consulting on any matter relating to the operation of this Agreement or the furtherance of its objectives. The WTO Secretariat shall act as the secretariat to the Committee.

9.2 The Committee shall examine all information provided pursuant to Articles 3 and 8 and this Article not less than every two years.

9.3 The Committee shall review annually the implementation and operation of this Agreement, taking into account the objectives thereof. The Committee shall inform annually the Council for Trade in Goods of developments during the period covered by such reviews.

[16] This obligation can be met by providing an up-to-date electronic link to the notifying Member's or other appropriate official web page that sets out this information.

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

9.4 Not later than five years after the date of entry into force of this Agreement and every three years thereafter, the Committee shall review the operation of this Agreement with a view to identifying all necessary modifications to improve the operation of this Agreement, taking into account the objectives thereof. Where appropriate, the Committee may submit to the Council for Trade in Goods proposals to amend the text of this Agreement having regard, inter alia, to the experience gained in its implementation.

9.5 The Committee shall maintain close contact with the FAO and with other relevant international organizations in the field of the fisheries management, including relevant RFMO/As.

ARTICLE 10: DISPUTE SETTLEMENT

10.1 The provisions of Articles XXII and XXIII of the GATT 1994 as elaborated and applied by the Dispute Settlement Understanding (DSU) shall apply to consultations and the settlement of disputes under this Agreement, except as otherwise specifically provided herein.[17]

10.2 Without prejudice to paragraph 1, the provisions of Article 4 of the SCM Agreement[18] shall apply to consultations and the settlement of disputes under Articles 3, 4 and 5 of this Agreement.

ARTICLE 11: FINAL PROVISIONS

11.1 Except as provided in Articles 3 and 4, nothing in this Agreement shall prevent a Member from granting a subsidy for disaster[19] relief, provided that the subsidy is:

(a) limited to the relief of a particular disaster;

(b) limited to the affected geographic area;

(c) time-limited; and

(d) in the case of reconstruction subsidies, limited to restoring the affected fishery, and/or the affected fleet to its pre-disaster level.

11.2 (a) This Agreement, including any findings, recommendations, and awards with respect to this Agreement, shall have no legal implications regarding territorial claims or delimitation of maritime boundaries.

(b) A panel established pursuant to Article 10 of this Agreement shall make no findings with respect to any claim that would require it to base its findings on any asserted territorial claims or delimitation of maritime boundaries.[20]

11.3 Nothing in this Agreement shall be construed or applied in a manner which will prejudice the jurisdiction, rights and obligations of Members, arising under international law, including the law of the sea.[21]

11.4 Except as otherwise provided, nothing in this Agreement shall imply that a Member is bound by measures or decisions of, or recognizes, any RFMO/As of which it is not a party or a cooperating non-party.

---

[17] Subparagraphs 1(b) and 1(c) of Article XXIII of the GATT 1994 and Article 26 of the DSU shall not apply to the settlement of disputes under this Agreement.

[18] For purposes of this Article, the term "prohibited subsidy" in Article 4 of the SCM Agreement refers to subsidies subject to prohibition in Article 3, Article 4 or Article 5 of this Agreement.

[19] For greater certainty, this provision does not apply to economic or financial crises

[20] This limitation shall also apply to an arbitrator established pursuant to Article 25 of the Dispute Settlement Understanding.

[21] Including rules and procedures of RFMO/As.

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

11.5 This Agreement does not modify or nullify any rights and obligations as provided by the SCM Agreement.

ARTICLE 12: TERMINATION OF AGREEMENT IF COMPREHENSIVE DISCIPLINES ARE NOT ADOPTED

If comprehensive disciplines are not adopted within four years of the entry into force of this Agreement, and unless otherwise decided by the General Council, this Agreement shall stand immediately terminated.

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ព្រះរាជក្រម

នស/រកម/០៣២៤/០០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ច្បាប់
ស្ដីពី
ការដឹកជញ្ជូនតាមផ្លូវទឹក

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

២/៧១

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

ច្បាប់នេះកំណត់អំពីការគ្រប់គ្រងនិងការអភិវឌ្ឍវិស័យដឹកជញ្ជូនតាមផ្លូវទឹកនិងកំពង់ផែនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងដើម្បីរក្សាសណ្តាប់ធ្នាប់ ធានាសុវត្ថិភាព សន្តិសុខនៃការដឹកជញ្ជូនតាមផ្លូវទឹក ព្រមទាំងការកសាងនិងថែរក្សាការពារហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ និងរួមចំណែកការពារបរិស្ថាន ព្រមទាំងផ្តល់កាលានុវត្តភាពវិនិយោគនិងការប្រកួតប្រជែងប្រកបដោយយុត្តិធម៌ សមធម៌ និងតម្លាភាព សម្រាប់បម្រើពាណិជ្ជកម្មជាតិនិងអន្តរជាតិ និងទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

មាត្រា២ .-

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះនាវា នាវិក កំពង់ផែ ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ច យានដ្ឋាននាវា ហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក និងសកម្មភាពដែលពាក់ព័ន្ធផ្សេងទៀតនៅក្នុងដែនដីនិងដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែនាវា កំពង់ផែ និងបបនីយកណ្ឌផែរបស់កងកម្លាំងមានសមត្ថកិច្ចនៃក្រសួងការពារជាតិនិងក្រសួងមហាផ្ទៃ ដែលកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

មាត្រា៣ .-

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

ជំពូកទី២
សមត្ថកិច្ចគ្រប់គ្រង

មាត្រា៤ .-

ក្រសួងសាធារណការនិងដឹកជញ្ជូន មានសមត្ថកិច្ចគ្រប់គ្រងវិស័យដឹកជញ្ជូនតាមផ្លូវទឹកនៃព្រះរាជាណាចក្រកម្ពុជា។

រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន អាចប្រគល់ឬធ្វើប្រតិភូកម្មសមត្ថកិច្ចគ្រប់គ្រងវិស័យដឹកជញ្ជូនតាមផ្លូវទឹកមួយចំនួនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ជំពូកទី៣
គោលការណ៍

មាត្រា៥ .-

គោលការណ៍នៃការគ្រប់គ្រងដឹកជញ្ជូនតាមផ្លូវទឹក មានដូចខាងក្រោម៖

- ធានាឱ្យមានលក្ខណៈសេរី យុត្តិធម៌ សមធម៌ និងគ្មានការរើសអើង សម្រាប់នាវាចរណ៍និងការចូលចេញកំពង់ផែនៅក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិនៃច្បាប់ជាតិនិងអន្តរជាតិ

៣/ ៧១

- ធានាទប់ស្កាត់ផលប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ ចំពោះការធ្វើនាវាចរណ៍និង/ឬការអភិវឌ្ឍកំពង់ផែ
- ធានាឱ្យមានសុវត្ថិភាព សណ្តាប់ធ្នាប់ សន្តិសុខ ការរក្សាបរិស្ថាន សុខដុមនីយកម្មជាមួយនឹងផែនការអភិវឌ្ឍន៍ជាតិ សម្រាប់ការធ្វើនាវាចរណ៍និងការអភិវឌ្ឍកំពង់ផែ
- អនុលោមតាមច្បាប់ជាតិនិងអន្តរជាតិ ទាក់ទងនឹងសុវត្ថិភាព សន្តិសុខ បរិស្ថាន សម្រាប់នាវា នាវិក និងកំពង់ផែ
- ធានាឱ្យមានតុល្យភាព សុខដុមនីយកម្ម និងអនុលោមភាព រវាងនាវានិងកំពង់ផែ ផលប្រយោជន៍របស់អ្នកប្រើប្រាស់និងអ្នកផ្តល់សេវា ផលប្រយោជន៍ឯកជននិងសាធារណៈ និងផលប្រយោជន៍ជាតិនិងអន្តរជាតិ។

ជំពូកទី៤
ការគ្រប់គ្រងនាវា
ផ្នែកទី១
ការគ្រប់គ្រងនាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស

មាត្រា៦ .-

នាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ដែលធ្វើនាវាចរណ៍តាមផ្លូវទឹកនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើការចុះបញ្ជីនាវា លើកលែងតែប្រភេទនាវាដែលប្រើសម្រាប់ដឹកជញ្ជូនជាលក្ខណៈគ្រួសារដែលត្រូវកំណត់ដោយអនុក្រឹត្យ។

ម្ចាស់នាវា ទោះជាបរទេសក្តី ដែលកាន់កាប់នាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេស ត្រូវស្នើសុំចុះបញ្ជីនាវា។

ម្ចាស់នាវាភារវេទកិច្ច ទោះជាបរទេសក្តី អាចស្នើសុំចុះបញ្ជីនាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេសស្របតាមកិច្ចសន្យាជាមួយម្ចាស់នាវា។

មាត្រា៧ .-

ការចុះបញ្ជីនាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ត្រូវទទួលបានវិញ្ញាបនបត្រចុះបញ្ជីនាវា ដែលមានសុពលភាពអចិន្ត្រៃយ៍ឬសុពលភាពបណ្តោះអាសន្នមិនលើសពី១(មួយ)ឆ្នាំ។

វិញ្ញាបនបត្រចុះបញ្ជីនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេសទុតិយតាឬតតិយតា មានតម្លៃស្មើនឹងវិញ្ញាបនបត្រចុះបញ្ជីនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេសដែលបានផ្តល់ជាលើកដំបូង។

មាត្រា៨ .-

នាវាដែលនាំចូលពីក្រៅប្រទេសដើម្បីស្នើសុំចុះបញ្ជីនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេស ត្រូវមានបង្កាន់ដៃពន្ធនាំចូល។ នាវាដែលនាំចូលបណ្តោះអាសន្ន ត្រូវស្ថិតនៅក្រោមរបបពន្ធគយនាំចូលបណ្តោះអាសន្ន។

មាត្រា៩ .-

ក្នុងការចុះបញ្ជីនាវា ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ចត្រូវផ្តល់អាសយដ្ឋានសម្រាប់ទំនាក់ទំនងដែលផ្លូវការមួយមិនអាចខ្វះបាន។ ក្នុងករណីប្តូរអាសយដ្ឋាន ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ចត្រូវជូនដំណឹងអំពីការប្តូរនេះ និងត្រូវផ្តល់អាសយដ្ឋានថ្មីទៅអង្គភាពមានសមត្ថកិច្ចចុះបញ្ជីនាវា យ៉ាងយូរបំផុតរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីបានប្តូរ។

៤/៧១

មាត្រា១០ ..

រាល់ការលក់ទិញ ការដូរ ប្រទានកម្ម ឬមូលហេតុគតិយុត្តផ្សេងទៀតដែលនាំឱ្យមានការផ្ទេរកម្មសិទ្ធិនាវា ត្រូវផ្ទេរកម្មសិទ្ធិនាវានិងប្តូរវិញ្ញាបនបត្រចុះបញ្ជីនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេស។

ក្នុងករណីមិនបានប្តូរវិញ្ញាបនបត្រចុះបញ្ជីនាវា ម្ចាស់នាវានៅតែទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

មាត្រា១១ ..

ការប្តូរភិនភាគនាវា ត្រូវប្តូរវិញ្ញាបនបត្រចុះបញ្ជីនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេស។

មាត្រា១២ ..

ក្នុងករណីដែលនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេស បានបាត់បង់ទាំងស្រុង ឬផ្ទេរកម្មសិទ្ធិទៅក្រៅប្រទេស ឬមិនអាចប្រើបាន ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ចត្រូវស្នើសុំលុបចេញពីការចុះបញ្ជីនាវា។

ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ច ត្រូវជាប់កាតព្វកិច្ចបង់អាករផ្សេងៗ អនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ប្រសិនបើខកខានបំពេញកាតព្វកិច្ច ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ។

មាត្រា១៣ ..

ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ច ត្រូវអនុវត្តតាមវិញ្ញាបនបត្រចុះបញ្ជីនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេស។ វិញ្ញាបនបត្រចុះបញ្ជីនាវាត្រូវព្យួរឬដកហូត ក្នុងករណីប្រើនាវាខុសពីគោលបំណងដែលបានផ្តល់ឱ្យស្របតាមវិញ្ញាបនបត្រចុះបញ្ជីនាវា។

មាត្រា១៤ ..

នាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ដែលធ្វើនាវាចរណ៍នៅតាមផ្លូវទឹកនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា តម្រូវឱ្យមានការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា។

ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ត្រូវទទួលបានវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា។

មាត្រា១៥ ..

ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ត្រូវធ្វើឡើងដោយមន្ត្រីត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា ដែលមានសមត្ថភាពវិជ្ជាជីវៈត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា។

មាត្រា១៦ ..

ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ក៏អាចធ្វើឡើងដោយភ្នាក់ងារឯកជនផងដែរ តាមការប្រគល់ការងារត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ប្រសិនបើភ្នាក់ងារនោះមានសមត្ថភាពវិជ្ជាជីវៈត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា ។

មាត្រា១៧ ..

នាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ដែលធ្វើអាជីវកម្មដឹកជញ្ជូនទំនិញឬអ្នកដំណើរ ត្រូវមានលិខិតអនុញ្ញាតឱ្យប្រតិបត្តិការនាវា។

នាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ដែលធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរ ត្រូវមានធានារ៉ាប់រងដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា១៨ .-

លក្ខខណ្ឌនិងនីតិវិធីនៃការគ្រប់គ្រងនាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ត្រូវកំណត់ដោយអនុក្រឹត្យ។

ផ្នែកទី២
ការគ្រប់គ្រងនាវាសញ្ជាតិខ្មែរ

មាត្រា១៩ .-

ម្ចាស់នាវាឬម្ចាស់នាវាការវេទកិច្ចដោយអនុលោមតាមកិច្ចសន្យាជាមួយម្ចាស់នាវា ដែលមាននាវាសមុទ្រ ឬកាន់កាប់នាវាសមុទ្រ ទោះជាបរទេសក្តី អាចស្នើសុំចុះបញ្ជីនាវាសញ្ជាតិខ្មែរ ដើម្បីទទួលបានសិទ្ធិស្របច្បាប់ធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិ។

មាត្រា២០ .-

ក្នុងការចុះបញ្ជីនាវាសញ្ជាតិខ្មែរ អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ ត្រូវផ្តល់វិញ្ញាបនបត្រចុះបញ្ជីនាវាសញ្ជាតិខ្មែរ វិញ្ញាបនបត្រសុវត្ថិភាពនាវិកអប្បបរមា វិញ្ញាបនបត្របច្ចេកទេស និងសម្របសម្រួលក្នុងការផ្តល់អាជ្ញាបណ្ណវិទ្យុទាក់ទង ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

មាត្រា២១ .-

វិញ្ញាបនបត្រចុះបញ្ជីនាវាសញ្ជាតិខ្មែរ មានពីរប្រភេទ៖

- វិញ្ញាបនបត្រចុះបញ្ជីនាវាសញ្ជាតិខ្មែរអចិន្ត្រៃយ៍ ដែលមានសុពលភាពអតិបរមា៥(ប្រាំ)ឆ្នាំ
- វិញ្ញាបនបត្រចុះបញ្ជីនាវាសញ្ជាតិខ្មែរបណ្តោះអាសន្ន ដែលមានសុពលភាពអតិបរមា៦(ប្រាំមួយ)ខែ។

មាត្រា២២ .-

នាវាសមុទ្រដែលត្រូវចុះបញ្ជីនាវាសញ្ជាតិខ្មែរ ត្រូវមានឈ្មោះដែលសរសេរជាអក្សរឡាតាំងនិង/ឬលេខអារ៉ាប់ ដែលយល់ព្រមពីអង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

រាល់ការប្តូរឈ្មោះនាវាសញ្ជាតិខ្មែរ ត្រូវមានការអនុញ្ញាតពីអង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

នាវាសញ្ជាតិខ្មែរ មិនត្រូវមានឈ្មោះផ្សេងពីឈ្មោះដែលមាននៅក្នុងវិញ្ញាបនបត្រចុះបញ្ជីនាវាសញ្ជាតិខ្មែរឡើយ។

អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរមានសិទ្ធិបញ្ឈប់ការប្រើឈ្មោះនាវា ដែលបានផ្តល់ឱ្យជាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ ក្រោយពីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់នាវាឬម្ចាស់នាវាការវេទកិច្ច ក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃ។

ក្នុងករណីម្ចាស់នាវាឬម្ចាស់នាវាការវេទកិច្ចមិនផ្តល់ឈ្មោះថ្មីសម្រាប់នាវា ដូចមានចែងនៅក្នុងកថាខណ្ឌទី៤ខាងលើនេះ អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ មានសិទ្ធិបញ្ចប់ការចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

មាត្រា២៣ .-

ក្រោយការចុះបញ្ជីនាវាសញ្ជាតិខ្មែរ ម្ចាស់នាវាឬម្ចាស់នាវាការវេទកិច្ចត្រូវផ្តល់អាសយដ្ឋានសម្រាប់ទំនាក់ទំនងដែលជាផ្លូវការមួយមិនអាចខ្វះបាន។ ក្នុងករណីប្តូរអាសយដ្ឋាន ម្ចាស់នាវាឬម្ចាស់នាវាការវេទកិច្ចត្រូវជូនដំណឹងអំពីការប្តូរនេះ និងត្រូវផ្តល់អាសយដ្ឋានថ្មីទៅអង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ យ៉ាងយូរបំផុតរយៈពេល១៥(ដប់ប្រាំ)ថ្ងៃបន្ទាប់ពីបានប្តូរ។

មាត្រា២៤ .-

នាវាសមុទ្រដែលបានចុះបញ្ជីដោយប្រទេសដទៃ អាចចុះបញ្ជីនាវាសញ្ជាតិខ្មែរបាន ក្នុងករណីដូចខាងក្រោម៖

- មានវិញ្ញាបនបត្រដែលបញ្ជាក់ថា នាវានោះបានលុបចេញពីការចុះបញ្ជីនាវានៃប្រទេសនោះ
- មានវិញ្ញាបនបត្រដែលបញ្ជាក់ថា នាវានោះត្រូវលុបចេញពីការចុះបញ្ជីនាវានៃប្រទេសនោះ ក្នុងរយៈពេលកំណត់មួយជាក់លាក់។

មាត្រា២៥ .-

ការចុះបញ្ជីនាវាសញ្ជាតិខ្មែរ មិនតម្រូវឱ្យនាវាមានពន្ធនាំចូលឡើយ។

មាត្រា២៦ .-

នាវាសមុទ្រដែលត្រូវចុះបញ្ជីនាវាសញ្ជាតិខ្មែរ ឬនាវាសញ្ជាតិខ្មែរ ត្រូវមានជានាវ៉ាប់រង។

ម្ចាស់នាវាឬម្ចាស់នាវាការវេទកិច្ច មានសិទ្ធិសម្រេចជ្រើសរើសយកជានាវ៉ាប់រងសម្រាប់នាវាសមុទ្ររបស់ខ្លួនដែលត្រូវចុះបញ្ជីនាវាសញ្ជាតិខ្មែរ ឬនាវាសញ្ជាតិខ្មែរ អនុលោមតាមគោលការណ៍អន្តរជាតិ។

មាត្រា២៧ .-

ម្ចាស់នាវាដែលត្រូវចុះបញ្ជីនាវាសញ្ជាតិខ្មែរ ឬបានចុះបញ្ជីនាវាសញ្ជាតិខ្មែរ មានសិទ្ធិចុះបញ្ជីជានានាវា។

ការជានានាវាដែលកំណត់ក្នុងច្បាប់នេះ មិនតម្រូវឱ្យមានការផ្ទេរ ការកាន់កាប់នាវាទៅឱ្យម្ចាស់បំណុលនោះឡើយ។ ការជានានាវាមានអានុភាព លុះត្រាតែមានការចុះបញ្ជីជានានាវា។ ការចុះបញ្ជីជានានាវាត្រូវធ្វើឡើងនៅអង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

ក្រៅពីបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រគល់វត្ថុនិងសិទ្ធិកាន់កាប់វត្ថុរបស់ម្ចាស់បំណុលនៃការបញ្ចាំ បទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីពាក់ព័ន្ធនឹងសិទ្ធិលើការបញ្ចាំ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការជានានាវាដែលមានចែងក្នុងច្បាប់នេះ។

ក្រោយពីបានបំពេញលក្ខខណ្ឌសម្រាប់ការចុះបញ្ជីជានានាវា អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ ត្រូវផ្តល់វិញ្ញាបនបត្រចុះបញ្ជីជានានាវា។

បែបបទនិងនីតិវិធីនៃការចុះបញ្ជីជានានាវា ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា២៨ .-

ការចុះបញ្ជីជានានាវា ត្រូវមានកាលបរិច្ឆេទច្បាស់លាស់។

ករណីមានការចុះបញ្ជីជានានាវាមានពីរឬច្រើនសម្រាប់នាវាមួយគ្រឿង ការទូទាត់សងទៅម្ចាស់បំណុលនូវចំនួនទឹកប្រាក់ដែលបានមកពីការលក់នាវាដោយការដេញថ្លៃ ត្រូវធ្វើតាមលំដាប់រៀងនៃកាលបរិច្ឆេទដែលបានកត់ត្រាទុក។

មាត្រា២៩ .-

រាល់ការលក់ទិញ ការដូរ ប្រទានកម្ម ឬមូលហេតុគតិយុត្តផ្សេងទៀតដែលនាំឱ្យមានការផ្ទេរកម្មសិទ្ធិនាវា ត្រូវមានការផ្ទេរកម្មសិទ្ធិនិងប្តូរវិញ្ញាបនបត្រចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

ការផ្ទេរកម្មសិទ្ធិនាវា អាចធ្វើបានប្រសិនបើមានការឯកភាពពីម្ចាស់ភាគហ៊ុននៃនាវា ស្របតាមនិទ្ទេសដែលបានកត់ត្រាទុកក្នុងការចុះបញ្ជីនាវាសញ្ជាតិខ្មែរ ឬការចុះបញ្ជីជានានាវា លើកលែងតែមានការចាត់ចែងផ្សេងពីនេះដោយតុលាការស្របតាមច្បាប់និងនីតិវិធីជាធរមាន។

មាត្រា៣០ .-

ការផ្ទេរ ការកែប្រែ ឬការរំលត់សិទ្ធិជាកម្មសិទ្ធិលើនាវា ត្រូវកត់ត្រាទុកក្នុងសំណុំឯកសារចុះបញ្ជីនាវាសញ្ជាតិខ្មែរ ដែលត្រូវរក្សាទុកនៅអង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

ករណីនាវាបានកាន់កាប់ដោយបុគ្គលពីរឬច្រើន សិទ្ធិជាកម្មសិទ្ធិអវិភាគលើនាវាត្រូវកត់ត្រាក្នុងសំណុំឯកសារចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

មាត្រា៣១ .-

អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ ត្រូវផ្តល់វិញ្ញាបនបត្រចុះបញ្ជីនាវាសញ្ជាតិខ្មែរទុតិយតាឬតតិយតាក្នុងករណីវិញ្ញាបនបត្រចុះបញ្ជីនាវាសញ្ជាតិខ្មែរ បានបាត់ រហែក ឬរលុបមិនអាចប្រើតទៅទៀតបាន។

វិញ្ញាបនបត្រចុះបញ្ជីនាវាសញ្ជាតិខ្មែរទុតិយតាឬតតិយតា មានតម្លៃស្មើនឹងវិញ្ញាបនបត្រចុះបញ្ជីនាវាសញ្ជាតិខ្មែរ ដែលបានផ្តល់លើកដំបូង។

មាត្រា៣២ .-

អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ មានសិទ្ធិបដិសេធចុះបញ្ជីនាវាសញ្ជាតិខ្មែរ ក្នុងករណីណាមួយដូចខាងក្រោម៖

១- មិនមានឯកសារគ្រប់គ្រាន់ ដូចជាឯកសារម្ចាស់នាវា ឯកសារនាវាជាដើម។

២- មិនបានបំពេញលក្ខខណ្ឌបច្ចេកទេសគ្រប់គ្រាន់ពាក់ព័ន្ធនឹងសុវត្ថិភាព សន្តិសុខ និងបរិស្ថាន ព្រមទាំងលក្ខខណ្ឌសុខភាពនិងផាសុកភាពនាវិក។

៣- នាវាដែលត្រូវបានហាមឃាត់ចុះបញ្ជី ឬលទ្ធភាពដែលបញ្ជាក់ថា នាវាអាចប្រើក្នុងគោលបំណងខុសច្បាប់ណាមួយ ឬអាចបង្កការខូចខាតដល់ផលប្រយោជន៍ ឬកិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជា។

មាត្រា៣៣ .-

អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ ត្រូវបញ្ចប់ការចុះបញ្ជីចំពោះនាវា ក្នុងករណីណាមួយដូចខាងក្រោម៖

១- ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ចមិនព្រមបង់ប្រាក់ពិន័យលើបទល្មើសដែលនាវារបស់ខ្លួនបានប្រព្រឹត្ត។

២- ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ចមិនព្រមបង់ថ្លៃចំណុះផ្ទុកចុះបញ្ជីនាវាឬថ្លៃផ្សេងទៀតប្រចាំឆ្នាំរយៈពេលលើសពី៣(បី)ខែ។

៣- ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ចបានស្នើសុំបញ្ចប់ការចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

៤- មានភស្តុតាងបញ្ជាក់ថា នាវាបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ។

៥- មានភស្តុតាងបញ្ជាក់ថា នាវាដែលចុះបញ្ជីនោះត្រូវបានបាត់បង់ទាំងស្រុង។

ការបញ្ចប់ការចុះបញ្ជីនាវាសញ្ជាតិខ្មែរ ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ តម្រូវឱ្យមានការ[illegible]ការចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

[illegible]មុនថ្ងៃនៃការបញ្ចប់ការចុះបញ្ជីនាវាសញ្ជាតិខ្មែរ ដូចមានចែងនៅក្នុងចំណុចទី១ ចំណុចទី២ និងចំណុចទី៣នៃកថាខណ្ឌទី១ខាងលើ អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ចនិងម្ចាស់បំណុល ហើយម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ច និង/ឬម្ចាស់

បំណុល ត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរមកអង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរវិញ ក្នុងរយៈពេលមិនលើស ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃទទួលបានការជូនដំណឹង។ ផុតរយៈពេល៣០(សាមសិប)ថ្ងៃនេះ អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ អាចសម្រេចបញ្ចប់ការចុះបញ្ជីនាវាសញ្ជាតិខ្មែរជាស្ថាពរ។

នៅមុនពេលនៃការបញ្ចប់ការចុះបញ្ជីនាវាសញ្ជាតិខ្មែរ ដូចមានចែងនៅក្នុងចំណុចទី៣និងចំណុចទី៥ នៃកថាខណ្ឌទី១ខាងលើ អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅម្ចាស់ភាគហ៊ុន និងម្ចាស់បំណុល ហើយម្ចាស់ភាគហ៊ុននិងម្ចាស់បំណុល ត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរមកអង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរវិញ ក្នុងរយៈពេលមិនលើស៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃទទួលបានការជូនដំណឹង។ ផុតរយៈពេល៣០(សាមសិប)ថ្ងៃនេះ អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ អាចសម្រេចបញ្ចប់ការចុះបញ្ជីនាវាសញ្ជាតិខ្មែរជាស្ថាពរ។

ការលុបការចុះបញ្ជីនាវាសញ្ជាតិខ្មែរ ដូចមានកំណត់នៅក្នុងចំណុចទី៣នៃកថាខណ្ឌទី១ខាងលើ ត្រូវមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីម្ចាស់ភាគហ៊ុននិងម្ចាស់បំណុល។

ក្រោយបញ្ចប់សព្វគ្រប់នូវលក្ខខណ្ឌសម្រាប់ការលុបចេញពីការចុះបញ្ជីនាវាសញ្ជាតិខ្មែរ អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ ត្រូវផ្ដល់វិញ្ញាបនបត្រលុបចេញពីការចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

មាត្រា៣៤ .-

នៅពេលដែលនាវាសញ្ជាតិខ្មែរត្រូវបាត់បង់ទាំងស្រុង ការធានានាវាត្រូវរលត់។ ករណីនេះ ការទូទាត់សងទៅម្ចាស់បំណុល ត្រូវធ្វើតាមលក្ខខណ្ឌដូចមានចែងនៅក្នុងកិច្ចសន្យាសាងសង់ ឬកិច្ចសន្យាធានានាវា ឬលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា៣៥ .-

ករណីមានការអនុវត្តដោយបង្ខំចំពោះនាវាសញ្ជាតិខ្មែរ ដោយតុលាការមានសមត្ថកិច្ច ត្រូវអនុវត្តតាមបទប្បញ្ញត្តិដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។ ការផ្អាកផ្ទាក់ឱ្យចុះបញ្ជីផ្សេងៗនៅក្នុងនីតិវិធីនេះ ត្រូវបញ្ជូនទៅអង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរត្រូវជូនដំណឹងអំពីការរឹបអូសនេះទៅម្ចាស់ភាគហ៊ុននាវា ម្ចាស់បំណុលឯកសិទ្ធិ ម្ចាស់បំណុលដែលមានការធានា ឬដើមបណ្ដឹងទាមទារសំណងដែលកើតឡើងក្នុងប្រតិបត្តិការរបស់នាវា។

ក្រោយពីបញ្ចប់នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះនាវាសញ្ជាតិខ្មែរ អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ ត្រូវចុះបញ្ជីនាវាសញ្ជាតិខ្មែរជូនម្ចាស់នាវាថ្មី ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់នេះឬលិខិតបទដ្ឋានគតិយុត្តជាធរមាន។

សិទ្ធិអាទិភាពក្នុងការទទួលសំណងពីការលក់នាវាសញ្ជាតិខ្មែរដោយបង្ខំ ត្រូវបានកំណត់តាមលំដាប់រៀងដូចខាងក្រោម៖

១- ឯកសិទ្ធិ។

២- ការធានានាវា។

៣- សិទ្ធិលើបំណុលផ្សេងទៀតដែលពាក់ព័ន្ធនឹងនាវា។

មាត្រា៣៦ .-

នាវាសមុទ្រដែលត្រូវចុះបញ្ជីនាវាសញ្ជាតិខ្មែរ ត្រូវត្រួតពិនិត្យលក្ខណៈបច្ចេកទេស និងទទួលបានវិញ្ញាបនបត្របច្ចេកទេសមានសុពលភាព៥(ប្រាំ)ឆ្នាំ ដែលត្រូវមានការត្រួតពិនិត្យផ្ទៀងផ្ទាត់ជារៀងរាល់ឆ្នាំតាមកម្មវិធីត្រួតពិនិត្យ។

ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា រួមមានការត្រួតពិនិត្យតួ ម៉ាស៊ីន ឧបករណ៍ និងគ្រឿងបរិក្ខារចាំបាច់ ដើម្បីធានាសុវត្ថិភាព សន្តិសុខ និងបរិស្ថានក្នុងការធ្វើនាវាចរណ៍។

មាត្រា៣៧ .-

ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវាសញ្ជាតិខ្មែរ ត្រូវធ្វើឡើងដោយមន្ត្រីត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវានៃអង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

មាត្រា៣៨ .-

ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវាសញ្ជាតិខ្មែរនិងការផ្តល់វិញ្ញាបនបត្របច្ចេកទេស ក៏អាចធ្វើឡើងដោយអង្គការចំណាត់ថ្នាក់នាវាផងដែរ តាមការប្រគល់ការងារត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវាសញ្ជាតិខ្មែរ ដោយក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា៣៩ .-

ក្រសួងសាធារណការនិងដឹកជញ្ជូន មានសិទ្ធិស្នើសុំរដ្ឋសមាជិកណាមួយនៃអង្គការនាវាចរណ៍សមុទ្រអន្តរជាតិ ដើម្បីត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវានិងផ្តល់វិញ្ញាបនបត្របច្ចេកទេស។

ក្រសួងសាធារណការនិងដឹកជញ្ជូន មានសិទ្ធិត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវានិងផ្តល់វិញ្ញាបនបត្របច្ចេកទេស តាមការស្នើសុំដោយរដ្ឋសមាជិកណាមួយនៃអង្គការនាវាចរណ៍សមុទ្រអន្តរជាតិ។

មាត្រា៤០ .-

បែបបទនិងនីតិវិធីនៃការគ្រប់គ្រងនាវាសញ្ជាតិខ្មែរ ត្រូវកំណត់ដោយអនុក្រឹត្យ។

នីតិវិធីនៃការផ្តល់អាជ្ញាបណ្ណវិទ្យុទាក់ទង ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ជំពូកទី៥
នាវិក
ផ្នែកទី១
ការបណ្តុះបណ្តាលនាវិក

មាត្រា៤១ .-

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវរៀបចំនិងជំរុញការបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលនាវិក។

ការបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលនាវិក ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៤២ .-

ការបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលនាវិក ត្រូវមានជាអាទិ៍មុខជំនាញ កម្មវិធីសិក្សានិងកម្មសិក្សា កម្រិតសញ្ញាបត្រ ឧបករណ៍ សម្ភារៈ បរិក្ខារ សាស្ត្រាចារ្យឬគ្រូបង្គាត់។

មាត្រា៤៣ .-

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវធានាឱ្យមានការវាយតម្លៃលើការបណ្តុះបណ្តាលនាវិក ដើម្បីទទួលបាននូវការទទួលស្គាល់ពីអង្គការនាវាចរណ៍សមុទ្រអន្តរជាតិ។

មាត្រា៤៤ .-

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីទទួលស្គាល់ការបណ្តុះបណ្តាលនាវិកដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា៤៥ ..

ក្រសួងសាធារណការនិងដឹកជញ្ជូន មានសិទ្ធិអនុញ្ញាតឱ្យផ្នែកឯកជនបង្កើតនិងធ្វើអាជីវកម្មសាលាបង្រៀនបើកបរនាវា សម្រាប់នាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស។

លក្ខខណ្ឌនិងនីតិវិធីនៃការបង្កើតនិងការធ្វើអាជីវកម្មសាលាបង្រៀនបើកបរនាវា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ផ្នែកទី២
នាវិកបម្រើការងារនៅលើនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេស

មាត្រា៤៦ ..

នាវិកដែលបម្រើការងារជាបរិបាលនាវា យន្តការីនាវា អ្នកបើកបរនាវា ជំនួយការបរិបាលនាវា និងជំនួយការយន្តការីនាវា ត្រូវមានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិក។

វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិក ត្រូវផ្តល់ឱ្យបេក្ខជន ស្របតាមប្រភេទ ទំហំ កម្លាំងម៉ាស៊ីន និងតំបន់ប្រតិបត្តិការរបស់នាវា តាមលក្ខខណ្ឌដូចខាងក្រោម៖

- មានអាយុយ៉ាងតិច១៨(ដប់ប្រាំបី)ឆ្នាំ
- មានលិខិតឬវិញ្ញាបនបត្រពិនិត្យកាយសម្បទាដែលចេញដោយក្រសួងទទួលបន្ទុកវិស័យការងារ
- មានវិញ្ញាបនបត្របញ្ជាក់ការសិក្សានៅក្នុងឬក្រៅប្រទេសនិងមានលិខិតបញ្ជាក់ថា នាវិកបានបម្រើការងារនៅលើនាវា
- មានការប្រឡងឬធ្វើតេស្ត ដែលបញ្ជាក់ថា នាវិកមានសមត្ថភាពជំនាញបំពេញការងារនៅលើនាវាបាន។

មាត្រា៤៧ ..

វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកជាបរិបាលនាវា ចែកជា៣(បី)កម្រិត ដូចខាងក្រោម៖

- កម្រិតទី១ : បរិបាលនាវាដែលត្រូវបម្រើការងារនៅលើនាវាមានបណ្តោយចាប់ពី៣៥(សាមសិបប្រាំ)ម៉ែត្រឡើង
- កម្រិតទី២ : បរិបាលនាវាដែលត្រូវបម្រើការងារនៅលើនាវាមានបណ្តោយចាប់ពី២៤(ម្ភៃបួន)ម៉ែត្រ និងតិចជាង៣៥(សាមសិបប្រាំ)ម៉ែត្រ
- កម្រិតទី៣ : បរិបាលនាវាដែលត្រូវបម្រើការងារនៅលើនាវាមានបណ្តោយតិចជាង២៤(ម្ភៃបួន)ម៉ែត្រ។

មាត្រា៤៨ ..

វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកជាយន្តការីនាវា ចែកជា៣(បី)កម្រិត ដូចខាងក្រោម៖

- កម្រិតទី១ : យន្តការីនាវាដែលបម្រើការងារនៅលើនាវាមានកម្លាំងម៉ាស៊ីនចាប់ពី៧៥០(ប្រាំពីររយហាសិប)សេះឡើង
- កម្រិតទី២ : យន្តការីនាវាដែលបម្រើការងារនៅលើនាវាមានកម្លាំងម៉ាស៊ីនចាប់ពី២៥០(ពីររយហាសិប)សេះ និងតិចជាង៧៥០(ប្រាំពីររយហាសិប)សេះ
- កម្រិតទី៣ : យន្តការីនាវាដែលបម្រើការងារនៅលើនាវាមានកម្លាំងម៉ាស៊ីនតិចជាង២៥០(ពីររយហាសិប)សេះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

មាត្រា៤៩ .-

វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកជាអ្នកបើកបរនាវា ចែកជា៣(បី)កម្រិត ដូចខាងក្រោម៖

- កម្រិតទី១ : អ្នកបើកបរនាវានៅលើនាវាដែលមានបណ្ដោយចាប់ពី១២(ដប់ពីរ)ម៉ែត្រឡើង
- កម្រិតទី២ : អ្នកបើកបរនាវានៅលើនាវាដែលមានបណ្ដោយចាប់ពី៧(ប្រាំពីរ)ម៉ែត្រ ដល់តិចជាង១២(ដប់ពីរ)ម៉ែត្រ
- កម្រិតទី៣ : អ្នកបើកបរនាវានៅលើនាវាដែលមានបណ្ដោយតិចជាង៧(ប្រាំពីរ)ម៉ែត្រ ដែលជាប្រភេទនាវាគាំទ្រ ឬនាវាផ្សេងទៀតដែលមានដំណើរចរឆ្លងកាត់ប្រឡាយនាវាចរណ៍ ច្រកនាវាចរណ៍ ឬផ្លូវនាវាចរណ៍ដែលមានចរាចរណ៍មមាញឹក។

ការតម្រូវឱ្យមានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកជាអ្នកបើកបរនាវាកម្រិតទី៣ ត្រូវបានលើកលែងចំពោះនាវាដែលប្រើសម្រាប់ដឹកជញ្ជូនជាលក្ខណៈគ្រួសារ។

មាត្រា៥០ .-

វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកជាជំនួយការបរិបាលនាវា ត្រូវផ្ដល់ឱ្យនាវិកដែលបំពេញមុខងារជានាវិកជំនាញបម្រើការងារផ្នែកបើកបរនិងជាជំនួយការរបស់បរិបាលនាវា។

វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកជាជំនួយការយន្តការីនាវា ត្រូវផ្ដល់ឱ្យនាវិកដែលបំពេញមុខងារជានាវិកជំនាញបម្រើការងារផ្នែកម៉ាស៊ីននិងជាជំនួយការរបស់យន្តការីនាវា។

មាត្រា៥១ .-

ប្រសិនបើមានកិច្ចព្រមព្រៀងឬអនុសញ្ញាអន្តរជាតិទទួលស្គាល់វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកជាទ្វេភាគីឬពហុភាគីជាមួយព្រះរាជាណាចក្រកម្ពុជា ជនបរទេសដែលស្នាក់នៅស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកស្របតាមច្បាប់នៃប្រទេសដែលផ្ដល់វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកនោះ អាចបើកបរនាវាបាន។

មាត្រា៥២ .-

នាវិកដែលមានសមត្ថភាពជំនាញ ត្រូវបំពេញការងារនៅលើនាវា ស្របតាមមុខងារនិងកម្រិតសមត្ថភាពដែលបានកំណត់នៅលើវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិក។

នាវិកដែលមានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកកម្រិតទាប មិនអនុញ្ញាតឱ្យបំពេញការងារដែលតម្រូវឱ្យមាននាវិកដែលមានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកកម្រិតខ្ពស់ឡើយ។

នាវិកដែលមានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកកម្រិតខ្ពស់ អាចបំពេញការងារនៅលើនាវាដែលតម្រូវឱ្យមាននាវិកដែលមានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកកម្រិតទាបបាន។

ក្នុងករណីមានគ្រោះអាសន្ននៅលើនាវា ដែលបរិបាលនាវានិងយន្តការីនាវាបាត់បង់សមត្ថភាពបញ្ជានិងធ្វើប្រតិបត្តិការនាវា នាវិកថ្នាក់ក្រោមបន្ទាប់ មានសិទ្ធិបន្តដឹកនាំនិងធ្វើប្រតិបត្តិការនាវា រហូតបញ្ចប់ដំណើរនាវា។

មាត្រា៥៣ .-

នីតិវិធីនៃការផ្ដល់វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកសម្រាប់នាវិកបម្រើការងារនៅលើនាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ផ្នែកទី៣
នាវិកបម្រើការងារនៅលើនាវាសមុទ្រ

មាត្រា៥៤ .-

នាវាសញ្ជាតិខ្មែរនីមួយៗត្រូវមាននាវិកសញ្ជាតិខ្មែរយ៉ាងតិច២០%(ម្ភៃភាគរយ)ដើម្បីបម្រើការងារនៅលើនាវា លើកលែងតែពុំមាននាវិកសញ្ជាតិខ្មែរដែលអាចបំពេញមុខងារនៅលើនាវានោះបាន។

នាវិកសញ្ជាតិខ្មែរដែលបម្រើការងារនៅលើនាវាសមុទ្រ ត្រូវមានមុខងារដូចខាងក្រោម៖

- កម្រិតគ្រប់គ្រង : នាយនាវា នាយបើកបរ នាយយន្តការី នាយយន្តការីទី២
- កម្រិតប្រតិបត្តិការ : នាយបើកបរទី២ នាយបើកបរទី៣ នាយទទួលបន្ទុកបើកបរ នាយវិទ្យុទាក់ទង វិទ្យុការីនាវា នាយយន្តការីទី៣ នាយទទួលបន្ទុកម៉ាស៊ីន នាយអគ្គិសនី
- កម្រិតគាំទ្រ : នាវិកជំនាញផ្នែកបើកបរ នាវិកប្រចាំវេនបើកបរ នាវិកជំនាញផ្នែកម៉ាស៊ីន នាវិកប្រចាំវេនម៉ាស៊ីន នាវិកជំនាញផ្នែកអគ្គិសនី។

នាវិកសញ្ជាតិខ្មែរដែលបំពេញមុខងារ ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវមានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិក។

មាត្រា៥៥ .-

នាវិកសញ្ជាតិខ្មែរដែលបម្រើការងារនៅលើនាវាសមុទ្រតាមមុខងារ ដូចមានចែងនៅក្នុងមាត្រា៥៤នៃច្បាប់នេះ ត្រូវមានការបណ្តុះបណ្តាលពិសេស ដើម្បីបំពេញមុខងារនៅលើនាវា។

មាត្រា៥៦ .-

នាយនាវាមានសិទ្ធិដឹកនាំ គ្រប់គ្រង និងបញ្ជានៅលើនាវា។

នាវិកបម្រើការងារនៅលើនាវាសញ្ជាតិខ្មែរ ត្រូវអនុវត្តតាមបញ្ជារបស់នាយនាវា និងត្រូវបំពេញមុខងារដែលនាយនាវាបានប្រគល់ឱ្យដោយប្រុងប្រយ័ត្ន។

សិទ្ធិនិងការទទួលខុសត្រូវរបស់នាយនាវានិងនាវិកដែលបម្រើការងារនៅលើនាវាសញ្ជាតិខ្មែរ ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៥៧ .-

នាវិកសញ្ជាតិខ្មែរនិងនាវិកបរទេសដែលបម្រើការងារនៅលើនាវាសញ្ជាតិខ្មែរ ត្រូវមានឯកសណ្ឋាននាវិក។

ឯកសណ្ឋាននាវិក ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៥៨ .-

នាវិកសញ្ជាតិខ្មែរដែលត្រូវបម្រើការងារនៅលើនាវាសមុទ្រ ត្រូវមានអាយុយ៉ាងតិច១៨(ដប់ប្រាំបី)ឆ្នាំ សុខភាពល្អដោយមានវិញ្ញាបនបត្របញ្ជាក់សុខភាពនាវិក កម្រិតសញ្ញាបត្រសមស្រប ឯកសារបញ្ជាក់អំពីការបម្រើការងាររបស់នាវិកនៅលើនាវា និងការធ្វើតេស្តសមត្ថភាពជំនាញ។

នាវិកសញ្ជាតិខ្មែរដែលកំពុងហាត់ការដើម្បីបម្រើការងារនៅលើនាវា ត្រូវមានអាយុយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ ប្រសិនបើការងារនោះមិនប៉ះពាល់ដល់ភាពលូតលាស់នៃរាងកាយរបស់នាវិក។

មាត្រា៥៩ .-

នាវិកបរទេសមានសិទ្ធិបម្រើការងារនៅលើនាវាសញ្ជាតិខ្មែរបាន ប្រសិនបើមានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិក[illegible]។

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវរៀបចំឱ្យមានកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងការទទួលស្គាល់សមត្ថភាពជំនាញនាវិក និងការផ្តល់វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកបដ្ឋិលេខដល់នាវិកបរទេសដែលត្រូវបម្រើការងារនៅលើនាវាសញ្ជាតិខ្មែរ។

មាត្រា៦០ .-

នីតិវិធីនិងលក្ខខណ្ឌនៃការផ្តល់វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិក វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកបដ្ឋិលេខ និងវិញ្ញាបនបត្របញ្ជាក់សុខភាពនាវិក សម្រាប់នាវិកបម្រើការងារនៅលើនាវាសមុទ្រ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា៦១ .-

នាវិកសញ្ជាតិខ្មែរដែលបម្រើការងារនៅលើនាវាសមុទ្រ ត្រូវមានសៀវភៅនាវិក។ សៀវភៅនាវិក ត្រូវកំណត់ដោយអនុក្រឹត្យ។

នាវិកសញ្ជាតិខ្មែរដែលបម្រើការងារនៅលើនាវាសមុទ្រ ក៏ត្រូវមានផងដែរនូវលិខិតឆ្លងដែន។

នាវិកបរទេសដែលបម្រើការងារនៅលើនាវាសញ្ជាតិខ្មែរ ត្រូវមានលិខិតឆ្លងដែននិង/ឬឯកសារដែលមានតម្លៃស្មើ ដែលផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់នាវិកនោះ។

មាត្រា៦២ .-

នាវាសញ្ជាតិខ្មែរ ត្រូវមានចំនួននាវិកអប្បបរមា ស្របតាមប្រភេទ ទំហំ កម្លាំងម៉ាស៊ីន តំបន់ប្រតិបត្តិការរបស់នាវា និងមុខងារដែលនាវិកត្រូវបំពេញ ដើម្បីធានាសុវត្ថិភាពនាវាចរណ៍។

ចំនួននាវិកអប្បបរមា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា៦៣ .-

នាវិកសញ្ជាតិខ្មែរឬនាវិកបរទេសដែលបម្រើការងារនៅលើនាវាសញ្ជាតិខ្មែរ ត្រូវមានកិច្ចសន្យាការងារនាវិក។

កិច្ចសន្យាការងារនាវិក ត្រូវមានចែងជាអាទិ៍អត្តសញ្ញាណរបស់គូភាគី តួនាទីដែលនាវិកត្រូវបម្រើការ ប្រាក់ឈ្នួលនិងអត្ថប្រយោជន៍ផ្សេងៗនិងរបៀបនៃការទូទាត់ ការធានារ៉ាប់រងសុខភាព ការឈប់សម្រាកប្រចាំឆ្នាំដែលមានប្រាក់ឈ្នួល លក្ខខណ្ឌបញ្ចប់ការងារ។

កិច្ចសន្យាការងារនាវិក ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរនិងត្រូវចុះហត្ថលេខាដោយនាវិកនិងម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ច ដោយមានចំនួន៣(បី)ច្បាប់ ដែលមួយច្បាប់ត្រូវរក្សាទុកនៅម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ច មួយច្បាប់ត្រូវរក្សាទុកនៅនាវិក និងមួយច្បាប់ទៀតត្រូវរក្សាទុកនៅអង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

នាវិកសញ្ជាតិខ្មែរដែលបម្រើការងារនៅលើនាវាបរទេស ត្រូវមានកិច្ចសន្យាការងារនាវិកស្របតាមច្បាប់នៃប្រទេសម្ចាស់សញ្ជាតិនាវានិងលិខិតុបករណ៍អន្តរជាតិ។

មាត្រា៦៤ .-

ក្នុងករណីការបញ្ចប់កិច្ចសន្យាការងារនាវិករបស់នាវិកនៅលើនាវាសញ្ជាតិខ្មែរ ដោយផុតសុពលភាពនៃកិច្ចសន្យាការងារនាវិក៖

១- ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ច ត្រូវ៖

- ទូទាត់ប្រាក់ឈ្នួលនាវិកឱ្យបានចប់សព្វគ្រប់ដល់នាវិក
- ផ្តល់មូលវិចារលើការងាររបស់នាយនាវា ដោយមានបញ្ជាក់អំពីរយៈពេលនិងបទពិសោធបម្រើការងារនៅលើនាវា។

២- នាយនាវាត្រូវផ្តល់មូលវិចារលើការងាររបស់នាវិក ដោយមានបញ្ជាក់អំពីឋានៈ រយៈពេល និងបទពិសោធបម្រើការងារនៅលើនាវា។

មាត្រា៦៥ .-

នាវិកមានសិទ្ធិបញ្ចប់កិច្ចសន្យាការងារនាវិកមុនកាលកំណត់ ដោយមូលហេតុណាមួយ ដូចខាងក្រោម៖

១- នាវាស្ថិតនៅក្នុងភាពមិនមានសុវត្ថិភាព បន្ទប់ស្នាក់នៅក្នុងនាវាមិនមានផាសុកភាព ហើយនាយនាវានៅតែធ្វេសប្រហែសមិនដោះស្រាយជូន។

២- នាយនាវាធ្វេសប្រហែសក្នុងការពិនិត្យដោះស្រាយ បើទោះបីជាមានចំនួននាវិកតវ៉ារហូតដល់ ៥០%ហើយក៏ដោយ។

៣- នាយនាវាមិនបានយកចិត្តទុកដាក់ដល់នាវិកដែលមានជំងឺ។

ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ចត្រូវផ្តល់ប្រាក់ឈ្នួលនាវិកយ៉ាងច្រើនបំផុតចំនួន៣(បី)ខែ គិតពីថ្ងៃបញ្ចប់កិច្ចសន្យាការងារនាវិក ក្នុងករណីការបញ្ចប់កិច្ចសន្យាការងារនាវិកមុនកាលកំណត់តាមមូលហេតុណាមួយ ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ។

មាត្រា៦៦ .-

ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ចមានសិទ្ធិបញ្ចប់កិច្ចសន្យាការងារនាវិកមុនកាលកំណត់ ដោយមូលហេតុណាមួយដែលនាវិកបានប្រព្រឹត្ត ដូចខាងក្រោម៖

១- មិនមានសមត្ថភាពបំពេញមុខងារនៅលើនាវា។

២- មិនគោរពបទបញ្ជាផ្ទៃក្នុងនៅលើនាវា។

៣- ប្រព្រឹត្តខុសដដែលៗនឹងមុខងារដែលខ្លួនត្រូវបំពេញ។

៤- ភូតភរកុហកឬធ្វេសប្រហែសនៅក្នុងការបំពេញមុខងារនៅលើនាវា។

៥- ប្រព្រឹត្តបទមជ្ឈិមឬបទឧក្រិដ្ឋណាមួយ។

៦- ប្រព្រឹត្តបទល្មើសផ្សេងទៀតដែលផ្ទុយនឹងច្បាប់ជាធរមាន។

នាយនាវាមានសិទ្ធិបណ្តេញនាវិកចេញពីការបម្រើការងារនៅលើនាវាសញ្ជាតិខ្មែរនៅមុនកាលកំណត់នៃកិច្ចសន្យាការងារនាវិក ក្នុងករណីនាវិកបានប្រព្រឹត្តខុសនូវមូលហេតុណាមួយ ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ។

ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ចត្រូវផ្តល់ប្រាក់ឈ្នួលនាវិក គិតត្រឹមថ្ងៃដែលបានបញ្ចប់កិច្ចសន្យាការងារនាវិកមុនកាលកំណត់នោះ។

មាត្រា៦៧ .-

នៅពេលដែលនាវាសញ្ជាតិខ្មែរត្រូវបានលុបចេញពីការចុះបញ្ជីនាវាសញ្ជាតិខ្មែរ នាវិកដែលបម្រើការងារនៅលើនាវានោះ ក៏ត្រូវបានបញ្ចប់កិច្ចសន្យាការងារនាវិកផងដែរ។

ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ចត្រូវផ្តល់មូលវិចារលើការងាររបស់នាវិក និងត្រូវផ្តល់ប្រាក់ឈ្នួលនាវិករយៈពេល២(ពីរ)ខែ គិតចាប់ពីថ្ងៃលុបចេញពីការចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

មាត្រា៦៨ .-

នៅពេលនាវាសញ្ជាតិខ្មែរបានខូចដោយស្ថិតក្នុងដំណាក់កាលជួសជុល នាវិកត្រូវបានប្រគល់ការងារផ្សេងដែលសមស្របតាមមុខជំនាញរបស់ខ្លួន។ ករណីនាវិកមិនទទួលបំពេញការងារនោះ ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ចអាចបញ្ចប់កិច្ចសន្យាការងារនាវិកបាន។

ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ចត្រូវផ្ដល់មូលវិចារលើការងាររបស់នាវិកនិងត្រូវផ្ដល់ប្រាក់ឈ្នួលនាវិក គិតត្រឹមថ្ងៃដែលត្រូវបានបញ្ចប់កិច្ចសន្យាការងារនាវិកមុនកាលកំណត់នោះ។

មាត្រា៦៩ ..

នាយនាវាត្រូវបញ្ជូននាវិកដែលបានបញ្ចប់កិច្ចសន្យាការងារនាវិកទៅកាន់ប្រទេសរបស់នាវិកវិញ ស្របតាមកិច្ចសន្យាការងារនាវិក។

រាល់ការចំណាយសម្រាប់ការស្នាក់នៅនិងការបរិភោគអាហារ ឬចំណាយដែលចាំបាច់ផ្សេងទៀត ក្នុងកំលុងពេលរង់ចាំការបញ្ជូនត្រឡប់ទៅកាន់ប្រទេសរបស់ខ្លួន និងការធ្វើដំណើររបស់នាវិកទៅកាន់ប្រទេសរបស់ខ្លួន ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ជាបន្ទុករបស់ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ច។

មាត្រា៧០ ..

នៅពេលនាវាសញ្ញាតិខ្មែរបានបាត់បង់ទាំងស្រុង នាវិកដែលបម្រើការងារនៅលើនាវានោះត្រូវបានបញ្ចប់នៅមុនពេលកំណត់ ដូចមានចែងនៅក្នុងកិច្ចសន្យាការងារនាវិក។

ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ចត្រូវផ្ដល់មូលវិចារលើការងារនាវិក និងផ្ដល់ប្រាក់ឈ្នួលនាវិករយៈពេល ២(ពីរ)ខែ គិតចាប់ពីថ្ងៃដែលនាវានោះបានបាត់បង់។

មាត្រា៧១ ..

នាវិកមានសិទ្ធិទទួលការទូទាត់លើការចំណាយផ្សេងៗសម្រាប់ប្រតិបត្តិការនាវា ទោះបីជានាវាសញ្ញាតិខ្មែរបានបាត់បង់ទាំងស្រុង និងអត្ថប្រយោជន៍ផ្សេងទៀតក្នុងប្រតិបត្តិការជួយសង្គ្រោះនាវា។

មាត្រា៧២ ..

ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ចត្រូវទទួលខុសត្រូវចំពោះនាវិកដែលបម្រើការងារនៅលើនាវាសញ្ញាតិខ្មែរ ស្ថិតនៅក្រៅប្រទេសរបស់ខ្លួន ក្នុងករណីដូចខាងក្រោម៖

១- នាវិកមានជំងឺត្រូវទទួលបានការព្យាបាលឬការវះកាត់ ដោយមិនអាចពន្យារពេលបាន។

២- នាវិកទទួលមរណភាព អាចត្រូវបានបញ្ជូនសពមកប្រទេសកំណើត ឬធ្វើការបញ្ចុះ ឬបូជានៅក្រៅប្រទេសកំណើត។

មាត្រា៧៣ ..

នាវិកដែលកំពុងបម្រើការងារលើនាវាសមុទ្រ ត្រូវទទួលបានប្រាក់ឈ្នួលនាវិក ដោយអនុលោមតាមការព្រមព្រៀង ដូចមានចែងនៅក្នុងកិច្ចសន្យាការងារនាវិក។

ប្រាក់ឈ្នួលនាវិក ត្រូវផ្ដល់ឱ្យនាវិកឱ្យបានទៀងទាត់នៅតាមខែនីមួយៗ។

ប្រាក់ឈ្នួលនាវិក ត្រូវផ្ដល់ឱ្យនាវិក ទោះបីក្នុងកំលុងពេលឈប់សម្រាកប្រចាំឆ្នាំនិងការងារថែមម៉ោង។

មាត្រា៧៤ ..

ការងារថែមម៉ោងរបស់នាវិកនៅពេលនាវាកំពុងធ្វើនាវាចរណ៍ មិនត្រូវលើសពី២(ពីរ)ម៉ោងក្នុងមួយថ្ងៃ បន្ថែមលើម៉ោងធ្វើការងារប្រចាំថ្ងៃរបស់នាវិក។

នៅពេលចាំបាច់ ការងារថែមម៉ោងរបស់នាវិក មិនត្រូវលើសពី៦(ប្រាំមួយ)ម៉ោងក្នុងមួយថ្ងៃ បន្ថែមលើម៉ោងធ្វើការងារប្រចាំថ្ងៃរបស់នាវិក។

ម៉ោងធ្វើការសរុបរបស់នាវិកនៅលើនាវា មិនត្រូវលើសពី៧២(ចិតសិបពីរ)ម៉ោងក្នុងមួយសប្ដាហ៍។

ការងារថែមម៉ោងរបស់នាវិកនៅលើនាវា មិនត្រូវយកមកអនុវត្តឡើយ ក្នុងករណីប្រធានសក្តិ។

១៦/៧១

មាត្រា៧៥ .-

ត្រូវបានបង្កើតគណៈកម្មការសម្របសម្រួលវិវាទការងារនាវិក ដើម្បីសម្របសម្រួលវិវាទការងាររបស់នាវិក។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការសម្របសម្រួលវិវាទការងារនាវិក ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៧៦ .-

វិវាទការងាររបស់នាវិកដែលបម្រើការងារលើនាវាសញ្ជាតិខ្មែរ អាចសម្របសម្រួលដោយយន្តការដោះស្រាយវិវាទណាមួយផ្សេងទៀត ឬដោយតុលាការមានសមត្ថកិច្ច។

មាត្រា៧៧ .-

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវជំរុញបង្កើតភ្នាក់ងារផ្គត់ផ្គង់នាវិក ដើម្បីជានាំស្វែងរកទីផ្សារនាវិក លើកកម្ពស់ការបណ្តុះបណ្តាលនិងពង្រឹងគុណភាពសមត្ថភាពនាវិក ធានាការពារសិទ្ធិនិងផលប្រយោជន៍របស់នាវិក សម្រាប់នាវិកដែលបម្រើការងារនៅលើនាវា។

លក្ខខណ្ឌនិងនីតិវិធីនៃការបង្កើតភ្នាក់ងារផ្គត់ផ្គង់នាវិក ត្រូវកំណត់ដោយអនុក្រឹត្យ។

ជំពូកទី៦
នាវាចរណ៍
ផ្នែកទី១
បទប្បញ្ញត្តិនាវាចរណ៍
កថាភាគទី១
បទប្បញ្ញត្តិទូទៅ

មាត្រា៧៨ .-

នាវាសញ្ជាតិខ្មែរត្រូវគោរពតាមបទប្បញ្ញត្តិនាវាចរណ៍ដូចមានចែងនៅក្នុងច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងត្រូវគោរពបទប្បញ្ញត្តិពាក់ព័ន្ធនឹងនាវាចរណ៍នៃប្រទេសដែលនាវាកំពុងស្ថិតនៅ។

នាវាឆ្នេរសមុទ្រ នាវាផ្លូវទឹកក្នុងប្រទេស និងនាវាបរទេស ដែលកំពុងស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពតាមបទប្បញ្ញត្តិនាវាចរណ៍ ដូចមានចែងនៅក្នុងច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

បទប្បញ្ញត្តិនៅក្នុងជំពូកនេះ មិនរារាំងដល់ប្រតិបត្តិការតាមវិធានពិសេសដែលអនុវត្តនៅក្នុងដែនទឹកកំពង់ផែ ព្រែកជីក និងផ្លូវទឹកបិទជិតដែលតភ្ជាប់ទៅផ្លូវសមុទ្រឡើយ។

មាត្រា៧៩ .-

បទប្បញ្ញត្តិនាវាចរណ៍ រួមមានវិធានបើកបរ ភ្លើងបើកបរ សញ្ញាបើកបរ សញ្ញាភ្លើង និងសញ្ញាសំឡេង។

មាត្រា៨០ .-

នាយនាវា ឬបរិបាលនាវា ឬអ្នកបើកបរនាវា ត្រូវយកចិត្តទុកដាក់ប្រុងប្រយ័ត្នចំពោះគ្រប់ប្រភេទគ្រោះថ្នាក់នាវាចរណ៍ គ្រោះថ្នាក់ប៉ះទង្គិច និងគ្រប់កាលៈទេសៈពិសេស ដោយរាប់បញ្ចូលទាំងលក្ខខណ្ឌកំណត់ត្រារបស់នាវា ដែលអាចអនុញ្ញាតឱ្យនាយនាវា ឬបរិបាលនាវា ឬអ្នកបើកបរនាវាមិនចាំបាច់គោរពតាមវិធានបើកបរ ដើម្បីចៀសវាងគ្រោះថ្នាក់ភ្លាមៗ។

នាយនាវា ឬបរិបាលនាវា ឬអ្នកបើកបរនាវា មិនត្រូវបានឱ្យរួចផុតពីការទទួលខុសត្រូវ ចំពោះផលអាក្រក់ដែលកើតឡើងដោយការធ្វេសប្រហែសមិនគោរពតាមវិធានបើកបរ ឬការធ្វេសប្រហែសដែលតម្រូវឱ្យអនុវត្តទម្លាប់របស់នាវិក ឬដោយកាលៈទេសៈពិសេសនៃករណីណាមួយឡើយ។

កថាភាគទី២
វិធានបើកបរ

មាត្រា៨១ .-

នាវិកត្រូវឃ្លាំមើលផ្លូវជាប់ជានិច្ចនិងឱ្យបានត្រឹមត្រូវដោយការមើលនិងស្តាប់ រួមផ្សំនឹងការប្រើគ្រប់មធ្យោបាយដែលមាន ស្របតាមកាលៈទេសៈនិងស្ថានភាពជាក់ស្តែង ដើម្បីវាយតម្លៃឱ្យបានគ្រប់ជ្រុងជ្រោយនូវស្ថានភាពដំណើរចរណ៍និងហានិភ័យនៃការប៉ះទង្គិច។

មាត្រា៨២ .-

នាវានីមួយៗត្រូវធ្វើដំណើរក្នុងល្បឿនសុវត្ថិភាពជានិច្ច ដែលអាចឱ្យនាវាចាត់វិធានការបានត្រឹមត្រូវនិងមានប្រសិទ្ធភាព ដើម្បីបញ្ចៀសការប៉ះទង្គិច និងអាចបញ្ឈប់ចលនានាវាបាននៅក្នុងចម្ងាយមួយសមស្រប ស្របតាមកាលៈទេសៈនិងស្ថានភាពជាក់ស្តែង។

មាត្រា៨៣ .-

នាវានីមួយៗត្រូវប្រើគ្រប់មធ្យោបាយដែលមានស្របតាមកាលៈទេសៈនិងស្ថានភាពជាក់ស្តែង ដើម្បីកំណត់ហានិភ័យនៃការប៉ះទង្គិចដែលអាចកើតមានឡើង ហើយបើមានការសង្ស័យអំពីហានិភ័យនេះកើតឡើង ត្រូវចាត់ទុកថាវាពិតជាកើតឡើង។

ប្រសិនបើមានបំពាក់រ៉ាដាដែលមានមុខងារប្រតិបត្តិការជាក់លាក់ ត្រូវប្រើឱ្យបានត្រឹមត្រូវ ដោយត្រូវផ្តើមពិនិត្យមើលក្នុងវង់គំហើញឆ្ងាយ ដើម្បីទទួលបានព័ត៌មានព្រមានជាមុនអំពីហានិភ័យនៃការប៉ះទង្គិច និងគណនាប៉ារ៉ាម៉ែត្រចលនារបស់គោលដៅដែលបានសង្កេត។

ព័ត៌មានពុំមានមូលដ្ឋានគ្រប់គ្រាន់ មិនត្រូវសន្មតយកជាបានការ ជាពិសេសព័ត៌មានដែលទទួលបានពីរ៉ាដា។

ក្នុងការកំណត់ហានិភ័យនៃការប៉ះទង្គិចដែលអាចកើតឡើង ត្រូវពិចារណាលើនិទ្ទេសដូចខាងក្រោមៈ

- ហានិភ័យនឹងកើតឡើង ប្រសិនបើទិសសង្កេតទៅនាវាដែលខិតមកជិតមិនផ្លាស់ប្តូរ
- ហានិភ័យអាចកើតឡើងបាននៅពេលណាមួយ ទោះបីជាមានការកត់សម្គាល់ឃើញច្បាស់ថាមានការប្រែប្រួលទិសសង្កេត ជាពិសេសនៅពេលធ្វើដំណើរខិតចូលជិតគ្នាជាមួយនាវាមានទំហំធំ ឬនាវាសណ្តោង ឬធ្វើដំណើរកៀកគ្នាខ្លាំងជាមួយនាវាផ្សេងទៀត។

មាត្រា៨៤ .-

ចំណាត់ការណាមួយដើម្បីបញ្ចៀសការប៉ះទង្គិច ត្រូវធ្វើឡើងស្របតាមវិធានបើកបរ ហើយប្រសិនបើកាលៈទេសៈអនុញ្ញាត ត្រូវធ្វើដោយការជឿជាក់ ធ្វើក្នុងពេលវេលាគ្រប់គ្រាន់ និងអនុវត្តកិច្ចការសង្កេតដោយផ្ចិតផ្ចង់ក្នុងនាមជាអ្នកដើរសមុទ្រដ៏ល្អ។

ការប្តូរទិសបើកបរនិង/ឬល្បឿនដើម្បីបញ្ចៀសការប៉ះទង្គិច ប្រសិនបើកាលៈទេសៈអនុញ្ញាត ត្រូវធ្វើឱ្យប្រែប្រួលខ្លាំង ដើម្បីឱ្យនាវាផ្សេងទៀតមើលឃើញដោយភ្នែកឬរ៉ាដា ហើយមិនត្រូវប្តូរទិសបើកបរនិង/ឬល្បឿនបន្តិចម្តងៗច្រើនដងឡើយ។

ប្រសិនបើមានលម្ហគ្រប់គ្រាន់ ការប្តូរទិសបើកបរអាចជាចំណាត់ការតែមួយដែលមានប្រសិទ្ធភាពបំផុត ដើម្បីបញ្ចៀសស្ថានភាពកៀកគ្នាខ្លាំង ហើយត្រូវធ្វើក្នុងពេលវេលាគ្រប់គ្រាន់និងមិនបង្កឱ្យមានស្ថានភាពកៀកគ្នាខ្លាំងផ្សេងទៀត។

ចំណាត់ការដែលបានធ្វើឡើងដើម្បីបញ្ចៀសការប៉ះទង្គិចជាមួយនាវាផ្សេងទៀត ត្រូវអនុវត្តកិច្ចការសង្កេតដើម្បីឱ្យនាវាឆ្លងកាត់គ្នាក្នុងចម្ងាយសុវត្ថិភាព ហើយចំណាត់ការដែលប្រកបដោយប្រសិទ្ធភាព ត្រូវពិនិត្យមើលដោយយកចិត្តទុកដាក់រហូតដល់នាវាផ្សេងទៀតត្រូវបានឆ្លងកាត់ផុត។

ប្រសិនបើចាំបាច់ ដើម្បីបញ្ចៀសការប៉ះទង្គិច ឬដើម្បីទុកពេលវេលាបន្ថែមសម្រាប់វាយតម្លៃស្ថានភាព នាវាត្រូវបន្ថយល្បឿន ឬបញ្ឈប់កម្លាំងចលករ ឬត្រូវប្រើកម្លាំងចលករបញ្ច្រាស ដើម្បីទប់កម្លាំងជម្រុលទៅមុខរបស់នាវា។

ក្នុងដំណើរឆ្លងកាត់ នាវាត្រូវគោរពតាមវិធានការដូចខាងក្រោម៖

- នាវាដែលតម្រូវមិនឱ្យបង្អាក់ការធ្វើដំណើរឬដំណើរឆ្លងកាត់ដោយសុវត្ថិភាពរបស់នាវាផ្សេងទៀត តាមវិធានណាមួយនៅពេលដែលបានតម្រូវ ត្រូវធ្វើចំណាត់ការឱ្យបានឆាប់ ដើម្បីទុកពេលនិងលម្ហគ្រប់គ្រាន់សម្រាប់ការឆ្លងកាត់ដោយសុវត្ថិភាពរបស់នាវាផ្សេងទៀត
- នាវាដែលតម្រូវមិនឱ្យបង្អាក់ការធ្វើដំណើរឬការឆ្លងកាត់ដោយសុវត្ថិភាពរបស់នាវាផ្សេងទៀត មិនត្រូវរួចពីកាតព្វកិច្ចនេះឡើយ ប្រសិនបើនាវានេះធ្វើដំណើរខិតទៅជិតនាវាផ្សេងទៀតបង្កគ្រោះថ្នាក់ប៉ះទង្គិច ហើយនៅពេលកំពុងធ្វើចំណាត់ការ ត្រូវយកចិត្តទុកដាក់ឱ្យបានពេញលេញដែលបានតម្រូវដោយវិធានបើកបរ
- នៅពេលនាវាពីរគ្រឿងកំពុងធ្វើដំណើរខិតជិតគ្នា ដែលអាចបង្កគ្រោះថ្នាក់ប៉ះទង្គិច នាវាដែលមានសិទ្ធិឆ្លងកាត់ហើយមិនត្រូវបានបង្អាក់ដំណើររបស់ខ្លួន ត្រូវរក្សាកាតព្វកិច្ចពេញលេញអនុលោមតាមបទប្បញ្ញត្តិនៃវិធានបើកបរ។

មាត្រា៨៥ .-

ការធ្វើនាវាចរណ៍នៅតាមប្រឡាយនាវាចរណ៍តូចចង្អៀត៖

១- នាវាដែលធ្វើដំណើរតាមបណ្ដោយប្រឡាយនាវាចរណ៍តូចចង្អៀតឬច្រកនាវាចរណ៍ ត្រូវបើកបរអែបគែមស្ដាំនៃប្រឡាយនាវាចរណ៍តូចចង្អៀតឬច្រកនាវាចរណ៍នោះ តាមដែលអាចធ្វើទៅបាននិងមានសុវត្ថិភាព។

២- នាវាមានប្រវែងខ្លីជាង២០(ម្ភៃ)ម៉ែត្រឬនាវាប្រើក្ដោង មិនត្រូវបង្អាក់ដល់ការធ្វើដំណើរប្រកបដោយសុវត្ថិភាពរបស់នាវាផ្សេងទៀត។

៣- នាវាដែលកំពុងនេសាទ មិនត្រូវបង្អាក់ដល់ការធ្វើដំណើររបស់នាវាផ្សេងទៀតឡើយ។

៤- នាវាមិនត្រូវឆ្លងកាត់ទទឹងប្រឡាយនាវាចរណ៍តូចចង្អៀតឬច្រកនាវាចរណ៍ ប្រសិនបើការឆ្លងកាត់នោះបង្អាក់ដល់ការធ្វើដំណើរប្រកបដោយសុវត្ថិភាពរបស់នាវាផ្សេងទៀត។ ក្នុងករណីមានការសង្ស័យអំពីបំណងឆ្លងកាត់ទទឹងរបស់នាវាផ្សេងទៀត នាវាដែលកំពុងធ្វើដំណើរតាមបណ្ដោយផ្លូវ អាចបន្លឺសញ្ញាសំឡេងដូចមានចែងនៅក្នុងកថាខណ្ឌទី៤ មាត្រា១០៦នៃច្បាប់នេះ។

៥- ការជែងនៅក្នុងប្រឡាយនាវាចរណ៍តូចចង្អៀតឬច្រកនាវាចរណ៍៖

ក- នៅក្នុងប្រឡាយនាវាចរណ៍តូចចង្អៀតឬច្រកនាវាចរណ៍ ការជែងអាចប្រព្រឹត្តទៅបានលុះត្រាតែនាវាត្រូវជែងបានយល់ព្រមឱ្យនាវាជែងឆ្លងកាត់ដោយសុវត្ថិភាព ហើយនាវាដែលមានបំណងសុំជែង [illegible]ពីបំណងសុំជែងដោយការបន្លឺសញ្ញាសំឡេង ដូចមានចែងនៅក្នុងចំណុចក កថាខណ្ឌទី៣ មាត្រា១០៦នៃច្បាប់នេះ។ នាវាត្រូវជែង បើយល់ព្រមឱ្យជែង ត្រូវឆ្លើយតបវិញដោយការបន្លឺសញ្ញាសំឡេង

ដូចមានចែងនៅក្នុងចំណុចខ កថាខណ្ឌទី៣ មាត្រា១០៦នៃច្បាប់នេះ និងចាត់វិធានការជាជំហានៗដើម្បីឱ្យនាវាដែលឆ្លងកាត់ដោយសុវត្ថិភាព។ ក្នុងករណីមានការសង្ស័យ នាវាត្រូវតែអាចបន្លឺសញ្ញាសំឡេងដូចមានចែងនៅក្នុងកថាខណ្ឌទី៤ មាត្រា១០៦នៃច្បាប់នេះ។

ខ- បញ្ញត្តិនេះមិនលើកលែងឱ្យនាវាសុំដែង រួចផុតពីកាតព្វកិច្ច ដូចមានចែងនៅក្នុងមាត្រា៨៩នៃច្បាប់នេះឡើយ។

៦- នាវាដែលកំពុងធ្វើដំណើរនៅជិតផ្លូវកោងឬទៅជិតប្រឡាយនាវាចរណ៍តូចចង្អៀតឬច្រកនាវាចរណ៍ ជាកន្លែងដែលនាវាផ្សេងទៀតមើលមិនឃើញ ត្រូវបើកបរដោយប្រុងប្រយ័ត្ន និងបន្លឺសញ្ញាសំឡេងដូចមានចែងនៅក្នុងកថាខណ្ឌទី៥ មាត្រា១០៦នៃច្បាប់នេះ។

៧- នាវាត្រូវចៀសវាងបោះយុថ្កានៅក្នុងប្រឡាយនាវាចរណ៍តូចចង្អៀត លើកលែងតែកាលៈទេសៈអនុញ្ញាត។

មាត្រា៨៦ .-

បញ្ញត្តិនៃមាត្រានេះអនុវត្តចំពោះគន្លងបែងចែកចរាចរណ៍ដែលបានអនុម័តដោយអង្គការនាវាចរណ៍សមុទ្រអន្តរជាតិ ហើយនាវាដែលធ្វើដំណើរឆ្លងកាត់គន្លងបែងចែកចរាចរណ៍នេះ ក៏មិនត្រូវរួចផុតពីកាតព្វកិច្ចអនុវត្តបទប្បញ្ញត្តិនាវាចរណ៍ផ្សេងទៀតឡើយ។

នាវាដែលប្រើគន្លងបែងចែកចរាចរណ៍ ត្រូវ៖

- ធ្វើដំណើរនៅតាមគន្លងចរាចរណ៍ ស្របតាមទិសដៅរួមនៃលំហូរចរាចរណ៍សម្រាប់គន្លងនោះ
- តាមដែលអាចធ្វើទៅបាន ត្រូវធ្វើដំណើរឱ្យឃ្លាតពីបន្ទាត់បែងចែកចរាចរណ៍ឬតំបន់បែងចែកចរាចរណ៍
- ជាទូទៅ ត្រូវចូលឬចេញគន្លងចរាចរណ៍នៅតាមមាត់ច្រកនៃគន្លង ហើយនៅពេលចូលឬចេញត្រង់ផ្នែកចំហៀង ត្រូវធ្វើឡើងក្នុងមុំតូចធៀបជាមួយនឹងទិសដៅរួមតាមដែលអាចធ្វើបាន។

តាមដែលអាចធ្វើបាន នាវាត្រូវចៀសវាងការឆ្លងកាត់ទទឹងគន្លងបែងចែកចរាចរណ៍ ហើយបើចាំបាច់ត្រូវកាត់ទទឹង ត្រូវឱ្យទិសក្បាលនាវាកាត់ត្រង់ឬស្ទើរត្រង់ធៀបទៅនឹងទិសដៅរួមនៃលំហូរចរាចរណ៍តាមដែលអាចធ្វើបាន។

ក្នុងតំបន់ចរាចរណ៍ជាប់ដីគោក នាវាត្រូវអនុវត្តដូចខាងក្រោម៖

- នាវាមិនត្រូវប្រើតំបន់ចរាចរណ៍ជាប់ដីគោក នៅពេលណាដែលនាវាអាចប្រើគន្លងចរាចរណ៍ប្រកបដោយសុវត្ថិភាព នៅក្នុងគន្លងបែងចែកចរាចរណ៍ដែលស្ថិតនៅជិតនោះ លើកលែងនាវាមានប្រវែងខ្លីជាង២០(ម្ភៃ)ម៉ែត្រ នាវាប្រើក្ដោង និងនាវាកំពុងធ្វើនេសាទ ដែលអាចប្រើតំបន់ចរាចរណ៍នោះបាន
- បើទោះជាមានបញ្ញត្តិក្នុងត្រេទី១ខាងលើនេះក៏ដោយ ក៏នាវាអាចប្រើតំបន់ចរាចរណ៍ជាប់ដីគោកបានដែរ នៅពេលនាវាកំពុងធ្វើដំណើរចូលចេញកំពង់ផែ ស្ថានីយសមុទ្រ ស្ថានីយកណ្ដាលឬកន្លែងដែលស្ថិតនៅក្នុងតំបន់ចរាចរណ៍នេះ ឬដើម្បីចៀសវាងគ្រោះថ្នាក់ភ្លាមៗ។

នាវា ក្រៅពីនាវាកាត់ទទឹង ឬនាវាចូលចេញគន្លងចរាចរណ៍ មិនត្រូវចូលតំបន់បែងចែកចរាចរណ៍ ឬឆ្លងកាត់បន្ទាត់បែងចែកចរាចរណ៍បានទេ លើកលែងតែករណីដូចខាងក្រោម៖

- ករណីអាសន្ន ដើម្បីបញ្ចៀសគ្រោះថ្នាក់ភ្លាមៗ
- ករណីធ្វើនេសាទនៅក្នុងតំបន់បែងចែកចរាចរណ៍។

២០/៧១

នាវាដែលធ្វើនាវាចរណ៍នៅតំបន់ដែលស្ថិតនៅជិតមាត់ច្រកគន្លងបែងចែកចរាចរណ៍ ត្រូវធ្វើនាវាចរណ៍ដោយប្រុងប្រយ័ត្នជាពិសេស។

តាមដែលអាចធ្វើទៅបាន នាវាត្រូវចៀសវាងបោះយុថ្កានៅក្នុងគន្លងបែងចែកចរាចរណ៍ ឬនៅតំបន់ដែលស្ថិតនៅជិតមាត់ច្រកគន្លងបែងចែកចរាចរណ៍។

នាវាដែលមិនប្រើគន្លងបែងចែកចរាចរណ៍ ត្រូវចៀសឱ្យឆ្ងាយពីគន្លងនេះ តាមដែលអាចធ្វើបាន។

នាវាកំពុងធ្វើនេសាទ មិនត្រូវបង្អាក់ការធ្វើដំណើររបស់នាវាដែលកំពុងប្រើគន្លងចរាចរណ៍នោះទេ។

នាវាមានប្រវែងខ្លីជាង២០(ម្ភៃ)ម៉ែត្រឬនាវាប្រើក្ដោង មិនត្រូវបង្អាក់ដល់ការធ្វើដំណើរដោយសុវត្ថិភាពរបស់នាវាប្រើម៉ាស៊ីនដែលកំពុងប្រើគន្លងចរាចរណ៍នោះទេ។

នាវាមានកម្រិតសមត្ថភាពចលនាចរណ៍ នៅពេលជាប់រវល់ប្រតិបត្តិការរក្សាសុវត្ថិភាពនាវាចរណ៍នៅក្នុងគន្លងបែងចែកចរាចរណ៍ រាយ ទម្លាក់ ថែទាំជួសជុល ឬលើកខ្សែកាបក្រោមទឹកនៅក្នុងគន្លងបែងចែកចរាចរណ៍ ត្រូវបានលើកលែងពីការអនុវត្តតាមបទប្បញ្ញត្តិនៅក្នុងវិធាននេះ។

មាត្រា៨៧.-

លើកលែងតែទីកន្លែងដែលតម្រូវអនុវត្តតាមវិធានផ្សេងដូចមានចែងនៅក្នុងមាត្រា៨៥ មាត្រា៨៦ និងមាត្រា៨៩នៃច្បាប់នេះ នាវាត្រូវអនុវត្តតាមគោលការណ៍ ដូចខាងក្រោម៖

១- នាវាប្រើម៉ាស៊ីន ត្រូវចៀសចេញពីនាវាមិនអាចបញ្ជាបាន នាវាមានកម្រិតសមត្ថភាពចលនាចរណ៍ នាវាកំពុងនេសាទ និងនាវាប្រើក្ដោង។

២- នាវាប្រើក្ដោង ត្រូវចៀសចេញពីនាវាមិនអាចបញ្ជាបាន នាវាមានកម្រិតសមត្ថភាពចលនាចរណ៍ និងនាវាកំពុងនេសាទ។

៣- នាវាកំពុងនេសាទ ត្រូវចៀសចេញពីនាវាមិនអាចបញ្ជា និងនាវាមានកម្រិតសមត្ថភាពចលនាចរណ៍។

៤- លើកលែងតែកាលៈទេសៈអនុញ្ញាត នាវាគ្រប់ប្រភេទ ក្រៅពីនាវាមិនអាចបញ្ជាបាន និងនាវាមានកម្រិតសមត្ថភាពចលនាចរណ៍ ត្រូវចៀសវាងការបង្អាក់ដល់ការឆ្លងកាត់ដោយសុវត្ថិភាពរបស់នាវាមានដែនកម្រិតជម្រៅស៊ីទឹកដែលបង្ហាញភ្លើងបើកបរឬសញ្ញាបើកបរ ដូចមានចែងនៅក្នុងមាត្រា១០១នៃច្បាប់នេះ។ នាវាមានដែនកម្រិតជម្រៅស៊ីទឹក ត្រូវបើកបរដោយការប្រុងប្រយ័ត្នជាពិសេស ដោយមានការយកចិត្តទុកដាក់ចំពោះលក្ខខណ្ឌពិសេសរបស់ខ្លួន។

៥- យន្តហោះសមុទ្រពេលកំពុងបើកបរលើទឹក ត្រូវរក្សាគម្លាត និងចៀសវាងការបង្អាក់ដល់ការធ្វើនាវាចរណ៍របស់នាវាទាំងអស់។ ទោះយ៉ាងណាក៏ដោយ ក្នុងកាលៈទេសៈមានហានិភ័យប៉ះទង្គិចកើតឡើងយន្តហោះសមុទ្រត្រូវគោរពតាមបញ្ញត្តិនៃជំពូកនេះ។

៦- យានហោះលើទឹក៖

- នៅពេលហោះឡើង ចុះចត និងហោះនៅជិតផ្ទៃទឹក ត្រូវរក្សាគម្លាត និងចៀសវាងការបង្អាក់ការធ្វើនាវាចរណ៍ពីនាវាទាំងអស់
- នៅពេលធ្វើប្រតិបត្តិការលើផ្ទៃទឹក ត្រូវអនុវត្តតាមបញ្ញត្តិនៃជំពូកនេះដូចនាវាប្រើម៉ាស៊ីនដែរ។

មាត្រា៨៨.-

នៅពេលដែលនាវាប្រើក្ដោងធ្វើដំណើរមកជិតគ្នា ដែលអាចនឹងបង្កការប៉ះទង្គិចនោះ នាវាមួយក្នុងចំណោមនាវាទាំងពីរ ត្រូវចៀសតាមករណីដូចតទៅ៖

១- នៅពេលណាដែលនាវានីមួយៗទទួលរងខ្យល់បក់នៅចំហៀងផ្សេងគ្នា នាវាដែលប៉ះខ្យល់នៅខាងឆ្វេង ត្រូវចៀស។

២- នៅពេលណាដែលនាវាទាំងពីរទទួលរងខ្យល់បក់នៅចំហៀងដូចគ្នា នាវាដែលធ្វើដំណើរនៅលើខ្យល់ ត្រូវចៀសពីផ្លូវនាវាដែលធ្វើដំណើរនៅក្រោមខ្យល់។

៣- ប្រសិនបើនាវាដែលទទួលរងនូវខ្យល់បក់នៅខាងឆ្វេង មើលឃើញនាវាដែលស្ថិតនៅលើខ្យល់ ហើយមិនអាចកំណត់បានពិតប្រាកដអំពីខ្យល់បក់នៅខាងឆ្វេងឬនៅខាងស្តាំរបស់នាវានោះ នាវានោះត្រូវចៀស។

សម្រាប់បទប្បញ្ញត្តិនៅក្នុងមាត្រានេះ ចំហៀងដែលស្ថិតនៅលើខ្យល់ត្រូវបានចាត់ទុកជាចំហៀងដែលស្ថិតនៅប្រឈមនឹងទិសដៅខ្យល់បក់ទៅលើផ្ទាំងក្តោងសំខាន់ ឬសម្រាប់ករណីនាវាបំពាក់ដោយក្តោងត្រង់ ចំហៀងដែលស្ថិតនៅលើខ្យល់ត្រូវបានចាត់ទុកជាចំហៀងដែលមានខ្យល់បក់លើផ្ទាំងក្តោងខ្លាំងជាង។

មាត្រា៨៩ ..

នាវាណាមួយកំពុងដេញនាវាមួយទៀត ត្រូវរក្សាចម្ងាយពីនាវាដែលត្រូវដេញនោះ។

នាវាត្រូវចាត់ទុកថាកំពុងដេញ នៅពេលដែលនាវានោះបានទៅជិតនាវាមួយទៀត ឋិតនៅក្នុងទិសដៅមានមុំធំជាង២២,៥ដឺក្រេ ចំហៀងខាងក្រោយនៃនាវានោះ។ ក្នុងទីតាំងនេះ នាពេលយប់ នាវាកំពុងដេញអាចមើលឃើញតែភ្លើងកន្សៃ ដោយមិនមើលឃើញភ្លើងចំហៀងណាមួយរបស់នាវាត្រូវដេញឡើយ។

នៅពេលនាវាមានការសង្ស័យអំពីការកំពុងដេញនាវាមួយទៀត នាវាដេញត្រូវចាត់ថាជាករណីដេញ និងត្រូវចាត់វិធានការស្របទៅតាមបទប្បញ្ញត្តិនាវាចរណ៍។

ការប្រែប្រួលទិសសង្កេតរវាងនាវាទាំងពីរជាបន្តបន្ទាប់ មិនធ្វើឱ្យនាវាដេញក្លាយជានាវាកាត់ទទឹងឡើយសម្រាប់ន័យនៅក្នុងបទប្បញ្ញត្តិនាវាចរណ៍ ឬធ្វើឱ្យនាវាដេញរួចពីកាតព្វកិច្ចរក្សាគម្លាតពីនាវាត្រូវដេញឡើយ លុះត្រាតែនាវាដេញត្រូវបានឆ្លងផុតពីនាវាដែលត្រូវដេញ។

មាត្រា៩០ ..

នៅពេលដែលនាវាប្រើម៉ាស៊ីនពីរគ្រឿង មានទិសដៅបើកបរទល់មុខគ្នាឬស្ទើរទល់មុខគ្នា ដែលអាចនឹងបង្កហានិភ័យនៃការប៉ះទង្គិច នាវាទាំងពីរនោះត្រូវងាកទៅខាងស្តាំរៀងៗខ្លួន។

ស្ថានភាពដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ចាត់ទុកថាកើតមាននៅពេលដែលនាវាមួយបានឃើញក្បាលនាវាមួយទៀតចំពីមុខឬស្ទើរចំពីមុខ ហើយនៅពេលយប់បានឃើញភ្លើងដងក្តោងឬភ្លើងចំហៀងទាំងពីររបស់នាវាមួយទៀត។

នៅពេលដែលនាវាមួយស្ថិតនៅក្នុងការសង្ស័យអំពីការចៀសជាមួយនាវាមួយផ្សេងទៀត ត្រូវសន្មតថាការចៀសគ្នានឹងកើតមានឡើង ហើយត្រូវចាត់វិធានការសមស្របដើម្បីចៀស។

មាត្រា៩១ ..

នៅពេលនាវាប្រើម៉ាស៊ីនពីរគ្រឿងកំពុងធ្វើដំណើរកាត់មុខគ្នា អាចនឹងបង្កហានិភ័យនៃការប៉ះទង្គិច នាវាដែលឃើញនាវាមួយទៀតស្ថិតនៅចំហៀងខាងស្តាំ ត្រូវចៀសនាវានោះ ហើយត្រូវចៀសវាងការចៀសនៅពីមុខនាវាមួយទៀត លើកលែងតែកាលៈទេសៈអនុញ្ញាត។

មាត្រា៩២ ..

ប្រសិនបើអាចធ្វើទៅបាន នាវានីមួយៗដែលត្រូវទុកផ្លូវឱ្យនាវាផ្សេងទៀត ត្រូវចាត់វិធានការជាមុន និងត្រឹមត្រូវដើម្បីទុកផ្លូវឱ្យនាវាផ្សេងទៀត។

២២/៧១

មាត្រា៩៣ .-

ប្រសិនបើនាវាមួយក្នុងចំណោមនាវាពីរគ្រឿងកំពុងចៀស នាវាត្រូវចៀសត្រូវរក្សាទិសបើកបរនិងល្បឿនដដែល និងត្រូវមានវិធានការចាំបាច់នានាដើម្បីបញ្ចៀសការប៉ះទង្គិច ប្រសិនបើនាវាចៀសនោះមិនបានចាត់វិធានការអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

នៅពេលនាវាពីរគ្រឿងចៀសគ្នា នាវាដែលត្រូវបានចៀស ត្រូវរក្សាទិសបើកបរនិងល្បឿន។ ក្នុងករណីមើលឃើញថានាវាដែលត្រូវចៀស មិនអាចចាត់វិធានការអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ នាវាដែលត្រូវបានចៀស ត្រូវចាត់វិធានការបញ្ចៀសការប៉ះទង្គិចដោយធ្វើចលនាចរណ៍ឱ្យបានឆាប់។

នៅពេលមានមូលហេតុណាមួយ នាវាដែលតម្រូវឱ្យរក្សាទិសបើកបរនិងល្បឿន មើលឃើញនាវារបស់ខ្លួននិងនាវាមួយផ្សេងទៀតស្ថិតនៅកៀកគ្នាខ្លាំង ដែលការប៉ះទង្គិចមិនអាចគេចផុតដោយចំណាត់ការរបស់នាវាមួយទៀតតែឯង នាវានេះត្រូវចៀសដើម្បីបញ្ចៀសការប៉ះទង្គិច។

នាវាប្រើម៉ាស៊ីនដែលចាត់វិធានការក្នុងស្ថានភាពឆ្លងកាត់ទទឹងអនុលោមតាមបញ្ញត្តិក្នុងកថាខណ្ឌទី២នៃមាត្រានេះ ដើម្បីបញ្ចៀសការប៉ះទង្គិចជាមួយនាវាប្រើម៉ាស៊ីនផ្សេងទៀត មិនត្រូវប្តូរទិសបើកបរទៅឆ្វេងដែលមាននាវាមួយទៀតស្ថិតនៅផ្នែកខាងឆ្វេងរបស់ខ្លួន លើកលែងតែកាលៈទេសៈអនុញ្ញាត។

បញ្ញត្តិនេះមិនអនុញ្ញាតឱ្យនាវាចៀស រួចផុតពីកាតព្វកិច្ចនៃការទុកផ្លូវឱ្យនាវាដែលត្រូវចៀស។

មាត្រា៩៤ .-

បញ្ញត្តិនៅក្នុងមាត្រានេះអនុវត្តចំពោះនាវាដែលមិនអាចមើលឃើញនាវាផ្សេងទៀតនៅពេលធ្វើនាវាចរណ៍នៅក្នុងតំបន់ឬជិតតំបន់ដែលការមើលឃើញមានកម្រិត។

នាវានីមួយៗត្រូវធ្វើដំណើរដោយល្បឿនសុវត្ថិភាពទៅតាមស្ថានភាពនិងកាលៈទេសៈជាក់ស្តែងនៃកម្រិតមើលឃើញ ហើយនាវាដែលមានបំពាក់ម៉ាស៊ីន ត្រូវត្រៀមជានិច្ចសម្រាប់ការធ្វើចលនាចរណ៍បន្ទាន់។

នៅពេលដែលត្រូវអនុវត្តបទប្បញ្ញត្តិក្នុងកថាភាគទី២ ផ្នែកទី១ នៃជំពូកនេះ នាវានីមួយៗត្រូវមានការប្រុងប្រយ័ត្នចំពោះស្ថានភាពនិងកាលៈទេសៈជាក់ស្តែងនៃកម្រិតមើលឃើញ។

នាវាដែលមើលឃើញនាវាផ្សេងទៀតតាមតែរេដា ត្រូវកំណត់អំពីស្ថានភាពកាន់តែខិតជិតគ្នាខ្លាំងនិង/ឬហានិភ័យនៃគ្រោះថ្នាក់ប៉ះទង្គិចកើតឡើង។ ប្រសិនបើស្ថានភាពនេះកើតឡើង នាវានេះត្រូវចាត់វិធានការបញ្ចៀសការប៉ះទង្គិចក្នុងពេលវេលាគ្រប់គ្រាន់ ហើយនៅពេលដែលវិធានការនេះជាការប្តូរទិសបើកបរតាមលទ្ធភាពដែលអាចធ្វើបាន ត្រូវចៀសវាងៈ

- ការប្តូរទិសបើកបរទៅឆ្វេង ប្រសិនបើនាវាផ្សេងទៀតស្ថិតនៅចំហៀងមុខមិនមែនជានាវាដែលត្រូវជែង
- ការប្តូរទិសបើកបរទៅចំហៀងដែលមាននាវាស្ថិតនៅចំហៀងចំឬនៅចំហៀងក្រោយ។

លើកលែងករណីត្រូវបានកំណត់ថាហានិភ័យនៃការប៉ះទង្គិចមិនកើតមាន នាវានីមួយៗដែលឮសញ្ញាសំឡេងអ័ព្ទនៃនាវាផ្សេងទៀតនៅចំហៀងខាងមុខ ឬដែលមិនអាចចៀសពីស្ថានភាពខិតជិតខ្លាំងជាមួយនាវាផ្សេងទៀតដែលស្ថិតនៅចំហៀងខាងមុខរបស់ខ្លួន នាវានោះត្រូវបន្ថយល្បឿនដល់អប្បបរមាដែលអាចធ្វើឱ្យនាវានោះរក្សាទិសបើកបរបាន។ ប្រសិនបើចាំបាច់ នាវានោះត្រូវបញ្ឈប់ចលនា ហើយនៅក្នុងករណីខ្លះត្រូវបើកបរដោយប្រុងប្រយ័ត្នខ្ពស់រហូតដល់គ្រោះថ្នាក់នៃការប៉ះទង្គិចត្រូវបានឆ្លងផុត។

២៣/៧១

កថាភាគទី៣
ភ្លើងបើកបរនិងសញ្ញាបើកបរ

មាត្រា៩៥ .-

បទប្បញ្ញត្តិភ្លើងបើកបរនិងសញ្ញាបើកបរ ត្រូវអនុវត្តនៅគ្រប់ស្ថានភាពអាកាសធាតុ។

ភ្លើងបើកបរដែលប្រើក្នុងវិធានពាក់ព័ន្ធ ត្រូវអនុវត្តចាប់ពីពេលថ្ងៃលិចរហូតដល់ថ្ងៃរះ ហើយនៅក្នុងពេលនេះមិនត្រូវប្រើភ្លើងផ្សេងទៀតឡើយ លើកលែងតែភ្លើងដែលមិនអាចឱ្យមានការភាន់ច្រឡំនឹងភ្លើងដូចមានចែងនៅក្នុងបទប្បញ្ញត្តិនេះ ឬមិនធ្វើឱ្យបាត់បង់គំហើញ ឬបច្ចេកលក្ខណៈដែលខុសគ្នា ឬរំខានការសង្កេតមើលបានត្រឹមត្រូវ។

ភ្លើងបើកបរដូចមានចែងនៅក្នុងបទប្បញ្ញត្តិនេះ ក៏ត្រូវបានប្រើផងដែរពីថ្ងៃរះដល់ថ្ងៃលិច នៅពេលការមើលឃើញមានកម្រិត និងត្រូវប្រើនៅក្នុងកាលៈទេសៈផ្សេងទៀតនៅពេលដែលចាត់ទុកថាចាំបាច់។

សញ្ញាបើកបរដែលប្រើក្នុងវិធានពាក់ព័ន្ធ ត្រូវបានអនុវត្តនៅពេលថ្ងៃ។

មាត្រា៩៦ .-

នាវាប្រើម៉ាស៊ីន ដែលកំពុងធ្វើដំណើរ ត្រូវបើកភ្លើងបើកបរដូចខាងក្រោម៖

- ភ្លើងដងក្តោងមុខ
- ភ្លើងដងក្តោងទី២ ដែលស្ថិតនៅខ្ពស់ជាងភ្លើងដងក្តោងមុខ លើកលែងតែនាវាដែលមានប្រវែងខ្លីជាង៥០(ហាសិប)ម៉ែត្រ
- ភ្លើងចំហៀង
- ភ្លើងកន្សៃ។

នាវាប្រើកម្លាំងចលករដោយកង្ហារ នៅពេលធ្វើប្រតិបត្តិការបាតនាវាត់ប៉ប្រះទឹក ត្រូវបើកភ្លើងបីរយហុកសិបដឺក្រេភ្លឹបភ្លែតពណ៌លឿង បន្ថែមពីលើភ្លើងដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ។

យានហោះលើផ្ទៃទឹក នៅពេលហោះឡើង ចុះចត ឬហោះជិតផ្ទៃទឹក ត្រូវបើកភ្លើងបីរយហុកសិបដឺក្រេភ្លឹបភ្លែតពណ៌ក្រហម ដែលមានអាំងតង់ស៊ីតេខ្ពស់ បន្ថែមពីលើភ្លើងដូចមានចែងនៅក្នុងកថាខណ្ឌទី១នៃមាត្រានេះ។

នាវាប្រើម៉ាស៊ីនមានប្រវែងខ្លីជាង១២(ដប់ពីរ)ម៉ែត្រ អាចបើកភ្លើងបីរយហុកសិបដឺក្រេពណ៌ស និងភ្លើងចំហៀងជំនួសបាន។

នាវាប្រើម៉ាស៊ីនមានប្រវែងខ្លីជាង៧(ប្រាំពីរ)ម៉ែត្រ និងល្បឿនអតិបរមា៧(ប្រាំពីរ)ណត អាចបើកភ្លើងបីរយហុកសិបដឺក្រេពណ៌សជំនួសបាន ហើយបើចាំបាច់ក៏អាចបើកភ្លើងចំហៀងបន្ថែមទៀតបានដែរ។

នាវាប្រើម៉ាស៊ីនមានប្រវែងខ្លីជាង១២(ដប់ពីរ)ម៉ែត្រ មានទទឹងមិនគ្រប់គ្រាន់សម្រាប់ដាក់ភ្លើងចំហៀងដាច់ដោយឡែកពីគ្នា អាចដាក់ភ្លើងចំហៀងនៅលើទីតាំងតែមួយនៅអ័ក្សបណ្តោយផ្នែកខាងមុខឬ ផ្នែកខាងក្រោយនាវាបាន។

មាត្រា៩៧ .-

នាវាប្រើម៉ាស៊ីន ដែលកំពុងសណ្តោង ត្រូវបើកភ្លើងបើកបរ ឬសញ្ញាបើកបរ ដូចខាងក្រោម៖

- ជំនួសភ្លើងក្តោងមុខឬភ្លើងដងក្តោងទី២ ដោយភ្លើងដងក្តោងពីរស្ថិតលើបន្ទាត់ឈរ ហើយប្រសិនបើប្រវែងសណ្តោងដែលវាស់ពីកន្សៃនាវាសណ្តោង ទៅដល់ផ្នែកក្រោយបំផុតនៃនាវាត្រូវសណ្តោងលើសពី២០០(ពីររយ)ម៉ែត្រ ត្រូវប្រើភ្លើងដងក្តោង៣ស្ថិតលើបន្ទាត់ឈរតែមួយ

២៤/៧១

- ភ្លើងចំហៀង
- ភ្លើងកន្សៀ
- ភ្លើងសណ្តោងដាក់លើបន្ទាត់ឈរតែមួយនៅលើភ្លើងកន្សៀ
- នៅពេលតួសណ្តោងមានប្រវែងលើសពី២០០(ពីររយ)ម៉ែត្រ ត្រូវដាក់កោនមានបាតទល់គ្នា ដែលអាចមើលឃើញច្បាស់បាន។

នៅពេលនាវារុញនិងនាវាត្រូវរុញ បានតភ្ជាប់គ្នាជាអង្គតែមួយ ត្រូវចាត់ទុកថា ជានាវាប្រើម៉ាស៊ីនតែមួយ និងត្រូវបើកភ្លើងបើកបរ ដូចមានចែងនៅក្នុងមាត្រា៩៦ខាងលើនេះ។

នាវាប្រើម៉ាស៊ីន ដែលកំពុងរុញឬសណ្តោងចំហៀង ដែលមិនមែនជាអង្គតែមួយ ត្រូវប្រើភ្លើងបើកបរ ដូចខាងក្រោម៖

- ជំនួសភ្លើងក្តោងមុខឬភ្លើងដងក្តោងទី២ ដោយភ្លើងដងក្តោងចំនួនពីរស្ថិតលើបន្ទាត់ឈរតែមួយ
- ភ្លើងចំហៀង
- ភ្លើងកន្សៀ។

គ្រេទី២ កថាខណ្ឌទី១ មាត្រា៩៦នៃច្បាប់នេះ ក៏ត្រូវយកមកអនុវត្តផងដែរ ចំពោះនាវាប្រើម៉ាស៊ីន ដូចមានចែងនៅក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី៣នៃមាត្រានេះ។

នាវាឬវត្ថុត្រូវសណ្តោង ក្រៅពីនាវាដូចមានចែងនៅក្នុងកថាខណ្ឌទី៧នៃមាត្រានេះ ត្រូវប្រើភ្លើងបើកបរ ដូចខាងក្រោម៖

- ភ្លើងចំហៀង
- ភ្លើងកន្សៀ
- កោនមានបាតទល់គ្នា ដែលអាចមើលឃើញច្បាស់ ប្រសិនបើប្រវែងសណ្តោងលើសពី២០០ (ពីររយ)ម៉ែត្រ។

ក្នុងករណីនាវាត្រូវសណ្តោងចំហៀងឬរុញស្ថិតនៅជាក្រុមតែមួយ ត្រូវប្រើភ្លើងដូចគ្នានឹងនាវាតែមួយ៖

- នាវាត្រូវរុញដែលស្ថិតនៅមុខបំផុត ហើយមិនមែនជាផ្នែកនៃអង្គតែមួយ ត្រូវដាក់ភ្លើងចំហៀងនៅផ្នែកខាងមុខរបស់នាវា
- នាវាត្រូវសណ្តោងចំហៀង ត្រូវដាក់ភ្លើងកន្សៀ និងភ្លើងចំហៀងនៅផ្នែកខាងមុខរបស់នាវា។

ផ្នែកខ្លះនៃនាវាឬវត្ថុដែលលិចទឹក ឬគ្រឿងតភ្ជាប់នាវា ឬវត្ថុត្រូវសណ្តោងដែលមិនអាចមើលឃើញ ត្រូវដាក់បង្ហាញ៖

- ប្រសិនបើប្រវែងសណ្តោងមានទទឹងខ្លីជាង២៥(ម្ភៃប្រាំ)ម៉ែត្រ ដាក់នូវភ្លើងបីរយហុកសិបដឺក្រេមួយពណ៌ស នៅលើឬជិតផ្នែកខាងមុខ និងមួយទៀតនៅលើឬជិតផ្នែកខាងក្រោយនៃវត្ថុត្រូវសណ្តោង លើកលែងតែជ្រោខុន មិនចាំបាច់ដាក់ភ្លើងនៅលើឬជិតផ្នែកខាងមុខនៃជ្រោខុននោះឡើយ
- ប្រសិនបើប្រវែងសណ្តោងមានទទឹង២៥(ម្ភៃប្រាំ)ម៉ែត្រឬវែងជាង ដាក់នូវភ្លើងបីរយហុកសិបដឺក្រេពីរពណ៌សបន្ថែមទៀតនៅលើឬជិតគែមសងខាងនាវា
- ប្រសិនបើប្រវែងសណ្តោងមានលើសពី១០០(មួយរយ)ម៉ែត្រ ដាក់នូវភ្លើងបីរយហុកសិបដឺក្រេពណ៌សបន្ថែម នៅចន្លោះភ្លើងដែលបានដាក់ដូចក្នុងគ្រេទី១និងទី២ខាងលើនេះ ធ្វើយ៉ាងណាឱ្យចម្ងាយរវាងភ្លើងទាំងនោះមិនលើសពី១០០(មួយរយ)ម៉ែត្រ

- កោនមានបាតទល់គ្នានៅលើឬជិតទីតាំងក្រោយបំផុតនៃនាវា ឬវត្ថុត្រូវសណ្ដោងចុងក្រោយបំផុត ហើយប្រសិនបើប្រវែងសណ្ដោងលើសពី២០០(ពីររយ)ម៉ែត្រ ត្រូវប្រើកោនមានបាតទល់គ្នាបន្ថែមទៀត ដែលអាចមើលឃើញច្បាស់បាន។

ក្នុងករណីមានមូលហេតុគ្រប់គ្រាន់បញ្ជាក់ថា នាវាឬវត្ថុត្រូវសណ្ដោងមិនអាចប្រើភ្លើងបើកបរឬសញ្ញាបើកបរ ដូចមានចែងនៅក្នុងកថាខណ្ឌទី៥និងកថាខណ្ឌទី៧នៃមាត្រានេះ ត្រូវចាត់វិធានការដែលអាចធ្វើបានដើម្បីបំពាក់ភ្លើងឱ្យនាវាឬវត្ថុត្រូវសណ្ដោង ឬដើម្បីបង្ហាញអំពីវត្តមាននៃនាវាឬវត្ថុត្រូវសណ្ដោង។

ប្រសិនបើមានមូលហេតុគ្រប់គ្រាន់បញ្ជាក់ថា នាវាដែលជាធម្មតាមិនធ្វើប្រតិបត្តិការសណ្ដោងមិនអាចដាក់បង្ហាញភ្លើងបើកបរដូចមានចែងនៅក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី៣នៃមាត្រានេះបាន នាវានោះនឹងមិនតម្រូវឱ្យដាក់ភ្លើងនោះឡើយ នៅពេលដែលសណ្ដោងនាវាផ្សេងទៀតក្នុងគ្រាអាសន្ន ឬត្រូវការជំនួយពីនាវាផ្សេងទៀត។ ករណីនេះ នាវាសណ្ដោងនិងនាវាត្រូវសណ្ដោង ត្រូវចាត់វិធានការដើម្បីបង្ហាញអំពីចំណងទំនាក់ទំនងរវាងគ្នា អនុលោមតាមបញ្ញត្តិមាត្រា១០៨នៃច្បាប់នេះ ជាពិសេសត្រូវបំភ្លឺឱ្យឃើញច្បាស់នូវខ្សែសណ្ដោង។

មាត្រា៩៨ .-

នាវាកំពុងធ្វើដំណើរដោយប្រើក្ដោង ត្រូវប្រើភ្លើងបើកបរដូចខាងក្រោម៖

- ភ្លើងចំហៀង
- ភ្លើងកន្សៃ។

នាវាប្រើក្ដោងមានប្រវែងខ្លីជាង២០(ម្ភៃ)ម៉ែត្រ ភ្លើងបើកបរដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវដាក់បញ្ចូលគ្នាក្នុងគោមតែមួយ នៅលើឬជិតកំពូលដងក្ដោង។

នាវាប្រើក្ដោងកំពុងធ្វើដំណើរ អាចបន្ថែមលើភ្លើងបើកបរដូចមានចែងនៅក្នុងកថាខណ្ឌទី១នៃមាត្រានេះ នូវភ្លើងបីរយហុកសិបដឺក្រេពីរនៅលើបន្ទាត់ឈរតែមួយ ខាងលើពណ៌ក្រហម ខាងក្រោមពណ៌បៃតងស្ថិតនៅលើឬជិតកំពូលដងក្ដោងដែលអាចមើលឃើញច្បាស់។ ភ្លើងទាំងពីរនេះមិនត្រូវដាក់នៅជាប់នឹងភ្លើងបើកបរដែលបានដាក់ក្នុងគោមតែមួយនោះឡើយ។

នាវាប្រើក្ដោងមានប្រវែងខ្លីជាង៧(ប្រាំពីរ)ម៉ែត្រ ប្រសិនបើអាចធ្វើបាន ត្រូវប្រើភ្លើងបើកបរដូចមានចែងនៅក្នុងកថាខណ្ឌទី១និងទី២នៃមាត្រានេះ ហើយក្នុងករណីមិនអាចធ្វើបាន ត្រូវត្រៀមពិលឬភ្លើងគោមពណ៌ស ដែលអាចបំភ្លឺបានក្នុងរយៈពេលគ្រប់គ្រាន់ ដើម្បីបង្ការការប៉ះទង្គិច។ ទូកអុំនិងទូកចែវ ប្រសិនបើអាចធ្វើបាន ត្រូវអនុវត្តតាមបញ្ញត្តិដូចមានចែងនៅក្នុងកថាខណ្ឌទី១នៃមាត្រានេះ ហើយក្នុងករណីមិនអាចធ្វើបាន ត្រូវអនុវត្តតាមបញ្ញត្តិដូចមានចែងនៅក្នុងកថាខណ្ឌទី២នៃមាត្រានេះ។

នាវាដែលកំពុងធ្វើដំណើរដោយក្ដោង ហើយក៏បានប្រើម៉ាស៊ីនចលករផងដែរ ត្រូវប្រើកោនកំពូលចុះក្រោមស្ថិតនៅខាងមុខក្ដោងដែលអាចមើលឃើញច្បាស់។

មាត្រា៩៩ .-

នាវាកំពុងធ្វើនេសាទ ទោះជាកំពុងធ្វើដំណើរឬបោះយុថ្កា ត្រូវប្រើភ្លើងបើកបរនិងសញ្ញាបើកបរដូចមានចែងនៅក្នុងមាត្រានេះ។

នាវាកំពុងអូសអួន ត្រូវប្រើភ្លើងបើកបរឬសញ្ញាបើកបរដូចខាងក្រោម៖

- ភ្លើងបីរយហុកសិបដឺក្រេពីរនៅលើបន្ទាត់ឈរតែមួយ ខាងលើពណ៌បៃតង ខាងក្រោមពណ៌ស
- សញ្ញាបើកបរ ដែលផ្គុំឡើងដោយកោនពីរស្ថិតលើបន្ទាត់ឈរតែមួយមានកំពូលទល់គ្នា

២៦/៧១

កាលណាកិច្ចសន្យាដឹកជញ្ជូនទំនិញ មានចែងខសន្យាដែលថា វិវាទដែលកើតឡើងរវាងភាគី ត្រូវដោះស្រាយតាមតុលាការ ឬមជ្ឈត្តការ ឬយន្តការដោះស្រាយវិវាទណាមួយផ្សេងទៀត ហើយអញ្ញត្រប័ណ្ណទំនិញ ដែលបានផ្ដល់ឱ្យស្របតាមកិច្ចសន្យានេះ មិនចែងអំពីកំណត់សម្គាល់នោះ អ្នកដឹកជញ្ជូនមិនអាចប្រើខសន្យានោះបានទេ ដោយត្រូវអនុវត្តតាមអញ្ញត្រប័ណ្ណទំនិញនោះ។

មាត្រា១៧០ .-

ខសន្យានៅក្នុងកិច្ចសន្យាដឹកជញ្ជូនទំនិញ ឬនៅក្នុងអញ្ញត្រប័ណ្ណទំនិញ ឬឯកសារណាមួយ ដែលបញ្ជាក់ភស្តុតាងនៃកិច្ចសន្យាដឹកជញ្ជូនទំនិញ ត្រូវចាត់ទុកជាមោឃៈ ប្រសិនបើខសន្យានោះ ប្រាសចាកដោយផ្ទាល់ឬដោយប្រយោលពីបទប្បញ្ញត្តិដូចមានចែងនៅក្នុងច្បាប់នេះ។ ខសន្យាដែលចាត់ទុកជាមោឃៈ មិនប៉ះពាល់ដល់សុពលភាពនៃកិច្ចសន្យានោះឡើយ។

ទោះបីជាមានបញ្ញត្តិដូចមានចែងនៅក្នុងកថាខណ្ឌទី១ ក៏អ្នកដឹកជញ្ជូនអាចបង្កើនការទទួលខុសត្រូវនិងកាតព្វកិច្ច ដូចមានចែងនៅក្នុងច្បាប់នេះផងដែរ។

នៅពេលណាចេញអញ្ញត្រប័ណ្ណទំនិញឬឯកសារដែលបញ្ជាក់ភស្តុតាងអំពីកិច្ចសន្យាដឹកជញ្ជូនទំនិញ ឯកសារនោះ ត្រូវមានសេចក្ដីបញ្ជាក់ដែលបញ្ជាក់ថា ការដឹកជញ្ជូនត្រូវអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ហើយត្រូវចាត់ទុកជាមោឃៈនូវខសន្យាដែលប្រាសចាក ដើម្បីចៀសវាងផលប៉ះពាល់ដល់អ្នកផ្ញើទំនិញ និងអ្នកទទួលទំនិញ។

នៅពេលណាដើមបណ្ដឹងបានប្ដឹងអំពីការបាត់បង់ទំនិញ ដែលបណ្ដាលមកពីខសន្យាដែលចាត់ទុកជាមោឃៈ ឬដែលបណ្ដាលមកពីកំហុសដែលមាននៅក្នុងសេចក្ដីបញ្ជាក់ អ្នកដឹកជញ្ជូនត្រូវសងការបាត់បង់ ឬការខូចខាតទំនិញ ឬការយឺតយ៉ាវប្រគល់ទំនិញ។

មាត្រា១៧១ .-

បទប្បញ្ញត្តិនៃច្បាប់នេះ មិនប៉ះពាល់ដល់ការអនុវត្តខសន្យានៅក្នុងកិច្ចសន្យាដឹកជញ្ជូនទំនិញពាក់ព័ន្ធនឹងការរំលែកសំណងរួមលើការខាតបង់ ឬការកំណត់ប្រាក់លាភការសម្រាប់ការជួយសង្គ្រោះនាវាក្នុងគ្រោះថ្នាក់នាវាចរណ៍ឡើយ។

មាត្រា១៧២ .-

បទប្បញ្ញត្តិនៃច្បាប់នេះ មិនកែប្រែសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកដឹកជញ្ជូន អ្នកដឹកជញ្ជូនបន្ត និងបុគ្គលក្នុងនាមអ្នកដឹកជញ្ជូននិងអ្នកដឹកជញ្ជូនបន្ត ដូចមានចែងនៅក្នុងច្បាប់អន្តរជាតិឬច្បាប់ជាតិដែលពាក់ព័ន្ធនឹងព្រំដែនសំណងរបស់ម្ចាស់នាវា។

បញ្ញត្តិនៃមាត្រា១៦៩ និងមាត្រា១៧០នៃច្បាប់នេះ មិនត្រូវប៉ះពាល់ដល់ការអនុវត្តបទប្បញ្ញត្តិដូចមានចែងនៅក្នុងច្បាប់អន្តរជាតិផ្សេងទៀតជាធរមាន ហើយច្បាប់អន្តរជាតិផ្សេងទៀតនោះក៏មិនត្រូវប៉ះពាល់ដល់ការអនុវត្តកថាខណ្ឌទី៤ មាត្រា១៧០នៃច្បាប់នេះដែរ។

អ្នកដឹកជញ្ជូនមិនទទួលខុសត្រូវសងចំពោះការខូចខាតដែលបង្កឡើងដោយឧប្បត្តិហេតុនុយក្លេអ៊ែ ប្រសិនបើប្រតិបត្តិករនៃឋបនាការនុយក្លេអ៊ែលើនាវា បានទទួលខុសត្រូវសងដោយអនុលោមតាមច្បាប់អន្តរជាតិ ឬច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ផ្នែកទី២
ការដឹកជញ្ជូនអ្នកដំណើរនិងឥវ៉ាន់

មាត្រា១៧៣ .-

ការដឹកជញ្ជូនអ្នកដំណើរ រួមនិងការវត្ថុរបស់អ្នកដំណើរ តាមនាវាឆ្នេរសមុទ្រ នាវាផ្លូវទឹកក្នុងប្រទេស ឬនាវាសញ្ជាតិខ្មែរ ត្រូវធ្វើឡើងតាមកិច្ចសន្យាដឹកជញ្ជូនអ្នកដំណើរ។

អ្នកដឹកជញ្ជូនត្រូវទទួលខុសត្រូវចំពោះព្យសនកម្មលើការរងរបួសឬការបាត់បង់ជីវិតអ្នកដំណើរ ឬការខូចខាតឬការបាត់បង់ការវត្ថុរបស់អ្នកដំណើរតាមកិច្ចសន្យាដឹកជញ្ជូនដែលខ្លួនបានដឹកជញ្ជូន ទោះបីជាយកថ្លៃឈ្នួលឬមិនយកថ្លៃឈ្នួលក៏ដោយ។

មាត្រា១៧៤ .-

សំបុត្រអ្នកដំណើរ ត្រូវបញ្ចូលនូវនិទ្ទេសសំខាន់ៗដូចខាងក្រោម៖

- ឈ្មោះនាវា លេខសម្គាល់នាវា
- ឈ្មោះរបស់អ្នកដំណើរ អាសយដ្ឋានបច្ចុប្បន្នរបស់អ្នកដំណើរ
- ការវត្ថុរបស់អ្នកដំណើរ
- លេខកៅអីឬកន្លែងអង្គុយ
- កំពង់ផែចេញដំណើរ កំពង់ផែគោលដៅ កាលបរិច្ឆេទចេញដំណើរ និងកាលបរិច្ឆេទមកដល់។

សំបុត្រអ្នកដំណើរ ត្រូវចុះហត្ថលេខាដោយអ្នកដឹកជញ្ជូនឬបុគ្គលក្នុងនាមខ្លួន និងមានកាលបរិច្ឆេទច្បាស់លាស់។

មាត្រា១៧៥ .-

អ្នកដឹកជញ្ជូនត្រូវសងចំពោះព្យសនកម្ម ដែលបណ្តាលឱ្យមានការរងរបួសឬការបាត់បង់ជីវិតអ្នកដំណើរ និងការបាត់បង់ឬការខូចខាតការវត្ថុរបស់អ្នកដំណើរ ប្រសិនបើឧប្បត្តិហេតុនោះអាចកើតចេញពីកំហុសឬការធ្វេសប្រហែសរបស់អ្នកដឹកជញ្ជូនឬបុគ្គលក្នុងនាមខ្លួន ក្នុងកំលុងពេលដឹកជញ្ជូន។

អ្នកដំណើរត្រូវបញ្ជាក់ភស្តុតាងថា ឧប្បត្តិហេតុដែលបង្កឱ្យមានការបាត់បង់ឬការខូចខាត ដែលបានកើតឡើងនៅក្នុងកំលុងពេលដឹកជញ្ជូន រួមនិងទំហំនៃការបាត់បង់ឬការខូចខាតនោះ ត្រូវបញ្ជាក់ដោយអ្នកប្តឹង។

៥០/៧១

កំហុសឬការធ្វេសប្រហែសរបស់អ្នកដឹកជញ្ជូនឬបុគ្គលក្នុងនាមខ្លួន ត្រូវចាត់ទុកថាបានកើតឡើង ប្រសិនបើគ្មានភស្តុតាងផ្ទុយដែលបញ្ជាក់ថា ការរងរបួសឬការបាត់បង់ជីវិតអ្នកដំណើរ ឬការបាត់បង់ឬការខូចខាតការវត្ថុរបស់អ្នកដំណើរ បណ្តាលមកពីមូលហេតុដែលជាប់ពាក់ព័ន្ធនឹងការបាក់បែកការប៉ះទង្គិច ការកឿង ការកើល ការផ្ទុះ ឬឆេះនាវា។

មាត្រា១៧៦ .-

អ្នកដឹកជញ្ជូននៅតែទទួលខុសត្រូវសងចំពោះការដឹកជញ្ជូនដដែល ទោះបីជាការអនុវត្តដឹកជញ្ជូននោះ ត្រូវបានប្រគល់ទៅអ្នកដឹកជញ្ជូនបន្តក៏ដោយ។

ករណីការប្រគល់ការអនុវត្តដឹកជញ្ជូន ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ អ្នកដឹកជញ្ជូនត្រូវទទួលខុសត្រូវសងចំពោះអំពើឬកំហុសដែលបានប្រព្រឹត្តដោយអ្នកដឹកជញ្ជូនបន្ត។

មាត្រា១៧៧ .-

អ្នកដឹកជញ្ជូនមិនទទួលខុសត្រូវសងចំពោះការបាត់បង់ឬការខូចខាតរូបិយបណ្ណ មូលប្បទានបត្រដែលអាចចរាចរបាន មាស ប្រាក់ ពេជ្រ ត្បូង ឬវត្ថុសិល្បៈ ឬវត្ថុមានតម្លៃផ្សេងៗឡើយ លើកលែងតែមានការប្រកាសអំពីចំនួននិងតម្លៃ និងមានការប្រគល់ដែលយល់ព្រមទទួលដោយអ្នកដឹកជញ្ជូន ក្នុងគោលបំណងរក្សាទុកនៅលើនាវាក្នុងកំលុងពេលដឹកជញ្ជូន។

មាត្រា១៧៨ .-

ប្រសិនបើអ្នកដឹកជញ្ជូនមានភស្តុតាងបញ្ជាក់ថា ការរងរបួសឬការបាត់បង់ជីវិតអ្នកដំណើរ ឬការបាត់បង់ឬការខូចខាតការវត្ថុអ្នកដំណើរ បានបង្កឡើងដោយឬរួមចំណែកដោយកំហុសឬការធ្វេសប្រហែសរបស់អ្នកដំណើរ អ្នកដឹកជញ្ជូនអាចរួចផុតពីការទទួលខុសត្រូវសងទាំងស្រុងឬដោយផ្នែក។

មាត្រា១៧៩ .-

លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះដោយគូភាគី សំណងរបស់អ្នកដឹកជញ្ជូនចំពោះការរងរបួសឬការបាត់បង់ជីវិតអ្នកដំណើរ មិនត្រូវលើសពី៤៦ ៦៦៦SDR (សែសិបប្រាំមួយពាន់ប្រាំមួយរយហុកសិបប្រាំមួយអេសដេអ៊ែ) សម្រាប់អ្នកដំណើរម្នាក់ក្នុងមួយជើង។

មាត្រា១៨០ .-

លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះដោយគូភាគី សំណងរបស់អ្នកដឹកជញ្ជូនចំពោះការបាត់បង់ឬការខូចខាតការវត្ថុជាប់ខ្លួន មិនត្រូវលើសពី៨៣៣SDR (ប្រាំបីរយសាមសិបបីអេសដេអ៊ែ) សម្រាប់អ្នកដំណើរម្នាក់ក្នុងមួយជើង។

លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះដោយគូភាគី សំណងរបស់អ្នកដឹកជញ្ជូនចំពោះការបាត់បង់ឬការខូចខាតរថយន្ត រួមទាំងការវត្ថុនៅលើរថយន្តនោះ មិនត្រូវលើសពី៣ ៣៣៣SDR (បីពាន់បីរយសាមសិបបីអេសដេអ៊ែ) ក្នុងរថយន្តមួយគ្រឿង ក្នុងមួយជើង។

លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះដោយគូភាគី សំណងរបស់អ្នកដឹកជញ្ជូនចំពោះការបាត់បង់ឬការខូចខាតការវត្ថុផ្សេងទៀតរបស់អ្នកដំណើរក្រៅពីការវត្ថុដូចមានចែងនៅក្នុងកថាខណ្ឌទី១និងទី២ខាងលើនេះ មិនត្រូវលើសពី១ ២០០SDR (មួយពាន់ពីររយអេសដេអ៊ែ) ក្នុងអ្នកដំណើរម្នាក់ ក្នុងមួយជើង។

មាត្រា១៨១ .-

ប្រាក់សំណង ដូចមានចែងនៅក្នុងច្បាប់នេះ ត្រូវប្តូរជារូបិយបណ្ណដែលត្រូវអនុវត្តនៅតាមតុលាការមានសមត្ថកិច្ច ផ្អែកលើតម្លៃកំណត់ដោយអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ។

៥១/៧១

មាត្រា១៨២ .-

អ្នកដឹកជញ្ជូននិងអ្នកដំណើរ អាចយល់ព្រមជាលាយលក្ខណ៍អក្សរលើសំណងរបស់អ្នកដឹកជញ្ជូន ចំពោះការរងរបួសឬការបាត់បង់ជីវិត ឬការបាត់បង់ឬការខូចខាតភារវត្ថុរបស់អ្នកដំណើរ ខ្ពស់ឬទាបជាង ព្រំដែនសំណងដូចមានចែងនៅក្នុងមាត្រា១៧៩ និងមាត្រា១៨០នៃច្បាប់នេះ។

មាត្រា១៨៣ .-

បើមានបណ្តឹងចំពោះបុគ្គលក្នុងនាមអ្នកដឹកជញ្ជូន ឬអ្នកដឹកជញ្ជូនបន្ត ដើម្បីទាមទារសំណង ដូចមានចែងនៅក្នុងច្បាប់នេះ បុគ្គលនោះមានសិទ្ធិការពារខ្លួនក្នុងព្រំដែនសំណងរបស់អ្នកដឹកជញ្ជូនឬអ្នកដឹកជញ្ជូនបន្ត ប្រសិនបើខ្លួនមានភស្តុតាងបញ្ជាក់ថាបានធ្វើការងារក្នុងនាមអ្នកដឹកជញ្ជូនឬអ្នកដឹកជញ្ជូនបន្ត។

មាត្រា១៨៤ .-

ព្រំដែនសំណងដូចមានចែងនៅក្នុងមាត្រា១៧៩និងមាត្រា១៨០នៃច្បាប់នេះ មានប្រសិទ្ធភាពអនុវត្ត ព្រំដែនសំណងនេះ ត្រូវជាចំនួនបូកសរុបនៃបណ្តឹងទាមទារសំណងទាំងអស់ ដែលបានកើតឡើងចំពោះការរងរបួសឬការបាត់បង់ជីវិត ឬការបាត់បង់ឬការខូចខាតភារវត្ថុ សម្រាប់អ្នកដំណើរម្នាក់ នៅកន្លែងដែលព្រំដែនសំណងនោះត្រូវបានអនុវត្ត។

ករណីការដឹកជញ្ជូនត្រូវបានអនុវត្តដោយអ្នកដឹកជញ្ជូនបន្ត ចំនួនបូកសរុបសំណងពីអ្នកដឹកជញ្ជូន និងអ្នកដឹកជញ្ជូនបន្ត ព្រមទាំងពីបុគ្គលក្នុងនាមអ្នកដឹកជញ្ជូនបន្ត មិនត្រូវលើសពីចំនួនដែលត្រូវផ្តល់ឱ្យ ទោះបីជាឱ្យទៅអ្នកដឹកជញ្ជូនឬអ្នកដឹកជញ្ជូនបន្តឡើយ។

គ្រប់ករណីដែលបុគ្គលក្នុងនាមអ្នកដឹកជញ្ជូនបន្ត បានទទួលសិទ្ធិដូចមានចែងនៅក្នុងមាត្រា១៨៣ នៃច្បាប់នេះ ដើម្បីទទួលសិទ្ធិការពារខ្លួនក្នុងព្រំដែនសំណងដូចមានចែងនៅក្នុងមាត្រា១៧៩ និងមាត្រា១៨០ នៃច្បាប់នេះ ចំនួនបូកសរុបសំណងពីអ្នកដឹកជញ្ជូន អ្នកដឹកជញ្ជូនបន្ត និងបុគ្គលក្នុងនាមអ្នកដឹកជញ្ជូនបន្ត មិនត្រូវលើសពីព្រំដែនសំណងឡើយ។

មាត្រា១៨៥ .-

អ្នកដឹកជញ្ជូនមិនមានសិទ្ធិទទួលអត្ថប្រយោជន៍ណាមួយពីព្រំដែនសំណងដូចមានចែងនៅក្នុង មាត្រា១៧៩ មាត្រា១៨០ និងមាត្រា១៨២នៃច្បាប់នេះឡើយ ប្រសិនបើមានភស្តុតាងបញ្ជាក់ថា ការខូចខាតនោះបានបណ្តាលមកពីអំពើឬកំហុសរបស់អ្នកដឹកជញ្ជូន ក្នុងគោលបំណងបង្កឱ្យមានការខូចខាត ឬដោយធ្វេសប្រហែសដោយដឹងច្បាស់ថា លទ្ធផលនៃការខូចខាតនឹងកើតមាន។

បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ ត្រូវអនុវត្តដូចគ្នាផងដែរចំពោះនិយោជិតឬភ្នាក់ងាររបស់អ្នកដឹកជញ្ជូន ឬអ្នកដឹកជញ្ជូនបន្ត ដែលបានអនុវត្តដឹកជញ្ជូនក្នុងនាមអ្នកដឹកជញ្ជូនឬអ្នកដឹកជញ្ជូនបន្ត។

មាត្រា១៨៦ .-

អ្នកដំណើរត្រូវផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអ្នកដឹកជញ្ជូនឬបុគ្គលក្នុងនាមខ្លួន ដូចខាងក្រោម៖

ក- ករណីមើលឃើញការខូចខាតភារវត្ថុ៖
   សម្រាប់ភារវត្ថុជាប់ខ្លួន នៅមុនឬនៅពេលអ្នកដំណើរចុះពីនាវា
   សម្រាប់ភារវត្ថុផ្សេងទៀត នៅមុនឬនៅពេលប្រគល់ភារវត្ថុម្តងទៀត។

ខ- ករណីខូចខាតភារវត្ថុដែលមិនអាចមើលឃើញបាន ឬបាត់បង់ភារវត្ថុ រយៈពេល១៥(ដប់ប្រាំ) ថ្ងៃគិតពីថ្ងៃអ្នកដំណើរចុះពីនាវា ឬថ្ងៃប្រគល់ភារវត្ថុម្តងទៀត ឬពេលវេលាដែលភារវត្ថុគួរត្រូវបានប្រគល់ម្តងទៀត។

៥២/៧១

ការខកខានអនុវត្តតាមបញ្ញត្តិដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ចាត់ទុកថាអ្នកដំណើរបានទទួលភារវត្ថុដោយមិនមានការខូចខាតឬមិនមានការបាត់បង់។

ការជូនដំណឹងដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ មិនចាំបាច់ផ្ដល់ឡើយប្រសិនបើលក្ខណៈនៃភារវត្ថុដែលបានទទួលនៅពេលទទួលភារវត្ថុ ដោយមានការត្រួតពិនិត្យរួមគ្នា។

មាត្រា១៨៧ .-

បណ្ដឹងទាមទារសំណង ដែលបានកើតឡើងចំពោះការរងរបួសឬការបាត់បង់ជីវិតអ្នកដំណើរ ឬចំពោះការបាត់បង់ឬការខូចខាតភារវត្ថុអ្នកដំណើរ ត្រូវមានអាជ្ញាយុកាលរយៈពេល៣(បី)ឆ្នាំ។

រយៈពេលអាជ្ញាយុកាល ត្រូវគណនាដូចខាងក្រោម៖

ក- ករណីរងរបួស ត្រូវគិតចាប់ពីកាលបរិច្ឆេទដែលអ្នកដំណើរចុះចេញពីនាវា។

ខ- ករណីបាត់បង់ជីវិតដែលបានកើតឡើងក្នុងកំលុងពេលដឹកជញ្ជូន ត្រូវគិតចាប់ពីកាលបរិច្ឆេទនៃការបាត់បង់ជីវិត។

គ- ក្នុងករណីរងរបួសដែលបានកើតឡើង ក្នុងកំលុងពេលដឹកជញ្ជូន និងបណ្ដាលឱ្យបាត់បង់ជីវិតក្រោយពេលចុះចេញពីនាវា ត្រូវគិតចាប់ពីកាលបរិច្ឆេទនៃការបាត់បង់ជីវិត។

ឃ- ករណីបាត់បង់ឬខូចខាតភារវត្ថុ ត្រូវគិតចាប់ពីកាលបរិច្ឆេទដែលអ្នកដំណើរចុះចេញពីនាវា ឬកាលបរិច្ឆេទដែលអ្នកដំណើរគួរត្រូវបានចុះចេញពីនាវា ដោយអាចកំណត់យកកាលបរិច្ឆេទណាមួយដែលនៅចុងក្រោយបង្អស់។

អាជ្ញាយុកាលដែលបានកំណត់ក្នុងកថាខណ្ឌទី២ខាងលើ ត្រូវមានរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការកើតឡើងនូវឧប្បត្តិហេតុ ក្នុងករណីដែលកាលបរិច្ឆេទនៃការបាត់បង់ជីវិតមិនអាចកំណត់បាន។

មាត្រា១៨៨ .-

បណ្ដឹងទាមទារសំណងលើការរងរបួសឬការបាត់បង់ជីវិត ឬការបាត់បង់ឬការខូចខាតភារវត្ថុអ្នកដំណើរ ត្រូវធ្វើឡើងទៅតុលាការមានសមត្ថកិច្ច ស្របតាមការកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។

នៅក្នុងអង្គហេតុដែលមានដើមបណ្ដឹងច្រើន ដើមបណ្ដឹងនីមួយៗ ត្រូវប្ដឹងទាមទារសំណងលើការរងរបួសឬការបាត់បង់ជីវិត ឬការបាត់បង់ឬការខូចខាតភារវត្ថុអ្នកដំណើរនៅចំពោះមុខតុលាការដែលបានទទួលចាត់ការពាក្យបណ្ដឹងទាមទារសំណងពីភាគីណាមួយ។ ក្នុងករណីដែលមានតុលាការផ្សេងបានទទួលពាក្យបណ្ដឹងទាមទារនេះ តុលាការនេះត្រូវផ្ទេរសំណុំរឿងមកតុលាការដែលកំពុងចាត់ការលើពាក្យបណ្ដឹងទាមទារសំណងរបស់ភាគីណាមួយនោះ។

បណ្ដឹងឧបាស្រ័យ ត្រូវធ្វើឡើងនៅចំពោះមុខតុលាការដែលមានយុត្តាធិការលើបណ្ដឹងដំបូង ស្របតាមបញ្ញត្តិដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ។

ក្រោយការកើតឡើងនូវឧប្បត្តិហេតុដែលបង្កឱ្យមានព្យសនកម្ម គូភាគីអាចព្រមព្រៀងគ្នាជ្រើសរើសតុលាការ ឬមជ្ឈត្តការ ឬយន្តការដោះស្រាយវិវាទណាមួយផ្សេងទៀត ទាំងនៅក្នុងប្រទេសឬនៅបរទេសដើម្បីដោះស្រាយវិវាទរបស់ខ្លួន។ ការព្រមព្រៀងនេះ មិនរារាំងដល់សិទ្ធិរបស់តតិយជនក្នុងការប្ដឹងទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជានោះទេ។

មាត្រា១៨៩ .-

ប្រការនៃកិច្ចសន្យាដឹកជញ្ជូននិងការវត្ថុអ្នកដំណើរ ដែលបានធ្វើឡើងនៅមុនពេលកើតឡើងនៃឧប្បត្តិហេតុ ដែលបង្កឱ្យមានការរងរបួសឬការបាត់បង់ជីវិត ឬការបាត់បង់ឬការខូចខាតភារវត្ថុ ដោយឱ្យ

អ្នកដឹកជញ្ជូនរួចផុតពីការផ្តល់សំណងទៅអ្នកដំណើរ ឬដោយផ្តល់សំណងទាបជាងព្រំដែនសំណងដូចមានចែងនៅក្នុងច្បាប់នេះ ឬផ្ទេរបន្ទុកភស្តុតាងដែលបានដាក់ទៅលើអ្នកដឹកជញ្ជូន ឬរឹតត្បិតលើការសម្រេចចិត្តរបស់ភាគីដូចមានចែងនៅក្នុងមាត្រា១៨៨នៃច្បាប់នេះ ត្រូវចាត់ទុកជាមោឃៈ។

ការចាត់ទុកជាមោឃៈ ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ មិនប៉ះពាល់ដល់សុពលភាពនៃកិច្ចសន្យារវាងភាគីឡើយ។

មាត្រា១៩០ .-

បទប្បញ្ញត្តិនៃច្បាប់នេះ មិនកែប្រែសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកដឹកជញ្ជូនឬបុគ្គលក្នុងនាមខ្លួនអ្នកដឹកជញ្ជូនបន្តឬបុគ្គលក្នុងនាមខ្លួន ដែលបានកំណត់នៅក្នុងច្បាប់អន្តរជាតិ ជាពិសេសពាក់ព័ន្ធនឹងព្រំដែនសំណងរបស់ម្ចាស់នាវា។

មាត្រា១៩១ .-

គ្មានសំណងណាមួយត្រូវបានធ្វើឡើងចំពោះការខូចខាតដែលបង្កឡើងដោយឧប្បត្តិហេតុនុយក្លេអ៊ែនោះឡើយ ប្រសិនបើប្រតិបត្តិករនៃបរិក្ខារនុយក្លេអ៊ែរលើនាវា ទទួលខុសត្រូវសងចំពោះការខូចខាត តាមអនុសញ្ញាអន្តរជាតិឬច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី១០
ការគ្រប់គ្រងកំពង់ផែ
ផ្នែកទី១
ចំណាត់ថ្នាក់កំពង់ផែនិងអង្គគ្រប់គ្រងកំពង់ផែ

មាត្រា១៩២ .-

កំពង់ផែមាន៤ថ្នាក់ ដូចខាងក្រោម៖

- ថ្នាក់ទី១ ជាកំពង់ផែសម្រាប់បម្រើសេវាឱ្យនាវាដែលធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិ និងមានសក្តានុពលសេដ្ឋកិច្ចសង្គមខ្ពស់បំផុត
- ថ្នាក់ទី២ ជាកំពង់ផែសម្រាប់បម្រើសេវាឱ្យនាវាដែលធ្វើនាវាចរណ៍ជាមួយប្រទេសជិតខាងដែលមានកិច្ចព្រមព្រៀងដោយឡែក
- ថ្នាក់ទី៣ ជាកំពង់ផែសម្រាប់បម្រើសេវាឱ្យនាវាដែលធ្វើនាវាចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ថ្នាក់ពិសេស ជាកំពង់ផែក្រៅពីកំពង់ផែក្នុងថ្នាក់ទី១ ថ្នាក់ទី២ និងថ្នាក់ទី៣។

មាត្រា១៩៣ .-

កំពង់ផែនីមួយៗត្រូវបង្កើតឡើងដោយផ្អែកលើនិទ្ទេសដូចមានចែងនៅក្នុងមាត្រា១៩២នៃច្បាប់នេះ និងនិទ្ទេសសំខាន់ៗផ្សេងទៀត ដូចខាងក្រោម៖

- ឈ្មោះកំពង់ផែ
- ទីតាំងភូមិសាស្ត្រ ដែលមានលក្ខណៈអំណោយផលពីធម្មជាតិ មានសក្តានុពលក្នុងប្រព័ន្ធដឹកជញ្ជូន
- កម្មវត្ថុនិងមុខងារ ដែលស្របតាមគោលបំណងនៃការបង្កើតកំពង់ផែ
- សមត្ថភាពឬទំហំកំពង់ផែដែលអាចលើកដាក់ទំនិញ ឬអ្នកដំណើរឡើងចុះ
- គម្រោងប្លង់រួមនិងព្រំដែនរបស់កំពង់ផែ។

៥៤/៧១

ការបង្កើតកំពង់ផែថ្នាក់ទី១ ថ្នាក់ទី២ និងថ្នាក់ពិសេសដែលបម្រើសេវាឱ្យនាវាដែលធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិឬជាមួយប្រទេសជិតខាង ត្រូវកំណត់ដោយអនុក្រឹត្យ។

ការបង្កើតកំពង់ផែថ្នាក់ទី៣និងថ្នាក់ពិសេសដែលបម្រើសេវាឱ្យនាវាដែលធ្វើនាវាចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា១៩៤ .-

កំពង់ផែគ្រប់ថ្នាក់ត្រូវមានដែនកំពង់ផែ ដែលរួមមានដែនទឹកនិងដីគោក។

មាត្រា១៩៥ .-

កំពង់ផែគ្រប់ថ្នាក់ត្រូវមានអង្គគ្រប់គ្រងកំពង់ផែ។

ផ្នែកទី២
មេបញ្ជាការផែ

មាត្រា១៩៦ .-

កំពង់ផែថ្នាក់ទី១និងកំពង់ផែថ្នាក់ទី២ ត្រូវមានមេបញ្ជាការផែ។

មេបញ្ជាការផែត្រូវចាត់តាំងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន មានសិទ្ធិចេញសេចក្តីសម្រេចចាត់តាំងមេបញ្ជាការផែសម្រាប់កំពង់ផែផ្សេងទៀត។

មេបញ្ជាការផែត្រូវជាមន្ត្រីក្របខ័ណ្ឌរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

លក្ខណវិនិច្ឆ័យជាមេបញ្ជាការផែ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា១៩៧ .-

មេបញ្ជាការផែមានភារកិច្ចដូចខាងក្រោម៖

- រៀបចំចលនានាវាចូលចេញកំពង់ផែ
- បញ្ជាការផ្លាស់ប្តូរទីតាំងរបស់នាវានៅក្នុងដែនទឹកកំពង់ផែឬការផ្លាស់ប្តូរទីតាំងចេញទៅក្រៅដែនទឹកកំពង់ផែ
- ហាមឃាត់ រឹតត្បិត ផ្អាក ឬរារាំងសកម្មភាពទាំងឡាយនៅក្នុងកំពង់ផែ ដើម្បីធានាសុវត្ថិភាពប្រតិបត្តិការបើកបរនិយកណ្តាផែនិងនាវាទាំងឡាយ
- មានសិទ្ធិបដិសេធក្នុងការផ្តល់លិខិតអនុញ្ញាតឱ្យនាវាចេញពីកំពង់ផែ
- ធ្វើការណែនាំនិងចាត់វិធានការអំពីករណីនាវាដឹកជញ្ជូនទំនិញគ្រោះថ្នាក់។

បទបញ្ជាមេបញ្ជាការផែ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ផ្នែកទី៣
ការអនុញ្ញាតឱ្យនាវាចូលចេញកំពង់ផែ

មាត្រា១៩៨ .-

មុននឹងចូលកំពង់ផែ នាវាដែលធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិ ត្រូវមានលិខិតអនុញ្ញាតឱ្យនាវាចូលកំពង់ផែ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ក្នុងករណីប្រធានសក្តិ នាវាដែលធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិ ក្នុងដំណើរឆ្លងកាត់ដែនទឹកនៃព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិចូលជ្រកនៅកំពង់ផែណាមួយឬកន្លែងណាមួយជាបណ្តោះអាសន្ន ដោយគ្រាន់តែជូនដំណឹងទៅអាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត និងមិនតម្រូវឱ្យមានលិខិតអនុញ្ញាតឱ្យនាវាចូលកំពង់ផែឡើយ។

នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតឱ្យនាវាចូលកំពង់ផែ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា១៩៩ .-

នៅពេលចេញពីកំពង់ផែ នាវាដែលធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិ ត្រូវមានលិខិតអនុញ្ញាតឱ្យនាវាចេញពីកំពង់ផែ។

នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតឱ្យនាវាចេញពីកំពង់ផែ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា២០០ .-

នាវាមិនត្រូវបានផ្តល់លិខិតអនុញ្ញាតឱ្យចេញពីកំពង់ផែ ក្នុងករណីនាវាកំពុងស្ថិតនៅក្នុងដំណើរការត្រួតពិនិត្យរបស់មន្ត្រីត្រួតពិនិត្យនាវាបរទេសឬនាវាកំពុងស្ថិតនៅក្នុងការបំពេញកាតព្វកិច្ចជាមួយភាគីដែលពាក់ព័ន្ធ រួមមានប្រតិបត្តិករកំពង់ផែ អ្នកផ្ញើទំនិញ អ្នកទទួលទំនិញជាអាទិ៍។

មាត្រា២០១ .-

ការចូលចេញកំពង់ផែ ត្រូវបានផ្តល់អាទិភាពចំពោះនាវាដែលបម្រើឱ្យការសង្គ្រោះនៅពេលមានគ្រោះអាសន្ន។

មាត្រា២០២ .-

កំពង់ផែនីមួយៗត្រូវទទួលឱ្យនាវាចូលបានស្របតាមថ្នាក់របស់ខ្លួន ដូចមានចែងនៅក្នុងមាត្រា១៩២នៃច្បាប់នេះ។

ក្នុងករណីចាំបាច់ ក្រសួងសាធារណការនិងដឹកជញ្ជូនមានសិទ្ធិអនុញ្ញាតឱ្យនាវាចូលចេញកំពង់ផែក្នុងថ្នាក់ផ្សេងទៀត។

មាត្រា២០៣ .-

នាវាបរទេសនិងនាវាសញ្ជាតិខ្មែរ មិនត្រូវធ្វើការដឹកជញ្ជូនទំនិញឬអ្នកដំណើរ រវាងកំពង់ផែដែលស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាបានឡើយ លើកលែងតែមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា២០៤ .-

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវជំរុញរៀបចំភ្នាក់ងារនាវា ដើម្បីផ្តល់សេវាកម្មដល់នាវាចូលចេញកំពង់ផែក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

នីតិបុគ្គលឬរូបវន្តបុគ្គលដែលធ្វើជាភ្នាក់ងារនាវា ត្រូវមានលិខិតអនុញ្ញាតភ្នាក់ងារនាវា។

នីតិវិធីផ្តល់លិខិតអនុញ្ញាតភ្នាក់ងារនាវា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា២០៥ .-

នាវាបរទេសដែលចូលចេញកំពង់ផែនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវប្រើភ្នាក់ងារនាវាដូចមានចែងនៅក្នុងមាត្រា២០៤នៃច្បាប់នេះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS

៥៦/៧១

បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះត្រូវបានលើកលែង ក្នុងករណីនាវាបរទេសស្ថិតនៅក្រោមការគ្រប់គ្រងនិងធ្វើប្រតិបត្តិការដោយក្រុមហ៊ុននាវាដែលមានទីស្នាក់ការក្រុមហ៊ុន សាខា ឬបុត្រសម្ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ករណីនេះ ក្រុមហ៊ុននាវាមិនមានសិទ្ធិសម្របសម្រួលផ្ដល់សេវាកម្មសម្រាប់នាវារបស់ក្រុមហ៊ុននាវាផ្សេងទៀតឡើយ។

ផ្នែកទី៤
ការអភិវឌ្ឍ ការសាងសង់ និងប្រតិបត្តិការកំពង់ផែ

មាត្រា២០៦ .-

ក្រសួងសាធារណការនិងដឹកជញ្ជូន មានសិទ្ធិសម្រេចលើផែនការអភិវឌ្ឍន៍កំពង់ផែឬដំណាក់កាលនៃផែនការអភិវឌ្ឍន៍កំពង់ផែរបស់កំពង់ផែនីមួយៗស្របតាមលក្ខណវិនិច្ឆ័យដូចមានចែងនៅក្នុងផែនការកម្មកំពង់ផែ។

ផែនការកម្មកំពង់ផែ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា២០៧ .-

ការសាងសង់និង/ឬជួសជុលបវបនីយកណ្ឌផែ ត្រូវមានលិខិតអនុញ្ញាតសាងសង់និង/ឬជួសជុលបវបនីយកណ្ឌផែ។

នីតិវិធីនៃការផ្ដល់លិខិតអនុញ្ញាតសាងសង់និង/ឬជួសជុលបវបនីយកណ្ឌផែ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា២០៨ .-

ការសាងសង់និងការជួសជុលបវបនីយកណ្ឌផែ ត្រូវធ្វើឡើងស្របតាមបទដ្ឋានបច្ចេកទេសសាងសង់និងជួសជុលបវបនីយកណ្ឌផែ។

បទដ្ឋានបច្ចេកទេសសាងសង់និងជួសជុលបវបនីយកណ្ឌផែ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា២០៩ .-

ការធ្វើប្រតិបត្តិការបវបនីយកណ្ឌផែ ត្រូវមានលិខិតអនុញ្ញាតធ្វើប្រតិបត្តិការបវបនីយកណ្ឌផែ។

បវបនីយកណ្ឌផែដែលបានសាងសង់រួចឬផ្នែកណាមួយដែលបានសាងសង់រួច ត្រូវធានាបាននូវសុវត្ថិភាព សន្តិសុខនិងបរិស្ថាន មុនដាក់ឱ្យធ្វើប្រតិបត្តិការ។

លិខិតអនុញ្ញាតធ្វើប្រតិបត្តិការបវបនីយកណ្ឌផែ មានសុពលភាព២(ពីរ)ឆ្នាំ។

នីតិវិធីនៃការផ្ដល់លិខិតអនុញ្ញាតធ្វើប្រតិបត្តិការបវបនីយកណ្ឌផែ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា២១០ .-

ប្រតិបត្តិករកំពង់ផែត្រូវមានសមត្ថភាពវិជ្ជាជីវៈដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា២១១ .-

អ្នកគ្រប់គ្រងកំពង់ផែ ត្រូវធ្វើរបាយការណ៍អំពីប្រតិបត្តិការបវបនីយកណ្ឌផែមកក្រសួងសាធារណការនិងដឹកជញ្ជូន។

ទម្រង់របាយការណ៍អំពីប្រតិបត្តិការបេបនីយកណ្ឌផែ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ផ្នែកទី៥
សន្តិសុខនិងបរិស្ថាន

មាត្រា២១២ .-

កំពង់ផែត្រូវមានបេបនីយកណ្ឌទទួលសំណល់ពីនាវា។

បទដ្ឋានបច្ចេកទេសបេបនីយកណ្ឌទទួលសំណល់ពីនាវា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា២១៣ .-

កំពង់ផែត្រូវមានផែនការបង្ការគ្រោះអាសន្នសម្រាប់ឆ្លើយតបនឹងការកំពប់ប្រេងឬសារធាតុគ្រោះថ្នាក់នៅកំពង់ផែ។

មាត្រា២១៤ .-

កំពង់ផែបម្រើសេវាឱ្យនាវាដែលធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិ ត្រូវមានរបាយការណ៍វាយតម្លៃសន្តិសុខបេបនីយកណ្ឌផែ ផែនការសន្តិសុខបេបនីយកណ្ឌផែ លិខិតបញ្ជាក់សន្តិសុខបេបនីយកណ្ឌផែ នាយសន្តិសុខបេបនីយកណ្ឌផែ និងបុគ្គលិកផ្នែកសន្តិសុខបេបនីយកណ្ឌផែ។

សន្តិសុខបេបនីយកណ្ឌផែ ត្រូវកំណត់ដោយអនុក្រឹត្យ។

ផ្នែកទី៦
បទបញ្ជាស្តីពីនាវាចរណ៍

មាត្រា២១៥ .-

កំពង់ផែត្រូវមានបទបញ្ជាស្តីពីនាវាចរណ៍។

បទបញ្ជាស្តីពីនាវាចរណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ផ្នែកទី៧
ថ្លៃឈ្នួលកំពង់ផែ

មាត្រា២១៦ .-

កំពង់ផែត្រូវមានតារាងថ្លៃឈ្នួលដែលកំណត់ដោយអង្គគ្រប់គ្រងកំពង់ផែ។

អង្គគ្រប់គ្រងកំពង់ផែត្រូវអនុវត្តការប្រមូលថ្លៃឈ្នួលកំពង់ផែ ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន មានសិទ្ធិកំណត់ព្រំដែនថ្លៃឈ្នួលកំពង់ផែ ដើម្បីធានាបាននូវភាពប្រកួតប្រជែងប្រកបដោយសមធម៌។

មាត្រា២១៧ .-

ការបង្ខិតបង្ខំឱ្យទទួលយកសេវាកម្មកំពង់ផែនៅកំពង់ផែណាមួយ ទោះតាមរូបភាពណាក៏ដោយត្រូវហាមឃាត់។

៥៨/ ៧១

ផ្នែកទី៨
ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ

មាត្រា២១៨ ._

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវរៀបចំ ដឹកនាំ និងគ្រប់គ្រងប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ។

ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ ត្រូវកំណត់ដោយអនុក្រឹត្យ។

ជំពូកទី១១
ហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក

មាត្រា២១៩ ._

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវរៀបចំ អភិវឌ្ឍ និងការពារហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក ដែលរួមមានផ្លូវនាវាចរណ៍ សំណង់សិល្បការ្យផ្លូវទឹក សញ្ញាជំនួយនាវាចរណ៍ និងប្រព័ន្ធដើម្បីទ្រទ្រង់ដល់ការធ្វើនាវាចរណ៍ ការដឹកជញ្ជូន និងកំពង់ផែ។

ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា២២០ ._

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវសិក្សានិងរៀបចំផែនទីផ្លូវទឹក ផែនទីនាវាចរណ៍ និងផ្សព្វផ្សាយសម្រាប់នាវាចរណ៍។

ផែនទីផ្លូវទឹកត្រូវរៀបចំឡើងសម្រាប់គោលបំណងអភិវឌ្ឍបណ្តាញផ្លូវទឹក ដោយបង្ហាញភូមិសាស្ត្ររួមនៃតំបន់ផ្លូវទឹក។

ផែនទីនាវាចរណ៍ត្រូវរៀបចំឡើងសម្រាប់គោលបំណងនាវាចរណ៍ ដោយបង្ហាញភូមិសាស្ត្រផ្លូវទឹក និងព័ត៌មានប្រកបដោយសុក្រឹតភាពសម្រាប់បម្រើការធ្វើនាវាចរណ៍ ដើម្បីធានាភាពជឿជាក់ ប្រសិទ្ធភាពបើកបរ និងចៀសវាងគ្រោះថ្នាក់នាវាចរណ៍។

មាត្រា២២១ ._

សំណង់សិល្បការ្យនិងអង្គបណ្តែតទឹក ដែលប៉ះពាល់ឬបង្កការប៉ះពាល់ដល់សុវត្ថិភាពរបស់នាវា ក្នុងការធ្វើនាវាចរណ៍ជាប្រក្រតីនៅតាមផ្លូវនាវាចរណ៍ ត្រូវហាមឃាត់។

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវទប់ស្កាត់រាល់សកម្មភាពដែលរាំងស្ទះដល់នាវាចរណ៍ ឬសកម្មភាពដែលធ្វើឱ្យនាវាចរណ៍ជួបការលំបាក ព្រមទាំងត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីចៀសវាងគ្រោះថ្នាក់។ ក្នុងករណីចាំបាច់ ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

មាត្រា២២២ ._

ក្រសួងសាធារណការនិងដឹកជញ្ជូន មានសិទ្ធិផ្អាកជាបណ្តោះអាសន្ននូវការធ្វើនាវាចរណ៍នៅតាមផ្លូវទឹកណាមួយ សម្រាប់គោលបំណងសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។

ជំពូកទី១២
កណ្ណធារកិច្ច

មាត្រា២២៣ ._

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវរៀបចំកណ្ណធារកិច្ចសម្រាប់នាវា ដែលធ្វើនាវាចរណ៍ឆ្លងកាត់ដែន[illegible]ជាតិ ឬចូលចេញកំពង់ផែនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា២២៤.-

នាវាដែលធ្វើនាវាចរណ៍នៅតាមដែនកណ្ដាជារកិច្ច ឬចូលចេញកំពង់ផែនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវប្រើសេវាកណ្ដាជារកិច្ច ដែលរួមមានកណ្ដាជារកិច្ចជាកាតព្វកិច្ច និងកណ្ដាជារកិច្ចមិនមែនកាតព្វកិច្ច។

មាត្រា២២៥.-

ក្នុងកិច្ចប្រតិបត្តិការកណ្ដាជារកិច្ច កណ្ដាជារត្រូវអនុវត្តដូចខាងក្រោម៖

- ផ្ដល់ព័ត៌មាននិងផ្ដល់យោបល់ដល់នាយនាវា អំពីស្ថានភាពដែនកណ្ដាជារកិច្ច ទីតាំងនិងវិធីដែលនាវាត្រូវចូលចត និងពិនិត្យមើលស្ថានភាពធ្វើដំណើររបស់នាវា ដែលអាចប្រព្រឹត្តទៅបានប្រកបដោយសុវត្ថិភាព
- រាយការណ៍ជាបន្ទាន់ទៅមេបញ្ជាការផែឬអាជ្ញាធរមានសមត្ថកិច្ច ករណីពិនិត្យឃើញភាពមិនប្រក្រតីពាក់ព័ន្ធនឹងសុវត្ថិភាព សន្តិសុខ និងបរិស្ថាន នាវិកនិងមនុស្សនៅលើនាវា ទំនិញ ឬការប្រព្រឹត្តណាមួយ ដែលអាចប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា។

ក្នុងកិច្ចប្រតិបត្តិការកណ្ដាជារកិច្ច កណ្ដាជារមានសិទ្ធិប្រើជំនួយការកណ្ដាជារមួយរូប។ កណ្ដាជាហាត់ការក៏អាចប្រើបានក្រោមការទទួលខុសត្រូវរបស់កណ្ដាជារនោះ។

ក្នុងកិច្ចប្រតិបត្តិការកណ្ដាជារកិច្ច កណ្ដាជារត្រូវស្លៀកពាក់ឯកសណ្ឋានកណ្ដាជារ។

គ្រប់ករណីនៃការធ្វើកណ្ដាជារកិច្ច នាយនាវាត្រូវទទួលខុសត្រូវទាំងស្រុងលើនាវារបស់ខ្លួន។

មាត្រា២២៦.-

ក្នុងកិច្ចប្រតិបត្តិការកណ្ដាជារកិច្ច នាយនាវាត្រូវផ្ដល់ព័ត៌មានអំពីលក្ខណៈចលនាចរណ៍ និងចំណុចសំខាន់ៗនៃនាវារបស់ខ្លួនពាក់ព័ន្ធនឹងកណ្ដាជារកិច្ចទៅកណ្ដាជារ។

មាត្រា២២៧.-

កណ្ដាជារមានសិទ្ធិបដិសេធបន្តកណ្ដាជារកិច្ច ប្រសិនបើយល់ឃើញថា ក្នុងការចាប់ផ្ដើមឬការបន្តកណ្ដាជារកិច្ច នាវាបានស្ថិតនៅក្នុងស្ថានភាពដែលបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពនាវាចរណ៍ មនុស្សនៅលើនាវា ចរាចរនាវាផ្សេងទៀត ឬបរិស្ថាន។ ក្នុងករណីនេះ កណ្ដាជារត្រូវរាយការណ៍ជាបន្ទាន់ទៅមេបញ្ជាការផែ។

មាត្រា២២៨.-

កណ្ដាជារត្រូវមានវិញ្ញាបនបត្រកណ្ដាជារ ដែលមានសុពលភាពមិនលើស៥(ប្រាំ)ឆ្នាំ។

វិញ្ញាបនបត្រកណ្ដាជារ ត្រូវផ្ដល់ឱ្យបេក្ខជនដែលមានគុណវុឌ្ឍិដូចខាងក្រោម៖

- មានការបណ្ដុះបណ្ដាលមុខជំនាញកណ្ដាជារ ឬមានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកជានាយនាវា ឬវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកជានាយបើកបរនាវា
- មានវិញ្ញាបនបត្របញ្ជាក់សុខភាព ដែលបញ្ជាក់ថាអាចបម្រើការងារនៅលើជាន់នាវាជំនួញបាន
- ទទួលបានការបណ្ដុះបណ្ដាលអំពីដែនកណ្ដាជារកិច្ចនិងបម្រើការងារជាជំនួយការកណ្ដាជារនៅក្នុងដែនកណ្ដាជារកិច្ច ដែលខ្លួនត្រូវបំពេញ
- មានចំណេះដឹងភាសាអង់គ្លេស
- ប្រឡងឬធ្វើតេស្តជាប់ជាស្ថាពរ ដែលរៀបចំដោយអគ្គនាយកដ្ឋានទទួលបន្ទុកកិច្ចការដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ។

វិញ្ញាបនបត្រកណ្ដាជារ ដែលបានផ្ដល់ឱ្យបេក្ខជនដើម្បីបំពេញមុខងារជាកណ្ដាជារដូចមានចែងនៅក្នុងកថាខណ្ឌទី២ ខាងលើនេះ ត្រូវដកហូតឬចាត់ទុកជាមោឃៈ ក្នុងករណីដូចខាងក្រោម៖

- កណ្ណធារបានបាត់បង់សមត្ថភាពការងារ
- កណ្ណធារខកខានបម្រើការងារជាកណ្ណធារ រយៈពេល៣០(សាមសិប)ខែ បន្ទាប់ពីបានទទួលវិញ្ញាបនបត្រកណ្ណធារ
- កណ្ណធារបានបំពេញកណ្ណធារកិច្ចនិងផ្តល់ការណែនាំមិនត្រឹមត្រូវ ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនាវាចរណ៍
- កណ្ណធារបានប្រព្រឹត្តអំពើរើសអើងឬទាមទារអត្ថប្រយោជន៍ខុសច្បាប់ណាមួយ ក្នុងពេលបំពេញភារកិច្ច។

មាត្រា២២៩ .-

កណ្ណធារកិច្ចជាកាតព្វកិច្ច ត្រូវបានលើកលែង ប្រសិនបើនាយនាវាទទួលបានវិញ្ញាបនបត្រលើកលែងកណ្ណធារ ក្រោយបានបំពេញលក្ខខណ្ឌណាមួយដូចខាងក្រោម៖

១- នាយនាវាបានធ្វើប្រតិបត្តិការឆ្លងកាត់ដែនកណ្ណធារកិច្ចច្រើនដងដោយសុវត្ថិភាព មិនប៉ះពាល់ដល់ចរាចរណ៍របស់នាវាផ្សេងទៀត មិនរំលោភដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា។

២- នាយនាវាបានបំពេញលក្ខខណ្ឌដូចមានចែងនៅក្នុងកថាខណ្ឌទី២ មាត្រា២២៨នៃច្បាប់នេះ។

វិញ្ញាបនបត្រលើកលែងកណ្ណធារ មានសុពលភាពមិនលើស៥(ប្រាំ)ឆ្នាំ។

វិញ្ញាបនបត្រលើកលែងកណ្ណធារ ត្រូវបានដកហូតឬចាត់ទុកជាមោឃៈ ក្នុងករណីដែលនាយនាវាបានបង្កផលប៉ះពាល់ដល់ចរាចរណ៍នាវាផ្សេងទៀត ឬរំលោភផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា។

កណ្ណធារកិច្ចជាកាតព្វកិច្ច ក៏ត្រូវបានលើកលែងផងដែរក្នុងករណីប្រធានសក្តិ។

មាត្រា២៣០ .-

កណ្ណធារកិច្ចត្រូវអនុវត្តដោយកណ្ណធារ ដែលជាមន្ត្រីក្របខ័ណ្ឌក្រសួងសាធារណការនិងដឹកជញ្ជូន។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន មានសិទ្ធិប្រគល់ឱ្យផ្នែកឯកជន ដើម្បីបំពេញកណ្ណធារកិច្ចនៅតាមដែនកណ្ណធារកិច្ចណាមួយ។

មាត្រា២៣១ .-

លក្ខខណ្ឌនិងនីតិវិធីកណ្ណធារកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ឯកសណ្ឋានកណ្ណធារ ត្រូវកំណត់ដោយអនុក្រឹត្យ។

ជំពូកទី១៣
យានដ្ឋាននាវា

មាត្រា២៣២ .-

ការបង្កើតយានដ្ឋាននាវា ត្រូវមានវិញ្ញាបនបត្រយានដ្ឋាននាវា ដែលមានសុពលភាពអចិន្ត្រៃយ៍។

យានដ្ឋាននាវាត្រូវមានលិខិតអនុញ្ញាតអាជីវកម្មយានដ្ឋាននាវា សម្រាប់សាងសង់និងជួសជុលនាវា។

នីតិវិធីនៃការផ្តល់វិញ្ញាបនបត្រយានដ្ឋាននាវានិងលិខិតអនុញ្ញាតអាជីវកម្មយានដ្ឋាននាវា សម្រាប់សាងសង់និងជួសជុលនាវា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា២៣៣ .-

ការសាងសង់និង/ឬការជួសជុលនាវា ត្រូវមានលិខិតអនុញ្ញាតសាងសង់និង/ឬជួសជុលនាវា។

នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតសាងសង់និង/ឬជួសជុលនាវា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា២៣៤ .-

ការសាងសង់និងជួសជុលនាវា ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសនៃការសាងសង់និងជួសជុលនាវា។

បទដ្ឋានបច្ចេកទេសនៃការសាងសង់និងជួសជុលនាវា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ជំពូកទី១៤
អធិការកិច្ចនិងការត្រួតពិនិត្យ
ផ្នែកទី១
ការធ្វើអធិការកិច្ចនាវាឆ្នេរសមុទ្រ នាវាផ្លូវទឹកក្នុងប្រទេស យានដ្ឋាននាវា ឋបនីយកណ្ដាផែ សំណាង់សិល្បការ្យ អង្គបណ្ដែតទឹក និងសកម្មភាពពាក់ព័ន្ធផ្សេងទៀត

មាត្រា២៣៥ .-

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវចាត់តាំងមន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ ដើម្បីត្រួតពិនិត្យនាវាឆ្នេរសមុទ្រ នាវាផ្លូវទឹកក្នុងប្រទេស យានដ្ឋាននាវា ឋបនីយកណ្ដាផែ សំណង់សិល្បការ្យ អង្គបណ្ដែតទឹក និងសកម្មភាពផ្សេងទៀត ដែលប៉ះពាល់ដល់សុវត្ថិភាពនាវាចរណ៍ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែត្រូវទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ដើម្បីពិនិត្យបទល្មើសដូចមានចែងនៅក្នុងច្បាប់នេះ ដោយអនុលោមតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ក្នុងពេលប្រតិបត្តិការពិនិត្យបទល្មើស មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវអនុវត្តដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ចំពោះមន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា២៣៦ .-

មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ មានសិទ្ធិនិងការកិច្ចដូចខាងក្រោម៖

- ចូលទៅក្នុងទីតាំងណាមួយឬឡើងលើនាវានៅតាមកំពង់ផែ ដើម្បីតាមដាន ពិនិត្យ និងប្រតិបត្តិការងារតាមសមត្ថកិច្ច ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ
- ឃាត់ជាបណ្ដោះអាសន្នចំពោះនាវាដែលមានចំណុចខ្វះខាត អាចបង្កភាពគ្រោះថ្នាក់ដល់សុវត្ថិភាពនាវាចរណ៍
- អញ្ជើញបុគ្គលពាក់ព័ន្ធនឹងនាវា យានដ្ឋាននាវា ឋបនីយកណ្ដាផែ សំណង់សិល្បការ្យ អង្គបណ្ដែតទឹក និងសកម្មភាពផ្សេងទៀត មកផ្ដល់ព័ត៌មាន ឯកសារ ឬវត្ថុផ្សេងៗ ដើម្បីធ្វើការស្រាវជ្រាវអនុវត្តការពិន័យអន្តរការណ៍ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ
- សហការជាមួយមន្ត្រីមានសមត្ថកិច្ចជំនាញរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ច ដើម្បីបង្ក្រាបបទល្មើសនាវាចរណ៍នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា
- ចាត់វិធានការផ្សេងទៀតនៅក្នុងក្របខ័ណ្ឌនៃការអនុវត្តបទប្បញ្ញត្តិនៃច្បាប់នេះ។

៦២/៧១

បែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចនាវានិងកំពង់ផែ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា២៣៧ .-

មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ អាចត្រួតពិនិត្យនាវាដោយគ្មានជូនដំណឹងជាមុន។

មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ អាចចូលទៅកាន់យានដ្ឋាននាវា ឋបនីយកណ្ដផែ សំណង់សិល្បការ្យ និងអង្គបណ្ដែតទឹក បន្ទាប់បានជូនដំណឹងជាលាយលក្ខណ៍អក្សរតាមកាលបរិច្ឆេទកំណត់ នៅក្នុងម៉ោងធ្វើការ ដើម្បីបំពេញភារកិច្ចរបស់ខ្លួន។

ផ្នែកទី២

ការត្រួតពិនិត្យនាវាបរទេសនៅកំពង់ផែ

មាត្រា២៣៨ .-

នាវាបរទេសដែលចូលកំពង់ផែនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់មន្ត្រីត្រួតពិនិត្យនាវាបរទេស ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា២៣៩ .-

ការត្រួតពិនិត្យនាវាបរទេស ត្រូវធ្វើឡើងក្នុងគោលបំណងត្រួតពិនិត្យផ្នែកបច្ចេកទេសនិងអនុលោមភាព ដើម្បីធានាឱ្យនាវាបរទេសដែលចូលកំពង់ផែនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោរពតាមអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ។

ការត្រួតពិនិត្យនាវាបរទេស ត្រូវធ្វើឡើងតាមការផ្ដួចផ្ដើមរបស់មន្ត្រីត្រួតពិនិត្យនាវាបរទេស ឬការស្នើសុំពីមន្ត្រីត្រួតពិនិត្យនាវាបរទេសនៅកំពង់ផែចេញដំណើរចុងក្រោយ ឬការស្នើសុំពីនាវិកដែលស្ថិតនៅលើនាវា ឬតាមការស្នើសុំរបស់កំពង់ផែ។

មាត្រា២៤០ .-

ការត្រួតពិនិត្យនាវាបរទេស រួមមាន៖

១- ការត្រួតពិនិត្យបឋម : ការពិនិត្យឯកសារនិងស្ថានភាពទូទៅផ្នែកខាងក្រៅរបស់នាវា។

២- ការត្រួតពិនិត្យលម្អិត : ធ្វើឡើងបន្ទាប់ពីការត្រួតពិនិត្យបឋម ប្រសិនបើមានមូលបទច្បាស់លាស់បញ្ជាក់ថា នាវាមានចំណុចខ្វះខាតទាំងផ្នែកឯកសារនិងសុវត្ថិភាព។

ក្នុងការត្រួតពិនិត្យលម្អិត ត្រូវអនុវត្តដូចខាងក្រោម៖

- មន្ត្រីត្រួតពិនិត្យនាវាបរទេស ត្រូវអនុញ្ញាតឱ្យនាវាចេញពីកំពង់ផែជាធម្មតា ក្នុងករណីពិនិត្យឃើញថា នាវានោះគ្មានចំណុចខ្វះខាត
- មន្ត្រីត្រួតពិនិត្យនាវាបរទេស ត្រូវឃាត់នាវាជាបណ្ដោះអាសន្ន ដើម្បីធ្វើការកែតម្រូវចំណុចខ្វះខាតឡើងវិញ ក្នុងករណីពិនិត្យឃើញថា នាវានោះមានចំណុចខ្វះខាតដែលត្រូវឃាត់
- មន្ត្រីត្រួតពិនិត្យនាវាបរទេស ត្រូវផ្អាកការត្រួតពិនិត្យលម្អិត និងបន្តធ្វើការត្រួតពិនិត្យតាមផ្នែកនីមួយៗ ក្នុងករណីពិនិត្យឃើញថា នាវានោះស្ថិតនៅក្រោមបទដ្ឋានបច្ចេកទេស។

មាត្រា២៤១ .-

ក្រោយពេលត្រួតពិនិត្យ មន្ត្រីត្រួតពិនិត្យនាវាបរទេស ត្រូវធ្វើរបាយការណ៍ត្រួតពិនិត្យនាវានៅចំពោះ

របាយការណ៍ត្រូវបញ្ជាក់អំពីចំណុចខ្វះខាត បុគ្គលដែលត្រូវជូនដំណឹង និងចំណុចខ្វះខាត កាលបរិច្ឆេទ និងទីកន្លែង ដែលនាវាត្រូវកែតម្រូវ។

បុគ្គលដែលត្រូវជូនដំណឹងដូចមានចែងនៅក្នុងកថាខណ្ឌទី២ខាងលើនេះ រួមមានមន្ត្រីត្រួតពិនិត្យនាវាបរទេសនៅកំពង់ផែបន្ទាប់ ប្រទេសម្ចាស់សញ្ញាតិនាវានិងនាវិក តំណាងស្ថានទូតឬស្ថានកុងស៊ុលនៃប្រទេសសញ្ញាតិនាវានិងនាវិក និងអង្គការចំណាត់ថ្នាក់នាវា។

មាត្រា២៤២ .-

មន្ត្រីត្រួតពិនិត្យនាវាបរទេស ត្រូវមានគុណវុឌ្ឍិដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា២៤៣ .-

ការត្រួតពិនិត្យនាវាបរទេសនៅតាមកំពង់ផែ ត្រូវកំណត់ដោយអនុក្រឹត្យ។

ផ្នែកទី៣

ការត្រួតពិនិត្យនាវាតាមផ្លូវទឹកនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា

មាត្រា២៤៤ .-

នាវាដែលធ្វើនាវាចរណ៍នៅតាមផ្លូវទឹកនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់មន្ត្រីមានសមត្ថកិច្ចនៃក្រសួង ស្ថាប័ន ដែលមានភារកិច្ចត្រួតពិនិត្យនាវានៅតាមផ្លូវទឹកនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាអនុលោមតាមច្បាប់នេះនិងច្បាប់ផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា២៤៥ .-

មន្ត្រីមានសមត្ថកិច្ចដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិបញ្ឈប់នាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ដែលកំពុងធ្វើដំណើរតាមផ្លូវទឹកនិងឡើងលើនាវា ដើម្បីត្រួតពិនិត្យបទល្មើស ក្នុងករណីមានភស្តុតាងឬការសង្ស័យដែលជឿជាក់ថា នាវាបានរំលោភលើបទប្បញ្ញត្តិនៃច្បាប់នេះ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។

ក្នុងការត្រួតពិនិត្យលើនាវា ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ មន្ត្រីមានសមត្ថកិច្ចដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិចាត់វិធានការឃាត់នាវា និង/ឬឃាត់ជនណាមួយដែលប្រព្រឹត្តបទល្មើស និងកសាងសំណុំរឿងបញ្ជូនទៅតុលាការមានសមត្ថកិច្ច ដោយអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនិងបទប្បញ្ញត្តិគតិយុត្តជាធរមាន។

ការត្រួតពិនិត្យនិងការចាត់វិធានការលើនាវា ត្រូវធ្វើឡើងដោយគ្មានការពន្យារពេល និងមិនបង្កហានិភ័យដល់សុវត្ថិភាពនាវាចរណ៍ឡើយ ហើយត្រូវជូនដំណឹងអំពីករណីនេះ ទៅក្រសួងសាធារណការនិងដឹកជញ្ជូន ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលនាវាត្រូវបានចុះបញ្ជី។

មាត្រា២៤៦ .-

នាវាបរទេសដែលធ្វើនាវាចរណ៍នៅតាមផ្លូវទឹកឆ្លងកាត់ នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើនាវាចរណ៍ដោយសន្តិភាពដោយត្រូវធ្វើដំណើរជានិច្ចមិនបង្អង់ និងមិនត្រូវប្រព្រឹត្តនូវអំពើណាមួយដូចខាងក្រោម ៖

- ការគំរាមកំហែង ឬប្រើកម្លាំងប្រឆាំងនឹងអធិបតេយ្យភាព បូរណភាពទឹកដី ឯករាជ្យភាព ឬក្នុងទម្រង់ណាមួយដែលរំលោភគោលការណ៍ច្បាប់ជាតិនិងច្បាប់អន្តរជាតិ។

៦៤/ ៧១

២- សកម្មភាពប្រមូលយកព័ត៌មានឬឃោសនា ក្នុងគោលបំណងបំផ្លាញសន្តិសុខឬកិច្ចការពារជាតិ។

៣- សកម្មភាពផ្ទេរផ្ទុកវត្ថុ រូបិយបណ្ណ ឬមនុស្ស។

៤- ចេតនាបំពុលបរិស្ថាន។

៥- សកម្មភាពធ្វើនេសាទ។

៦- សកម្មភាពសិក្សានិងស្រាវជ្រាវ។

៧- សកម្មភាពរំខានប្រព័ន្ធទំនាក់ទំនងឬស្ថានីយវិទ្យុឆ្នេរសមុទ្រ។

៨- សកម្មភាពសំចតដោយគ្មានជូនដំណឹង។

៩- សកម្មភាពផ្សេងទៀត ដែលអាចប៉ះពាល់ដោយប្រយោល។

នាវាបរទេសដែលធ្វើនាវាចរណ៍ឆ្លងកាត់នៅតាមតំបន់សមុទ្រដែនដី នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវលើកទង់ជាតិនៃប្រទេសម្ចាស់សញ្ជាតិនិងទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា មានឯកសារនាវានិងនាវិក ទំនិញ ឬអ្នកដំណើរ ដែលមានសុពលភាព។

មាត្រា២៤៧ .-

មន្ត្រីមានសមត្ថកិច្ចដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិបញ្ឈប់និងឡើងលើនាវាបរទេសដែលកំពុងធ្វើដំណើរឆ្លងកាត់នៅតាមផ្លូវទឹកក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការពិនិត្យបទល្មើស ដែលបានប្រព្រឹត្តដោយនាវាឬនៅលើនាវា។

ការពិនិត្យបទល្មើស ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើ រួមមានការសាកសួរនាយនាវា ការពិនិត្យឯកសារនាវានិងនាវិក និងភស្តុតាងជាក់ស្តែងនៅលើនាវា ហើយបន្ទាប់ពីត្រួតពិនិត្យឃើញថា មានបទល្មើសជាក់ស្តែង សមត្ថកិច្ចត្រួតពិនិត្យនាវា មានសិទ្ធិចាប់នាវា ចាប់ជនល្មើស និងរៀបចំសំណុំរឿងទៅតុលាការមានសមត្ថកិច្ចដោយអនុវត្តស្របតាមក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទប្បញ្ញត្តិគតិយុត្តជាធរមាន។

គ្រប់ករណីនៃការបញ្ឈប់និងឡើងលើនាវាបរទេសដែលកំពុងធ្វើដំណើរឆ្លងកាត់នៅតាមផ្លូវទឹកក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា មន្ត្រីមានសមត្ថកិច្ចដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវមានភស្តុតាងឬការសង្ស័យដែលជឿជាក់ថានាវាបរទេស បានប្រព្រឹត្តល្មើសដែលផ្ទុយនឹងច្បាប់នេះ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត និងត្រូវធ្វើការពិនិត្យបទល្មើសរួមនឹងចាត់វិធានការដែលអាចកើតមានដោយគ្មានការពន្យារពេល។

មាត្រា២៤៨ .-

ក្នុងករណីមានបទល្មើសដែលបានកើតឡើងនៅលើនាវាបរទេស ដែលកំពុងធ្វើដំណើរឆ្លងកាត់នៅដែនទឹកផ្ទៃក្នុង ឬនៅក្នុងតំបន់សមុទ្រដែនដីនៃព្រះរាជាណាចក្រកម្ពុជា មន្ត្រីមានសមត្ថកិច្ចមានសិទ្ធិចាប់នាវា ឬចាប់ជនណាម្នាក់បាន ក្នុងករណីណាមួយដូចខាងក្រោម៖

- ផលវិបាកនៃបទល្មើសនោះ មានវិសាលភាពប៉ះពាល់ដល់អធិបតេយ្យ បូរណភាពទឹកដី ឯករាជ្យ ឬផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា
- មានការស្នើសុំពីនាយនាវា ឬស្ថានទូត ឬស្ថានតំណាងនៃប្រទេសសញ្ជាតិនាវា
- ដើម្បីបានការបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែន ជាអាទិ៍ បទល្មើសគ្រឿងញៀន ការរត់ពន្ធ ការជួញដូរមនុស្ស ។

មាត្រា២៤៩ ..

គ្រប់ករណីនៃការបញ្ឈប់ ឡើងលើនាវា និងចាត់វិធានការណាមួយ ដូចមានចែងនៅក្នុងមាត្រា២៤៧ និងមាត្រា២៤៨នៃច្បាប់នេះ មន្ត្រីមានសមត្ថកិច្ចត្រូវជូនដំណឹងទៅម្ចាស់នាវា ឬតំណាងម្ចាស់នាវា ប្រទេសម្ចាស់សញ្ជាតិនាវា ឬស្ថានទូត ឬស្ថានតំណាង។ ការជូនដំណឹងនេះត្រូវធ្វើឡើងទន្ទឹមនឹងការចាត់វិធានការ ឬត្រូវធ្វើឡើងភ្លាមបន្ទាប់ពីការចាត់វិធានការ។

គ្រប់ករណីនៃការបញ្ឈប់នាវាដែលកំពុងធ្វើដំណើរដើម្បីធ្វើការពិនិត្យបទល្មើស ឬក្នុងករណីមានការដេញប្រផាប់ចាប់ប្រកីងនៅពេលដែលនាវាមិនព្រមឈប់ មន្ត្រីមានសមត្ថកិច្ចមិនត្រូវបង្កឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនាវាចរណ៍ឡើយ។

ផ្នែកទី៤
ឯកសណ្ឋាន

មាត្រា២៥០ ..

ក្នុងពេលបំពេញភារកិច្ច មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ និងមន្ត្រីត្រួតពិនិត្យនាវាបរទេស ត្រូវមានឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ និងត្រូវមានលិខិតបញ្ជាបេសកកម្ម។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ និងមន្ត្រីត្រួតពិនិត្យនាវាបរទេស ត្រូវកំណត់ដោយអនុក្រឹត្យ។

ជំពូកទី១៥
សហវិធាន

មាត្រា២៥១ ..

កម្រៃសេវាសាធារណៈដែលតម្រូវឱ្យមាននៅក្នុងច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ជំពូកទី១៦
ទោសប្បញ្ញត្តិ

មាត្រា២៥២ ..

ទណ្ឌកម្មនៅក្នុងច្បាប់នេះ រួមមាន ទណ្ឌកម្មរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌ។

មាត្រា២៥៣ ..

ទណ្ឌកម្មរដ្ឋបាល រួមមានៈ

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការផ្អាកជាបណ្តោះអាសន្ន
- ការតម្រូវឱ្យរុះរើ
- ការតម្រូវឱ្យធ្វើបដិទានឡើងវិញ
- ការព្យួរ ការដកហូត ការលុបចោលវិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត ឬឯកសារដែលបានផ្តល់អនុលោមតាមច្បាប់នេះ។

បទល្មើសដែលត្រូវរងទណ្ឌកម្មរដ្ឋបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល ជាសមត្ថកិច្ចរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចអំពីទណ្ឌកម្មរដ្ឋបាល ក្រៅពីការព្រមានជាលាយលក្ខណ៍អក្សរ ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ មានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលសេចក្តីសម្រេចចិត្ត។ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវសម្រេចលើពាក្យប្តឹងតវ៉ានេះក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យប្តឹងតវ៉ា។ បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន លើពាក្យបណ្តឹងតវ៉ាមានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ចតាមនីតិវិធីក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច។ ការដាក់ពាក្យប្តឹងតវ៉ារបស់បុគ្គលខាងលើ មិនមានអានុភាពផ្អាកការអនុវត្តសេចក្តីសម្រេច អំពីទណ្ឌកម្មរដ្ឋបាលនោះទេ។

មាត្រា២៥៤ .-

ទណ្ឌកម្មព្រហ្មទណ្ឌ រួមមាន៖

- ពិន័យអន្តរការណ៍
- ពិន័យជាប្រាក់
- ទោសដាក់ពន្ធនាគារ។

បទល្មើសដែលត្រូវពិន័យអន្តរការណ៍ស្របតាមច្បាប់នេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

ការសម្រេចដាក់ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌។

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យបណ្តឹងអាជ្ញារលត់។ ការបង់ប្រាក់ពិន័យអន្តរការណ៍មិនមែនជាឧបសគ្គដល់ការអនុវត្តទណ្ឌកម្មរដ្ឋបាល និងទណ្ឌកម្មព្រហ្មទណ្ឌ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងច្បាប់ព្រហ្មទណ្ឌជាធរមានផ្សេងទៀតឡើយ។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវកសាងសំណុំរឿងនៃបទល្មើស ហើយបញ្ជូនទៅតុលាការតាមនីតិវិធី។

បែបបទនិងនីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យអន្តរការណ៍ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍ និងការចាត់ចែងប្រាក់ចំណូលដែលបានមកពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រាជរដ្ឋាភិបាល អាចផ្តល់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសដូចមានចែងនៅក្នុងច្បាប់នេះ។

មាត្រា២៥៥ .-

មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ មន្ត្រីត្រួតពិនិត្យនាវាបរទេស ឬមន្ត្រីមានសមត្ថកិច្ចដែលអនុវត្តបំពានបទប្បញ្ញត្តិនៃច្បាប់នេះនិងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងទៀតក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ត្រូវទទួលខុសត្រូវផ្នែករដ្ឋបាលនេះ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។ ការទទួលខុសត្រូវផ្នែករដ្ឋបាល មិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់ ការផ្តន្ទាទោសព្រហ្មទណ្ឌ ព្រមទាំងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ស្របតាមច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀតឡើយ។

មាត្រា២៥៦ .-

នាយនាវា ឬអ្នកបរិបាលនាវាដែលបានបដិសេធដោយគ្មានមូលហេតុច្បាស់លាស់ផ្តល់ជំនួយសង្គ្រោះដល់នាវា នាវិក អ្នកដំណើរ ឬបុគ្គលណាមួយ ដែលកំពុងរងគ្រោះក្រោយការប៉ះទង្គិចនាវា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៨ ០០០ ០០០(ប្រាំបីលាន)រៀល។

មាត្រា២៥៧ .-

ជនណាដែលដឹងច្បាស់ថា នាវាដែលខ្លួនធ្វើនាវាចរណ៍ បានបង្កឱ្យមានគ្រោះថ្នាក់ឬការខូចខាត ហើយបានរត់គេចខ្លួនពីការទទួលខុសត្រូវព្រហ្មទណ្ឌឬរដ្ឋប្បវេណី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៨ ០០០ ០០០(ប្រាំបីលាន)រៀល។

មាត្រា២៥៨ .-

ជនណាដែលបានធ្វើនាវាចរណ៍ដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពតាមបទប្បញ្ញត្តិស្តីពីនាវាចរណ៍តម្រូវ បណ្តាលឱ្យមានរងរបួសដល់អ្នកដទៃ ហើយបណ្តាលឱ្យអ្នករងគ្រោះអសមត្ថភាពធ្វើការងារក្នុងរយៈពេលស្មើឬលើសពី៨(ប្រាំបី)ថ្ងៃ គិតពីថ្ងៃកើតហេតុ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៨ ០០០ ០០០(ប្រាំបីលាន)រៀល។

អំពើល្មើសខាងលើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀល ទៅ១២ ០០០ ០០០(ដប់ពីរលាន)រៀល ក្នុងករណីណាមួយដូចខាងក្រោម៖

១- គ្មានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកឬវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកបដ្ឋិលេខដែលតម្រូវឱ្យមាន អនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

២- បណ្តាលឱ្យមានរបួសមនុស្សច្រើននាក់។

៣- រត់គេចខ្លួនពីកន្លែងកើតហេតុក្នុងគោលបំណងគេចវេសពីការទទួលខុសត្រូវ។

៤- ស្ថិតក្នុងស្ថានភាពស្រវឹង ដោយមានអត្រាជាតិអាល់កុលចាប់ពី០,៤០(សូន្យក្បៀសសែសិប)មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី០,៨០(សូន្យក្បៀសប៉ែតសិប)ក្រាមក្នុងមួយលីត្រឈាមឡើងទៅ។

មាត្រា២៥៩ .-

ជនណាដែលបានធ្វើនាវាចរណ៍ដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពតាមបទប្បញ្ញត្តិស្តីពីនាវាចរណ៍តម្រូវ បណ្តាលឱ្យអ្នកដទៃបាត់បង់ជីវិត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀល ទៅ១២ ០០០ ០០០(ដប់ពីរលាន)រៀល។

អំពើល្មើសខាងលើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៨ ០០០ ០០០(ប្រាំបីលាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល ក្នុងករណីណាមួយដូចខាងក្រោម៖

១- គ្មានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកឬវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកបដ្ឋិលេខដែលតម្រូវឱ្យមានអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

២- បណ្តាលឱ្យមនុស្សស្លាប់ច្រើននាក់។

៣- រត់គេចខ្លួនពីកន្លែងកើតហេតុក្នុងគោលបំណងគេចវេសពីការទទួលខុសត្រូវ។

៤- ស្ថិតក្នុងស្ថានភាពស្រវឹង ដោយមានអត្រាជាតិអាល់កុលចាប់ពី០,៤០(សូន្យក្បៀសសែសិប)មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី០,៨០ (សូន្យក្បៀសប៉ែតសិប)ក្រាមក្នុងមួយលីត្រឈាមឡើងទៅ។

មាត្រា២៦០ .-

នាវិកដែលបានធ្វើនាវាចរណ៍ ដោយគ្មានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកឬវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកបង្ការលេខ ឬក្នុងរយៈពេលដែលវិញ្ញាបនបត្រសមត្ថភាពជំនាញទាំងនោះ ត្រូវបានព្យួរទុក ដកហូត ឬទុកជាមោឃៈ ត្រូវពិន័យអន្តរការណ៍តាមការកំណត់នៃអនុក្រឹត្យ។

បទល្មើសខាងលើ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ៦(ប្រាំមួយ)ខែ និងពិន័យជាប្រាក់ពី៤០០ ០០០(បួនសែន)រៀល ទៅ២ ០០០ ០០០(ពីរលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍រួចហើយ ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងកំលុងពេល១(មួយ) ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

មាត្រា២៦១ .-

ជនណាដែលបានធ្វើនាវាចរណ៍ដោយគ្មានវិញ្ញាបនបត្រចុះបញ្ជីនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹក ក្នុងប្រទេស ត្រូវពិន័យអន្តរការណ៍តាមការកំណត់នៃអនុក្រឹត្យ។

អំពើល្មើសខាងលើ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ថ្ងៃ ទៅ១(មួយ)ខែ និងពិន័យជាប្រាក់ពី១០០ ០០០(មួយសែន)រៀល ទៅ៤០០ ០០០(បួនសែន)រៀល ករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍រួចហើយ ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងកំលុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

មាត្រា២៦២ .-

ជនណាដែលបានធ្វើនាវាចរណ៍ដោយក្លែងបន្លំជានាវាសញ្ជាតិខ្មែរ ដោយមិនបានចុះបញ្ជីនាវាសញ្ជាតិខ្មែរស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល។

មាត្រា២៦៣ .-

មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ មន្ត្រីត្រួតពិនិត្យនាវាបរទេស ឬមន្ត្រីមានសមត្ថកិច្ចណាដែល នៅក្នុងក្របខ័ណ្ឌមុខងារ ឬក្នុងឱកាសបំពេញមុខងាររបស់ខ្លួន ដែលបានដកហូតយកវិញ្ញាបនបត្រចុះបញ្ជីនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេស វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា លិខិតអនុញ្ញាតឱ្យនាវាធ្វើអាជីវកម្មដឹកជញ្ជូន វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិក ឬឃាត់នាវាដោយគ្មានមូលហេតុច្បាស់លាស់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ថ្ងៃ ទៅ១(មួយ)ខែ និងពិន័យជាប្រាក់ពី១០០ ០០០(មួយសែន)រៀលទៅ៤០០ ០០០(បួនសែន)រៀល។

ក្នុងករណីដែលអំពើល្មើសខាងលើបណ្តាលឱ្យមានការខូចខាត ឬបាត់បង់ផ្នែកណាមួយនៃនាវា អង្គភាពសាមីត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ឬបាត់បង់នោះ ស្របតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងច្បាប់ជាធរមានផ្សេងទៀត។

ក្នុងករណីមន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ មន្ត្រីត្រួតពិនិត្យនាវាបរទេស ឬមន្ត្រីមានសមត្ថកិច្ចដែលប្រើសិទ្ធិអំណាចរំលោភដោយទទួលបានអត្ថប្រយោជន៍ក្នុងការបំពេញមុខងាររបស់ខ្លួន ឬក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន នូវអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវផ្តន្ទាទោសតាមបញ្ញត្តិនៃមាត្រា៣៥(រំលោភអំណាច) នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលជាបទល្មើសពុករលួយ និងត្រូវស្ថិតនៅក្រោមសមត្ថកិច្ចតែមួយគត់របស់អង្គភាពប្រឆាំងអំពើពុករលួយ ក្នុងការស៊ើបអង្កេត និងកសាងសំណុំរឿងពុករលួយទៅតុលាការ។

អង្គភាពនិងបុគ្គលដទៃទៀតដែលបានដឹងពីបទល្មើសពុករលួយ ដែលមានចែងនៅក្នុងច្បាប់នេះ និងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀត នៃព្រះរាជាណាចក្រកម្ពុជា ត្រូវប្ដឹងទៅអង្គភាព ឬការិយាល័យរាជធានី ខេត្តប្រឆាំងអំពើពុករលួយ អំពីរឿងហេតុនៃបទល្មើសទាំងនេះ។

មាត្រា២៦៤ .-

ជនណាដែលបានរារាំង ឬប្រើប្រាស់មធ្យោបាយណាមួយ ដើម្បីជាឧបសគ្គដល់នាវាចរណ៍នៅតាមផ្លូវទឹក ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៨ ០០០ ០០០(ប្រាំបីលាន)រៀល។

មាត្រា២៦៥ .-

ជនណាដែលសង់សំណង់សិល្បការ្យ ឬអង្គបណ្ដែតទឹក ឬធ្វើសកម្មភាពផ្សេងទៀតដែលប៉ះពាល់ដល់សុវត្ថិភាពរបស់នាវាក្នុងការធ្វើនាវាចរណ៍ជាប្រក្រតីនៅតាមផ្លូវនាវាចរណ៍ ហើយរឹងទទឹងមិនព្រមរុះរើ និងធ្វើបដិទាន ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៨ ០០០ ០០០(ប្រាំបីលាន)រៀល។

មាត្រា២៦៦ .-

ជនណាដែលបានសាងសង់ ឬជួសជុលឋបនីយកណ្ដផែ ដោយគ្មានលិខិតអនុញ្ញាតសាងសង់ ឬជួសជុលឋបនីយកណ្ដផែ ហើយរឹងទទឹងមិនព្រមផ្អាកជាបណ្ដោះអាសន្ននិងមិនព្រមបំពេញបែបបទស្នើសុំលិខិតអនុញ្ញាត ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ចាប់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៨ ០០០ ០០០(ប្រាំបីលាន)រៀល។

មាត្រា២៦៧ .-

ជនណាដែលធ្វើប្រតិបត្តិការឋបនីយកណ្ដផែ ដោយគ្មានលិខិតអនុញ្ញាតធ្វើប្រតិបត្តិការឋបនីយកណ្ដផែ ដូចមានចែងនៅក្នុងមាត្រា២០៩នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍តាមការកំណត់នៃអនុក្រឹត្យ។

អំពើល្មើសខាងលើ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី៤០០ ០០០(បួនសែន)រៀល ទៅ៤ ០០០ ០០០(បួនលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់បានទទួលរងការពិន័យអន្តរការណ៍រួចហើយ ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងកំលុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

មាត្រា២៦៨ .-

ជនណាដែលបដិសេធផ្ដល់អាទិភាពឱ្យនាវាចូលចេញកំពង់ផែ ដូចមានចែងនៅក្នុងមាត្រា២០១នៃច្បាប់នេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៤ ០០០ ០០០(បួនលាន)រៀល។

មាត្រា២៦៩ .-

ចំពោះរូបវន្តបុគ្គលដែលប្រព្រឹត្តបទល្មើសដែលមានចែងចាប់ពីមាត្រា២៥៦ដល់មាត្រា២៥៩ កថាខណ្ឌទី២នៃមាត្រា២៦០ កថាខណ្ឌទី២នៃមាត្រា២៦១ មាត្រា២៦២ កថាខណ្ឌទី១នៃមាត្រា២៦៣ មាត្រា២៦៤ដល់មាត្រា២៦៦ កថាខណ្ឌទី២នៃមាត្រា២៦៧ និងមាត្រា២៦៨ នៃច្បាប់នេះ តុលាការអាចប្រកាសទោសបន្ថែមមួយឬច្រើន ដូចមានចែងក្នុងមាត្រា៥៣(ប្រភេទទោសបន្ថែម)នៃក្រមព្រហ្មទណ្ឌ។

ខ្លឹមសារ បែបបទ និងនីតិវិធីសម្រាប់ការអនុវត្តទោសបន្ថែមទាំងនេះ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។

៧០/៧១

មាត្រា២៧០ .-

នីតិបុគ្គលអាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងចាប់ពីមាត្រា២៥៨ ដល់មាត្រា២៦២ និងមាត្រា២៦៤ដល់មាត្រា២៦៨នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ២០០ ០០០ ០០០(ពីររយលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

មាត្រា២៧១ .-

ការអនុវត្តបញ្ញត្តិនៃជំពូកទី១៦នៃច្បាប់នេះ មិនរារាំងដល់ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀតក្នុងករណីដែលអំពើដែលកំណត់ថាជាបទល្មើសដែលមានចែងក្នុងច្បាប់នេះ ជាបទល្មើសដែលបានបញ្ញត្តិក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

ជំពូកទី១៧
អន្តរប្បញ្ញត្តិ

មាត្រា២៧២ .-

បទប្បញ្ញត្តិដែលតម្រូវឱ្យនាវិកដែលបម្រើការជាបរិបាលនាវា យន្តការីនាវា អ្នកបើកបរនាវា ជំនួយការបរិបាលនាវា និងជំនួយការយន្តការីនាវា ដូចមានចែងនៅក្នុងមាត្រា៤៦នៃច្បាប់នេះ ត្រូវអនុវត្តក្នុងរយៈពេល ១(មួយ)ឆ្នាំ បន្ទាប់ពីច្បាប់នេះចូលជាធរមាន។

មាត្រា២៧៣ .-

លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងវិស័យដឹកជញ្ជូនផ្លូវទឹកនិងកំពង់ផែ មានសុពលភាពរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ជំពូកទី១៨
អវសានប្បញ្ញត្តិ

មាត្រា២៧៤ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

មាត្រា២៧៥ .-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ*សៅរ៍ ៩កើត* ខែ *ជេស្ឋ* ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី *១៥* ខែ *មិថុនា* ឆ្នាំ២០២៤

នស.រកម.០៦២៤.០០៩

ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាសបន្ទាប់
ប្រមុខរដ្ឋស្តីទី

(ហត្ថលេខា)

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

(ហត្ថលេខា)

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

(ហត្ថលេខា)

ប៉េង ពោធិ៍នា

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

(ហត្ថលេខា និងត្រា)

វង្សី វិស្សុត

៧១/៧១

ឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការដឹកជញ្ជូនតាមផ្លូវទឹក
សទ្ទានុក្រម

ការធ្វើនាវាចរណ៍ឬនាវាចរណ៍ សំដៅដល់ការធ្វើដំណើររបស់នាវា ឬធ្វើចលនាចរណ៍របស់នាវា។

ការធ្វើនាវាចរណ៍ឬនាវាចរណ៍ជាលក្ខណៈអន្តរជាតិ សំដៅដល់ការធ្វើនាវាចរណ៍ ដែលក្នុងនោះនាវាចេញដំណើរពីកំពង់ផែដែលស្ថិតនៅក្នុងប្រទេសមួយ ឆ្ពោះទៅកាន់កំពង់ផែដែលស្ថិតនៅក្នុងប្រទេសផ្សេងទៀតដោយត្រូវឆ្លងកាត់សមុទ្រ។

ការឃាត់នាវា សំដៅដល់ (១)- ការចាត់វិធានការអន្តរាគមន៍ដោយមន្ត្រីត្រួតពិនិត្យនាវាបរទេសនៅតាមកំពង់ផែ នៅពេលដែលស្ថានភាពនាវា និងក្រុមនាវិក មិនអនុលោមតាមបទប្បញ្ញត្តិសំខាន់ៗនៃអនុសញ្ញាអន្តរជាតិ ដើម្បីធានាថានាវានឹងមិនចេញដំណើរ រហូតដល់ពេលនាវាអាចឆ្លងកាត់សមុទ្រដោយគ្មានគ្រោះថ្នាក់ ដល់នាវា នាវិក និងបរិស្ថាន (២)- ការឃាត់នាវាដើម្បីពិនិត្យបទល្មើសស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និង(៣)- ការឃាត់នាវាសមុទ្រដើម្បីធានាដល់ការទូទាត់សំណងនាវាចរណ៍។

ការចុះបញ្ជីធានានាវាឬចុះបញ្ជីធានានាវា សំដៅដល់ការចុះបញ្ជីធានានាវាដែលធ្វើឡើងដោយម្ចាស់នាវាដើម្បីទទួលបានការខ្ចីប្រាក់សម្រាប់ការសាងសង់ឬធ្វើប្រតិបត្តិការនាវា តាមអត្រាកំណត់នៅក្នុងកិច្ចសន្យាធានានាវាឬកិច្ចសន្យាសាងសង់នាវា ដែលបានធ្វើឡើងរវាងម្ចាស់នាវា និងម្ចាស់បំណុល ដូចជាធនាគារ ឬក្រុមហ៊ុនធានារ៉ាប់រងណាមួយ។

ក្រុមហ៊ុននាវា សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់នាវា ឬដែលធ្វើប្រតិបត្តិការនាវា។

កំពង់ផែ សំដៅដល់តំបន់ដែលមានដែនទឹកនិងដីគោកជាក់លាក់ និងមានឋបនីយកណ្ដាផែសម្រាប់បម្រើឱ្យនាវាចូល ចេញ បោះយុថ្កា និងចត ដើម្បីលើកដាក់ ផ្ទេរ ផ្ទុក និងរក្សាទុកទំនិញ និងផ្ទេរផ្ទុកអ្នកដំណើរ។

កណ្ដាធារ សំដៅដល់អ្នកនាំផ្លូវនាវាដែលមានភារកិច្ចជួយដល់នាយនាវាឬនាយបើកបរនាវា ដើម្បីធ្វើនាវាចរណ៍ប្រកបដោយសុវត្ថិភាពនៅក្នុងដែនកណ្ដាធារកិច្ច ឬដែនទឹកកំពង់ផែ។

កណ្ដាធារកិច្ច សំដៅដល់កិច្ចការដែលកណ្ដាធារត្រូវបំពេញនៅលើនាវា ដើម្បីឱ្យនាវាធ្វើនាវាចរណ៍ឆ្លងកាត់ដែនកណ្ដាធារកិច្ចឬចូលចេញកំពង់ផែ ប្រកបដោយសុវត្ថិភាព នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

កម្លាំងចលករ សំដៅដល់កម្លាំងដែលបង្កើតបានពីការប្រើប្រព័ន្ធមេកានិក រួមមានម៉ាស៊ីនចលករ ស្លាបចក្រឬកង្ហារ និងប្រព័ន្ធ ដើម្បីជំរុញនាវាឱ្យមានចលនានៅលើផ្ទៃទឹក ដែលជាទូទៅសំដៅលើចលនាទៅមុខ។

កម្លាំងចលករបញ្ច្រាស សំដៅដល់កម្លាំងចលករនាវាដោយការប្រើប្រព័ន្ធមេកានិក ដើម្បីឱ្យនាវាមានចលនាថយក្រោយ។

ការបាត់បង់នាវាទាំងស្រុង សំដៅដល់នាវាដែលបានបាត់ដោយអំពើចោរកម្ម មិនអាចរកឃើញឬបានជួបគ្រោះថ្នាក់នាវាចរណ៍ដោយលិចចូលក្នុងសមុទ្រ ដែលមិនអាចស្រង់វិញបាន បាក់បែកជាកំណាត់ ឆេះអស់ឬផ្ទុះដែលមិនអាចជួសជុលប្រើវិញបាន។

ក្ដោងសំខាន់ សំដៅដល់ប្រភេទក្ដោងដែលបំពាក់នៅលើដងក្ដោងសំខាន់របស់នាវាប្រើក្ដោង។

ក្ដោងត្រង់ សំដៅដល់ប្រភេទក្ដោងដែលត្រូវបានរៀបចំនិងបំពាក់នៅលើដងក្ដោង មានទម្រង់ជាបួនជ្រុងក្ដោងមានដងផ្តេត កែងនឹងដងក្ដោង និងកែងជាមួយទ្រនង់បាតនាវាផងដែរ។

ការប៉ះទង្គិចនាវា សំដៅដល់គ្រោះថ្នាក់នាវាចរណ៍ដែលកើតឡើងដោយការប៉ះ ការកៀរ ឬការបុករវាងនាវាពីរគ្រឿងឬច្រើន ដែលបង្កឱ្យមានការបាត់បង់ឬខូចខាតដល់នាវាឬទំនិញនៅលើនាវា ឬដែលបង្កឱ្យមានការរងរបួសឬបាត់បង់ជីវិតមនុស្សនៅលើនាវា ព្រមទាំងការខូចខាតដល់ភាគីទី៣ ដូចជាការប៉ះពាល់ដល់បរិស្ថាន និងរំខានដល់សកម្មភាពសេដ្ឋកិច្ចស្របច្បាប់ផ្សេងៗទៀតនៅក្នុងដែនទឹក។

i

ករណីប្រធានសក្តិ សំដៅដល់បាតុភូតដែលកើតឡើងដោយធម្មជាតិ ដែលមនុស្សមិនអាចដឹងមុន និងមិនអាចទប់ទល់បាន។

ខសន្យា សំដៅដល់បទប្បញ្ញត្តិឬប្រការ ដែលមាននៅក្នុងកិច្ចសន្យា។

គ្រោះថ្នាក់នាវាចរណ៍ សំដៅដល់គ្រោះថ្នាក់នៃនាវា ដែលកើតឡើងនៅក្នុងការធ្វើនាវាចរណ៍ដោយឧប្បត្តិហេតុផ្សេងៗ រួមមានការប៉ះទង្គិច ការឆេះ ការលិច ការកឿង ការកើល ដែលបង្កឡើងដោយបាតុភូតធម្មជាតិឬកត្តាមនុស្ស។

គន្លងបែងចែកចរាចរណ៍ សំដៅដល់គន្លងនាវាចរណ៍ ដែលបែងចែកទិសដៅចរាចរណ៍និងត្រូវកំណត់ដោយក្រសួងសាធារណការនិងដឹកជញ្ជូន។

ច្រកនាវាចរណ៍ សំដៅដល់ផ្លូវនាវាចរណ៍នៅក្នុងតំបន់ទន្លេ បឹង ឆកសមុទ្រ ពាម ដែនទឹកកំពង់ផែជាអាទិ៍ នៅចន្លោះតំបន់ទឹករាក់ ទំនាបលិចទឹក និង/ឬកោះជាអាទិ៍។

ចំណុចខ្វះខាតដែលត្រូវឃាត់នាវា សំដៅដល់ចំណុចខ្វះខាតដែលបង្ហាញថា មានការគំរាមកំហែងដល់សុវត្ថិភាពនាវា នាវិក និងបរិស្ថាន នៅពេលដែលនាវាធ្វើដំណើរឆ្លងកាត់សមុទ្រ។

ជម្រៅស៊ីទឹក សំដៅដល់ប្រវែងពីបាតរបស់នាវារហូតដល់ខ្សែបន្ទាត់ទឹករបស់នាវាឬផ្ទៃទឹក។

ដែនទឹកនៃកំពង់ផែ សំដៅដល់តំបន់ រួមមានច្រកចូលចេញ តំបន់សម្រាលទំនិញ តំបន់បោះយុថ្កា កន្លែងបត់នាវា ចំណតនាវា និងឋបនីយកណ្ឌផ្សេងទៀតជាអាទិ៍។ តំបន់សម្រាលទំនិញ ជាតំបន់ស្ថិតនៅក្នុងឬនៅក្រៅដែនទឹកនៃកំពង់ផែ សម្រាប់ឱ្យនាវាដែលមានជម្រៅស៊ីទឹកជ្រៅ ឬនាវាដឹកប្រេង/ឧស្ម័នដែលមានហានិភ័យកំពប់ប្រេង/ឧស្ម័នក្នុងពេលផ្ទេរផ្ទុក ចូលចតដោយប្រើយុថ្កា ដើម្បីផ្ទេរផ្ទុកទំនិញ។ តំបន់បោះយុថ្កា ជាតំបន់ស្ថិតនៅក្នុងដែនទឹកនៃកំពង់ផែឬក្រៅដែនទឹកនៃកំពង់ផែ សម្រាប់ឱ្យនាវាចូលចតដោយការប្រើយុថ្កាបោះភ្ជាប់ទៅនឹងបាតទឹក។ ចំណតនាវា រួមមានចំណតគោកនិងចំណតទឹក។ ចំណតគោក ជាសំណង់រឹងសម្រាប់នាវាចូលចតដែលមានទីតាំងជាប់ផ្ទាល់ទៅនឹងដីគោកនៃកំពង់ផែ។ ចំណតទឹក ជាតំបន់ស្ថិតនៅក្នុងដែនទឹកនៃកំពង់ផែ សម្រាប់ឱ្យនាវាចូលចតដោយការចងភ្ជាប់នាវាទៅនឹងពោងដែលតភ្ជាប់យ៉ាងមាំទៅបាតទឹក។

ដីគោកនៃកំពង់ផែ សំដៅដល់ទីធ្លាដីគោកដែលមានឋបនីយកណ្ឌសម្រាប់បម្រើឱ្យការលើកដាក់ ការផ្ទេរផ្ទុក ការរក្សាទុកទំនិញ ការឡើងចុះរបស់អ្នកដំណើរ និងឋបនីយកណ្ឌជំនួយផ្សេងទៀត។

ដែនទឹកផ្ទៃក្នុង សំដៅដល់តំបន់សមុទ្រដែលស្ថិតនៅខាងក្នុងខ្សែបន្ទាត់មូលដ្ឋាន។

ដែនកណ្ឌូជារកិច្ច សំដៅដល់ផ្នែកមួយនៃផ្លូវនាវាចរណ៍ ដែលត្រូវបានកំណត់ឱ្យនាវាត្រូវប្រើសេវាកណ្ឌូជារកិច្ច។

ដេញប្រផាប់ចាប់ប្រកីង សំដៅដល់សកម្មភាពនាវារបស់មន្ត្រីមានសមត្ថកិច្ច ដេញនាវាបរទេសនៅក្នុងតំបន់សមុទ្រដែនដីបន្ទាប់ពីនាវាបានចេញពីដែនទឹកផ្ទៃក្នុង ដើម្បីឃាត់ឡើងលើនាវា និងត្រួតពិនិត្យអំពើល្មើស ប្រសិនបើមានភស្តុតាងឬសង្ស័យអំពីអំពើល្មើស ហើយនាវានោះមិនព្រមឈប់តាមការស្នើសុំរបស់មន្ត្រីមានសមត្ថកិច្ចនោះ។

ឋបនីយកណ្ឌផែ សំដៅដល់ទីតាំងដែលមានប្រតិបត្តិការរវាងនាវានិងកំពង់ផែ។ ឋបនីយកណ្ឌផែរួមមានតំបន់ចំណត តំបន់បោះយុថ្កា តំបន់រង់ចាំ ប្រឡាយនាវាចរណ៍ និងពាម ព្រមទាំងសំណង់និងឧបករណ៍សម្ភារៈនាវា។

ម៉ាស៊ីនបន្សុទ្ធនុយក្លេអ៊ែលើនាវា សំដៅដល់ម៉ាស៊ីនរ៉េអាក់ទ័រ ម៉ាស៊ីនកែច្នៃសារធាតុនុយក្លេអ៊ែ ម៉ាស៊ីនផលិតថាមពលនុយក្លេអ៊ែ ម៉ាស៊ីនរក្សាទុកសារធាតុនុយក្លេអ៊ែ ឬប្រភេទឋបនការណាមួយដែលមានថាមពលនុយក្លេអ៊ែ សារធាតុវិទ្យុសកម្ម ឬសំណល់វិទ្យុសកម្ម។

ii

ណាត សំដៅដល់ខ្នាតល្បឿនគិតជាម៉ែល៍សមុទ្រក្នុងមួយម៉ោង។ ១ម៉ែល៍សមុទ្រសម្រាប់វាស់ល្បឿនត្រូវបានសន្មតយកម៉ែល៍សមុទ្រអន្តរជាតិស្មើនឹង១៨៥២(មួយពាន់ប្រាំបីរយហាសិបពីរ)ម៉ែត្រ។

តំបន់បោះយុថ្កា សំដៅដល់ទីតាំងនៅក្នុងផ្លូវទឹក ដែលបានកំណត់សម្រាប់ឱ្យនាវាបោះយុថ្កា។

តំបន់សមុទ្រជែនដី សំដៅដល់តំបន់សមុទ្រដែលស្ថិតនៅក្នុងចម្ងាយ១២ម៉ែល៍សមុទ្រ ពីខ្សែបន្ទាត់មូលដ្ឋានឆ្ពោះទៅសមុទ្រ។

ថ្លៃឈ្នួលកំពង់ផែ សំដៅដល់ថ្លៃចំណុះផ្ទុកសរុប ថ្លៃប្រើប្រឡាយនាវាចរណ៍ ថ្លៃបោះយុថ្កា ថ្លៃចងនិងស្រាយពួរ ថ្លៃចត ថ្លៃលើកដាក់ទំនិញ ថ្លៃផ្ទេរផ្ទុកទំនិញ ថ្លៃកណ្ណធារកិច្ច ថ្លៃប្រើនាវារុញនិងសណ្តោង និងថ្លៃប្រើសេវាផ្សេងទៀត។

ទំនិញគ្រោះថ្នាក់ សំដៅដល់ទំនិញដែលគេបានចាត់ថ្នាក់នៅក្នុងក្រមអន្តរជាតិស្តីពីការដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមផ្លូវសមុទ្រ និងងាយមានគ្រោះថ្នាក់ដល់ការដឹកជញ្ជូន ប្រសិនបើមិនមានវិធានការទប់ស្កាត់ឬការប្រុងប្រយ័ត្នជាមុន។

ទំនិញ សំដៅដល់ផលិតផល ជាវត្ថុរឹង រាវ និងឧស្ម័ន ក្នុងទម្រង់វេចខ្ចប់ឬកុងតឺន័រ រាយឬចាក់ធារ និងសត្វរស់ឬរុក្ខជាតិរស់។

ទិសបើកបរ សំដៅដល់ទិសឆ្ពោះរបស់នាវា បង្ហាញជាដឺក្រេវាស់តាមទិសដៅទ្រនិចនាឡិកា ចេញពីខ្សែបណ្តោយខាងជើងនៃផែនដីទៅបន្ទាត់ពុះបណ្តោយនៃនាវា។

ទិសសង្កេត សំដៅដល់ទិសតម្រង់ទៅវត្ថុត្រូវសង្កេត មានរង្វាស់ជាដឺក្រេដែលវាស់តាមទិសដៅទ្រនិចនាឡិកា ចេញពីខ្សែបណ្តោយខាងជើងនៃផែនដីទៅបន្ទាត់កាត់រវាងអ្នកសង្កេតនិងវត្ថុត្រូវសង្កេត។

នាវា សំដៅដល់ជលយានដែលសាងសង់ឡើងសម្រាប់ធ្វើដំណើរនៅលើផ្លូវទឹក។

នាវាឆ្នេរសមុទ្រ សំដៅដល់នាវាដែលចុះបញ្ជីជានាវាឆ្នេរសមុទ្រ ដើម្បីទទួលភាពស្របច្បាប់សម្រាប់ធ្វើនាវាចរណ៍នៅតាមឈូងសមុទ្រ ឆកសមុទ្រ និងព្រែកជាប់សមុទ្រក្នុងព្រះរាជាណាចក្រកម្ពុជា។

នាវាផ្លូវទឹកក្នុងប្រទេស សំដៅដល់នាវាដែលចុះបញ្ជីជានាវាផ្លូវទឹកក្នុងប្រទេស ដើម្បីទទួលភាពស្របច្បាប់សម្រាប់ធ្វើនាវាចរណ៍នៅតាមទន្លេ ព្រែក ស្ទឹង បឹង ក្នុងព្រះរាជាណាចក្រកម្ពុជា។

នាវាសមុទ្រ សំដៅដល់នាវាដែលធ្វើនាវាចរណ៍ឆ្លងកាត់សមុទ្រ។

នាវាសញ្ជាតិខ្មែរ សំដៅដល់នាវាសមុទ្រ ដែលចុះបញ្ជីជានាវាសញ្ជាតិខ្មែរដោយអង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរនៃក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីទទួលភាពស្របច្បាប់សម្រាប់ធ្វើនាវាចរណ៍ឆ្លងកាត់សមុទ្រ។

នាវាបរទេស សំដៅដល់នាវាសមុទ្រដែលចុះបញ្ជីជានាវាសមុទ្រដោយអាជ្ញាធរមានសមត្ថកិច្ចបរទេស ដើម្បីទទួលភាពស្របច្បាប់សម្រាប់ធ្វើនាវាចរណ៍ឆ្លងកាត់សមុទ្រ។

នាវាដឹកទំនិញ សំដៅដល់នាវាដែលបានសាងសង់ឡើងសម្រាប់គោលបំណងដឹកជញ្ជូនទំនិញ ដែលមាននាវាដឹកទំនិញទូទៅ នាវាដឹកទំនិញកុងតឺន័រ នាវាដឹកទំនិញចាក់ធារ នាវាដឹកប្រេង នាវាដឹកឧស្ម័ន [illegible] ប៉ុងតុង [illegible]ជាខុនជាអាទិ៍។

នាវាដឹកអ្នកដំណើរ សំដៅដល់នាវាដែលបានសាងសង់ឡើងសម្រាប់គោលបំណងដឹកជញ្ជូនអ្នកដំណើរ ដែលមាន[illegible]នាវាដឹកអ្នកដំណើរ នាវាកម្សាន្ត នាវាលម្ហែជាអាទិ៍។

នាវាពន្លត់អគ្គិភ័យ សំដៅដល់នាវាដែលសាងសង់ឡើងសម្រាប់គោលបំណងពន្លត់អគ្គិភ័យ។

នាវាសង្គ្រោះ សំដៅដល់នាវាដែលសាងសង់ឡើងសម្រាប់គោលបំណងជួយសង្គ្រោះនាវា និងមនុស្សក្នុងឧប្បត្តិហេតុគ្រោះអាសន្ន និងអាចសម្គាល់បានថាជានាវាសង្គ្រោះ។

នាវាកងកម្លាំងមានសមត្ថកិច្ច សំដៅដល់នាវាកងកម្លាំងមានសមត្ថកិច្ចនៃក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ សម្រាប់គោលបំណងរក្សាសន្តិសុខជាតិនិងកិច្ចការពារជាតិ។

នាវាបំពេញបេសកកម្មពិសេស សំដៅដល់នាវាធ្វើប្រតិបត្តិការដោយមន្ត្រីដែលត្រូវបានចាត់តាំងឱ្យបំពេញការងារផ្នែកសណ្ដាប់ធ្នាប់នាវាចរណ៍។

នាវាបំពេញសកម្មភាពសុវត្ថិភាពសាធារណៈ សំដៅដល់នាវាសម្រាប់ល្បាត ហែក្បួន ពិធីបុណ្យពិសេស ត្រួតពិនិត្យចរាចរណ៍ សង្គ្រោះ ពន្លត់អគ្គិភ័យ ជំនួយផ្នែកសុខាភិបាល ជំនួយសង្គ្រោះនាវា រុករកនិងសង្គ្រោះ ជាអាទិ៍។

នាវាប្រើម៉ាស៊ីន សំដៅដល់នាវាដែលធ្វើចលនាបានដោយប្រើកម្លាំងម៉ាស៊ីន។

នាវានេសាទ សំដៅដល់នាវាដែលសាងសង់ឡើងដោយមានបំពាក់ឧបករណ៍សម្ភារៈនេសាទសម្រាប់ធ្វើនេសាទ។

នាវាកំពុងនេសាទ សំដៅដល់នាវា ដែលកំពុងធ្វើនេសាទដោយប្រើមង សន្ទូច អួនអូស ឬអួនហ៊ុម ឬឧបករណ៍នេសាទផ្សេងទៀត ដែលធ្វើឱ្យនាវាលំបាកបញ្ជាចលនាចរណ៍។

នាវាប្រើក្ដោង សំដៅដល់នាវាដែលធ្វើចលនាដោយប្រើកម្លាំងខ្យល់បក់ឬប្រសិនបើមានម៉ាស៊ីន ក៏ម៉ាស៊ីននោះនៅតែមិនប្រើដដែល។

នាវាសណ្ដោង សំដៅដល់នាវាដែលបានសាងសង់ឡើងសម្រាប់សណ្ដោងឬរុញនាវាផ្សេងទៀត។

នាវារុញ សំដៅដល់នាវាដែលបានសាងសង់ឡើងសម្រាប់រុញនាវាផ្សេងទៀត។

នាវាមានកម្រិតសមត្ថភាពចលនាចរណ៍ សំដៅដល់នាវាដែលមានដែនកម្រិតចលនាចរណ៍ក្នុងពេលបំពេញការងាររបស់ខ្លួន រួមមាននាវាកំពុងដាក់ឬលើកសញ្ញាជំនួយនាវាចរណ៍ លើកខ្សែកាបឬបំពង់បង្ហូរនាវាកំពុងធ្វើប្រតិបត្តិការជីកស្ដារប្រឡាយនាវាចរណ៍ នាវាកំពុងធ្វើការសិក្សាស្រាវជ្រាវផ្នែកក្រោមទឹក នាវាកំពុងធ្វើការផ្ទេរទំនិញឬមនុស្ស នាវាកំពុងធ្វើប្រតិបត្តិការយករ៉ែ នាវាកំពុងធ្វើប្រតិបត្តិការស្រង់បំណែកនាវាលិចឬសំណល់នាវានៅក្នុងទឹក និងនាវាកំពុងធ្វើប្រតិបត្តិការសណ្ដោងឬរុញ។

នាវាមិនអាចបញ្ជាបាន សំដៅដល់នាវាដែលស្ថិតក្នុងកាលៈទេសៈខុសប្រក្រតី មិនអាចធ្វើចលនាចរណ៍តាមវិធាន ក្នុងបទប្បញ្ញត្តិនាវាចរណ៍បាន និងមិនមានសមត្ថភាពងាកចេញពីផ្លូវធ្វើដំណើររបស់នាវាផ្សេងទៀត។

នាវាមានដែនកម្រិតជម្រៅស៊ីទឹក សំដៅដល់នាវាប្រើម៉ាស៊ីនដែលមានដែនកម្រិតងាកចេញពីទិសបើកបរ ដោយសារជម្រៅស៊ីទឹកនាវាត្រូវការជម្រៅទឹកនិងទទឹងផ្លូវចរគ្រប់គ្រាន់ដើម្បីឱ្យនាវាឆ្លងកាត់បាន។

នាវាគាំទ្រ សំដៅដល់នាវាតូចៗដែលផ្ដល់សេវាតាមតម្រូវការរបស់នាវាធំៗ រួមមានសេវាកម្មទូទៅសេវាគ្រោះអាសន្ន សេវាផ្គត់ផ្គង់ ជាអាទិ៍។

នាវាក្រោមបទដ្ឋាន សំដៅដល់នាវាដែលតួ គ្រឿងម៉ាស៊ីន ឧបករណ៍ ឬសុវត្ថិភាពប្រតិបត្តិការ មានស្ថានភាពស្ថិតនៅក្រោមបទដ្ឋានដែលតម្រូវដោយអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ។

នាវាកណ្ដធារ សំដៅដល់នាវាសម្រាប់ដឹកកណ្ដធារ និងប្រើទង់សញ្ញាកណ្ដធារនៅលើនាវាជាប្រចាំ។

នាវិក សំដៅដល់បុគ្គលដែលបម្រើការងារនៅលើនាវា និងមានបញ្ជីឈ្មោះជានាវិក។

នាយនាវា សំដៅដល់នាវិកដែលគ្រប់គ្រងនិងបញ្ជានាវានៅលើនាវាសមុទ្រ។

iv

នាយបើកបរ សំដៅដល់នាយក្នុងផ្នែកបើកបរ ដែលមានឋានន្តរសក្តិបន្ទាប់ពីនាយនាវា និងជាអ្នកដឹកនាំបញ្ជានាវានៅពេលណាដែលនាយនាវាបាត់បង់សមត្ថភាពដឹកនាំបញ្ជា។

នាយបើកបរទី២ សំដៅដល់នាយក្នុងផ្នែកបើកបរ ដែលមានឋានន្តរសក្តិបន្ទាប់ពីនាយបើកបរ។

នាយបើកបរទី៣ សំដៅដល់នាយក្នុងផ្នែកបើកបរ ដែលមានឋានន្តរសក្តិបន្ទាប់ពីនាយបើកបរទី២។

នាយទទួលបន្ទុកបើកបរ សំដៅដល់នាយក្នុងផ្នែកបើកបរ ដែលមានឋានន្តរសក្តិទាបជាងគេបំផុត។

នាវិកជំនាញផ្នែកបើកបរ សំដៅដល់នាវិកជំនាញ ដែលមានគុណវុឌ្ឍិប្រចាំវេនបើកបរនាវា និងបម្រើការងារប្រចាំថ្ងៃក្នុងកម្រិតជំនួយការនៅលើដាន់នាវា។

នាវិកប្រចាំវេនបើកបរ សំដៅដល់នាវិកដែលមានគុណវុឌ្ឍិប្រចាំវេនបើកបរនាវា។

នាយយន្តការីនាវា សំដៅដល់នាយក្នុងផ្នែកម៉ាស៊ីនដែលមានឋានន្តរសក្តិខ្ពស់បំផុត ហើយដែលទទួលខុសត្រូវលើមេកានិកស្លាបចក្រ ប្រតិបត្តិការ និងថែទាំថបនាការមេកានិក និងអគ្គិសនីនាវា។

នាយយន្តការីទី២ សំដៅដល់នាយក្នុងផ្នែកម៉ាស៊ីនដែលមានឋានន្តរសក្តិបន្ទាប់ពីនាយយន្តការី និងជាអ្នកទទួលខុសត្រូវសម្រាប់មេកានិកស្លាបចក្រ ប្រតិបត្តិការ និងថែទាំថបនាការមេកានិក និងអគ្គិសនីនាវា នៅពេលដែលនាយយន្តការីនាវាបាត់បង់សមត្ថភាព។

នាយយន្តការីទី៣ សំដៅដល់នាយក្នុងផ្នែកម៉ាស៊ីនដែលមានឋានន្តរសក្តិបន្ទាប់ពីនាយយន្តការីទី២។

នាយទទួលបន្ទុកម៉ាស៊ីន សំដៅដល់នាយក្នុងផ្នែកម៉ាស៊ីនដែលមានឋានន្តរសក្តិទាបជាងគេបំផុត។

នាយអគ្គិសនីនាវា សំដៅដល់នាយក្នុងផ្នែកម៉ាស៊ីនដែលទទួលខុសត្រូវ សម្រាប់ប្រតិបត្តិការ និងថែទាំថបនាការអគ្គិសនីនាវា។

នាវិកជំនាញផ្នែកម៉ាស៊ីន សំដៅដល់នាវិកជំនាញ ដែលមានគុណវុឌ្ឍិប្រចាំវេនប្រតិបត្តិការម៉ាស៊ីននិងបម្រើការងារប្រចាំថ្ងៃជាជំនួយការនៅក្នុងបន្ទប់ម៉ាស៊ីន។

នាវិកប្រចាំវេនម៉ាស៊ីន សំដៅដល់នាវិកដែលមានគុណវុឌ្ឍិប្រចាំវេនប្រតិបត្តិការម៉ាស៊ីន។

នាវិកជំនាញផ្នែកអគ្គិសនី សំដៅដល់នាវិកជំនាញ ដែលមានគុណវុឌ្ឍិជាជំនួយការសម្រាប់ប្រតិបត្តិការនិងថែទាំថបនាការអគ្គិសនីនាវា។

នាយវិទ្យុទាក់ទង សំដៅដល់នាយក្នុងផ្នែកបើកបរដែលមានគុណវុឌ្ឍិប្រតិបត្តិការ និងថែទាំថបនាការប្រព័ន្ធវិទ្យុនៅលើនាវាសម្រាប់ការទំនាក់ទំនង ការផ្តល់និងទទួលព័ត៌មាន និងការផ្តល់និងទទួលសញ្ញាគ្រោះអាសន្ន។

នាវូបករណ៍ឬឧបករណ៍ សំដៅដល់សម្ភារៈបច្ចេកទេសដែលប្រើប្រាស់នៅលើនាវា។

បរិបាលនាវា សំដៅដល់នាវិកដែលមានគុណវុឌ្ឍិបញ្ជានៅលើនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេសមានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកជាបរិបាលនាវា។

បច្ចេកលក្ខណៈ សំដៅដល់លក្ខណៈពិសេសរបស់មនុស្ស វត្ថុ ឬទីតាំងដែលគេបានប្រើសម្រាប់កំណត់អត្តសញ្ញាណមនុស្ស វត្ថុ ឬទីតាំងនោះ។

ប្រឡាយនាវាចរណ៍ សំដៅដល់គន្លងនាវាចរណ៍ ដែលមានទទឹងតូចចង្អៀត មានជម្រៅទឹកគ្រប់គ្រាន់ និងមានផ្លាកសញ្ញាជំនួយនាវាចរណ៍ ដើម្បីធានាសុវត្ថិភាពនាវាចរណ៍។

ប្រតិបត្តិករកំពង់ផែ សំដៅដល់នីតិបុគ្គលឬរូបវន្តបុគ្គល ដែលផ្តល់សេវាកម្មកំពង់ផែដល់អ្នកប្រើប្រាស់ សេវាកំពង់ផែ មានជាអាទិ៍សេវាចូលចតនាវា ផ្ទេរ ផ្ទុកទំនិញពីនាវានិងអ្នកដំណើរ រក្សាទំនិញនិងសេវាផ្សេងទៀតដែលពាក់ព័ន្ធនឹងទំនិញនិងអ្នកដំណើរ។

v

ប្រតិបត្តិករនៃឋបនការនុយក្លេអ៊ែលើនាវា សំដៅដល់បុគ្គលដែលអាជ្ញាធរមានសមត្ថកិច្ចបានកំណត់ ឬទទួលស្គាល់ឱ្យធ្វើជាប្រតិបត្តិករនៃឋបនការលើនាវានោះ។

ផ្លូវទឹក សំដៅដល់ផ្លូវទឹកក្នុងប្រទេស ដែលរួមមានទន្លេ បឹង ស្ទឹង ព្រែក និងផ្លូវសមុទ្រដែលរួមមាន ឈូងសមុទ្រ ឆកសមុទ្រ និងព្រែកជាប់សមុទ្រ ហើយដែលអាចបម្រើដល់នាវាចរណ៍។

ផ្លូវនាវាចរណ៍ សំដៅដល់ផ្នែកស្ថិតនៅក្នុងផ្លូវទឹកសម្រាប់ធ្វើនាវាចរណ៍តាមគោលបំណងផ្សេងៗ គ្រប់រដូវកាល។

ផែនការអភិវឌ្ឍន៍កំពង់ផែ សំដៅដល់ផែនការសាងសង់កំពង់ផែថ្មី ដែលមានទំនាក់ទំនងផ្សារភ្ជាប់ នឹងការអភិវឌ្ឍសេដ្ឋកិច្ចជាតិនិងប្រយោជន៍សាធារណៈ ឬការពង្រឹងបន្ថែមលើហេដ្ឋារចនាសម្ព័ន្ធកំពង់ផែ ដែលកំពុងធ្វើប្រតិបត្តិការដោយផ្អែកលើកំណើនចរាចរណ៍ទំនិញឬអ្នកដំណើរ។

ព្រែកជីក សំដៅដល់ប្រឡាយនាវាចរណ៍សិប្បនិម្មិត ដែលត្រូវអភិវឌ្ឍនៅក្រៅផ្លូវទឹកសម្រាប់តភ្ជាប់ ផ្លូវនាវាចរណ៍។

ព្យសនកម្ម សំដៅដល់ការបាត់បង់ឬខូចខាតទ្រព្យសម្បត្តិ ការរងរបួសឬការបាត់បង់ជីវិត ដែលតម្រូវ ឱ្យមានសំណង។

ភិនភាគនាវា សំដៅដល់ចំណុចពិសេសសម្រាប់សម្គាល់នាវា រួមមានលេខសម្គាល់នាវានិង/ឬឈ្មោះ នាវា ប្រវែងបណ្ដោយ ប្រវែងទទឹង ប្រវែងជម្រៅស៊ីទឹក ប្រភេទនាវា ប្រភេទម៉ាស៊ីននាវា ពណ៌របស់នាវាជាអាទិ៍។

ភ្លើងបើកបរ សំដៅដល់ភ្លើងសញ្ញាដែលបំពាក់នៅលើនាវា ដើម្បីបង្ហាញអំពីស្ថានភាព និងការតម្រង់ទិស របស់នាវា រួមមានភ្លើងដងក្ដោង ភ្លើងចំហៀង ភ្លើងកន្សៃ ភ្លើងសណ្ដោង ភ្លើងបីរយហុកសិបដឺក្រេ និងភ្លើង ភ្លឹបភ្លែត។

ភ្លើងដងក្ដោង សំដៅដល់ភ្លើងពណ៌សដែលដាក់នៅលើអ័ក្សបណ្ដោយនាវាមុខក្រោយ ដែលបង្ហាញ ក្នុងធ្នូរង្វង់២២៥(ពីររយម្ភៃប្រាំ)ដឺក្រេ។

ភ្លើងចំហៀង សំដៅដល់ភ្លើងពណ៌ក្រហមនៅខាងឆ្វេង និងភ្លើងពណ៌បៃតងនៅខាងស្ដាំ បំភ្លឺក្នុងធ្នូ រង្វង់១១២,៥(មួយរយដប់ពីរក្បៀសប្រាំ)ដឺក្រេ ពីមុខត្រង់ទៅដល់ចំណុច២២,៥(ម្ភៃពីរក្បៀសប្រាំ)ដឺក្រេ ចំហៀងខាងក្រោយ។

ភ្លើងកន្សៃ សំដៅដល់ភ្លើងពណ៌សដាក់នៅជិតកន្សៃនាវាដែលអាចធ្វើទៅបាន ដែលបំភ្លឺនៅក្នុងធ្នូរង្វង់ ១៣៥(មួយរយសាមសិបប្រាំ)ដឺក្រេ។

ភ្លើងសណ្ដោង សំដៅដល់ភ្លើងពណ៌លឿងដាក់នៅជិតកន្សៃនាវាដែលអាចធ្វើទៅបាន ដែលបំភ្លឺនៅក្នុង ធ្នូរង្វង់១៣៥ដឺក្រេ។

ភ្លើងបីរយហុកសិបដឺក្រេ សំដៅដល់ភ្លើងបំភ្លឺជាប់ពេញធ្នូរង្វង់៣៦០(បីរយហុកសិប)ដឺក្រេក្នុងប្លង់ ដេក។

អនីយភាពនៃការប៉ះទង្គិច សំដៅដល់ភាពជឿជាក់នៃការប៉ះទង្គិចអាចកើតមានឡើង។

ឥវ៉ាន់ សំដៅដល់វត្ថុឬរថយន្តរបស់អ្នកដំណើរ ដែលបានដឹកដោយអ្នកដឹកជញ្ជូនស្របតាមកិច្ចសន្យា ដឹកជញ្ជូនអ្នកដំណើរ។

ឥវ៉ាន់ជាប់ខ្លួន សំដៅដល់វត្ថុដែលអ្នកដំណើរបានយកតាមខ្លួន ឬបានដាក់ផ្ញើទុកនៅលើនាវាក្នុង កន្លែងការពារណាមួយ ឬបានដាក់នៅក្នុងរថយន្តរបស់ខ្លួនតាមនាវា។

vi

ម្ចាស់នាវា សំដៅដល់បុគ្គលដែលមានសិទ្ធិជាកម្មសិទ្ធិលើនាវា។ ម្ចាស់នាវា រួមមានបុគ្គលដែលជាម្ចាស់លើនាវាផ្ទាល់ខ្លួន ឬក្រុមហ៊ុននាវា។

មេបញ្ជាការផែ សំដៅដល់មន្ត្រីមុខងារសាធារណៈដែលចាត់តាំងដោយក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីទទួលបន្ទុកជានាកាពារសុវត្ថិភាពដែនទឹកកំពង់ផែ គ្រប់គ្រងចលនានាវា តាមដាន ត្រួតពិនិត្យការពារការបំពុលទឹក ដាក់បទបញ្ជា និងផ្តល់ការឯកភាពលើសកម្មភាពផ្សេងៗក្នុងកំពង់ផែក្នុងក្របខ័ណ្ឌដែនសមត្ថកិច្ចរបស់ខ្លួន។ ជាទូទៅ មេបញ្ជាការផែមានតួនាទីគ្រប់គ្រងផ្លូវទឹកក្នុងកំពង់ផែ។

ម្ចាស់នាវាភាវៈកិច្ច សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលបានទទួលសិទ្ធិគ្រប់គ្រងនិងធ្វើប្រតិបត្តិការនាវាពីម្ចាស់នាវាស្របតាមកិច្ចសន្យាជួល។

មន្ត្រីត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស សំដៅដល់មន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ សំដៅដល់មន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួងសាធារណការនិងដឹកជញ្ជូន ដែលមានគុណវុឌ្ឍិធ្វើអធិការកិច្ចនាវាឆ្នេរសមុទ្រ នាវាផ្លូវទឹកក្នុងប្រទេស យានដ្ឋាននាវា ឋបនីយកណ្ឌផែ សំណង់សិល្បការ្យ អង្គបណ្តែតទឹក និងសកម្មភាពផ្សេងទៀត។

មន្ត្រីត្រួតពិនិត្យនាវាបរទេស សំដៅដល់មន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួងសាធារណការនិងដឹកជញ្ជូនដែលមានគុណវុឌ្ឍិត្រួតពិនិត្យនាវាបរទេស។

មន្ត្រីមានសមត្ថកិច្ច សំដៅដល់មន្ត្រីនៃក្រសួង ស្ថាប័ន ដែលមានភារកិច្ចត្រួតពិនិត្យនាវានៅតាមផ្លូវទឹកនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាអនុលោមតាមច្បាប់នេះនិងច្បាប់ផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា។

មូលបទច្បាស់លាស់ សំដៅដល់ភស្តុតាងដែលបង្ហាញថា នាវា នាវូបករណ៍ ឬក្រុមនាវិក មិនស្របតាមលក្ខខណ្ឌនៃអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ ឬនាយនាវាឬក្រុមនាវិក មិនស្គាល់ច្បាស់អំពីនីតិវិធីសំខាន់ៗនៅលើនាវា ដែលទាក់ទងនឹងសុវត្ថិភាពនាវា និងការបំពុលបរិស្ថាន។

យន្តហោះសមុទ្រ សំដៅដល់យន្តហោះ ដែលសាងសង់ឡើងសម្រាប់ចលនាចរណ៍ហោះឡើងនិងចុះលើផ្ទៃទឹក។

យានហោះលើទឹក សំដៅដល់យន្តហោះសមុទ្រ ដែលសាងសង់ឡើងសម្រាប់ហោះហើរក្នុងកម្ពស់ទាបដោយបំពាក់បច្ចេកវិទ្យាប្រើកម្លាំងរុញឡើងពីផ្ទៃទឹក គួបផ្សំជាមួយតួ និងផ្នែកផ្សេងទៀតរបស់តួមានរាងជាអាអេរ៉ូឌីណាមិក។

យន្តការីនាវា សំដៅដល់នាវិកដែលទទួលខុសត្រូវគ្រប់គ្រងនិងប្រតិបត្តិការម៉ាស៊ីននាវា។

លិខិតវិទ្ធាភទ សំដៅដល់លិខិតដែលធ្វើឡើងជាលាយលក្ខណ៍អក្សរនិងជាផ្លូវការ ក្នុងគោលបំណងដើម្បីប្រកាសបដិសេធដោយមានបង្ហាញអំណះអំណាងលើការទទួលខុសត្រូវពាក់ព័ន្ធចំពោះការបាត់បង់ ឬព្យសនកម្មណាមួយ។

ល្បឿនសុវត្ថិភាព សំដៅដល់ល្បឿនអតិបរិមាដែលអាចចាត់វិធានការបញ្ចៀសការប៉ះទង្គិចក្នុងថិរវេលានិងចម្ងាយដែលអាចបញ្ឈប់នាវាបាន។

វិស័យដឹកជញ្ជូនតាមផ្លូវទឹកនិងកំពង់ផែឬវិស័យដឹកជញ្ជូនតាមផ្លូវទឹក សំដៅដល់សកម្មភាពឬសេវាកម្មដែលពាក់ព័ន្ធនឹងនាវា នាវិក នាវាចរណ៍ ការដឹកជញ្ជូន ការផ្ទេរផ្ទុកទំនិញនិងអ្នកដំណើរ កំពង់ផែ ចំណតនាវា យានដ្ឋាននាវា ការកសាងនិងថែរក្សាការពារហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធជាអាទិ៍។

vii

វិញ្ញាបនបត្របច្ចេកទេស សំដៅដល់វិញ្ញាបនបត្រដែលតម្រូវឱ្យមានចំពោះនាវាធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិ អនុលោមតាមអនុសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងសុវត្ថិភាព សន្តិសុខ និងបរិស្ថាន ក្រោយការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា។

វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកបង្វិលេខ សំដៅដល់វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកនៃប្រទេសមួយ ដែលត្រូវបានទទួលស្គាល់ដោយប្រទេសមួយទៀត ស្ថិតក្រោមកិច្ចព្រមព្រៀងនៃប្រទេសទាំងពីរ ដើម្បីអាចឱ្យនាវិកនោះអាចបម្រើការងារលើនាវានៃប្រទេសម្ចាស់សញ្ជាតិមួយទៀតបាន។

វិទ្យុការីនាវា សំដៅដល់នាយក្នុងផ្នែកបើកបរដែលមានឋានន្តរសក្តិបន្ទាប់ពីនាយវិទ្យុទាក់ទង និងមានគុណវុឌ្ឍិសម្រាប់ប្រតិបត្តិការនិងថែទាំឋបនាការវិទ្យុទាក់ទងនៅលើនាវា។

សំណង់សិល្បការ្យផ្លូវទឹក សំដៅដល់ទំនប់ការពារច្រាំង កំពង់ផែ ទំនប់រលក សន្ទះផ្លូវនាវាចរណ៍ ស្ថានីយជម្រៅទឹកផ្លូវនាវាចរណ៍ ស្ថានីយកណ្តាល មជ្ឈមណ្ឌលសម្របសម្រួលនាវាចរណ៍ កំពង់ចម្លង យានដ្ឋាននាវា សញ្ញាជំនួយនាវាចរណ៍។

សំណង់សិល្បការ្យ សំដៅដល់សំណង់សិល្បការ្យទូទៅក្រៅពីសំណង់សិល្បការ្យផ្លូវទឹក រួមមាន ស្ពាន បង្គោលបញ្ជូនចរន្តអគ្គិសនី បំពង់ឬទុយោក្រោមបាតសមុទ្រឬទន្លេ ទ្វារទឹក ស្ថានីយជលសាស្ត្រ ជាអាទិ៍។

សញ្ញាជំនួយនាវាចរណ៍ សំដៅដល់គ្រឿងផ្តល់សញ្ញា ប្រព័ន្ធឬសេវាកម្មដែលបំពាក់នៅលើផ្លូវទឹកនិងធ្វើប្រតិបត្តិការដើម្បីបង្កើនសុវត្ថិភាពនិងប្រសិទ្ធភាពនាវាចរណ៍។

សំណងរួមលើការខាតបង់ សំដៅដល់សំណងដែលបណ្តាលមកពីការលះបង់ដោយចេតនានូវចំណែកនៃនាវាឬទំនិញលើនាវា ដើម្បីចៀសវាងការបាត់បង់នាវាទាំងស្រុង ហើយដែលចំណែកនោះ ត្រូវបែងចែកតាមគ្រប់ភាគីដែលពាក់ព័ន្ធនឹងផលប្រយោជន៍ក្នុងដំណើរចរណ៍នោះ។

សញ្ញាបើកបរ សំដៅដល់រូបសញ្ញានៅលើនាវា សម្រាប់លើកបង្ហាញអំពីប្រភេទនិងសកម្មភាពរបស់នាវា រួមមាន ស្ទៃ កោន កោនទល់កំពូល កោនទល់បាត និងស៊ីឡាំង។

សញ្ញាសំឡេង សំដៅដល់សំឡេងដែលបន្លឺដោយឧបករណ៍ផ្តល់សញ្ញាសំឡេងរបស់នាវាមួយទៅនាវាផ្សេងទៀត សម្រាប់បញ្ជាក់អំពីចេតនានៃការបើកបររបស់នាវានោះ។

សញ្ញាភ្លើង សំដៅដល់សញ្ញាភ្លើងដែលនាវាមួយផ្តល់ទៅនាវាផ្សេងទៀត សម្រាប់បញ្ជាក់អំពីចេតនារបស់នាវានោះ។

សញ្ញាគ្រោះអាសន្ន សំដៅដល់សញ្ញាដែលនាវាកំពុងស្ថិតនៅក្នុងគ្រោះអាសន្ន ផ្តល់ជាសញ្ញាផ្សេងៗ ដែលបានកំណត់នៅក្នុងច្បាប់អន្តរជាតិ ដើម្បីស្វែងរកជំនួយសង្គ្រោះ។ សញ្ញាទាំងនោះ រួមមានសញ្ញាភ្លើង សញ្ញាសំឡេង សញ្ញារូបភាពផ្សេងៗ សញ្ញាគ្រោះអាសន្នតាមប្រព័ន្ធអេឡិចត្រូនិក។

ហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក សំដៅដល់ផ្លូវទឹក សំណង់សិល្បការ្យផ្លូវទឹក និងប្រព័ន្ធដែលពាក់ព័ន្ធនឹងការធ្វើនាវាចរណ៍។

អាជ្ញាធរមានសមត្ថកិច្ចនៅជិតបំផុត សំដៅដល់អង្គភាពនៃក្រសួង ស្ថាប័ន ឬមជ្ឈមណ្ឌលទំនាក់ទំនងផ្តល់និងទទួលព័ត៌មាន ឬកំពង់ផែ ឬស្ថានីយទំនាក់ទំនងរវាងនាវា និងមជ្ឈមណ្ឌលនៅលើគោក ដែលស្ថិតនៅជិតបំផុត។

អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ សំដៅដល់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែនៃក្រសួងសាធារណការនិងដឹកជញ្ជូន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

អង្គភាពមានសមត្ថកិច្ចចុះបញ្ជីនាវា សំដៅដល់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ។

អង្គការចំណាត់ថ្នាក់នាវា សំដៅដល់អង្គការដែលបង្កើតឡើងដោយក្រុមម្ចាស់នាវាឬក្រុមសមាគមម្ចាស់នាវា ដើម្បីផ្តល់សេវាត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា និងផ្តល់វិញ្ញាបនបត្របច្ចេកទេសដែលពាក់ព័ន្ធអនុលោមតាមអនុសញ្ញាអន្តរជាតិ។

អង្គគ្រប់គ្រងកំពង់ផែ សំដៅដល់អង្គភាពសាធារណៈឬឯកជន ដែលទទួលបន្ទុកការងាររដ្ឋបាល ការគ្រប់គ្រង និងការអភិវឌ្ឍកំពង់ផែ និងក្នុងករណីខ្លះធ្វើប្រតិបត្តិការកំពង់ផែនិងអភិរក្សទីលានបរិវេណដីគោកក៏ដូចជាដែនទឹកកំពង់ផែ។

អង្គបណ្តែតទឹក សំដៅដល់សំណង់បណ្តែតទឹកដែលប្រើសម្រាប់គោលបំណងផ្សេងៗ រួមមាន ចំណតនាវា ស្តុកនិងផ្ទេរផ្ទុកទំនិញ សាងសង់ឬជួសជុលនាវា ស្ទូច ខួង បូមស្តារ លំនៅឋាន ភោជនីយដ្ឋាន កម្សាន្តវារីវប្បកម្ម អាជីវកម្មជាអាទិ៍។

អ្នកដំណើរ សំដៅដល់បុគ្គលទាំងឡាយដែលជិះនៅលើនាវាក្រៅពីនាវិក ហើយមានឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកដំណើរ។

អ្នកដឹកជញ្ជូន សំដៅដល់បុគ្គលឬតំណាងរបស់អ្នកដឹកជញ្ជូនដែលបានធ្វើកិច្ចសន្យាដឹកជញ្ជូនទំនិញ ឬកិច្ចសន្យាដឹកជញ្ជូនអ្នកដំណើរ ទោះបីជាអនុវត្តដោយខ្លួនឯង ឬប្រគល់ការអនុវត្តកិច្ចសន្យានោះទៅអ្នកដឹកជញ្ជូនបន្ត។

អ្នកដឹកជញ្ជូនបន្ត សំដៅដល់បុគ្គលផ្សេងទៀតក្រៅពីអ្នកដឹកជញ្ជូនឬតំណាងអ្នកដឹកជញ្ជូន ដែលអនុវត្តកិច្ចសន្យាដឹកជញ្ជូនទំនិញឬកិច្ចសន្យាដឹកជញ្ជូនអ្នកដំណើរ ទោះបីជាកិច្ចសន្យានោះ បានត្រូវប្រគល់ទាំងស្រុង ឬដោយផ្នែកណាមួយ ដោយអ្នកដឹកជញ្ជូនឬតំណាងអ្នកដឹកជញ្ជូន។

អ្នកលួចរត់តាមនាវា សំដៅដល់បុគ្គលដែលនៅកំពង់ផែណាមួយឬទីកន្លែងជិតកំពង់ផែនោះ លាក់ខ្លួននៅក្នុងនាវា ដោយគ្មានការយល់ព្រមពីម្ចាស់នាវា ឬនាយនាវា ឬអ្នកទទួលបន្ទុកនាវា ឬបុគ្គលដែលឡើងលើនាវា ក្រោយពេលដែលនាវាបានចាកចេញពីកំពង់ផែឬទីកន្លែងជិតកំពង់ផែនោះ។

អ្នកដើរសមុទ្រដ៏ល្អ សំដៅដល់នាវិកដែលមានជំនាញ ចំណេះដឹង និងបទពិសោធក្នុងការគ្រប់គ្រងពេលវេលានិងអនុវត្តកិច្ចការសង្កេតដោយផ្ចិតផ្ចង់ក្នុងប្រតិបត្តិការនាវា។

អ្នកបើកបរនាវា សំដៅដល់អ្នកដែលធ្វើប្រតិបត្តិការបើកបរនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេស ដោយការបញ្ជាចង្កូតនិងម៉ាស៊ីនតែម្នាក់ឯង។

ឯកសិទ្ធិ សំដៅដល់សិទ្ធិដែលនាវិកត្រូវទទួលការសងពីម្ចាស់នាវាឬម្ចាស់នាវាភាគវេទកិច្ចលើកម្មវត្ថុ ឬសកម្មភាពដែលនាវិកបានបំពេញក្នុងអត្ថប្រយោជន៍របស់ម្ចាស់នាវាឬម្ចាស់នាវាភាគវេទកិច្ច។

ឯកតាតម្លៃSDR សំដៅដល់ឯកតាសម្រាប់គិតតម្លៃរូបិយបណ្ណដែលកំណត់ដោយអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ix

ព្រះរាជក្រម

នស/រកម/០៨២៤/០០៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១២៣/០២០ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីឯកភាវូបនីយកម្មនៃវិធានមួយចំនួនពាក់ព័ន្ធនឹងការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាស ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤ នាសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីឯកភាពូបនីយកម្ម នៃវិធានមួយចំនួនពាក់ព័ន្ធនឹងការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាស

មាត្រា១ .-

អនុម័តយល់ព្រមលើអនុសញ្ញាស្តីពីឯកភាវូបនីយកម្មនៃវិធានមួយចំនួនពាក់ព័ន្ធនឹងការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាស ធ្វើនៅទីក្រុងម៉ុងរ៉េអាល់នៃប្រទេសកាណាដា នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

មាត្រា២ .-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ។

មាត្រា៣ .-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃអង្គារ ១៣រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២០ ខែសីហា ឆ្នាំ២០២៤

នស.រកម.០៨២៤.០១៩

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល

ម៉ៅ ហាវណ្ណាល់

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

២/២

អនុសញ្ញា

ស្តីពី

ឯកភាវូបនីយកម្មនៃវិធានមួយចំនួន

ពាក់ព័ន្ធនឹងការដឹកជញ្ជូនអន្តរជាតិ

តាមផ្លូវអាកាស

អនុសញ្ញា
ស្តីពី
ឯកភាពកម្មនីយកម្មនៃវិធានមួយចំនួន
ពាក់ព័ន្ធនឹងការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាស

បណ្តារដ្ឋភាគីនៃអនុសញ្ញានេះ៖

ដោយទទួលស្គាល់ ការរួមចំណែកយ៉ាងសំខាន់ នៃអនុសញ្ញាស្តីពីឯកភាវូបនីយកម្មនៃវិធានមួយចំនួនពាក់ព័ន្ធនឹងការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាស ចុះហត្ថលេខានៅទីក្រុងវ៉ាសូវី កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ១៩២៩ ដែលតទៅហៅថា "**អនុសញ្ញាវ៉ាសូវី**" និងលិខិតូបករណ៍ពាក់ព័ន្ធ ផ្សេងៗ ដើម្បីសុខដុមនីយកម្មនៃច្បាប់អាកាសចរណ៍អន្តរជាតិ ឯកជន

ដោយទទួលស្គាល់ តម្រូវការក្នុងការធ្វើទំនើបកម្មនិងការរួមបញ្ចូលអនុសញ្ញាវ៉ាសូវី ព្រមទាំងលិខិតូបករណ៍ពាក់ព័ន្ធផ្សេងៗ

ដោយទទួលស្គាល់ សារៈសំខាន់នៃការធានាការពារផលប្រយោជន៍អ្នកប្រើប្រាស់ក្នុងការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាស និងតម្រូវការផ្តល់សំណងដោយសមធម៌ ផ្អែកលើគោលការណ៍បង្គិទាន

ដោយបញ្ជាក់អះអាងឡើងវិញ នូវបំណងប្រាថ្នាក្នុងការអភិវឌ្ឍតាមលំដាប់លំដោយនៃប្រតិបត្តិការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាស និងដំណើរការដោយរលូននៃអ្នកដំណើរ អីវ៉ាន់ និងទំនិញ ដោយអនុលោមតាមគោលការណ៍និងគោលបំណងនៃអនុសញ្ញាស្តីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដែលបានធ្វើនៅទីក្រុងស៊ីកាហ្គោ កាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៤៤

ដោយជឿជាក់ថា សកម្មភាពរួមរបស់បណ្តារដ្ឋភាគីក្នុងការធ្វើសុខដុមនីយកម្ម និងចងក្រងបញ្ញត្តិមួយចំនួនគ្រប់គ្រងការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាសបន្ថែមទៀត តាមរយៈអនុសញ្ញាថ្មីមួយ គឺជាមធ្យោបាយ សមស្របបំផុត ដើម្បីសម្រេចឱ្យបាននូវផលប្រយោជន៍ដែលមានតុល្យភាពប្រកបដោយសមធម៌

បានព្រមព្រៀង ដូចតទៅ៖

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ ._ វិសាលភាពនៃការអនុវត្ត

១- អនុសញ្ញានេះអនុវត្តចំពោះការដឹកជញ្ជូនបុគ្គល អីវ៉ាន់ ឬទំនិញ តាមផ្លូវអាកាសអន្តរជាតិទាំងអស់ដែលប្រតិបត្តិដោយអាកាសយាន ដើម្បីទទួលបាននូវផលប្រយោជន៍។ អនុសញ្ញានេះក៏អនុវត្តដោយស្មើភាពផងដែរ ចំពោះការដឹកជញ្ជូនតាមអាកាសយានដោយមិនយកកម្រៃ ដែលប្រតិបត្តិដោយសហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសមួយ។

១/២៣

២- តាមគោលបំណងនៃអនុសញ្ញានេះ ការប្រើប្រាស់ពាក្យ "ការដឹកជញ្ជូនអន្តរជាតិ" សំដៅដល់ការដឹកជញ្ជូន ដែលយោងតាមការព្រមព្រៀងរបស់គូភាគី មានចំណុចចេញដំណើរនិងចំណុចគោលដៅ ទោះមានឬមិនមានការ ឈប់សំចត ឬការផ្ទេរទំនិញក៏ដោយ ស្ថិតនៅក្នុងទឹកដីនៃរដ្ឋភាគីពីរ ឬនៅក្នុងទឹកដីនៃរដ្ឋភាគីតែមួយ ប្រសិនបើ កន្លែងឈប់សំចតត្រូវបានគ្រោងទុកនៅក្នុងទឹកដីនៃរដ្ឋភាគីមួយទៀត ទោះជារដ្ឋភាគីនោះពុំមែនជារដ្ឋភាគីក៏ដោយ។ ការដឹកជញ្ជូនរវាងពីរចំណុច នៅក្នុងទឹកដីនៃរដ្ឋភាគីតែមួយ ដោយពុំមានការឈប់សំចតនៅក្នុងទឹកដីនៃរដ្ឋភាគី មួយផ្សេងទៀត គឺពុំមែនជាការដឹកជញ្ជូនអន្តរជាតិទេ តាមគោលបំណងនៃអនុសញ្ញានេះ។

៣- តាមគោលបំណងនៃអនុសញ្ញានេះ ការដឹកជញ្ជូនដែលប្រតិបត្តិដោយក្រុមហ៊ុនដឹកជញ្ជូនច្រើនបន្តបន្ទាប់គ្នា ត្រូវចាត់ទុកថា ជាការដឹកជញ្ជូនតែមួយ ប្រសិនបើគូភាគីសន្មតថា ជាប្រតិបត្តិការតែមួយ ទោះជាមានការព្រមព្រៀងគ្នា ក្រោមទម្រង់ជាកិច្ចសន្យាទោលឬកិច្ចសន្យាច្រើនក៏ដោយ ហើយការដឹកជញ្ជូននេះមិនបាត់បង់ចរិតលក្ខណៈអន្តរជាតិ ដោយគ្រាន់តែកិច្ចសន្យាមួយឬកិច្ចសន្យាច្រើន ត្រូវបានអនុវត្តទាំងស្រុងនៅក្នុងទឹកដីនៃរដ្ឋភាគីដូចគ្នាមួយ។

៤- អនុសញ្ញានេះក៏អនុវត្តផងដែរ ចំពោះការដឹកជញ្ជូនដែលមានចែងក្នុងជំពូកទី៥ អាស្រ័យតាមខ្លឹមសារ ដែលមានចែងក្នុងជំពូកនោះ។

មាត្រា២ .. ការដឹកជញ្ជូនដែលធ្វើឡើងដោយរដ្ឋភាគីនិងការដឹកជញ្ជូនបញ្ញើប្រៃសណីយ៍

១- អនុសញ្ញានេះអនុវត្តចំពោះការដឹកជញ្ជូន ដែលធ្វើឡើងដោយរដ្ឋភាគីឬដោយអង្គភាពសាធារណៈ ស្របច្បាប់ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា១។

២- ក្នុងការដឹកជញ្ជូនបញ្ញើប្រៃសណីយ៍ ក្រុមហ៊ុនដឹកជញ្ជូនទទួលខុសត្រូវតែចំពោះរដ្ឋបាលប្រៃសណីយ៍ពាក់ព័ន្ធ ប៉ុណ្ណោះ ដោយអនុលោមតាមវិធាននានា ដែលអនុវត្តលើទំនាក់ទំនងរវាងក្រុមហ៊ុនដឹកជញ្ជូន និងរដ្ឋបាលប្រៃសណីយ៍។

៣- លើកលែងតែមានចែងក្នុងចំណុចទី២នៃមាត្រានេះ បទប្បញ្ញត្តិនៃអនុសញ្ញានេះមិនត្រូវអនុវត្តចំពោះ ការដឹកជញ្ជូនបញ្ញើប្រៃសណីយ៍ឡើយ។

ជំពូកទី២
ឯកសារនិងភារកិច្ចរបស់គូភាគីពាក់ព័ន្ធការដឹកជញ្ជូនអ្នកដំណើរអីវ៉ាន់និងទំនិញ
មាត្រា៣ .. អ្នកដំណើរនិងអីវ៉ាន់

១- ក្នុងការដឹកជញ្ជូនអ្នកដំណើរ ឯកសារដឹកជញ្ជូនឯកត្តជនឬសមូហភាពនឹងត្រូវផ្តល់ជូនដែលក្នុងនោះ ត្រូវមាន៖

(ក) ការបញ្ជាក់ចំណុចចេញដំណើរនិងចំណុចគោលដៅ។

(ខ) ការបញ្ជាក់ចំណុចឈប់សំចតយ៉ាងហោចណាស់មួយកន្លែង ប្រសិនបើចំណុចចេញដំណើរនិង ចំណុចគោលដៅស្ថិតនៅក្នុងទឹកដីនៃរដ្ឋភាគីតែមួយ ហើយមានចំណុចឈប់សំចតដែលបាន ព្រមព្រៀងមួយឬច្រើននៅក្នុងទឹកដីនៃរដ្ឋភាគីមួយផ្សេងទៀត។

២- ការប្រើមធ្យោបាយផ្សេងទៀត ដែលរក្សាព័ត៌មានដូចបានបញ្ជាក់ក្នុងចំណុចទី១ អាចជំនួសដោយការផ្តល់ឯកសារ ដូចមានចែងក្នុងចំណុចនោះ។ ប្រសិនបើមធ្យោបាយផ្សេងទៀតត្រូវបានប្រើប្រាស់ ក្រុមហ៊ុនដឹកជញ្ជូនត្រូវផ្តល់ជូនអ្នកធ្វើដំណើរនូវឯកសារជាលាយលក្ខណ៍អក្សរមួយ ដែលរក្សាព័ត៌មានដូចមានចែងក្នុងនោះ។

៣- ក្រុមហ៊ុនដឹកជញ្ជូនត្រូវផ្តល់សលាកបត្រសម្គាល់អីវ៉ាន់ជូនអ្នកដំណើរ សម្រាប់កញ្ចប់អីវ៉ាន់នីមួយៗដែលបានផ្ញើ។

៤- នៅពេលដែលអនុសញ្ញានេះត្រូវអនុវត្ត អ្នកដំណើរត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីការគ្រប់គ្រង និងអាចដាក់កម្រិតការទទួលខុសត្រូវរបស់ក្រុមហ៊ុនដឹកជញ្ជូនទាក់ទងនឹងមរណភាពឬការរងរបួស ក៏ដូចជាការបំផ្លាញ ឬការបាត់បង់ ឬការខូចខាតអីវ៉ាន់ និងការយឺតយ៉ាវ។

៥- ការមិនអនុលោមតាមបទប្បញ្ញត្តិនៃចំណុចខាងលើ មិនប៉ះពាល់ដល់អត្ថិភាពឬសុពលភាពនៃកិច្ចសន្យាដឹកជញ្ជូន ដែលមិនស្ថិតនៅក្រោមវិធាននៃអនុសញ្ញានេះ រួមទាំងវិធានទាំងឡាយពាក់ព័ន្ធទៅនឹងការដាក់កម្រិតការទទួលខុសត្រូវឡើយ។

មាត្រា៤ .- ទំនិញ

១- ក្នុងករណីដឹកជញ្ជូនទំនិញ អញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាសត្រូវផ្តល់ជូន។

២- ការប្រើប្រាស់មធ្យោបាយដទៃទៀតដែលរក្សាទុកកំណត់ត្រានៃការដឹកជញ្ជូន គឺអាចជំនួសការផ្តល់អញ្ញត្តិបណ្ណដឹកជញ្ជូន។ ប្រសិនបើមធ្យោបាយនេះត្រូវបានប្រើប្រាស់ ក្រុមហ៊ុនដឹកជញ្ជូនត្រូវផ្តល់ជូនអ្នកផ្ញើនូវបង្កាន់ដៃទំនិញ ដែលមានអត្តសញ្ញាណទំនិញនិងព័ត៌មានក្នុងកំណត់ត្រាដែលបានរក្សាទុកតាមមធ្យោបាយទាំងនេះ ប្រសិនបើមានការស្នើសុំពីអ្នកផ្ញើ។

មាត្រា៥ .- មាតិកានៃអញ្ញត្តិបណ្ណដឹកជញ្ជូនទំនិញតាមផ្លូវអាកាសឬបង្កាន់ដៃទំនិញ

អញ្ញត្តិបណ្ណដឹកជញ្ជូនទំនិញតាមផ្លូវអាកាសឬបង្កាន់ដៃទំនិញ ត្រូវមាន៖

(ក) ការបញ្ជាក់ចំណុចចេញដំណើរនិងចំណុចគោលដៅ។

(ខ) ការបញ្ជាក់ចំណុចឈប់សំចតយ៉ាងហោចណាស់មួយកន្លែង ប្រសិនបើចំណុចចេញដំណើរនិងចំណុចគោលដៅស្ថិតនៅក្នុងទឹកដីនៃរដ្ឋភាគីតែមួយ ហើយមានចំណុចឈប់សំចតដែលបានព្រមព្រៀងមួយឬច្រើននៅក្នុងទឹកដីនៃរដ្ឋភាគីមួយផ្សេងទៀត។

(គ) ការបញ្ជាក់ទម្ងន់នៃបញ្ញើ។

មាត្រា៦ .- ឯកសារពាក់ព័ន្ធនៅនឹងលក្ខណៈទំនិញ

អ្នកផ្ញើអាចតម្រូវឱ្យផ្តល់ឯកសារបញ្ជាក់លក្ខណៈនៃទំនិញ ដើម្បីបំពេញបែបបទគយ នគរបាល និងអាជ្ញាធរសាធារណៈប្រហាក់ប្រហែល ក្នុងករណីចាំបាច់។ បទប្បញ្ញត្តិនេះមិនបង្កើតបន្ទុក កាតព្វកិច្ចឬការទទួលខុសត្រូវដល់ក្រុមហ៊ុនដឹកជញ្ជូនទេ ក្នុងការបំពេញបែបបទទាំងនេះ។

៣/២៣

មាត្រា៧ .- ការបរិយាយអញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាស

១- អញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាស ត្រូវរៀបចំដោយអ្នកផ្ញើ ជាបីសន្លឹកច្បាប់ដើម។

២- សន្លឹកទីមួយត្រូវបានបោះសម្គាល់ "សម្រាប់ក្រុមហ៊ុនដឹកជញ្ជូន" ហើយចុះហត្ថលេខាដោយអ្នកផ្ញើ។ សន្លឹកទីពីរត្រូវបានបោះសម្គាល់ "សម្រាប់អ្នកទទួល" ហើយចុះហត្ថលេខាដោយអ្នកផ្ញើនិងក្រុមហ៊ុនដឹកជញ្ជូន។ សន្លឹកទីបីចុះហត្ថលេខាដោយក្រុមហ៊ុនដឹកជញ្ជូន ដែលត្រូវប្រគល់ជូនអ្នកផ្ញើ បន្ទាប់ពីបានទទួលទំនិញ។

៣- ហត្ថលេខារបស់ក្រុមហ៊ុនដឹកជញ្ជូននិងហត្ថលេខារបស់អ្នកផ្ញើ អាចត្រូវបានធ្វើឡើង ឬបោះត្រា។

៤- ប្រសិនបើមានសំណើរបស់អ្នកផ្ញើ ក្រុមហ៊ុនដឹកជញ្ជូនរៀបចំអញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាស ដោយសន្មតថាបានរៀបចំឡើងក្នុងនាមអ្នកផ្ញើ លើកលែងតែមានភស្តុតាងបញ្ជាក់ផ្ទុយពីនេះ។

មាត្រា៨ .- ឯកសារទំនិញច្រើនកញ្ចប់

នៅពេលមានទំនិញលើសពីមួយកញ្ចប់៖

(ក) ក្រុមហ៊ុនដឹកជញ្ជូនទំនិញមានសិទ្ធិតម្រូវឱ្យអ្នកផ្ញើ រៀបចំអញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាសដាច់ដោយឡែកពីគ្នា។

(ខ) អ្នកផ្ញើមានសិទ្ធិតម្រូវឱ្យក្រុមហ៊ុនដឹកជញ្ជូន ផ្តល់បង្កាន់ដៃទំនិញដាច់ដោយឡែកពីគ្នា នៅពេលដែលមធ្យោបាយផ្សេងទៀត ដូចមានចែងក្នុងចំណុចទី២នៃមាត្រា៤ខាងលើ ត្រូវបានប្រើប្រាស់។

មាត្រា៩ .- ការមិនអនុលោមតាមលក្ខខណ្ឌតម្រូវឯកសារ

ការមិនអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា៤ដល់មាត្រា៨ មិនប៉ះពាល់ដល់អត្ថិភាពឬសុពលភាពកិច្ចសន្យាដឹកជញ្ជូន ដែលមិនស្ថិតនៅក្រោមវិធាននៃអនុសញ្ញានេះ រួមទាំងវិធានទាំងឡាយដែលពាក់ព័ន្ធទៅនឹងការដាក់កម្រិតការទទួលខុសត្រូវឡើយ។

មាត្រា១០ .- ការទទួលខុសត្រូវចំពោះលក្ខណៈពិសេសនៃឯកសារ

១- អ្នកផ្ញើត្រូវទទួលខុសត្រូវចំពោះភាពត្រឹមត្រូវនូវលក្ខណៈពិសេសនិងព័ត៌មានទំនិញ ដែលបានកត់ត្រាចូលអញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាស ដោយអ្នកផ្ញើឬអ្នកតំណាង ឬក៏ផ្តល់ដោយអ្នកផ្ញើឬអ្នកតំណាងទៅឱ្យក្រុមហ៊ុនដឹកជញ្ជូន ដើម្បីកត់ត្រាចូលក្នុងបង្កាន់ដៃទំនិញ ឬក្នុងកំណត់ត្រា ដែលត្រូវរក្សាទុកដោយមធ្យោបាយផ្សេងទៀត ដូចមានចែងនៅក្នុងចំណុចទី២នៃមាត្រា៤។ បទប្បញ្ញត្តិខាងលើនេះក៏អនុវត្តដែរ នៅពេលបុគ្គលតំណាងអ្នកផ្ញើជាភ្នាក់ងាររបស់ក្រុមហ៊ុនដឹកជញ្ជូនផងដែរ។

២- អ្នកផ្ញើត្រូវទូទាត់សំណងជូនក្រុមហ៊ុនដឹកជញ្ជូន នូវរាល់ការខូចខាតទាំងឡាយណាដែលបានកើតឡើងចំពោះក្រុមហ៊ុនដឹកជញ្ជូន ឬបុគ្គលស្ថិតក្រោមបន្ទុកក្រុមហ៊ុនដឹកជញ្ជូន ដោយសារតែភាពមិនប្រក្រតី ភាពមិនត្រឹមត្រូវ ឬភាពមិនពេញលេញនៃលក្ខណៈពិសេសនិងព័ត៌មានទំនិញផ្តល់ដោយអ្នកផ្ញើឬតំណាង។

៣- យោងតាមបទប្បញ្ញត្តិនៃចំណុចទី១និងចំណុចទី២នៃមាត្រានេះ ក្រុមហ៊ុនដឹកជញ្ជូនត្រូវទូទាត់សំណងជូនអ្នកផ្ញើនូវរាល់ការខូចខាតទាំងឡាយណា ដែលបានកើតឡើងចំពោះអ្នកផ្ញើឬបុគ្គលស្ថិតក្រោមបន្ទុកអ្នកផ្ញើ ដោយសារតែភាពមិនប្រក្រតី ភាពមិនត្រឹមត្រូវ ឬភាពមិនពេញលេញនៃលក្ខណៈពិសេសនិងព័ត៌មានទំនិញ ដែលក្រុមហ៊ុនដឹកជញ្ជូន ឬតំណាង កត់ត្រាចូលក្នុងបង្កាន់ដៃទំនិញ ឬកំណត់ត្រារក្សាទុកតាមមធ្យោបាយផ្សេងទៀត ដូចមានចែងក្នុងចំណុចទី២នៃមាត្រា៤។

មាត្រា១១ .- តម្លៃជាភស្តុតាងនៃឯកសារ

១- អញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាសឬបង្កាន់ដៃទំនិញ គឺជាភស្តុតាងដំបូងលើការព្រមព្រៀងនៃកិច្ចសន្យាលើការទទួលយកទំនិញនិងលើលក្ខខណ្ឌដឹកជញ្ជូន ដែលមានចែងនៅក្នុងនោះ។

២- ការប្រកាសព័ត៌មានក្នុងអញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាសឬបង្កាន់ដៃទំនិញពាក់ព័ន្ធនឹងទម្ងន់ វិមាត្រ និងការវេចខ្ចប់នៃទំនិញ ក៏ដូចជាចំនួននៃកញ្ចប់ទំនិញ គឺជាភស្តុតាងដំបូងនៃការប្រកាសភាពពិតប្រាកដ។ ការប្រកាសព័ត៌មានពាក់ព័ន្ធនឹងបរិមាណ ទំហំ និងលក្ខខណ្ឌនៃទំនិញ មិនអាចចាត់ទុកជាភស្តុតាង តវ៉ាជាមួយក្រុមហ៊ុនដឹកជញ្ជូនបានទេ ដរាបណាព័ត៌មានទាំងនេះចែងក្នុងអញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាសឬបង្កាន់ដៃទំនិញ ត្រូវបានបញ្ជាក់ដោយក្រុមហ៊ុនដឹកជញ្ជូន ក្រោមវត្តមានអ្នកផ្ញើឬយោងតាមលក្ខខណ្ឌជាក់ស្តែងនៃទំនិញ។

មាត្រា១២ .- សិទ្ធិរៀបចំចាត់ចែងទំនិញ

១- យោងតាមការទទួលខុសត្រូវរបស់ខ្លួនក្នុងការបំពេញកាតព្វកិច្ច ស្ថិតក្រោមកិច្ចសន្យាដឹកជញ្ជូន អ្នកផ្ញើមានសិទ្ធិរៀបចំចាត់ចែងទំនិញ ដូចជាយកទំនិញចេញពីអាកាសយានដ្ឋានចេញដំណើរ ឬអាកាសយានដ្ឋានគោលដៅ ឬក្នុងកំឡុងពេលឈប់សំចត ឬក៏ស្នើសុំឱ្យបញ្ជូនទំនិញទៅកាន់ចំណុចគោលដៅ ឬក៏ក្នុងពេលដឹកជញ្ជូនឱ្យទៅបុគ្គលណាម្នាក់មិនមែនជាអ្នកទទួលដែលបានកំណត់ពីដំបូង ឬក៏ស្នើសុំឱ្យយកទំនិញមកអាកាសយានដ្ឋានចេញដំណើរវិញ។ អ្នកផ្ញើមិនត្រូវអនុវត្តសិទ្ធិរៀបចំចាត់ចែងទំនិញ ដែលបង្កឱ្យប៉ះពាល់ដល់ក្រុមហ៊ុនដឹកជញ្ជូនឬអ្នកផ្ញើដទៃផ្សេងទៀត ហើយត្រូវទូទាត់សងចំណាយផ្សេងៗដែលកើតឡើងដោយការអនុវត្តសិទ្ធិនេះ។

២- ប្រសិនបើមិនអាចអនុវត្តតាមការណែនាំរបស់អ្នកផ្ញើ ក្រុមហ៊ុនដឹកជញ្ជូនត្រូវជូនដំណឹងភ្លាមទៅអ្នកផ្ញើ។

៣- ប្រសិនបើក្រុមហ៊ុនដឹកជញ្ជូនអនុវត្តតាមការណែនាំរបស់អ្នកផ្ញើលើការចាត់ចែងទំនិញ ដោយពុំតម្រូវឱ្យមានការផ្តល់សន្លឹកអញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាសឬបង្កាន់ដៃទំនិញទៅអ្នកផ្ញើ ក្រុមហ៊ុនដឹកជញ្ជូនត្រូវទទួលខុសត្រូវលើការខូចខាតដែលអាចបង្កឡើងតាមរយៈព្រឹត្តិការណ៍ខាងលើ ដល់បុគ្គលដែលកំពុងកាន់កាប់សន្លឹកអញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាស ឬបង្កាន់ដៃទំនិញដោយស្របច្បាប់ ហើយការទទួលខុសត្រូវនេះ នឹងមិនប៉ះពាល់ដល់សិទ្ធិរបស់ក្រុមហ៊ុនដឹកជញ្ជូនក្នុងការទាមទារយកសំណងពីអ្នកផ្ញើឡើយ។

៤- សិទ្ធិខាងលើរបស់អ្នកផ្ញើត្រូវអស់សុពលភាព នៅពេលដែលសិទ្ធិអ្នកទទួលចាប់ផ្ដើមមានសុពលភាព ដោយអនុលោមតាមមាត្រា១៣។ ទោះជាយ៉ាងនេះក្ដី ប្រសិនបើអ្នកទទួលបដិសេធមិនទទួលយកទំនិញ ឬមិនអាចទាក់ទងបានសិទ្ធិរៀបចំចាត់ចែងទំនិញរបស់អ្នកផ្ញើមានសុពលភាពឡើងវិញ។

មាត្រា១៣ .- ការប្រគល់ទំនិញ

១- លើកលែងតែក្នុងករណីដែលអ្នកផ្ញើអនុវត្តសិទ្ធិរបស់ខ្លួនស្របតាមមាត្រា១២ អ្នកទទួលមានសិទ្ធិតម្រូវឱ្យក្រុមហ៊ុនដឹកជញ្ជូនប្រគល់ទំនិញមកខ្លួន នៅពេលទំនិញមកដល់ចំណុចគោលដៅ ដោយទូទាត់ថ្លៃចំណាយ និងដោយអនុវត្តតាមលក្ខខណ្ឌនៃការដឹកជញ្ជូន។

២- ក្រុមហ៊ុនដឹកជញ្ជូនមានកាតព្វកិច្ចជូនដំណឹងដល់អ្នកទទួល ឱ្យបានឆាប់នៅពេលទំនិញមកដល់ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ។

៣- ប្រសិនបើក្រុមហ៊ុនដឹកជញ្ជូនទទួលស្គាល់ថា បាត់ទំនិញឬទំនិញមិនទាន់មកដល់ បន្ទាប់ពីរយៈពេលប្រាំពីរ (៧)ថ្ងៃនៃកាលបរិច្ឆេទដែលត្រូវមកដល់ អ្នកទទួលមានសិទ្ធិតវ៉ាជាមួយក្រុមហ៊ុនដឹកជញ្ជូន ដោយអនុវត្តសិទ្ធិដែលមានចែងក្នុងកិច្ចសន្យាដឹកជញ្ជូន។

មាត្រា១៤ .- ការអនុវត្តសិទ្ធិរបស់អ្នកផ្ញើនិងអ្នកទទួល

អ្នកផ្ញើនិងអ្នកទទួលអាចអនុវត្តសិទ្ធិរៀងៗខ្លួន ដែលមានចែងក្នុងមាត្រា១២និងមាត្រា១៣ ដោយប្រើឈ្មោះរបស់ខ្លួន ទោះជាដើម្បីជាផលប្រយោជន៍ផ្ទាល់ខ្លួនឬផលប្រយោជន៍អ្នកដទៃ ក្នុងលក្ខខណ្ឌដែលអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងកិច្ចសន្យាដឹកជញ្ជូន។

មាត្រា១៥ .- ទំនាក់ទំនងរវាងអ្នកផ្ញើនិងអ្នកទទួលឬទំនាក់ទំនងទៅវិញទៅមកជាមួយតតិយជន

១- មាត្រា១២ មាត្រា១៣ និងមាត្រា១៤ មិនប៉ះពាល់នោះទេ ដល់ទំនាក់ទំនងរវាងអ្នកផ្ញើនិងអ្នកទទួល ឬទំនាក់ទំនងទៅវិញទៅមកជាមួយតតិយជន ដែលសិទ្ធិរបស់តតិយជនបានទទួលពីអ្នកផ្ញើឬពីអ្នកទទួល។

២- បទប្បញ្ញត្តិនៃមាត្រា១២ មាត្រា១៣ និងមាត្រា១៤ អាចប្រែប្រួលបានតាមរយៈបទប្បញ្ញត្តិបញ្ជាក់នៅក្នុងអញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាសឬបង្កាន់ដៃទំនិញតែប៉ុណ្ណោះ។

មាត្រា១៦ .- បែបបទគយ នគរបាល ឬអាជ្ញាធរសាធារណៈផ្សេងៗ

១- អ្នកផ្ញើត្រូវផ្ដល់ព័ត៌មាននិងឯកសារដែលចាំបាច់ដើម្បីបំពេញបែបបទគយ នគរបាល និងអាជ្ញាធរសាធារណៈផ្សេងៗ មុនពេលទំនិញអាចផ្ដល់ជូនទៅឱ្យអ្នកទទួល។ អ្នកផ្ញើត្រូវទទួលខុសត្រូវចំពោះក្រុមហ៊ុនដឹកជញ្ជូនសម្រាប់ការខូចខាត ដែលបានកើតឡើងដោយសារតែនត្ថិភាព ឬភាពមិនគ្រប់គ្រាន់ ឬភាពមិនប្រក្រតីនៃព័ត៌មានឬឯកសារទាំងនោះ លើកលែងតែការខូចខាតបណ្ដាលមកពីកំហុសរបស់ក្រុមហ៊ុនដឹកជញ្ជូនឬបុគ្គលិក ឬភ្នាក់ងាររបស់ក្រុមហ៊ុន។

២- ក្រុមហ៊ុនដឹកជញ្ជូនពុំស្ថិតក្រោមកាតព្វកិច្ចដើម្បីធ្វើការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ ឬភាពគ្រប់គ្រាន់នៃព័ត៌មាន ឬឯកសារទាំងនោះទេ។

ជំពូកទី៣
ការទទួលខុសត្រូវរបស់ក្រុមហ៊ុនដឹកជញ្ជូននិងវិសាលភាពសំណងលើការខូចខាត

មាត្រា១៧ .- មរណភាពនិងការរងរបួសរបស់អ្នកដំណើរ ការខូចខាតអីវ៉ាន់

១- ក្រុមហ៊ុនដឹកជញ្ជូនត្រូវទទួលខុសត្រូវលើការខូចខាត ក្នុងករណីមរណភាពឬរងរបួសផ្នែករាងកាយរបស់អ្នកដំណើរ ក្នុងលក្ខខណ្ឌតែមួយដែលឧបទ្ទវហេតុបង្កឱ្យមានមរណភាព ឬការរងរបួស បានកើតឡើងនៅក្នុងអាកាសយាន ឬក្នុងពេលដំណើរការឡើងឬចុះពីអាកាសយាន។

២- ក្រុមហ៊ុនដឹកជញ្ជូនត្រូវទទួលខុសត្រូវលើការខូចខាត ក្នុងករណីមានការបំផ្លិចបំផ្លាញ ឬបាត់បង់ ឬខូចខាតចំពោះអីវ៉ាន់ផ្ញើ ក្នុងលក្ខខណ្ឌតែមួយដែលព្រឹត្តិការណ៍បង្កឱ្យមានការបំផ្លិចបំផ្លាញ បាត់បង់ ឬខូចខាត បានកើតឡើងនៅក្នុងអាកាសយាន ឬក្នុងរង្វង់រយៈពេលអីវ៉ាន់ផ្ញើនៅក្នុងបន្ទុករបស់ក្រុមហ៊ុនដឹកជញ្ជូន។ ទោះជាយ៉ាងណាក្តី ក្រុមហ៊ុនដឹកជញ្ជូនមិនទទួលខុសត្រូវ ប្រសិនបើនិងក្នុងករណីដែលការខូចខាតបណ្តាលមកពីលក្ខណៈដើម គុណភាព ឬវិការៈនៃអីវ៉ាន់។ ចំពោះអីវ៉ាន់យកតាមខ្លួន រួមទាំងរបស់របរផ្ទាល់ខ្លួន ក្រុមហ៊ុនដឹកជញ្ជូនត្រូវទទួលខុសត្រូវ ប្រសិនបើការខូចខាតកើតឡើងមកពីកំហុសរបស់ក្រុមហ៊ុនឬបុគ្គលិក ឬភ្នាក់ងាររបស់ក្រុមហ៊ុន។

៣- ប្រសិនបើក្រុមហ៊ុនដឹកជញ្ជូនទទួលស្គាល់ការបាត់អីវ៉ាន់ផ្ញើ ឬប្រសិនបើអីវ៉ាន់ផ្ញើពុំបានមកដល់ក្នុងរយៈពេលផុតកំណត់២១(ម្ភៃមួយ)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដែលត្រូវមកដល់ អ្នកដំណើរអាចប្រើប្រាស់សិទ្ធិតវ៉ាជាមួយក្រុមហ៊ុនដឹកជញ្ជូនដែលសិទ្ធិនេះមានចែងក្នុងកិច្ចសន្យាដឹកជញ្ជូន។

៤- នៅក្នុងអនុសញ្ញានេះ ពាក្យ "អីវ៉ាន់" សំដៅដល់ទាំងអីវ៉ាន់ផ្ញើនិងអីវ៉ាន់យកតាមខ្លួន លើកលែងតែមានបញ្ជាក់ផ្ទុយពីនេះ។

មាត្រា១៨ .- ការខូចខាតទំនិញ

១- ក្រុមហ៊ុនដឹកជញ្ជូនត្រូវទទួលខុសត្រូវលើការខូចខាត ក្នុងករណីមានការបំផ្លិចបំផ្លាញ ឬបាត់បង់ ឬខូចខាតចំពោះទំនិញ ក្នុងលក្ខខណ្ឌមួយដែលព្រឹត្តិការណ៍នោះបង្កឱ្យមានការខូចខាត បានកើតឡើងក្នុងកំឡុងពេលនៃការដឹកជញ្ជូនតាមផ្លូវអាកាស។

២- ក៏ប៉ុន្តែ ក្រុមហ៊ុនដឹកជញ្ជូនមិនទទួលខុសត្រូវឡើយ ប្រសិនបើនិងក្នុងករណីដែលក្រុមហ៊ុនមានភស្តុតាងបញ្ជាក់ថា ការបំផ្លិចបំផ្លាញ ឬការបាត់បង់ ឬការខូចខាតចំពោះទំនិញ បានកើតឡើងពីមូលហេតុមួយឬច្រើនដូចខាងក្រោម៖

៧/២៣

(ក) លក្ខណៈដើម គុណភាព ឬវិការៈនៃទំនិញ។

(ខ) ការវេចខ្ចប់ទំនិញមិនត្រឹមត្រូវ ដោយបុគ្គលម្នាក់ដែលមិនមែនជាក្រុមហ៊ុនឬបុគ្គលិក ឬភ្នាក់ងាររបស់ក្រុមហ៊ុន។

(គ) ព្រឹត្តិការណ៍សង្គ្រាម ឬជម្លោះប្រដាប់អាវុធ។

(ឃ) ទង្វើរបស់អាជ្ញាធរសាធារណៈដែលបានធ្វើឡើង ពាក់ព័ន្ធនឹងការចូល ការចេញ ឬការឆ្លងកាត់ទំនិញ។

៣- ការដឹកជញ្ជូនតាមផ្លូវអាកាស តាមន័យចំណុចទី១នៃមាត្រានេះ គឺរួមទាំងរយៈពេលដែលទំនិញស្ថិតនៅក្នុងបន្ទុករបស់ក្រុមហ៊ុនដឹកជញ្ជូន។

៤- រយៈពេលនៃការដឹកជញ្ជូនតាមផ្លូវអាកាស គឺមិនរាប់បញ្ចូលរយៈពេលនៃការដឹកជញ្ជូនតាមផ្លូវគោក សមុទ្រ ឬផ្លូវទឹកនៃដែនដី ដែលដឹកជញ្ជូននៅក្រៅអាកាសយានដ្ឋាន។ ទោះជាយ៉ាងនេះក្តី ប្រសិនបើការដឹកជញ្ជូននេះអនុវត្តតាមកិច្ចសន្យាដឹកជញ្ជូនតាមផ្លូវអាកាស ក្នុងគោលបំណងផ្ទុក ឬប្រគល់ ឬផ្ទេរទំនិញ ការខូចខាតណាមួយត្រូវបានសន្មតថា គឺជាការកើតឡើងក្នុងរយៈពេលនៃការដឹកជញ្ជូនតាមផ្លូវអាកាស លើកលែងតែមានភស្តុតាងផ្ទុយពីនេះ។ ប្រសិនបើក្រុមហ៊ុនដឹកជញ្ជូនជំនួសមធ្យោបាយដឹកជញ្ជូនផ្សេងទៀត សម្រាប់ការដឹកជញ្ជូនទាំងស្រុង ឬមួយផ្នែក ដែលគូភាគីបានព្រមព្រៀងជាការដឹកជញ្ជូនតាមផ្លូវអាកាស ដោយពុំមានការយល់ព្រមពីអ្នកផ្ញើទេ នោះការដឹកជញ្ជូនតាមមធ្យោបាយផ្សេងទៀតនោះ ត្រូវចាត់ទុកថា នៅក្នុងរយៈពេលនៃការដឹកជញ្ជូនតាមផ្លូវអាកាស។

មាត្រា១៩.- ការយឺតយ៉ាវ

ក្រុមហ៊ុនដឹកជញ្ជូន ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលបណ្តាលមកពីការយឺតយ៉ាវក្នុងការដឹកជញ្ជូនអ្នកដំណើរ អីវ៉ាន់ ឬទំនិញតាមផ្លូវអាកាស។ ទោះជាយ៉ាងនេះក្តី ក្រុមហ៊ុនដឹកជញ្ជូនមិនទទួលខុសត្រូវចំពោះការខូចខាតដែលបណ្តាលមកពីការយឺតយ៉ាវ ប្រសិនបើក្រុមហ៊ុនមានភស្តុតាងបញ្ជាក់ថា ក្រុមហ៊ុន បុគ្គលិកនិងភ្នាក់ងាររបស់ខ្លួន បានចាត់រាល់វិធានការសមហេតុផលដែលបានតម្រូវ ដើម្បីបញ្ចៀសការខូចខាត ឬបញ្ជាក់ថា ក្រុមហ៊ុន ឬបុគ្គលិកនិងភ្នាក់ងាររបស់ក្រុមហ៊ុនពុំមានលទ្ធភាពចាត់វិធានការទាំងនោះបាន។

មាត្រា២០.- ការលើកលែង

ប្រសិនបើក្រុមហ៊ុនដឹកជញ្ជូនមានភស្តុតាងបញ្ជាក់ថា ការខូចខាតបណ្តាលមកពីឬមានចំណែកមកពីការធ្វេសប្រហែស ឬការប្រព្រឹត្តខុស ឬការមិនបានបំពេញកាតព្វកិច្ចរបស់អ្នកទាមទារសំណង ឬបុគ្គលដែលទទួលសិទ្ធិ ក្រុមហ៊ុនដឹកជញ្ជូនត្រូវបានរួចបន្ទុកទាំងស្រុងឬនៅផ្នែកណាមួយពីការទទួលខុសត្រូវរបស់ខ្លួនចំពោះអ្នកទាមទារសំណង ក្នុងលក្ខខណ្ឌ ដែលការខូចខាតបណ្តាលមកពីឬមានចំណែកមកពីការធ្វេសប្រហែស ឬការប្រព្រឹត្តខុស ឬការមិនបានបំពេញកាតព្វកិច្ចទាំងនេះ។ ក្នុងករណីមានមរណភាពឬរងរបួសដល់អ្នកដំណើរ នៅពេលសំណងត្រូវបានទាមទារដោយបុគ្គលម្នាក់ដែលមិនមែន ជាអ្នកដំណើរ ក្រុមហ៊ុនដឹកជញ្ជូនត្រូវបានរួចផុតទាំងស្រុងឬផ្នែកណា

មួយពីការទទួលខុសត្រូវរបស់ខ្លួន នៅពេលដែលក្រុមហ៊ុនមានភស្តុតាងបញ្ជាក់ថា ការខូចខាតនោះបណ្តាលមកពី ឬមានចំណែកមកពីការធ្វេសប្រហែស ឬ ការប្រព្រឹត្តខុស ឬការខកខានរបស់អ្នកដំណើរនោះ។ មាត្រានេះអនុវត្ត ចំពោះបទប្បញ្ញត្តិទាំងអស់ស្តីពីការទទួលខុសត្រូវសំណងនៅក្នុងអនុសញ្ញានេះ រួមទាំងចំណុចទី១នៃមាត្រា២១។

មាត្រា២១ .- សំណងក្នុងករណីមរណភាពឬការរងរបួសដល់អ្នកដំណើរ

១- ចំពោះការខូចខាតដែលកើតឡើងក្រោមចំណុចទី១នៃមាត្រា១៧ ដែលមិនលើសពី១០០ ០០០SDR (អេសដេអ៊ែ) សម្រាប់អ្នកដំណើរម្នាក់ ក្រុមហ៊ុនដឹកជញ្ជូនមិនអាចបដិសេធ ឬដាក់កម្រិតលើការទទួលខុសត្រូវ របស់ខ្លួនឡើយ។

២- ក្រុមហ៊ុនដឹកជញ្ជូនមិនទទួលខុសត្រូវលើការខូចខាតដែលកើតឡើងក្រោមចំណុចទី១នៃមាត្រា១៧ ក្នុងលក្ខខណ្ឌដែលការខូចខាតមានកម្រិតលើសពី១០០ ០០០SDR(អេសដេអ៊ែ) សម្រាប់អ្នកដំណើរម្នាក់ ប្រសិនបើក្រុមហ៊ុន ដឹកជញ្ជូនមានភស្តុតាងបញ្ជាក់ថា៖

(ក) ការខូចខាតនេះមិនបណ្តាលមកពីការធ្វេសប្រហែស ឬការប្រព្រឹត្តខុសផ្សេងៗ ឬការមិនបានបំពេញ កាតព្វកិច្ចរបស់ក្រុមហ៊ុនដឹកជញ្ជូនឬបុគ្គលិកឬភ្នាក់ងាររបស់ក្រុមហ៊ុន ឬ

(ខ) ការខូចខាតនេះបណ្តាលមកពីការធ្វេសប្រហែស ឬការប្រព្រឹត្តខុសផ្សេងៗ ឬការមិនបានបំពេញ កាតព្វកិច្ចរបស់តតិយជនទាំងស្រុង។

មាត្រា២២ .- កម្រិតការទទួលខុសត្រូវពាក់ព័ន្ធនឹងការយឺតយ៉ាវ អីវ៉ាន់ និងទំនិញ

១- ក្នុងករណីមានការខូចខាតដែលបណ្តាលមកពីការយឺតយ៉ាវ ដូចមានចែងក្នុងមាត្រា១៩ ក្នុងការដឹកជញ្ជូន អ្នកដំណើរ ការទទួលខុសត្រូវរបស់ក្រុមហ៊ុនដឹកជញ្ជូនសម្រាប់អ្នកដំណើរម្នាក់ គឺត្រូវបានកំណត់ត្រឹម៤ ១៥០SDR (អេសដេអ៊ែ)។

២- ចំពោះការដឹកជញ្ជូនអីវ៉ាន់ ក្នុងករណីមានការបំផ្លិចបំផ្លាញ បាត់បង់ ខូចខាត និងការយឺតយ៉ាវ ការទទួល ខុសត្រូវរបស់ក្រុមហ៊ុនដឹកជញ្ជូន គឺត្រូវបានកំណត់ត្រឹម១ ០០០SDR(អេសដេអ៊ែ) សម្រាប់អ្នកដំណើរម្នាក់ លើកលែងតែនៅពេលប្រគល់អីវ៉ាន់ផ្ញើជូនក្រុមហ៊ុនដឹកជញ្ជូន អ្នកផ្ញើបានធ្វើការប្រកាសពិសេសអំពីតម្លៃអីវ៉ាន់ នៅទីកន្លែងប្រគល់អីវ៉ាន់ និងបានបង់ប្រាក់បន្ថែមក្នុងករណីចាំបាច់។ ក្នុងករណីនេះ ក្រុមហ៊ុនដឹកជញ្ជូនត្រូវ ទទួលខុសត្រូវបង់ចំនួនទឹកប្រាក់ដែលមិនលើសពីចំនួនទឹកប្រាក់ដែលបានប្រកាសទេ លើកលែងតែក្រុមហ៊ុនដឹក ជញ្ជូនមានភស្តុតាងបញ្ជាក់ថាចំនួនទឹកប្រាក់នោះថ្លៃជាងតម្លៃអីវ៉ាន់ជាក់ស្តែងរបស់អ្នកផ្ញើ ដែលបានប្រកាសនៅ កន្លែងប្រគល់អីវ៉ាន់។

៣- ចំពោះការដឹកជញ្ជូនទំនិញ ក្នុងករណីមានការបំផ្លិចបំផ្លាញ បាត់បង់ ខូចខាត និងការយឺតយ៉ាវ ការទទួល ខុសត្រូវរបស់ក្រុមហ៊ុនដឹកជញ្ជូន គឺត្រូវបានកំណត់ត្រឹម១៧SDR(អេសដេអ៊ែ) ក្នុងមួយគីឡូក្រាម លើកលែងតែ នៅពេលប្រគល់ បញ្ញើទៅក្រុមហ៊ុនដឹកជញ្ជូន អ្នកផ្ញើបានធ្វើការប្រកាសពិសេសអំពីតម្លៃទំនិញ និងបានបង់ប្រាក់ បន្ថែមក្នុងករណីចាំបាច់។ ក្នុងករណីនេះ ក្រុមហ៊ុនដឹកជញ្ជូនត្រូវទទួលខុសត្រូវបង់ចំនួនទឹកប្រាក់ដែលមិនលើស ពីចំនួនទឹកប្រាក់ដែលបានប្រកាសទេ លើកលែងតែក្រុមហ៊ុនដឹកជញ្ជូនមានភស្តុតាងបញ្ជាក់ថា ចំនួនទឹកប្រាក់ នោះថ្លៃជាងតម្លៃទំនិញជាក់ស្តែងរបស់អ្នកផ្ញើ ដែលបានប្រកាសនៅកន្លែងប្រគល់ទំនិញ។

៩/២៣

៤- ក្នុងករណីនៃការបំផ្លិចបំផ្លាញ បាត់បង់ ខូចខាត ឬយឺតយ៉ាវលើផ្នែកខ្លះនៃទំនិញ ឬវត្ថុនៅក្នុងទំនិញ ទម្ងន់ដែលត្រូវយកធ្វើជាមូលដ្ឋានដើម្បីកំណត់កម្រិតនៃការទទួលខុសត្រូវរបស់ក្រុមហ៊ុនដឹកជញ្ជូន ត្រូវតែជាទម្ងន់សរុបនៃកញ្ចប់ទំនិញពាក់ព័ន្ធមួយឬច្រើន។ ទោះជាយ៉ាងណាក្តី នៅពេលដែលការបំផ្លិចបំផ្លាញ បាត់បង់ ខូចខាត ឬការយឺតយ៉ាវលើផ្នែកខ្លះនៃទំនិញ ឬវត្ថុនៅក្នុងទំនិញប៉ះពាល់ដល់តម្លៃកញ្ចប់ទំនិញផ្សេងទៀតដែលមានចុះក្នុងអញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាស ឬបង្កាន់ដៃតែមួយ ឬចុះក្នុងកំណត់ត្រាដែលរក្សាទុកដោយមធ្យោបាយដទៃទៀត ដូចមានចែងក្នុងចំណុចទី២នៃមាត្រា៤ ប្រសិនបើអញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាសនិងបង្កាន់ដៃទំនិញមិនត្រូវបានចេញឱ្យ ទម្ងន់សរុបនៃកញ្ចប់ទំនិញនេះឬកញ្ចប់ទាំងនេះ ត្រូវយកមកធ្វើជាមូលដ្ឋានដើម្បីកំណត់កម្រិតការទទួលខុសត្រូវ។

៥- បទប្បញ្ញត្តិខាងលើនៃចំណុចទី១និងទី២នៃមាត្រានេះ មិនអនុវត្ត ប្រសិនបើមានភស្តុតាងបញ្ជាក់ថា ការខូចខាតបណ្តាលមកពីការប្រព្រឹត្តឬការមិនបានបំពេញកាតព្វកិច្ចរបស់ក្រុមហ៊ុនដឹកជញ្ជូន បុគ្គលិកឬភ្នាក់ងារក្រុមហ៊ុន ដែលធ្វើ ឡើងក្នុងចេតនាបង្កការខូចខាត ឬដោយខ្វះការយកចិត្តទុកដាក់ និងដោយដឹងថា ការខូចខាតអាចកើតមានឡើង ហើយក្នុងលក្ខខណ្ឌដែលការប្រព្រឹត្តឬការមិនបានបំពេញកាតព្វកិច្ចរបស់បុគ្គលិកឬភ្នាក់ងារត្រូវបានបញ្ជាក់ថា បានកើតឡើងក្នុងវិសាលភាពនៃការបំពេញការងាររបស់ពួកគេ។

៦- កម្រិតទទួលខុសត្រូវដែលមានចែងក្នុងមាត្រា២១និងក្នុងមាត្រានេះ មិនរារាំងតុលាការ លើការផ្តល់សំណងបន្ថែមទាំងស្រុងឬផ្នែកណាមួយ ដោយផ្អែកតាមច្បាប់របស់ខ្លួន នូវប្រាក់ប្រដាប់ក្តីនិងចំណាយផ្សេងៗទៀតនៃការដោះស្រាយវិវាទរបស់ដើមបណ្តឹង រួមទាំងការប្រាក់។ បទប្បញ្ញត្តិខាងលើមិនអនុវត្តទេ ប្រសិនបើចំនួនទឹកប្រាក់នៃការខូចខាតដែលផ្តល់ជូន ដោយមិនរាប់បញ្ចូលប្រាក់ប្រដាប់ក្តីនិងចំណាយផ្សេងៗទៀតនៃដំណើរការដោះស្រាយវិវាទ មិនលើសពីចំនួនទឹកប្រាក់សរុបដែលក្រុមហ៊ុនដឹកជញ្ជូនបានផ្តល់ជាលាយលក្ខណ៍អក្សរជូនដើមបណ្តឹងក្នុងរង្វង់រយៈពេល៦(ប្រាំមួយ)ខែ ចាប់ពីកាលបរិច្ឆេទនៃព្រឹត្តិការណ៍បង្កឱ្យមានការខូចខាតឬមុនពេលចាប់ផ្តើមដំណើរការរឿងក្តី ប្រសិនបើសកម្មភាពនោះកើតមានក្រោយ។

មាត្រា២៣ .- ការប្តូរឯកតារូបិយបណ្ណ

១- ចំនួនទឹកប្រាក់ដែលបានលើកឡើង ធៀបជាមួយ"Special Drawing Right" ក្នុងអនុសញ្ញានេះ សំដៅដល់ "Special Drawing Right" ដូចបានកំណត់ដោយមូលនិធិរូបិយវត្ថុអន្តរជាតិ។ ក្នុងករណីនៃការដោះស្រាយតាមផ្លូវតុលាការ ការប្តូរចំនួនទឹកប្រាក់សរុបទៅជារូបិយបណ្ណជាតិ ត្រូវតែធ្វើឡើងដោយអនុលោមតាមតម្លៃនៃរូបិយបណ្ណជាតិទាំងនេះ ដោយធៀបជាមួយ"Special Drawing Right" នៅកាលបរិច្ឆេទនៃសេចក្តីសម្រេច។ តម្លៃនៃរូបិយបណ្ណជាតិមួយ ធៀបជាមួយ"Special Drawing Right" របស់រដ្ឋភាគីមួយជាសមាជិកនៃមូលនិធិរូបិយវត្ថុអន្តរជាតិ ត្រូវបានគណនា ស្របតាមវិធីសាស្ត្រនៃការវាយតម្លៃ ដែលអនុវត្តដោយមូលនិធិរូបិយវត្ថុអន្តរជាតិ សម្រាប់ប្រតិបត្តិការនិងអន្តរការណ៍ របស់ខ្លួនដោយគិតចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេច។ តម្លៃនៃរូបិយបណ្ណជាតិមួយ ធៀបជាមួយ "Special Drawing Right" របស់រដ្ឋភាគីមួយ ដែលមិនមែនជាសមាជិកមូលនិធិរូបិយវត្ថុអន្តរជាតិ ត្រូវបានគណនាតាមរបៀបដែលកំណត់ដោយរដ្ឋភាគីនោះ។

២- ទោះបីជាយ៉ាងនេះក្តី រដ្ឋភាគីទាំងឡាយដែលមិនមែនជាសមាជិកនៃមូលនិធិរូបិយវត្ថុអន្តរជាតិ និងច្បាប់របស់ខ្លួនមិនអនុញ្ញាតឱ្យអនុវត្តតាមចំណុចទី១នៃមាត្រានេះ នៅពេលផ្តល់សច្ចាប័ន ឬការចូលជាសមាជិក ឬពេលណាមួយបន្ទាប់ពីនោះ អាចប្រកាសថា កម្រិតនៃការទទួលខុសត្រូវរបស់ក្រុមហ៊ុនដឹកជញ្ជូន ដូចមានចែងក្នុងមាត្រា២១ គឺត្រូវបានកំណត់ជាចំនួនសរុប១ ៥០០ ០០០ឯកតារូបិយបណ្ណ សម្រាប់អ្នកដំណើរម្នាក់ លើការដោះស្រាយតាមផ្លូវតុលាការនៅក្នុងទឹកដីរបស់ខ្លួន ជាចំនួនសរុប៦២ ៥០០ឯកតារូបិយបណ្ណសម្រាប់អ្នកដំណើរម្នាក់ ដោយយោងតាមចំណុចទី១នៃមាត្រា២២ ជាចំនួនសរុប១៥ ០០០ឯកតារូបិយបណ្ណសម្រាប់អ្នកដំណើរម្នាក់ដោយយោងតាមចំណុចទី២នៃមាត្រា២២ និងជាចំនួនសរុប២៥០ឯកតារូបិយបណ្ណក្នុងមួយគីឡូក្រាម ដោយយោងតាមចំណុចទី៣នៃមាត្រា២២។ ឯកតារូបិយបណ្ណនេះ ស្មើនឹងហុកសិបប្រាំកន្លះមិល្លីក្រាម នៃមាសសុទ្ធខ្នាតប្រាំបួនរយភាគពាន់។ ចំនួនសរុបទាំងនេះ អាចប្តូរទៅជារូបិយបណ្ណជាតិ ដោយគិតជាលេខបង្គត់។ ការប្តូរនៃចំនួនសរុបទាំងនេះ ឱ្យទៅជារូបិយបណ្ណជាតិ ត្រូវធ្វើឡើងស្របតាមច្បាប់នៃរដ្ឋភាគីនោះ។

៣- ការគណនាដូចបានបញ្ជាក់ក្នុងវាក្យខណ្ឌចុងក្រោយនៃចំណុចទី១របស់មាត្រានេះ និងវិធីសាស្ត្រនៃការប្តូរប្រាក់ដូចបានបញ្ជាក់ក្នុងចំណុចទី២នៃមាត្រានេះ ត្រូវប្រព្រឹត្តទៅតាមរបៀបបង្ហាញជារូបិយបណ្ណជាតិនៃរដ្ឋភាគី ដែលមានតម្លៃពិតប្រាកដដូចគ្នានឹងចំនួនទឹកប្រាក់មានចែងក្នុងមាត្រា២១និងមាត្រា២២ តាមលទ្ធភាពអាចធ្វើទៅបាន ហើយជាលទ្ធផលដែលកើតចេញមកពីការអនុវត្តវាក្យខណ្ឌទាំងបីដំបូងនៃចំណុចទី១ នៃមាត្រានេះ។ បណ្តារដ្ឋភាគីត្រូវធ្វើទំនាក់ទំនងជាមួយអង្គភាពតម្កល់អនុសញ្ញាដើម្បីតម្កល់នូវរបៀបនៃការគណនា ស្របតាមចំណុចទី១ នៃមាត្រានេះឬលទ្ធផលនៃការប្តូរប្រាក់ ដូចក្នុងចំណុចទី២នៃមាត្រានេះ តាមករណីនៅពេលដែលតម្កល់លិខិតុបករណ៍សច្ចាប័ន ទទួលយក ឯកភាព ឬចូលជាសមាជិកនៃអនុសញ្ញានេះ និងនៅពេលណាដែលមានការផ្លាស់ប្តូរវិធីសាស្ត្រគណនា ឬលទ្ធផលនៃការប្តូរប្រាក់។

មាត្រា២៤ .- ការពិនិត្យឡើងវិញនូវកម្រិតទទួលខុសត្រូវ

១- ដោយមិនប៉ះពាល់ដល់បទប្បញ្ញត្តិមាត្រា២៥នៃអនុសញ្ញានេះ និងយោងចំណុចទី២ខាងក្រោម កម្រិតនៃការទទួលខុសត្រូវ ដូចបានបញ្ជាក់ក្នុងមាត្រា២១ មាត្រា២២ និងមាត្រា២៣ ត្រូវធ្វើការពិនិត្យឡើងវិញ ដោយអង្គភាពតម្កល់អនុសញ្ញា រៀងរាល់៥(ប្រាំ)ឆ្នាំម្តង។ ការពិនិត្យឡើងវិញលើកទី១ ត្រូវប្រព្រឹត្តទៅនៅចុងឆ្នាំទី៥ ដោយគិតចាប់ពីថ្ងៃចូលជាធរមាននៃអនុសញ្ញានេះ ឬប្រសិនបើអនុសញ្ញានេះមិនទាន់ចូលជាធរមានក្នុងរង្វង់រយៈពេល៥(ប្រាំ) ឆ្នាំ គិតចាប់តាំងពីថ្ងៃដំបូងបើកឱ្យចុះហត្ថលេខា គឺនៅក្នុងរង្វង់ឆ្នាំទី១នៃការចូលជាធរមាន ដោយយោងទៅលើកត្តាអតិផរណា ដែលជាប់ពាក់ព័ន្ធនឹងអត្រាបង្គរនៃអតិផរណា ចាប់តាំងពីការពិនិត្យឡើងវិញពីមុន ឬប្រសិនបើជាករណីនៃការពិនិត្យឡើងវិញលើកទី១ ចាប់តាំងពីថ្ងៃចូលជាធរមាននៃអនុសញ្ញា។ ការវាស់វែងអត្រា អតិផរណាដើម្បីប្រើប្រាស់ក្នុងការកំណត់កត្តាអតិផរណា ត្រូវថ្លឹងថ្លែងតាមមធ្យមភាគអត្រាប្រចាំឆ្នាំនៃការកើនឡើង ឬថយចុះសន្ទស្សន៍ថ្លៃអ្នកប្រើប្រាស់របស់រដ្ឋភាគី ដែលមានរូបិយបណ្ណរបស់ខ្លួន រួមមាន Special Drawing Right ដូចបានបញ្ជាក់ក្នុងចំណុចទី១នៃមាត្រា២៣។

១១/២៣

២- ប្រសិនបើការពិនិត្យឡើងវិញ ដូចមានចែងក្នុងចំណុចខាងលើ សម្រេចថា កត្តាអតិផរណាលើស១០% (ដប់)ភាគរយ អង្គភាពតម្កល់អនុសញ្ញាត្រូវជូនដំណឹងទៅរដ្ឋភាគី អំពីការកែសម្រួលលើកម្រិតការទទួលខុសត្រូវ។ រាល់ការកែសម្រួល ត្រូវចូលជាធរមានក្នុងរយៈពេល៦(ប្រាំមួយ)ខែ បន្ទាប់ពីការជូនដំណឹងទៅរដ្ឋភាគី។ ប្រសិនបើក្នុងកំលុងពេល៣(បី)ខែ បន្ទាប់ពីការជូនដំណឹងទៅរដ្ឋភាគី សំឡេងភាគច្រើននៃរដ្ឋភាគីពុំឯកភាព នោះការកែសម្រួលនឹងមិនអាចចូលជាធរមាន ហើយអង្គភាពតម្កល់អនុសញ្ញាត្រូវលើកបញ្ហានេះនៅក្នុងកិច្ចប្រជុំមួយរបស់រដ្ឋភាគី។ អង្គភាពតម្កល់អនុសញ្ញាត្រូវជូនដំណឹងភ្លាមៗ ទៅរដ្ឋភាគីស្តីពីការចូលជាធរមាននៃរាល់ការកែសម្រួល។

៣- ទោះជាមានចំណុចទី១នៃមាត្រានេះក៏ដោយ នីតិវិធីដែលមានចែងក្នុងចំណុចទី២នៃមាត្រានេះ ត្រូវបានអនុវត្តគ្រប់ពេលវេលា លុះត្រាតែមួយភាគបីនៃរដ្ឋភាគី បង្ហាញពីគោលជំហរគាំទ្រ ក្រោមលក្ខខណ្ឌថា កត្តា អតិផរណា ដូចមានចែងក្នុងចំណុចទី១លើសពី៣០%(សាមសិប)ភាគរយ គិតចាប់តាំងពីការកែសម្រួលលើកមុន ឬចាប់តាំងពីថ្ងៃចូលជាធរមាននៃអនុសញ្ញានេះ ប្រសិនបើពុំមានការកែសម្រួលលើកមុន។ ការត្រួតពិនិត្យឡើងវិញ ជាបន្តបន្ទាប់ដោយប្រើប្រាស់នីតិវិធី ដូចមានចែងក្នុងចំណុចទី១នៃមាត្រានេះ ត្រូវប្រព្រឹត្តទៅក្នុងចន្លោះរយៈពេល៥(ប្រាំ)ឆ្នាំ ចាប់ផ្តើមនៅចុងឆ្នាំទី៥ បន្ទាប់ពីកាលបរិច្ឆេទនៃការត្រួតពិនិត្យឡើងវិញក្រោមចំណុចនេះ។

មាត្រា២៥ ._ ការកំណត់អំពីកម្រិតទទួលខុសត្រូវ

ក្រុមហ៊ុនដឹកជញ្ជូនមួយអាចកំណត់ថា កិច្ចសន្យាដឹកជញ្ជូនអាចមានកម្រិតទទួលខុសត្រូវខ្ពស់ជាងការកម្រិតទទួលខុសត្រូវដែលមានចែងក្នុងអនុសញ្ញានេះ ឬមិនកម្រិតការទទួលខុសត្រូវណាមួយក៏បាន។

មាត្រា២៦ ._ មោឃភាពនៃបទប្បញ្ញត្តិកិច្ចសន្យា

បទប្បញ្ញត្តិទាំងឡាយ មានបំណងបន្ធូរបន្ថយការទទួលខុសត្រូវរបស់ក្រុមហ៊ុនដឹកជញ្ជូន ឬកំណត់កម្រិតទទួលខុសត្រូវទាបជាងអ្វីដែលបានកំណត់ក្នុងអនុសញ្ញានេះ ត្រូវទុកជាមោឃៈ ក៏ប៉ុន្តែមោឃភាពនៃបទប្បញ្ញត្តិណាមួយ មិនជាប់ពាក់ព័ន្ធនឹងមោឃភាពនៃកិច្ចសន្យាទាំងមូល ដែលនៅតែស្ថិតនៅក្រោមបទប្បញ្ញត្តិនៃអនុសញ្ញានេះ។

មាត្រា២៧ ._ សេរីភាពនៃការធ្វើកិច្ចសន្យា

ពុំមានបទប្បញ្ញត្តិនៃអនុសញ្ញានេះ ត្រូវហាមឃាត់ក្រុមហ៊ុនដឹកជញ្ជូនមិនឱ្យធ្វើកិច្ចសន្យាដឹកជញ្ជូន បោះបង់ការការពារខ្លួនដែលមានស្រាប់នៅក្រោមអនុសញ្ញានេះ ឬមិនឱ្យដាក់លក្ខខណ្ឌនានាដែលមិនផ្ទុយនឹងបទប្បញ្ញត្តិនៃអនុសញ្ញានេះ។

មាត្រា២៨ ._ បុរេប្រទាន

ក្នុងករណីមានគ្រោះថ្នាក់អាកាសយាន បណ្តាលឱ្យមរណភាពឬរងរបួសដល់អ្នកដំណើរ ក្រុមហ៊ុនដឹកជញ្ជូនត្រូវធ្វើបុរេប្រទានដោយពុំមានភាពយឺតយ៉ាវជូនចំពោះរូបវន្តបុគ្គលមួយឬច្រើន ដែលមានសិទ្ធិក្នុងការទាមទារសំណង ដើម្បីឆ្លើយតបតម្រូវការសេដ្ឋកិច្ចបន្ទាន់នៃបុគ្គលទាំងនោះ ប្រសិនបើច្បាប់ជាតិតម្រូវ។ បុរេប្រទានទាំងនេះមិនចាត់ទុកជាការទទួលស្គាល់នៃការទទួលខុសត្រូវ និងអាចកាត់កងជាមួយចំនួនទឹកប្រាក់ដែលក្រុមហ៊ុនដឹកជញ្ជូនត្រូវទូទាត់ជាបន្តបន្ទាប់លើការខូចខាត។

១៧/២៣

មាត្រា២៩ .- មូលដ្ឋាននៃការទាមទារសំណង

ក្នុងការដឹកជញ្ជូនអ្នកដំណើរ អីវ៉ាន់ និងទំនិញ រាល់ការប្ដឹងតវ៉ាទាមទារសំណងចំពោះការខូចខាត យោងតាមអនុសញ្ញានេះ ឬដោយយោងតាមកិច្ចសន្យា ឬដោយអំពើអនីត្យានុកូល ឬដោយមូលហេតុដទៃទៀត អាចធ្វើបានតែក្នុងលក្ខខណ្ឌនិងកម្រិតទទួលខុសត្រូវ ដែលមានចែងក្នុងអនុសញ្ញានេះ ដោយមិនប៉ះពាល់ដល់ការកំណត់បុគ្គលដែលមានសិទ្ធិប្ដឹងនិងសិទ្ធិពាក់ព័ន្ធរបស់បុគ្គលទាំងនោះឡើយ។ ក្នុងករណីនៃការប្ដឹងប្រភេទនេះ សំណងជាទណ្ឌកម្មជាការព្រមាន ឬសំណងមិនមែនជាការប៉ះប៉ូវផ្សេងទៀត មិនអាចទាមទារមកវិញបានឡើយ។

មាត្រា៣០ .- បុគ្គលិក ភ្នាក់ងារ ទឹកប្រាក់សរុបនៃសំណង

១- ប្រសិនបើមានបណ្ដឹងចំពោះបុគ្គលិកឬភ្នាក់ងារក្រុមហ៊ុនដឹកជញ្ជូន ដោយសារមានការខូចខាតកើតឡើងដូចមានចែងក្នុងអនុសញ្ញា បុគ្គលិកឬភ្នាក់ងារនេះត្រូវមានសិទ្ធិប្រើប្រាស់លក្ខខណ្ឌនិងកម្រិតទទួលខុសត្រូវ ដែលក្រុមហ៊ុនដឹកជញ្ជូនខ្លួនឯងមានសិទ្ធិអនុវត្តក្រោមអនុសញ្ញានេះ ប្រសិនបើបុគ្គលទាំងនោះមានភស្តុតាងបង្ហាញថាបុគ្គលទាំងនោះបានបំពេញភារកិច្ចនៅក្នុងវង្វង់វិសាលភាពនៃការងាររបស់ខ្លួន។

២- ក្នុងករណីនេះ ចំនួនទឹកប្រាក់សរុបដែលអាចត្រូវទាមទារបានមកវិញពីក្រុមហ៊ុនដឹកជញ្ជូន បុគ្គលិកនិងភ្នាក់ងាររបស់ក្រុមហ៊ុន មិនត្រូវលើសពីកម្រិតដូចបានកំណត់ឡើយ។

៣- ប៉ុន្តែចំពោះការដឹកជញ្ជូនទំនិញ បទប្បញ្ញត្តិនៃចំណុចទី១និងចំណុចទី២នៃមាត្រានេះ មិនត្រូវអនុវត្តប្រសិនបើ មានភស្តុតាងបង្ហាញថា ការខូចខាតបណ្ដាលមកពីទង្វើ ឬពីការមិនបានបំពេញកាតព្វកិច្ចរបស់បុគ្គលិកឬភ្នាក់ងារ ដែលបានប្រព្រឹត្ត ក្នុងចេតនាបង្កឱ្យមានការខូចខាត ឬដោយធ្វេសប្រហែស និងទាំងបានដឹងថា ការខូចខាតអាចនឹងកើតមានឡើង។

មាត្រា៣១ .- ការជូនដំណឹងអំពីការប្ដឹងតវ៉ាឱ្យទាន់ពេល

១- ការទទួលបានអីវ៉ាន់ផ្ញើឬទំនិញដោយបុគ្គលដែលជាអ្នកមានសិទ្ធិទទួល ដោយពុំមានការប្ដឹងតវ៉ា គឺជាភស្តុតាងដំបូង ដែលបង្ហាញថា អីវ៉ាន់ឬទំនិញនេះត្រូវបានប្រគល់ជូននៅក្នុងស្ថានភាពល្អ ដោយអនុលោមតាមឯកសារ ដឹកជញ្ជូន ឬតាមកំណត់ត្រាដែលត្រូវបានរក្សាទុកដោយមធ្យោបាយផ្សេងទៀតដូចមានចែងក្នុងចំណុចទី២នៃមាត្រា៣និងចំណុចទី២នៃមាត្រា៤។

២- ក្នុងករណីមានការខូចខាត បុគ្គលដែលមានសិទ្ធិទទួលអីវ៉ាន់ឬទំនិញផ្ញើ ត្រូវប្ដឹងតវ៉ាទៅក្រុមហ៊ុនដឹកជញ្ជូនភ្លាមៗ បន្ទាប់ពីរកឃើញការខូចខាត និងយ៉ាងយូរបំផុតក្នុងរង្វង់រយៈពេល៧(ប្រាំពីរ)ថ្ងៃ បន្ទាប់ពីថ្ងៃទទួល ចំពោះករណីអីវ៉ាន់ផ្ញើ និងក្នុងរង្វង់រយៈពេល១៤(ដប់បួន)ថ្ងៃ បន្ទាប់ពីថ្ងៃទទួល ចំពោះករណីទំនិញ។ ក្នុងករណីមានភាពយឺតយ៉ាវ ការប្ដឹងតវ៉ាត្រូវធ្វើឡើងយ៉ាងយូរបំផុតក្នុងរង្វង់រយៈពេល២១(ម្ភៃមួយ)ថ្ងៃ ចាប់ពីថ្ងៃដែលអីវ៉ាន់ឬទំនិញនេះត្រូវបានបញ្ជូនដាក់ឱ្យស្ថិតនៅក្នុងការចាត់ចែងរបស់បុគ្គលដែលមានសិទ្ធិទទួល។

១៧/២៣

៣- រាល់ការប្តឹងតវ៉ាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងប្រគល់ឱ្យប្របញ្ជូនចេញនៅក្នុងរង្វង់រយៈពេល ដូចមានចែងខាងលើ។

៤- ប្រសិនបើពុំមានការប្តឹងតវ៉ាណាមួយត្រូវបានធ្វើឡើង នៅក្នុងរង្វង់រយៈពេល ដូចមានចែងខាងលើ រាល់ការប្តឹងតវ៉ាទៅក្រុមហ៊ុនដឹកជញ្ជូនមិនអាចធ្វើបានឡើយ លើកលែងតែក្នុងករណីមានការឆបោកពីក្រុមហ៊ុនដឹកជញ្ជូន។

មាត្រា៣២ .- មរណភាពរបស់បុគ្គលទទួលខុសត្រូវ

ក្នុងករណីដែលបុគ្គលទទួលខុសត្រូវទទួលមរណភាព ការប្តឹងទាមទារសំណងពីអ្នកតំណាងដោយស្របច្បាប់របស់ក្រុមហ៊ុនដឹកជញ្ជូនអាចធ្វើបាន ដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ។

មាត្រា៣៣ .- យុត្តាធិការ

១- បណ្តឹងទាមទារសំណងខូចខាតត្រូវធ្វើឡើងតាមជម្រើសរបស់ដើមបណ្តឹងដែលអាចធ្វើឡើងនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋភាគីណាមួយ ទាំងនៅតុលាការនៃទីតាំងនៃទីស្នាក់ការឬទីកន្លែងអាជីវកម្មចម្បងរបស់ក្រុមហ៊ុនដឹកជញ្ជូន ឬទីតាំងអាជីវកម្មរបស់ក្រុមហ៊ុនតាមរយៈនោះកិច្ចសន្យាត្រូវបានបង្កើតឡើង ឬទៅកាន់តុលាការ នៃទីកន្លែងគោលដៅ។

២- ពាក់ព័ន្ធនឹងការខូចខាតបណ្តាលមកពីមរណភាពឬការរងរបួសរបស់អ្នកដំណើរណាម្នាក់ ពាក្យបណ្តឹងអាចដាក់ទៅតុលាការណាមួយ ក្នុងចំណោមតុលាការ ដូចមានចែងក្នុងចំណុចទី១នៃមាត្រានេះ ឬនៅលើទឹកដីនៃរដ្ឋភាគីណាមួយដែលអ្នកដំណើរមានលំនៅឋានចម្បងនិងអចិន្ត្រៃយ៍តាំងនៅ នៅពេលដែលមានឧបទ្ទវហេតុកើតឡើង និងដែលក្រុមហ៊ុនដឹកជញ្ជូនមានប្រតិបត្តិការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសទៅឬមក ទាំងការប្រើប្រាស់អាកាសយានផ្ទាល់របស់ក្រុមហ៊ុនឬអាកាសយានរបស់ក្រុមហ៊ុនផ្សេងទៀត ផ្អែកលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម មួយ និងដែលនៅក្នុងដែនដីនោះ ក្រុមហ៊ុនដឹកជញ្ជូនធ្វើប្រតិបត្តិការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសចេញពីទីតាំងដែលបានជួល ឬពីទីតាំងដែលជាកម្មសិទ្ធិផ្ទាល់របស់ក្រុមហ៊ុនដឹកជញ្ជូនខ្លួនឯង ឬរបស់ក្រុមហ៊ុនដឹកជញ្ជូន មួយផ្សេងទៀត ដែលមានកិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយគ្នា។

៣- តាមគោលបំណងនៃចំណុចទី២៖

(ក) "កិច្ចព្រមព្រៀងពាណិជ្ជកម្ម" សំដៅលើកិច្ចព្រមព្រៀងមួយ ក្រៅពីកិច្ចព្រមព្រៀងភ្នាក់ងារដែលធ្វើឡើងរវាងក្រុមហ៊ុនដឹកជញ្ជូននានាពាក់ព័ន្ធនឹងការផ្តល់សេវាកម្មដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសរួមគ្នារបស់បុគ្គលទាំងនោះ។

(ខ) "លំនៅឋានចម្បងនិងអចិន្ត្រៃយ៍" សំដៅដល់ទីកន្លែងស្នាក់នៅតែមួយគត់ អចល័ត និងអចិន្ត្រៃយ៍របស់អ្នកធ្វើដំណើរ នៅពេលមានឧបទ្ទវហេតុកើតមានឡើង។ សញ្ជាតិរបស់អ្នកធ្វើដំណើរពុំមែនជាកត្តាកំណត់លើចំណុចនេះទេ។

៤- បញ្ហានីតិវិធីត្រូវគ្រប់គ្រងដោយច្បាប់របស់តុលាការដែលមានសមត្ថកិច្ចទទួលរឿងក្តី។

មាត្រា៣៤ .- មជ្ឈត្តការ

១- យោងតាមបទប្បញ្ញត្តិនៃមាត្រានេះ គូភាគីនៃកិច្ចសន្យាដឹកជញ្ជូនទំនិញអាចចែងថា រាល់ជម្លោះពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ក្រុមហ៊ុនដឹកជញ្ជូន យោងតាមអនុសញ្ញានេះ ត្រូវដោះស្រាយតាមរយៈមជ្ឈត្តកម្ម។ ការព្រមព្រៀងនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

២- ដំណើរការនីតិវិធីមជ្ឈត្តការ ត្រូវធ្វើឡើងតាមជម្រើសរបស់ភាគីប្តឹងទាមទារដែលអាចធ្វើឡើងនៅក្នុងយុត្តាធិការណាមួយ ដូចមានចែងក្នុងមាត្រា៣៣។

៣- មជ្ឈត្តករ ឬវេទិកាមជ្ឈត្តកម្ម ត្រូវអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះ។

៤- បទប្បញ្ញត្តិនៃចំណុចទី២និងចំណុចទី៣នៃមាត្រានេះ ត្រូវចាត់ទុកថា ជាផ្នែកមួយនៃគ្រប់ខចែងអំពីមជ្ឈត្តការ ឬកិច្ចព្រមព្រៀង ហើយខ្លឹមសារទាំងឡាយណាដែលផ្ទុយពីខចែងឬកិច្ចព្រមព្រៀងនេះ ត្រូវចាត់ទុកជាមោឃៈ។

មាត្រា៣៥ .- ដែនកំណត់នៃសកម្មភាពបណ្តឹង

3. As regards baggage or cargo, the passenger or consignor will have a right of action against the first carrier, and the passenger or consignee who is entitled to delivery will have a right of action against the last carrier, and further, each may take action against the carrier which performed the carriage during which the destruction, loss, damage or delay took place. These carriers will be jointly and severally liable to the passenger or to the consignor or consignee.

Article 37 — Right of Recourse against Third Parties

Nothing in this Convention shall prejudice the question whether a person liable for damage in accordance with its provisions has a right of recourse against any other person.

Chapter IV

Combined Carriage

Article 38 — Combined Carriage

1. In the case of combined carriage performed partly by air and partly by any other mode of carriage, the provisions of this Convention shall, subject to paragraph 4 of Article 18, apply only to the carriage by air, provided that the carriage by air falls within the terms of Article 1.

2. Nothing in this Convention shall prevent the parties in the case of combined carriage from inserting in the document of air carriage conditions relating to other modes of carriage, provided that the provisions of this Convention are observed as regards the carriage by air.

Chapter V

Carriage by Air Performed by a Person other than the Contracting Carrier

Article 39 — Contracting Carrier — Actual Carrier

The provisions of this Chapter apply when a person (hereinafter referred to as "the contracting carrier") as a principal makes a contract of carriage governed by this Convention with a passenger or consignor or with a person acting on behalf of the passenger or consignor, and another person (hereinafter referred to as "the actual carrier") performs, by virtue of authority from the contracting carrier, the whole or part of the carriage, but is not with respect to such part a successive carrier within the meaning of this Convention. Such authority shall be presumed in the absence of proof to the contrary.

Article 40 — Respective Liability of Contracting and Actual Carriers

If an actual carrier performs the whole or part of carriage which, according to the contract referred to in Article 39, is governed by this Convention, both the contracting carrier and the actual carrier shall, except as otherwise provided in this Chapter, be subject to the rules of this Convention, the former for the whole of the carriage contemplated in the contract, the latter solely for the carriage which it performs.

Article 41 — Mutual Liability

1. The acts and omissions of the actual carrier and of its servants and agents acting within the scope of their employment shall, in relation to the carriage performed by the actual carrier, be deemed to be also those of the contracting carrier.

2. The acts and omissions of the contracting carrier and of its servants and agents acting within the scope of their employment shall, in relation to the carriage performed by the actual carrier, be deemed to be also those of the actual carrier. Nevertheless, no such act or omission shall subject the actual carrier to liability exceeding the amounts referred to in Articles 21, 22, 23 and 24. Any special agreement under which the contracting carrier assumes obligations not imposed by this Convention or any waiver of rights or defences conferred by this Convention or any special declaration of interest in delivery at destination contemplated in Article 22 shall not affect the actual carrier unless agreed to by it.

Article 42 — Addressee of Complaints and Instructions

Any complaint to be made or instruction to be given under this Convention to the carrier shall have the same effect whether addressed to the contracting carrier or to the actual carrier. Nevertheless, instructions referred to in Article 12 shall only be effective if addressed to the contracting carrier.

Article 43 — Servants and Agents

In relation to the carriage performed by the actual carrier, any servant or agent of that carrier or of the contracting carrier shall, if they prove that they acted within the scope of their employment, be entitled to avail themselves of the conditions and limits of liability which are applicable under this Convention to the carrier whose servant or agent they are, unless it is proved that they acted in a manner that prevents the limits of liability from being invoked in accordance with this Convention.

Article 44 — Aggregation of Damages

In relation to the carriage performed by the actual carrier, the aggregate of the amounts recoverable from that carrier and the contracting carrier, and from their servants and agents acting within the scope of their employment, shall not exceed the highest amount which could be awarded against either the contracting carrier or the actual carrier under this Convention, but none of the persons mentioned shall be liable for a sum in excess of the limit applicable to that person.

Article 45 — Addressee of Claims

In relation to the carriage performed by the actual carrier, an action for damages may be brought, at the option of the plaintiff, against that carrier or the contracting carrier, or against both together or separately

If the action is brought against only one of those carriers, that carrier shall have the right to require the other carrier to be joined in the proceedings, the procedure and effects being governed by the law of the court seised of the case.

Article 46 — Additional Jurisdiction

Any action for damages contemplated in Article 45 must be brought, at the option of the plaintiff, in the territory of one of the States Parties, either before a court in which an action may be brought against the contracting carrier, as provided in Article 33, or before the court having jurisdiction at the place where the actual carrier has its domicile or its principal place of business.

Article 47 — Invalidity of Contractual Provisions

Any contractual provision tending to relieve the contracting carrier or the actual carrier of liability under this Chapter or to fix a lower limit than that which is applicable according to this Chapter shall be null and void, but the nullity of any such provision does not involve the nullity of the whole contract, which shall remain subject to the provisions of this Chapter.

Article 48 — Mutual Relations of Contracting and Actual Carriers

Except as provided in Article 45, nothing in this Chapter shall affect the rights and obligations of the carriers between themselves, including any right of recourse or indemnification.

Chapter VI

Other Provisions

Article 49 — Mandatory Application

Any clause contained in the contract of carriage and all special agreements entered into before the damage occurred by which the parties purport to infringe the rules laid down by this Convention, whether by deciding the law to be applied, or by altering the rules as to jurisdiction, shall be null and void.

Article 50 — Insurance

States Parties shall require their carriers to maintain adequate insurance covering their liability under this Convention. A carrier may be required by the State Party into which it operates to furnish evidence that it maintains adequate insurance covering its liability under this Convention.

Article 51 — Carriage Performed in Extraordinary Circumstances

The provisions of Articles 3 to 5, 7 and 8 relating to the documentation of carriage shall not apply in the case of carriage performed in extraordinary circumstances outside the normal scope of a carrier's business.

Article 52 — Definition of Days

The expression "days" when used in this Convention means calendar days, not working days.

Chapter VII

Final Clauses

Article 53 — Signature, Ratification and Entry into Force

1. This Convention shall be open for signature in Montreal on 28 May 1999 by States participating in the International Conference on Air Law held at Montreal from 10 to 28 May 1999. After 28 May 1999, the Convention shall be open to all States for signature at the Headquarters of the International Civil Aviation Organization in Montreal until it enters into force in accordance with paragraph 6 of this Article.

2. This Convention shall similarly be open for signature by Regional Economic Integration Organisations. For the purpose of this Convention, a "Regional Economic Integration Organisation" means any organisation which is constituted by sovereign States of a given region which has competence in respect of certain matters governed by this Convention and has been duly authorized to sign and to ratify, accept, approve or accede to this Convention. A reference to a "State Party" or "States Parties" in this Convention, otherwise than in paragraph 2 of Article 1, paragraph 1(b) of Article 3, paragraph (b) of Article 5, Articles 23, 33, 46 and paragraph (b) of Article 57, applies equally to a Regional Economic Integration Organisation. For the purpose of Article 24, the references to "a majority of the States Parties" and "one-third of the States Parties" shall not apply to a Regional Economic Integration Organisation.

3. This Convention shall be subject to ratification by States and by Regional Economic Integration Organisations which have signed it.

4. Any State or Regional Economic Integration Organisation which does not sign this Convention may accept, approve or accede to it at any time.

5. Instruments of ratification, acceptance, approval or accession shall be deposited with the International Civil Aviation Organization, which is hereby designated the Depositary.

6. This Convention shall enter into force on the sixtieth day following the date of deposit of the thirtieth instrument of ratification, acceptance, approval or accession with the Depositary between the States which have deposited such instrument. An instrument deposited by a Regional Economic Integration Organisation shall not be counted for the purpose of this paragraph.

7 For other States and for other Regional Economic Integration Organisations, this Convention shall take effect sixty days following the date of deposit of the instrument of ratification, acceptance, approval or accession.

8. The Depositary shall promptly notify all signatories and States Parties of:

(a) each signature of this Convention and date thereof;

(b) each deposit of an instrument of ratification, acceptance, approval or accession and date thereof;

(c) the date of entry into force of this Convention;

(d) the date of the coming into force of any revision of the limits of liability established under this Convention;

(e) any denunciation under Article 54.

Article 54 — Denunciation

1. Any State Party may denounce this Convention by written notification to the Depositary.

2. Denunciation shall take effect one hundred and eighty days following the date on which notification is received by the Depositary.

Article 55 — Relationship with other Warsaw Convention Instruments

This Convention shall prevail over any rules which apply to international carriage by air:

1. between States Parties to this Convention by virtue of those States commonly being Party to

(a) the *Convention for the Unification of Certain Rules Relating to International Carriage by Air* Signed at Warsaw on 12 October 1929 (hereinafter called the Warsaw Convention);

(b) the *Protocol to Amend the Convention for the Unification of Certain Rules Relating to International Carriage by Air Signed at Warsaw on 12 October 1929*, Done at The Hague on 28 September 1955 (hereinafter called The Hague Protocol);

(c) the *Convention, Supplementary to the Warsaw Convention, for the Unification of Certain Rules Relating to International Carriage by Air Performed by a Person Other than the Contracting Carrier*, signed at Guadalajara on 18 September 1961 (hereinafter called the Guadalajara Convention);

(d) the *Protocol to Amend the Convention for the Unification of Certain Rules Relating to International Carriage by Air Signed at Warsaw on 12 October 1929 as Amended by the Protocol Done at The Hague on 28 September 1955* Signed at Guatemala City on 8 March 1971 (hereinafter called the Guatemala City Protocol),

(e) Additional Protocol Nos. 1 to 3 and Montreal Protocol No. 4 to amend the Warsaw Convention as amended by The Hague Protocol or the Warsaw Convention as amended by

both The Hague Protocol and the Guatemala City Protocol Signed at Montreal on 25 September 1975 (hereinafter called the Montreal Protocols); or

2. within the territory of any single State Party to this Convention by virtue of that State being Party to one or more of the instruments referred to in sub-paragraphs (a) to (e) above.

Article 56 — States with more than one System of Law

1. If a State has two or more territorial units in which different systems of law are applicable in relation to matters dealt with in this Convention, it may at the time of signature, ratification, acceptance, approval or accession declare that this Convention shall extend to all its territorial units or only to one or more of them and may modify this declaration by submitting another declaration at any time.

2. Any such declaration shall be notified to the Depositary and shall state expressly the territorial units to which the Convention applies.

3. In relation to a State Party which has made such a declaration:

(a) references in Article 23 to "national currency" shall be construed as referring to the currency of the relevant territorial unit of that State; and

(b) the reference in Article 28 to "national law" shall be construed as referring to the law of the relevant territorial unit of that State.

Article 57 — Reservations

No reservation may be made to this Convention except that a State Party may at any time declare by a notification addressed to the Depositary that this Convention shall not apply to:

(a) international carriage by air performed and operated directly by that State Party for non-commercial purposes in respect to its functions and duties as a sovereign State; and/or

(b) the carriage of persons, cargo and baggage for its military authorities on aircraft registered in or leased by that State Party, the whole capacity of which has been reserved by or on behalf of such authorities.

IN WITNESS WHEREOF the undersigned Plenipotentiaries, having been duly authorized, have signed this Convention.

DONE at Montreal on the 28th day of May of the year one thousand nine hundred and ninety-nine in the English, Arabic, Chinese, French, Russian and Spanish languages, all texts being equally authentic. This Convention shall remain deposited in the archives of the International Civil Aviation Organization, and certified copies thereof shall be transmitted by the Depositary to all States Parties to this Convention, as well as to all States Parties to the Warsaw Convention, The Hague Protocol, the Guadalajara Convention, the Guatemala City Protocol, and the Montreal Protocols.

នស/រកម/១១២៤/ ០០៤

ព្រះរាជក្រម

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីនិរាករណ៍ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការជំរុញ និងសម្រួលពាណិជ្ជកម្មតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៤ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យនិងឱ្យយោបល់កែសម្រួលលើទម្រង់និងគតិច្បាប់នេះកាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៤ នាសម័យប្រជុំព្រឹទ្ធសភាលើកទី២ នីតិកាលទី៥ ព្រមទាំងរដ្ឋសភាបានអនុម័តជាលើកទី២ដោយវិធីបោះឆ្នោតចំហកាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៧ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ច្បាប់
ស្តីពី
និរាករណ៍ច្បាប់ស្តីពីការអនុម័តយល់ព្រមលើ កិច្ចព្រមព្រៀងស្តីពីការជំរុញ និងសម្រួល ពាណិជ្ជកម្មតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២/៣

មាត្រា១ .-

ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្ដីពីការជំរុញ និងសម្រួលពាណិជ្ជកម្មតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៤ ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៨ ត្រូវទុកជានិរាករណ៍។

មាត្រា២ .-

ច្បាប់នេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃដែលការដកខ្លួនរបស់ព្រះរាជាណាចក្រកម្ពុជាបានចូលជាស្ថាពរ ដោយផ្អែកតាមកិច្ចព្រមព្រៀងស្ដីពីការជំរុញ និងសម្រួលពាណិជ្ជកម្មតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម។

មាត្រា៣ .-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តរាល់នីតិវិធី និងកិច្ចការចាំបាច់នានាដើម្បីធានាដល់ការដកខ្លួនជាស្ថាពរចេញពីកិច្ចព្រមព្រៀងស្ដីពីការជំរុញ និងសម្រួលពាណិជ្ជកម្មតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម។

មាត្រា៤ .-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃព្រហស្បតិ៍ ៦រោច ខែកត្ដិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០២៤

ចរល.២៤១១.១២៤២

នរោត្តម សីហមុនី

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ដលេខា
នាយករដ្ឋមន្ត្រី

សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម និម្មល

៣/៣

នស/រកម/១១២៤/០០៥

ព្រះរាជក្រម

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីប្រព័ន្ធទឹកកខ្វក់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៤ នាសម័យប្រជុំព្រឹទ្ធសភាលើកទី២ នីតិកាលទី៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

១ / ៣២

ច្បាប់
ស្ដីពី
ប្រព័ន្ធទឹកកខ្វក់

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

ច្បាប់នេះកំណត់អំពីការគ្រប់គ្រង ការអភិវឌ្ឍ ការសាងសង់ ការជួសជុល ការថែទាំ ការធ្វើប្រតិបត្តិការ និងការប្រើប្រាស់ប្រព័ន្ធទឹកកខ្វក់ ក្នុងគោលបំណងដើម្បីធានាប្រសិទ្ធភាព គុណភាព សុវត្ថិភាព និងនិរន្តរភាព នៃប្រព័ន្ធទឹកកខ្វក់ និងការការពារបរិស្ថាន រួមចំណែកធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា២ .-

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះប្រព័ន្ធទឹកកខ្វក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា៣ .-

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

ជំពូកទី២
សមត្ថកិច្ចគ្រប់គ្រង

មាត្រា៤ .-

ការអភិវឌ្ឍប្រព័ន្ធទឹកកខ្វក់ ស្ថិតក្រោមការទទួលខុសត្រូវដោយផ្ទាល់របស់រដ្ឋ។ រដ្ឋអាចផ្តល់សិទ្ធិជូនវិស័យឯកជនអភិវឌ្ឍនិងគ្រប់គ្រងប្រតិបត្តិការប្រព័ន្ធទឹកកខ្វក់ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្រសួងសាធារណការនិងដឹកជញ្ជូនមានសមត្ថកិច្ចគ្រប់គ្រងលើការអភិវឌ្ឍប្រព័ន្ធទឹកកខ្វក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

រដ្ឋបាលថ្នាក់ក្រោមជាតិ មានសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធលូនិងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងការងារប្រព័ន្ធទឹកកខ្វក់ផ្សេងទៀតតាមការប្រគល់ឬផ្ទេរប្រតិភូកម្មពីក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍប្រព័ន្ធទឹកកខ្វក់ ក្រោយពីមានការឯកភាពពីរាជរដ្ឋាភិបាល។

ការបែងចែកមុខងារនិងភារកិច្ចលើការគ្រប់គ្រងប្រព័ន្ធលូនិងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់របស់ស្ថាប័ននីមួយៗត្រូវកំណត់ដោយអនុក្រឹត្យ។

ជំពូកទី៣
គោលការណ៍

មាត្រា៥ .-

ច្បាប់នេះមានគោលការណ៍ជាមូលដ្ឋាន៖

- ការគ្រប់គ្រងទឹកកខ្វក់ ត្រូវអនុលោមតាមស្តង់ដាតម្រូវនៃក្រមបរិស្ថាននិងធនធានធម្មជាតិ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ការអភិវឌ្ឍ ការសាងសង់ ការជួសជុល ការថែទាំ និងការធ្វើប្រតិបត្តិការប្រព័ន្ធទឹកកខ្វក់ ត្រូវអនុលោមតាមលិខិតបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិបច្ចេកទេសប្រព័ន្ធទឹកកខ្វក់ ស្របទៅតាមជីវសាស្ត្រ [illegible]និងស្ថានភាពសេដ្ឋកិច្ចជាតិ
- ការវិនិយោគលើប្រព័ន្ធទឹកកខ្វក់ ត្រូវបានជំរុញនិងលើកទឹកចិត្តតាមគ្រប់ទម្រង់

- ការផ្តល់និងការប្រើប្រាស់ប្រព័ន្ធលូត្រូវប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងនិរន្តរភាព
- ការគ្រប់គ្រងនិងការប្រើប្រាស់ប្រព័ន្ធទឹកកខ្វក់ដែលមានស្រាប់ត្រូវឱ្យមានសង្គតិភាព។

ជំពូកទី៤
ផែនការមេអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់
ផ្នែកទី១
ការរៀបចំផែនការមេអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់

មាត្រា៦ .-

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំផែនការមេអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ផែនការមេអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់ ត្រូវអនុលោមតាមស្ថានភាពភូមិសាស្ត្រនៃតំបន់នីមួយៗ ដោយផ្អែកលើមូលដ្ឋានគ្រឹះសំខាន់ៗនៃការអភិវឌ្ឍក្រុង ទីប្រជុំជន តំបន់ជនបទ សហគមន៍ តំបន់បណ្តុំលំនៅឋាន តំបន់បង្ហូរទឹកកខ្វក់ សំណល់ទឹកភ្លៀងនៅតាមបណ្តាញផ្លូវថ្នល់ និងអត្រាកំណើនប្រជាពលរដ្ឋក្នុងតំបន់នីមួយៗ ដែលមានសំណូមពរ និងតម្រូវការសាងសង់ ប្រើប្រាស់ និងបញ្ចេញចោលទឹកកខ្វក់។

ផែនការមេអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់ត្រូវរៀបចំឱ្យមានសង្គតិភាពជាមួយនឹងគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ និងគោលនយោបាយជាតិពាក់ព័ន្ធផ្សេងទៀត និងត្រូវធ្វើការតាមដានត្រួតពិនិត្យនិងវាយតម្លៃឡើងវិញក្នុងរយៈពេលយ៉ាងយូរ១០(ដប់)ឆ្នាំ ស្របតាមការអភិវឌ្ឍក្រុង ទីប្រជុំជន តំបន់ជនបទ សហគមន៍ កំណើនប្រជាពលរដ្ឋ តម្រូវការនៃការសាងសង់ និងការប្រើប្រាស់ជាក់ស្តែង។

ផែនការមេអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់ ត្រូវសម្រេចដោយរាជរដ្ឋាភិបាល។

មាត្រា៧ .-

តំបន់អាទិភាពដែលចាំបាច់ត្រូវរៀបចំផែនការមេអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់ មានជាអាទិ៍៖

១- តំបន់មានការត្រួតពិនិត្យការបំពុលទឹក។
២- តំបន់ការពារគុណភាពទឹកនិងបរិមាណទឹកនៅក្នុងតំបន់ធម្មជាតិ។
៣- តំបន់អភិវឌ្ឍន៍ថ្មី ក្រុងថ្មី តំបន់សាងសង់បុរី តំបន់អាជីវកម្ម និងតំបន់រៀបចំដីឡូត៍ថ្មី។
៤- តំបន់ឬមណ្ឌលពាណិជ្ជកម្មនិងផលិតកម្ម តំបន់ទេសចរណ៍និងសេវាកម្ម។
៥- តំបន់សេដ្ឋកិច្ចពិសេស ឬសួនឧស្សាហកម្ម ឬសួនននវានុវត្តន៍ ឬតំបន់កសិឧស្សាហកម្ម។

ការកំណត់តំបន់អាទិភាពផែនការមេអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់ត្រូវសម្រេចដោយរាជរដ្ឋាភិបាល។

មាត្រា៨ .-

ការរៀបចំផែនការមេអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់ ត្រូវផ្តោតលើចំណុចដូចខាងក្រោម៖

- តំបន់គ្របដណ្តប់ប្រព័ន្ធទឹកកខ្វក់និងលក្ខខណ្ឌដែលត្រូវធ្វើប្រព្រឹត្តកម្មនិងបង្ហូរចេញ
- ការតម្រង់ទិសគោលនយោបាយនិងយុទ្ធសាស្ត្រអនុវត្តសម្រាប់ធ្វើប្រព្រឹត្តកម្មទឹកកខ្វក់ និងការពិពណ៌នាផែនការអនុវត្តលម្អិត
- ការលើកកម្ពស់គម្រោងពង្រីកប្រព័ន្ធទឹកកខ្វក់ក្នុងតំបន់នានា និងការពង្រីកវិសាលភាពរៀបចំឡើងវិញនៃប្រព័ន្ធលូ

- ការរៀបចំគម្រោង គំនូរប្លង់ រចនាសម្ព័ន្ធ និងសមត្ថភាពនៃបបនីយកណ្ឌទឹកកខ្វក់
- ការសិក្សាស្ថានភាពទីតាំងរចនាសម្ព័ន្ធដែលមានស្រាប់ ឋានលេខាសាស្ត្រ លំហូរល្បាយ ចរន្តប្រភពទឹក និងលក្ខខណ្ឌធម្មជាតិផ្សេងទៀតដែលមានក្នុងតំបន់គម្រោង
- ការប្រើប្រាស់ដីនិងការអភិវឌ្ឍប្រព័ន្ធទឹកកខ្វក់
- ការកែលម្អឬការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធទឹកកខ្វក់ និងការប្រើប្រាស់ទឹក
- ការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍ និងការបណ្តុះបណ្តាលធនធានមនុស្សដែលទាក់ទងនឹងការងារប្រព័ន្ធទឹកកខ្វក់
- ការប៉ាន់ស្មានតម្លៃនិងតម្រូវការចំណាយអនុវត្តគម្រោង រួមទាំងធ្វើវិភាគផលចំណេញនិងទិដ្ឋភាពពាក់ព័ន្ធផ្សេងទៀតលើការអភិវឌ្ឍប្រព័ន្ធទឹកកខ្វក់។

លក្ខខណ្ឌនិងនីតិវិធីនៃការរៀបចំផែនការមេអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ផ្នែកទី២
ការរៀបចំគម្រោងអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់

មាត្រា៩ .-

ការរៀបចំគម្រោងអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់ ត្រូវអនុវត្តតាមដំណាក់កាលដូចខាងក្រោម៖

១- ព័ត៌មាននិងទិន្នន័យជាមូលដ្ឋាន។
២- នីតិវិធីនៃលំហូរការងារសិក្សាគម្រោងប្លង់។
៣- ប្រភេទនិងគុណភាពឬភាពធន់នៃលូ។
៤- ប្រភេទនិងសំណង់អណ្តូងលូ។
៥- កម្រាលបាត ការតភ្ជាប់និងការដំឡើងលូ។

ការរៀបចំគម្រោងអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់លម្អិត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា១០ .-

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំគម្រោងអភិវឌ្ឍន៍ប្រព័ន្ធលូនិងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ឱ្យសមស្របតាមស្ថានភាពភូមិសាស្ត្រដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយត្រូវស្នើសុំយោបល់បច្ចេកទេសពីក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួង ស្ថាប័នពាក់ព័ន្ធ និងត្រូវអនុលោមតាមផែនការមេអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់ដែលសម្រេចដោយរាជរដ្ឋាភិបាល។

ក្នុងករណីចាំបាច់ រដ្ឋបាលថ្នាក់ក្រោមជាតិ អាចស្នើសុំឱ្យក្រសួងសាធារណការនិងដឹកជញ្ជូន រៀបចំគម្រោងអភិវឌ្ឍន៍ប្រព័ន្ធលូនិងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

មាត្រា១១ .-

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការតាមដានត្រួតពិនិត្យនិងវាយតម្លៃលើការរៀបចំគម្រោងអភិវឌ្ឍន៍ប្រព័ន្ធលូនិងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

លក្ខខណ្ឌនិងនីតិវិធីនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការរៀបចំគម្រោងអភិវឌ្ឍន៍ប្រព័ន្ធលូនិងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ត្រូវកំណត់ដោយអនុក្រឹត្យ។

ជំពូកទី៥
ប្រភេទប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់និងប្រព័ន្ធលូ

មាត្រា១២ .-

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវរៀបចំបែងចែកប្រភេទប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់និងប្រព័ន្ធលូ តាមមុខងារជាក់លាក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសប្រព័ន្ធទឹកកខ្វក់ដូចមានចែងក្នុងមាត្រា៧០នៃច្បាប់នេះ និងត្រូវធ្វើបញ្ជីសារពើភណ្ឌប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់និងប្រព័ន្ធលូ ដោយពិគ្រោះជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងរយៈពេលយ៉ាងយូរបំផុត៥(ប្រាំ)ឆ្នាំម្តង ដើម្បីបែងចែកប្រភេទប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់និងប្រព័ន្ធលូ ឬកែប្រែប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់និងប្រព័ន្ធលូ។

មាត្រា១៣ .-

ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ត្រូវបែងចែកជា ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ អាងចម្រោះទឹកកខ្វក់ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតទ្រទ្រង់ឱ្យប្រព័ន្ធទឹកកខ្វក់។

ការបែងចែកប្រភេទនិងទំហំប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នីមួយៗ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូននិងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

មាត្រា១៤ .-

ប្រព័ន្ធលូត្រូវបែងចែកជា បណ្តាញលូរួមនិងបណ្តាញលូញែក តាមប្រភេទនិងទំហំបណ្តាញលូនីមួយៗ។

ការបែងចែកប្រព័ន្ធលូ ប្រភេទ និងទំហំបណ្តាញលូនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ជំពូកទី៦
ការអភិវឌ្ឍប្រព័ន្ធទឹកកខ្វក់
ផ្នែកទី១
ការសាងសង់ ការស្តារឡើងវិញ និងការពង្រីកប្រព័ន្ធទឹកកខ្វក់

មាត្រា១៥ .-

រដ្ឋជំរុញនិងលើកទឹកចិត្តតាមគ្រប់ទម្រង់ដល់ការចូលរួមអភិវឌ្ឍ សាងសង់ ស្តារឡើងវិញ និងពង្រីកប្រព័ន្ធទឹកកខ្វក់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

មាត្រា១៦ .-

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ត្រូវជំរុញការសាងសង់ ការស្តារឡើងវិញ និងការពង្រីកប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅក្នុងរាជធានី ទីប្រជុំជននានានៃខេត្ត ក្រុង ស្រុក ខណ្ឌ ឱ្យបានគ្រប់គ្រាន់ ដើម្បីបម្រើតម្រូវការប្រើប្រាស់និងផ្តល់សេវាប្រើប្រាស់ប្រព័ន្ធលូឱ្យសមស្របតាមស្ថានភាពភូមិសាស្ត្រនៃតំបន់នីមួយៗ ដោយអនុលោមតាមផែនការមេអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់។

មាត្រា១៧ .-

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ឬវិស័យឯកជនដែលទទួលបានសិទ្ធិក្នុងការអភិវឌ្ឍ ការសាងសង់ ការស្តារឡើងវិញ ឬការពង្រីកប្រព័ន្ធទឹកកខ្វក់ ត្រូវអនុវត្តតាមគម្រោងប្លង់សាងសង់និងកិច្ចសន្យា និងត្រូវគោរពតាមបទប្បញ្ញត្តិបច្ចេកទេសប្រព័ន្ធទឹកកខ្វក់ដូចមានចែងក្នុងមាត្រា៧០នៃច្បាប់នេះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

រាល់ការអភិវឌ្ឍ ការសាងសង់ ការស្តារឡើងវិញ និងការពង្រីកប្រព័ន្ធទឹកកខ្វក់ ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ត្រូវធ្វើការបែងចែកតាមប្រភេទ និងទំហំដូចមានចែងក្នុងមាត្រា១៣ និងមាត្រា១៤ នៃច្បាប់នេះ។

មាត្រា១៨ .-

បុគ្គលដែលទទួលបានគម្រោងសាងសង់ត្រូវចាប់ផ្តើមអនុវត្តភ្លាម បន្ទាប់ពីបានជូនដំណឹងជាសាធារណៈ ឬទទួលបានលិខិតជូនដំណឹងពីសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់។ មុនពេលនិងក្នុងពេលកំពុងដំណើរការសាងសង់ បុគ្គលដែលអនុវត្តគម្រោងសាងសង់ត្រូវអនុវត្តតាមបទប្បញ្ញត្តិសុវត្ថិភាពការងារ និងវិធានការសុវត្ថិភាពចរាចរណ៍ មានជាអាទិ៍ ត្រូវរៀបចំដាក់សញ្ញាប្រាប់ដំណឹង របងការពារបណ្តោះអាសន្ន បរិក្ខារចរាចរណ៍ និងត្រូវប្រតិបត្តិតាមវិធានការដែលធានាដល់សុវត្ថិភាពចរាចរណ៍។

បុគ្គលដែលអនុវត្តគម្រោងសាងសង់ត្រូវធ្វើការត្រួតពិនិត្យឡើងវិញ ដោយអនុលោមតាមចំណុចនីមួយៗដែលចែងក្នុងកិច្ចសន្យា នៅពេលគម្រោងត្រូវបញ្ចប់ជាស្ថាពរ។ ក្នុងករណីគម្រោងនោះមានភាពរអាក់រអួល បុគ្គលដែលអនុវត្តគម្រោងសាងសង់ត្រូវរៀបចំរបាយការណ៍លម្អិតអំពីការប្រែប្រួលនៃគម្រោងជូនស្ថាប័នមានសមត្ថកិច្ច។

មាត្រា១៩ .-

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ត្រូវរក្សាទុកឯកសារពាក់ព័ន្ធនឹងគម្រោងប្រព័ន្ធទឹកកខ្វក់ និងកត់ត្រាទុកព័ត៌មានក្នុងប្រព័ន្ធព័ត៌មានវិទ្យាឬប្រព័ន្ធឌីជីថលនិងបណ្ណសារដ្ឋានរបស់ខ្លួន បន្ទាប់ពីគម្រោងសាងសង់ គម្រោងស្តារឡើងវិញ ឬគម្រោងពង្រីកនោះត្រូវបញ្ចប់ជាស្ថាពរ។

ព័ត៌មាននិងឯកសារពាក់ព័ន្ធដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ដែលត្រូវកត់ត្រានិងរក្សាទុកមានដូចខាងក្រោម៖

- គម្រោងប្លង់នៃតំបន់ប្រព័ន្ធទឹកកខ្វក់
- ទីតាំងតំបន់ដីកកប់ប្រព័ន្ធបែងចែកបណ្តាញលូ
- ទីតាំងផ្តេកឬទីតាំងបញ្ឈរនៃផ្នែកបណ្តាញលូណាមួយ ដោយរួមទាំងសម្ភារៈបរិក្ខារ និងគ្រឿងបង្គុំលូដែលប្រើប្រាស់សម្រាប់បណ្តាញលូ
- ផ្ទៃរាបសម្រាប់ធ្វើប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងបរិក្ខាបណ្តាញលូ ដ្យាក្រាមពាក់ព័ន្ធនឹងកម្រិតឬនីវ៉ូទឹក និងផែនទីគំនូរបង្ហាញពីហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទឹកកខ្វក់
- ទីតាំងនិងគម្រោងប្លង់សម្រាប់ទឹកកខ្វក់ហូរចូល
- ទិន្នន័យវិភាគកម្រិតសារធាតុបំពុលនិងបរិមាណទឹកកខ្វក់ហូរចូល
- កាលបរិច្ឆេទនៃការចាប់ផ្តើមសាងសង់និងការបញ្ចប់ការសាងសង់ជាស្ថាពរ
- បញ្ហាផ្សេងៗដែលត្រូវបានកត់ត្រាក្នុងពេលប្រតិបត្តិការ ការថែទាំ និងការអនុវត្តគម្រោង។

ផ្នែកទី២
ការប្រើប្រាស់ដី

មាត្រា២០ .-

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់អាចប្រើប្រាស់ដីសម្រាប់បម្រើឱ្យការសាងសង់សំណង់សិល្បការ្យប្រព័ន្ធទឹកកខ្វក់ដែលមាននៅក្នុងផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងដីចំណីតាមបណ្តាញផ្លូវ ឬដីចំណីទន្លេ ឬសមុទ្រ និង/ឬដីឯកជន បន្ទាប់ពីគម្រោងសាងសង់នោះទទួលបានការឯកភាពពីរាជរដ្ឋាភិបាល។

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ត្រូវស្នើសុំដល់ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធឬម្ចាស់ដី ដើម្បីរៀបចំនិងរក្សាទុកដីទាំងនោះសម្រាប់សាងសង់សំណង់សិល្បការ្យប្រព័ន្ធទឹកកខ្វក់ ដោយអនុលោម តាមបទប្បញ្ញត្តិនៃច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា២១ .–

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ត្រូវបញ្ជាក់ហេតុផលឱ្យបានច្បាស់លាស់អំពីការប្រើប្រាស់ដី ដូចមានចែងក្នុងមាត្រា២០នៃច្បាប់នេះ ក្នុងការសាងសង់សំណង់សិល្បការ្យប្រព័ន្ធទឹកកខ្វក់។

ហេតុផលដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ មានដូចខាងក្រោម៖

១- បម្រើផលប្រយោជន៍សាធារណៈនិងផលប្រយោជន៍ជាតិ។

២- លើកកម្ពស់សុខភាពសាធារណៈនិងបរិស្ថាន។

៣- បង្កើនសោភណភាពក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសហគមន៍។

៤- ចូលរួមទាក់ទាញទេសចរ ដើម្បីបង្កើនផលប្រយោជន៍សេដ្ឋកិច្ចជាតិនិងសហគមន៍។

៥- ព្យាករការចាប់ផ្ដើមដំណើរការ កម្រិត វិធីសាស្ត្រ និងរយៈពេលនៃការសាងសង់។

៦- ផ្ដល់ហេតុផលចាំបាច់ផ្សេងទៀត។

មាត្រា២២ .–

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ត្រូវផ្ដល់ព័ត៌មាននិងជនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់ អចលនវត្ថុនិង/ឬម្ចាស់សិទ្ធិនិងអ្នកប្រើប្រាស់ប្រព័ន្ធលូក្នុងតំប[illegible]្រូវការចាំបាច់នៃការប្រើប្រាស់ដី និង ហេតុផលដូចមានចែងក្នុងមាត្រា២០និងមាត្រា២១នៃច្បាប់នេះ ដើម្បីចូលរួមសហការដោះស្រាយផល ប៉ះពាល់ពាក់ព័ន្ធនឹងគម្រោង។

ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិ ដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ខាងលើ ត្រូវទទួលបានសំណងជាមុនដោយសមរម្យនិងយុត្តិធម៌ និងត្រូវអនុលោមតាមច្បាប់ស្ដីពីអស្សាមិករណ៍។

មាត្រា២៣ .–

ម្ចាស់អចលនវត្ថុនិង/ឬម្ចាស់សិទ្ធិនៃទីតាំងទាំងអស់មិនត្រូវធ្វើការផ្លាស់ប្ដូរឬកែប្រែបណ្ដាញលូ និងសំណង់សិល្បការ្យទឹកកខ្វក់ ដែលកំពុងប្រើប្រាស់រាល់ថ្ងៃនៅក្នុងទីតាំងរបស់ខ្លួន ឬទីតាំងសាធារណៈ ដោយគ្មានការអនុញ្ញាតពីសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់នោះឡើយ។

ផ្នែកទី៣
ការសាងសង់ប្រព័ន្ធទឹកកខ្វក់ក្នុងតំបន់អភិវឌ្ឍន៍ថ្មី

មាត្រា២៤ .–

ការបង្កើតតំបន់អភិវឌ្ឍន៍ថ្មីៗ ដូចជាក្រុង ទីក្រុងរណប កំពង់ផែ អាកាសយានដ្ឋាន ស្ថានីយរថភ្លើង តំបន់សេដ្ឋកិច្ចពិសេស សួនឧស្សាហកម្ម សួននវានុវត្តន៍ តំបន់ពាណិជ្ជកម្ម តំបន់កសិឧស្សាហកម្ម តំបន់ទេសចរណ៍ និងតំបន់ផ្សេងទៀតត្រូវសាងសង់ប្រព័ន្ធទឹកកខ្វក់ឱ្យបានគ្រប់គ្រាន់ ស្របតាមលក្ខខណ្ឌបច្ចេកទេស និង[illegible]បច្ចេកទេសប្រព័ន្ធទឹកកខ្វក់ដូចមានចែងក្នុងមាត្រា៧០នៃច្បាប់នេះ ដើម្បីបំពេញតម្រូវការ [illegible] និង[illegible]សេវាប្រើប្រាស់ប្រព័ន្ធលូ ក្នុងតំបន់ឬទីតាំងអភិវឌ្ឍន៍ថ្មីទាំងនោះ មុននឹងតភ្ជាប់ជាមួយ [illegible]

លក្ខខណ្ឌបច្ចេកទេសនៃការសាងសង់ប្រព័ន្ធទឹកកខ្វក់ក្នុងតំបន់អភិវឌ្ឍន៍ថ្មីត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា២៥ .-

តំបន់អភិវឌ្ឍន៍ថ្មីត្រូវសាងសង់បណ្តាញលូញែក ដើម្បីបង្ការមិនឱ្យទឹកភ្លៀងហូរចូលទៅក្នុងអាងចម្រោះទឹកកខ្វក់ និងងាយស្រួលក្នុងការចម្រោះ លើកលែងតែមានការសម្រេចផ្សេងពីរាជរដ្ឋាភិបាល។

ផ្នែកទី៤
ការសាងសង់បណ្តាញទឹកកខ្វក់នៃទីតាំងអគារ

មាត្រា២៦ .-

រាល់ការសាងសង់អគារឬមណ្ឌលអាជីវកម្មនិងផលិតកម្ម ឬទីតាំងប្រហាក់ប្រហែលផ្សេងទៀត ត្រូវសាងសង់អាងប្រព្រឹត្តកម្មទឹកកខ្វក់ បណ្តាញលូនិងសំណង់សិល្បការ្យទឹកកខ្វក់ផ្សេងទៀតឱ្យបានគ្រប់គ្រាន់ និងសមស្របតាមបទប្បញ្ញត្តិបច្ចេកទេសប្រព័ន្ធទឹកកខ្វក់ ដូចមានចែងក្នុងមាត្រា៧០នៃច្បាប់នេះ មុននឹងតភ្ជាប់ជាមួយបណ្តាញលូ។

បុគ្គលដែលជាម្ចាស់ទីតាំងនៃអគារឬមណ្ឌលអាជីវកម្មនិងផលិតកម្មឬទីតាំងប្រហាក់ប្រហែលផ្សេងទៀត ត្រូវរៀបចំគម្រោងប្លង់លម្អិតនៃការសាងសង់អាងប្រព្រឹត្តកម្មទឹកកខ្វក់ បណ្តាញលូនិងសំណង់សិល្បការ្យទឹកកខ្វក់ផ្សេងទៀត ដាក់បញ្ចូលក្នុងគម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ ដើម្បីស្នើសុំការអនុញ្ញាតពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធស្របតាមច្បាប់ស្តីពីសំណង់។

មាត្រា២៧ .-

ការសាងសង់អាងប្រព្រឹត្តកម្មទឹកកខ្វក់និង/ឬបណ្តាញលូដែលមានទីតាំងស្ថិតនៅក្បែរអគារត្រូវហាមឃាត់ ក្នុងករណីដូចខាងក្រោម៖

១- អាចបង្កឱ្យមានបញ្ហាដល់គ្រឹះអគារឬគ្រឹះអគារផ្សេងទៀតនៅក្បែរខាង។

២- អាចរំខានដល់ប្រព័ន្ធទឹកស្អាត ឬអគ្គិសនីក្រោមដី និង/ឬ បណ្តាញក្រោមដីផ្សេងៗទៀត។

៣- ស្ថិតនៅក្បែរប្រព័ន្ធការពារសុវត្ថិភាព សន្តិសុខ និងសុខភាពសាធារណៈ ដែលអាចងាយបង្កឱ្យមានគ្រោះថ្នាក់ជាយថាហេតុ។

ការសាងសង់អាងប្រព្រឹត្តកម្មទឹកកខ្វក់និង/ឬបណ្តាញលូខាងលើ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានការឯកភាពពីវិស្វករទទួលបន្ទុក
- ត្រូវច្នៃប្រឌិតនិងធ្វើឱ្យប្រាកដថាគ្រឹះអគារមិនត្រូវបានរំខានឬប៉ះពាល់ដោយការសាងសង់អាងប្រព្រឹត្តកម្មទឹកកខ្វក់និង/ឬបណ្តាញលូ
- ត្រូវច្នៃប្រឌិតនិងធ្វើឱ្យប្រាកដថា សេវាប្រព័ន្ធទឹកស្អាតឬអគ្គិសនីក្រោមដីទាំងនោះមិនត្រូវបានប៉ះពាល់
- ត្រូវច្នៃប្រឌិតនិងធ្វើឱ្យប្រាកដថា សុវត្ថិភាព សន្តិសុខ និងសុខភាពសាធារណៈត្រូវបានការពារ [illegible]ភាព។

ការជីកកកាយនិងសាងសង់នៅក្បែរអគារឬក្បែរប្រព័ន្ធទឹកស្អាតឬអគ្គិសនីក្រោមដី និង/ឬ បណ្តាញក្រោមដីផ្សេងៗទៀត ដើម្បីផ្លាស់ប្តូរ ទីតាំង ផ្លាស់ប្តូរថ្មី ឬជួសជុលបណ្តាញលូ ត្រូវមានរបាយការណ៍បច្ចេកទេស[illegible]លក្ខណ៍អក្សរមកសមត្ថកិច្ច គ្រប់គ្រងប្រព័ន្ធទឹកកខ្វក់។

មាត្រា២៨ .-

ការសាងសង់អាងប្រព្រឹត្តកម្មទឹកកខ្វក់និង/ឬបណ្ដាញលូ ដែលមានទីតាំងស្ថិតនៅក្រោមអគារអាចត្រូវបានអនុញ្ញាតក្នុងករណីដូចខាងក្រោម៖

១- អគារនោះតម្រូវឱ្យសាងសង់អាងប្រព្រឹត្តកម្មទឹកកខ្វក់និង/ឬបណ្ដាញលូជាចាំបាច់។

២- ទីតាំងអាងប្រព្រឹត្តកម្មទឹកកខ្វក់និងបណ្ដាញលូ គ្មានជម្រើសធ្វើនៅកន្លែងផ្សេងក្រៅពីក្រោមអគារ។

ការសាងសង់អាងប្រព្រឹត្តកម្មទឹកកខ្វក់និង/ឬបណ្ដាញលូដែលមានទីតាំងស្ថិតនៅក្រោមអគារ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានការឯកភាពពីវិស្វករទទួលបន្ទុក
- ត្រូវដាក់បណ្ដាញលូនៅក្រោមអគារសមស្របតាមលក្ខណៈបច្ចេកទេស
- ត្រូវដាក់បណ្ដាញលូមានគម្លាតសុវត្ថិភាពបច្ចេកទេសរវាងគ្រឹះអគារនីមួយៗនិងផ្នែកខ្ពស់បំផុតនៃបណ្ដាញលូ
- មិនត្រូវបង្កើន ឬបន្ថែមបន្ទុកទម្ងន់ទៅលើបណ្ដាញលូ
- ត្រូវធ្វើតេស្តបណ្ដាញលូគំរូនិងត្រួតពិនិត្យយ៉ាងត្រឹមត្រូវមុននឹងធ្វើការសាងសង់។

ក្នុងករណីដែលការសាងសង់អាងប្រព្រឹត្តកម្មទឹកកខ្វក់និង/ឬបណ្ដាញលូ ស្ថិតនៅក្រោមអគារដែលបានសាងសង់រួច បុគ្គលដែលអនុវត្តគម្រោងសាងសង់ត្រូវទទួលខុសត្រូវលើកម្រិតបច្ចេកទេស ក្នុងកំឡុងពេលសាងសង់អាងប្រព្រឹត្តកម្មទឹកកខ្វក់និង/ឬបណ្ដាញលូ។

មាត្រា២៩ .-

ការសាងសង់អាងប្រព្រឹត្តកម្មទឹកកខ្វក់និង/ឬបណ្ដាញលូ នៅលើទីតាំងជម្រាល ជាន់ផុតពីដីនិង/ឬរំលងអគារ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានការឯកភាពពីវិស្វករទទួលបន្ទុក
- អគារនោះតម្រូវឱ្យសាងសង់អាងប្រព្រឹត្តកម្មទឹកកខ្វក់និង/ឬបណ្ដាញលូជាចាំបាច់
- អគារនោះគ្មានកន្លែងឬគ្មានជម្រើសកន្លែងផ្សេងសម្រាប់សាងសង់អាងប្រព្រឹត្តកម្មទឹកកខ្វក់និង/ឬបណ្ដាញលូ។

ដើម្បីការពារហេដ្ឋារចនាសម្ព័ន្ធអាងប្រព្រឹត្តកម្មទឹកកខ្វក់ឱ្យបានរឹងមាំ បុគ្គលដែលអនុវត្តគម្រោងសាងសង់ត្រូវពិនិត្យលទ្ធភាពជម្រើសសាងសង់តាមលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- ត្រូវចៀសវាងទីជម្រាលខ្លាំង
- ត្រូវសាងសង់បណ្ដាញលូទម្លាក់ចុះក្រោមទៅតាមស្ថានភាពផ្ទៃរាបស្មើនៃជម្រាល
- ត្រូវប្រាកដថា បន្ទុកពីលើឬក្នុងបណ្ដាញលូ មិនបានធ្វើឱ្យរាំងស្ទះ ឬកាត់បន្ថយលំហូរទឹក
- ត្រូវប្រើប្រាស់សម្ភារៈបរិក្ខារនិងវិធីសាស្ត្រនៃការសាងសង់ដោយអនុលោមតាមលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិបច្ចេកទេសប្រព័ន្ធទឹកកខ្វក់ ដូចមានចែងក្នុងមាត្រា៧០នៃច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា៣០ .-

លក្ខខណ្ឌលម្អិតនៃការសាងសង់អាងប្រព្រឹត្តកម្មទឹកកខ្វក់និង/ឬបណ្ដាញលូ ក្រោមអគារ ជាន់ណាមួយនៃអគារ ផ្នែកខាងលើនៃអគារ ក្បែរអគារ និងរំលងអគារ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ផ្នែកទី៥
ការកែប្រែបណ្ដាញទឹកកខ្វក់

មាត្រា៣១ .-

ការកែប្រែអាងប្រព្រឹត្តកម្មទឹកកខ្វក់ ឬបណ្ដាញលូ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតជាមុនពីសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ និងត្រូវកំណត់ឱ្យបានច្បាស់លាស់អំពីទីតាំងអាងប្រព្រឹត្តកម្មទឹកកខ្វក់ ឬបណ្ដាញលូ។

ការកែប្រែបណ្ដាញលូនិងគម្រូបអណ្ដូងលូ ត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖

- បណ្ដាញលូនិងគម្របអណ្ដូងលូត្រូវសមស្របទៅនឹងទម្ងន់មធ្យោបាយដឹកជញ្ជូន ឬចរាចរណ៍ឆ្លងកាត់ជាប្រចាំ
- បណ្ដាញលូនិងគម្របអណ្ដូងលូ ត្រូវធន់ទៅនឹងប្រតិកម្មពីសារធាតុគីមី និងជីវសាស្ត្រផ្សេងៗ ដែលកើតចេញពីធរណី បរិយាកាស ឬអង្គធាតុផ្សេងៗ។

មាត្រា៣២ .-

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ត្រូវអនុញ្ញាតឱ្យធ្វើការកែប្រែអាងប្រព្រឹត្តកម្មទឹកកខ្វក់ ឬបណ្ដាញលូ ក្នុងករណីពិនិត្យឃើញថាគម្រោងប្លង់ស្នើសុំកែប្រែនោះបានបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖

- គណនាត្រឹមត្រូវអំពីវិមាត្រនិងទំហំនៃអាងប្រព្រឹត្តកម្មទឹកកខ្វក់ ឬបណ្ដាញលូ
- គណនាត្រឹមត្រូវអំពីប្រភេទនិងគុណភាពនៃអាងប្រព្រឹត្តកម្មទឹកកខ្វក់ ឬបណ្ដាញលូ
- គណនាត្រឹមត្រូវអំពីបរិមាណ ជារទឹក និងចរន្តទឹក
- គណនាត្រឹមត្រូវអំពីស្ថានភាពភូមិសាស្ត្រនៃជម្រាល
- មានអនុលោមភាពទៅតាមប្រភេទនៃបណ្ដាញលូ។

លក្ខខណ្ឌបច្ចេកទេសនៃការគណនា ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ជំពូកទី៧
ការប្រើប្រាស់ប្រព័ន្ធទឹកកខ្វក់
ផ្នែកទី១
ការតភ្ជាប់បណ្ដាញលូ

មាត្រា៣៣ .-

បុគ្គលដែលជាម្ចាស់ទីតាំងស្ថិតក្នុងតំបន់មានប្រព័ន្ធលូដែលមានស្រាប់និងទើបផ្លាស់ប្ដូរប្រព័ន្ធលូថ្មី និងក្នុងតំបន់ទើបកសាងឬរៀបចំប្រព័ន្ធលូថ្មី ត្រូវដាក់ពាក្យស្នើសុំតភ្ជាប់បំពង់លូចេញពីទីតាំងរបស់ខ្លួនជាមួយបណ្ដាញលូនៅក្នុងតំបន់។

ការស្នើសុំតភ្ជាប់បំពង់លូចេញពីទីតាំងរបស់ខ្លួនជាមួយបណ្ដាញលូត្រូវបានលើកលែងក្នុងករណីតំបន់ទីតាំងនោះនៅជាប់ឬក្បែរប្រភពទទួលទឹកសំណល់ និងត្រូវបំពេញលក្ខខណ្ឌបច្ចេកទេសតម្រូវដូចមានចែងក្នុងច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ទម្រង់និងបែបបទពាក្យស្នើសុំតភ្ជាប់ជាមួយបណ្ដាញលូត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា៣៤ .–

ការរំខានឬបង្អាក់ដំណើរការនៃការតភ្ជាប់បណ្ដាញលូណាមួយដោយគ្មានការអនុញ្ញាតពីសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ត្រូវបានហាមឃាត់។

មាត្រា៣៥ .–

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ឬប្រតិបត្តិករ ត្រូវសាងសង់បណ្ដាញលូនិងបង្កើតចំណុចតភ្ជាប់តាមបណ្ដាញលូ។

បុគ្គលដែលជាម្ចាស់ទីតាំង ត្រូវទទួលខុសត្រូវក្នុងការរៀបចំបំពង់លូទឹកកខ្វក់ឬបំពង់លូទឹកភ្លៀងរហូតដល់ចំណុចតភ្ជាប់តាមបណ្ដាញលូ និងត្រូវអនុវត្តតាមលក្ខខណ្ឌបច្ចេកទេសដែលបានកំណត់ដោយសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់។

មាត្រា៣៦ .–

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ឬប្រតិបត្តិករ អាចពង្រីកការតភ្ជាប់ជាមួយបណ្ដាញលូឱ្យកាន់តែទូលំទូលាយ និងត្រូវធ្វើឱ្យប្រាកដថា៖

១- រាល់ចំណុចចាប់ផ្ដើមនៃបណ្ដាញលូក្នុងតំបន់ណាមួយអាចតភ្ជាប់ដោយផ្ទាល់ ឬអាចបែងចែកទៅតាមប្រព័ន្ធលូនៅក្នុងតំបន់អាងស្ដុកទឹកកខ្វក់។

២- បណ្ដាញលូត្រូវបានសាងសង់ស្របតាមលក្ខខណ្ឌតម្រូវនៃចំណុចចាប់ផ្ដើមរបស់បណ្ដាញលូនៅក្នុងតំបន់អាងស្ដុកទឹកកខ្វក់។

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ឬប្រតិបត្តិករ ត្រូវតាមដាននិងត្រួតពិនិត្យលើចំណុចចាប់ផ្ដើមតំណភ្ជាប់នៃបណ្ដាញលូនីមួយៗឱ្យបានត្រឹមត្រូវ។

មាត្រា៣៧ .–

រាល់ការតភ្ជាប់ជាមួយបណ្ដាញលូត្រង់ចំណុចប្រសព្វ ចំណុចបត់បែន ចំណុចចុះឡើងជម្រាល និងចំណុចប្រែប្រួលតាមកម្រិតថ្នាក់ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ប្រើប្រាស់បំពង់លូតភ្ជាប់ឱ្យមានគុណភាពតាមបទប្បញ្ញត្តិបច្ចេកទេសប្រព័ន្ធទឹកកខ្វក់ដូចមានចែងក្នុងមាត្រា៧០នៃច្បាប់នេះ និងមានទំហំឬវិមាត្រសមស្របជាមួយនឹងបណ្ដាញលូ ឬបណ្ដាញលូមេ
- ដាក់បំពង់លូមានអង្កត់ផ្ចិតតូចឱ្យខ្ពស់ជាងបំពង់លូធំ ក្នុងករណីបំពង់លូតភ្ជាប់មានអង្កត់ផ្ចិតមិនដូចគ្នា
- ត្រួតពិនិត្យលក្ខណៈបច្ចេកទេសតភ្ជាប់តាមទម្រង់នីមួយៗ និងប្រើប្រាស់សម្ភារៈបរិក្ខារនិងគ្រឿងបង្គុំលូសម្រាប់តភ្ជាប់បណ្ដាញលូនីមួយៗឱ្យបានត្រឹមត្រូវ
- រៀបចំឱ្យមានបណ្ដាញលូដោយឡែក ឬជម្រើសតាមមធ្យោបាយសមស្របណាមួយក្នុងករណីតភ្ជាប់បណ្ដាញលូចេញពីចំណុចប្រសព្វនិងចំណុចបត់បែនភ្ជាប់ជាមួយបណ្ដាញលូ ចំណុចចុះឬឡើងជម្រាល ឬបណ្ដាញលូដែលប្រែប្រួលតាមកម្រិតថ្នាក់ផ្សេងគ្នា។

មាត្រា៣៨ .–

រាល់ការតភ្ជាប់បំពង់លូនៃអគារចាប់ពីពីរអគារឡើងទៅ ឬបណ្ដុំអគារជាមួយបណ្ដាញលូ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- គម្រោងប្រព័ន្ធអាងប្រព្រឹត្តកម្មទឹកកខ្វក់មានចំណុចតភ្ជាប់សម្រាប់អគារនីមួយៗ ឬបណ្ដុំអគារតាមលក្ខណៈបច្ចេកទេសកំណត់

- អាងប្រព្រឹត្តកម្មទឹកកខ្វក់និងបណ្តាញលូ អាចទ្រទ្រង់ការបង្ហូរទឹកកខ្វក់ចេញពីអគារទាំងអស់
- ត្រូវមានអំណះអំណាងគ្រប់គ្រាន់និងមានលក្ខខណ្ឌបច្ចេកទេសត្រឹមត្រូវតាមសណ្ឋានដីនៃទីតាំងអគារនីមួយៗដែលអាចតភ្ជាប់បាន ឬគ្មានជម្រើសផ្សេងសម្រាប់ការតភ្ជាប់។

ចំពោះការតភ្ជាប់ចំណុចប្រសព្វ ចំណុចបត់បែន ចំណុចចុះឬឡើងជម្រាល និងចំណុចប្រែប្រួលតាមកម្រិតថ្នាក់ ត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា៣៧នៃច្បាប់នេះ។

មាត្រា៣៩ .-

ការតភ្ជាប់បណ្តាញលូពីតំបន់សេដ្ឋកិច្ចពិសេស សួនឧស្សាហកម្ម ឬសួននវានុវត្តន៍ជាមួយបណ្តាញលូ ត្រូវមានការអនុញ្ញាតពីសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ និងមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់និងម្ចាស់ទីតាំង ដែលកំណត់អំពីទីតាំងតភ្ជាប់ តម្រូវការបច្ចេកទេស ពេលវេលា កម្រិតសារធាតុបំពុល និងលំហូរទឹកសំណល់ដែលហូរចូលក្នុងចំណុចតភ្ជាប់ និងត្រូវគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា៤០ .-

លក្ខខណ្ឌបច្ចេកទេសនៃការតភ្ជាប់ជាមួយបណ្តាញលូ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា៤១ .-

អ្នកសាងសង់ឬដំឡើងតំណភ្ជាប់ ត្រូវប្រើប្រាស់សម្ភារៈបរិក្ខារនិងគ្រឿងបង្គុំលូឱ្យមានគុណភាពត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសកំណត់ និងត្រូវតភ្ជាប់ឬដំឡើងសម្ភារៈបរិក្ខារនិងគ្រឿងបង្គុំលូឱ្យស្របតាមបទប្បញ្ញត្តិបច្ចេកទេសប្រព័ន្ធទឹកកខ្វក់ ព្រមទាំងត្រូវផ្តល់ឯកសារពាក់ព័ន្ធដែលជាភស្តុតាងនៃការវាយតម្លៃសម្ភារៈបរិក្ខារនិងគ្រឿងបង្គុំលូ កម្រិតលំហូរទឹក និងកម្រិតសារធាតុបំពុលទឹកបង្ហូរចេញ ជូនទៅសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់។

មាត្រា៤២ .-

អ្នកសាងសង់ឬដំឡើងតំណភ្ជាប់ មិនអាចតភ្ជាប់ ឬដំឡើងសម្ភារៈបរិក្ខារនិងគ្រឿងបង្គុំលូជាមួយបណ្តាញលូ មុនពេលមានការត្រួតពិនិត្យពីភ្នាក់ងារមានសមត្ថកិច្ច ឬវិស្វករទទួលបន្ទុកបានឡើយ។ ភ្នាក់ងារមានសមត្ថកិច្ច ឬវិស្វករទទួលបន្ទុកមានសិទ្ធិឱ្យធ្វើការកែតម្រូវ ក្នុងករណីត្រួតពិនិត្យឃើញថាការប្រើប្រាស់សម្ភារៈបរិក្ខារនិងគ្រឿងបង្គុំលូ ដើម្បីតភ្ជាប់ជាមួយបណ្តាញលូនោះមិនបានត្រឹមត្រូវតាមបទប្បញ្ញត្តិបច្ចេកទេសប្រព័ន្ធទឹកកខ្វក់។

មាត្រា៤៣ .-

រាល់ការតភ្ជាប់ជាមួយបណ្តាញលូ ត្រូវប្រើប្រាស់សម្ភារៈបរិក្ខារនិងគ្រឿងបង្គុំលូ ស្របតាមបទប្បញ្ញត្តិបច្ចេកទេសប្រព័ន្ធទឹកកខ្វក់។

សម្ភារៈបរិក្ខារនិងគ្រឿងបង្គុំលូដែលតភ្ជាប់ជាមួយបណ្តាញលូ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា៤៤ .-

ការជីកកាយ ការជីកគាស់ ឬការជីកលុង និងការបោះខួងផ្លូវថ្នល់ ដើម្បីតភ្ជាប់ជាមួយបណ្តាញលូនៅក្រោមផ្លូវថ្នល់ណាមួយ ត្រូវស្នើសុំការអនុញ្ញាតពីសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ និងត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ចៀសវាងប៉ះពាល់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធលូ ឬហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងទៀត
- ដោះស្រាយជាបន្ទាន់ចំពោះការរំខាននានា មុននឹងបន្តអនុវត្តការងារ
- តភ្ជាប់ជាមួយបណ្ដាញលូឱ្យស្របតាមបទប្បញ្ញត្តិបច្ចេកទេសប្រព័ន្ធទឹកកខ្វក់និងសាកល្បងបង្ហូរទឹកកខ្វក់ បន្ទាប់ពីការតភ្ជាប់ជាមួយបណ្ដាញលូរួចរាល់
- សម្រួលសណ្ដាប់ធ្នាប់ចរាចរណ៍ បង្ការឧបទ្ទវហេតុផ្សេងៗដែលអាចកើតមានឡើងជាយថាហេតុ និងគោរពតាមការណែនាំរបស់ភ្នាក់ងារមានសមត្ថកិច្ចឬវិស្វករទទួលបន្ទុក
- រៀបចំទីតាំងឱ្យមានស្ថានភាពដូចដើមវិញឬល្អជាងស្ថានភាពដើម។

មាត្រា៤៥ .-

រាល់ការតភ្ជាប់ជាមួយបណ្ដាញលូ ត្រូវបង់កម្រៃសេវាសាធារណៈ។

កម្រៃសេវាសាធារណៈតភ្ជាប់ជាមួយបណ្ដាញលូ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ផ្នែកទី២
ការប្រើប្រាស់ប្រព័ន្ធលូ

មាត្រា៤៦ .-

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ឬប្រតិបត្តិករ ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានអំពីតំបន់ប្រព័ន្ធលូឬបណ្ដាញលូ កាលបរិច្ឆេទនៃការចាប់ផ្ដើមបើកឱ្យប្រើប្រាស់ វិធីសាស្ត្រនៃការតភ្ជាប់ជាមួយបណ្ដាញលូ អនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន មុនពេលចាប់ផ្ដើមដាក់ឱ្យប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ និង/ឬប្រព័ន្ធលូ។

ការផ្សព្វផ្សាយខាងលើត្រូវបានលើកលែង ចំពោះទីតាំងឬតំបន់ភូមិសាស្ត្រណាមួយដែលមានប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ និង/ឬប្រព័ន្ធលូដែលមានស្រាប់ ហើយបាននិងកំពុងដំណើរការ។

មាត្រា៤៧ .-

រាល់ការបញ្ចេញទឹកកខ្វក់ឬទឹកសំណល់ក្រោយធ្វើប្រព្រឹត្តកម្មបឋមចេញពីទីតាំងណាមួយទៅស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ ត្រូវបង្ហូរតាមប្រព័ន្ធលូ។

ចំពោះតំបន់ឬទីតាំងដែលមិនទាន់មានប្រព័ន្ធលូ ម្ចាស់ទីតាំងត្រូវសាងសង់ឬដំឡើងអាងសិបទិកដូចមានចែងក្នុងផ្នែកទី៤នៃជំពូកនេះ។

រាល់ការបង្ហូរទឹកកខ្វក់ឬទឹកសំណល់ក្រោយធ្វើប្រព្រឹត្តកម្មបឋមតាមប្រព័ន្ធលូ ត្រូវបង់កម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ ស្របតាមបទប្បញ្ញត្តិដែលកំណត់នៅក្នុងជំពូកទី១១នៃច្បាប់នេះ។

មាត្រា៤៨ .-

បុគ្គលដែលជាម្ចាស់ទីតាំងបញ្ចេញទឹកកខ្វក់ទៅចំណុចតភ្ជាប់ ដូចមានចែងក្នុងកថាខណ្ឌទី២ មាត្រា៣៥ នៃច្បាប់នេះ ត្រូវអនុវត្តតាមវិធានការដូចខាងក្រោម៖

ក- ការបញ្ចេញទឹកកខ្វក់ពីលំនៅឋាន៖

- តំបន់ដែលទើបសាងសង់ប្រព័ន្ធលូថ្មី ដែលមានប្រព័ន្ធលូរួមនិងអាងប្រព្រឹត្តកម្មទឹកកខ្វក់ប្រមូលផ្ដុំ ត្រូវបញ្ចេញទឹកកខ្វក់ទៅចំណុចតភ្ជាប់ដោយផ្ទាល់។

ខ- តំបន់ទីក្រុង ទីប្រជុំជននានា និងតំបន់ផ្សេងទៀតដែលមានបណ្ដាញលូញែកត្រូវបញ្ចេញទឹកកខ្វក់និងទឹកភ្លៀងទៅចំណុចតភ្ជាប់នៃបណ្ដាញលូញែកនីមួយៗ។

២- ការបញ្ចេញទឹកកខ្វក់ពីប្រភពផ្សេងទៀតក្រៅពីលំនៅឋានៈ

ក- ម្ចាស់ទីតាំងនីមួយៗដែលមានអាងប្រមូលផ្ដុំរួម ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ផ្ទាល់ខ្លួនសម្រាប់ធ្វើប្រព្រឹត្តកម្មទឹកកខ្វក់បឋមត្រូវបញ្ចេញទឹកកខ្វក់ស្របតាមកម្រិតកំណត់ស្ដង់ដានៃការបញ្ចេញទឹកសំណល់ទៅចំណុចតភ្ជាប់។

ខ- ម្ចាស់ទីតាំងនីមួយៗត្រូវស្នើសុំទៅភ្នាក់ងារបរិស្ថាន ធ្វើការវិភាគកម្រិតសារធាតុបំពុលដែលបង្ហូរទៅចំណុចតភ្ជាប់ ហើយត្រូវយកលទ្ធផលធ្វើតេស្តនោះ បញ្ជូនទៅសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់។

ភ្នាក់ងារមានសមត្ថកិច្ចឬវិស្វករទទួលបន្ទុក ត្រូវទទួលខុសត្រូវក្នុងការត្រួតពិនិត្យនិងតាមដានការបញ្ចេញទឹកកខ្វក់ ដើម្បីធានាអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសប្រព័ន្ធទឹកកខ្វក់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា៤៩ .-

បុគ្គលដែលជាម្ចាស់ទីតាំងដែលមានបំណងចង់ប្ដូរទិសដៅអ័ក្សបណ្ដាញលូ ឬបង្វែរបណ្ដាញលូ ឬផ្លាស់ប្ដូរសំណង់សិល្បការ្យទឹកកខ្វក់ក្នុងទីតាំងរបស់ខ្លួនដើម្បីបញ្ចេញទឹកកខ្វក់ ត្រូវអនុវត្តដូចខាងក្រោមៈ

១- ស្នើសុំការអនុញ្ញាតជាលាយលក្ខណ៍អក្សរទៅសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ដោយបញ្ជាក់អំពីហេតុផលសមរម្យ និងធានាអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសប្រព័ន្ធទឹកកខ្វក់។

២- ចៀសវាងមិនឱ្យខូចខាតឬធ្វើឱ្យប៉ះពាល់ ឬបំផ្លិចបំផ្លាញដល់សំណង់សិល្បការ្យទឹកកខ្វក់ ឬហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងទៀតក្នុងទីតាំងនោះ។

៣- រៀបចំកែលម្អទីតាំងនោះឱ្យបានល្អដូចដើមវិញ ឬឱ្យបានល្អជាងស្ថានភាពដើម។

រាល់ការចំណាយលើការប្ដូរទិសដៅ ការបង្វែរ និងការផ្លាស់ប្ដូរទីតាំងជាបន្ទុករបស់បុគ្គលដែលជាម្ចាស់ទីតាំង។

មាត្រា៥០ .-

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ឬប្រតិបត្តិករ ត្រូវរៀបចំឱ្យមានកិច្ចសន្យាប្រើប្រាស់ប្រព័ន្ធលូជាមួយនឹងបុគ្គលជាម្ចាស់ទីតាំងដែលបង្ហូរទឹកកខ្វក់តាមប្រព័ន្ធលូ។

ទម្រង់និងបែបបទនៃកិច្ចសន្យាប្រើប្រាស់ប្រព័ន្ធលូ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា៥១ .-

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ឬប្រតិបត្តិករមានសិទ្ធិផ្អាក បិទ ឬបញ្ឈប់សេវាប្រើប្រាស់ប្រព័ន្ធលូជាបណ្ដោះអាសន្ន បន្ទាប់ពីបានជូនដំណឹងជាលាយលក្ខណ៍អក្សរចំនួន២(ពីរ)លើក ដល់បុគ្គលជាម្ចាស់ទីតាំងក្នុងករណីដែលបុគ្គលនោះបង្ហូរទឹកកខ្វក់មិនត្រឹមត្រូវបណ្ដាលមកពីការកកស្ទះ ឬប្រេះបែកបំពង់លូ ឬប្រព័ន្ធលូ និងមិនព្រមជួសជុល ឬកែលម្អបំពង់លូ ឬបណ្ដាញលូរបស់ខ្លួនឡើងវិញ។

ក្នុងករណីដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ឬប្រតិបត្តិករអាចស្នើសុំកិច្ចសហការពីអង្គភាពរដ្ឋាករទឹក ឬអ្នកផ្គត់ផ្គង់ទឹកស្អាតឱ្យបញ្ឈប់ការផ្គត់ផ្គង់ទឹកស្អាតជាបណ្ដោះ

អាសន្ន ដើម្បីធ្វើការជួសជុល និងកែលម្អបំពង់លូឬបណ្តាញលូឡើងវិញព្រមទាំងត្រូវចាត់វិធានការបង្ហូរទឹកកខ្វក់ជាបណ្តោះអាសន្ន ដើម្បីកាត់បន្ថយផលប៉ះពាល់ជាអប្បបរមាទៅលើសកម្មភាពផលិតកម្ម និងសកម្មភាពប្រចាំថ្ងៃរបស់ម្ចាស់ទីតាំង និងកាត់បន្ថយការបំពុលបរិស្ថាន។

មាត្រា៥២ .-

បុគ្គលដែលប្រើប្រាស់ប្រព័ន្ធលូ ត្រូវចូលរួមថែទាំបំពង់លូឬបណ្តាញលូនិងបរិក្ខារលូ ដោយខ្លួនឯង និងមិនត្រូវអនុញ្ញាតឱ្យបុគ្គលណាមួយបង្ហូរទឹកកខ្វក់ចូលក្នុងបំពង់លូឬបណ្តាញលូរបស់ខ្លួនឡើយ។

ដោយឡែក បុគ្គលដែលប្រើប្រាស់ប្រព័ន្ធលូដែលមានទីតាំងស្ថិតនៅក្នុងតំបន់មានអាងចម្រោះទឹកកខ្វក់ក្នុងទីប្រជុំជននីមួយៗ ត្រូវអនុវត្តដូចខាងក្រោម៖

១- មិនត្រូវឱ្យកម្ទេចកម្ទីសំណង់ ឬដី ឬខ្សាច់ ឬសំរាមហូរចូលក្នុងបណ្តាញលូ។

២- ទឹកកខ្វក់ដែលបង្ហូរចេញពីគ្រប់ផ្នែកទាំងអស់នៃទីតាំងត្រូវបញ្ជូនចូលទៅក្នុងបណ្តាញលូឬប្រព័ន្ធលូដែលបានសាងសង់នៅក្នុងទីប្រជុំជននីមួយៗ។

មាត្រា៥៣ .-

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ត្រូវកែតម្រូវជាបន្ទាន់ ប្រសិនបើពិនិត្យឃើញថាគុណភាពទឹកក្រោយពីបានធ្វើប្រព្រឹត្តកម្មបញ្ចេញពីប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ឬស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ឆ្ពោះទៅតំបន់ទឹកសាធារណៈ មិនអនុលោមតាមកម្រិតស្តង់ដាគុណភាពទឹកតំបន់ទឹកសាធារណៈ ដូចមានចែងក្នុងបទប្បញ្ញត្តិនៃក្រមបរិស្ថាននិងធនធានធម្មជាតិ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ផ្នែកទី៣
ការការពារប្រព័ន្ធលូ

មាត្រា៥៤ .-

ការធ្វើឱ្យរាំងស្ទះបណ្តាញលូ ដោយគ្មានការអនុញ្ញាតពីសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ត្រូវហាមឃាត់។

ការធ្វើឱ្យរាំងស្ទះបណ្តាញលូ អាចប្រព្រឹត្តទៅប្រសិនបើទទួលបានការអនុញ្ញាតពីសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ដោយមូលហេតុណាមួយ ដូចខាងក្រោម៖

១- ផ្នែកណាមួយនៃបណ្តាញលូដែលកកស្ទះចាំបាច់ត្រូវបូមស្តារ។

២- ផ្នែកណាមួយនៃបណ្តាញលូបាក់បែក ឬស្រុតចុះដែលមិនអាចធ្វើចរាចរណ៍ ឬការធ្វើដំណើរឆ្លងកាត់បាន និងត្រូវធ្វើការជួសជុលឡើងវិញ។

៣- ផ្នែកណាមួយនៃបណ្តាញលូត្រូវធ្វើការកែប្រែ ឬផ្លាស់ប្តូរ។

មាត្រា៥៥ .-

ការកាត់ផ្តាច់ផ្នែកណាមួយនៃបណ្តាញលូ ត្រូវហាមឃាត់។

ការកាត់ផ្តាច់ផ្នែកណាមួយនៃបណ្តាញលូ ត្រូវបានលើកលែងក្នុងករណីដូចខាងក្រោម៖

១- ការចាត់វិធានការសង្គ្រោះបន្ទាន់ពីគ្រោះទឹកជំនន់។

២- ការសាងសង់ និងការពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ឬផ្លូវដែក ឬហេដ្ឋារចនាសម្ព័ន្ធបម្រើសេវាសាធារណៈផ្សេងទៀត។

៣- ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។

៤- សកម្មភាពពាក់ព័ន្ធផ្សេងទៀតតាមបទបញ្ជារបស់រាជរដ្ឋាភិបាល។

ការកាត់ផ្តាច់ផ្នែកណាមួយនៃបណ្តាញលូ ដូចមានចែងក្នុងចំណុចទី២ ចំណុចទី៣ និងចំណុចទី៤ នៃកថាខណ្ឌទី២ខាងលើ ត្រូវចាត់វិធានការធ្វើបណ្តាញលូជំនួស ដើម្បីសម្រួលដល់ការបង្ហូរទឹកកខ្វក់។

មាត្រា៥៦ .-

ត្រូវបានហាមឃាត់រាល់សកម្មភាព មានដូចខាងក្រោម៖

១- ការបំផ្លិចបំផ្លាញ ឬធ្វើឱ្យខូចខាតដោយចេតនានូវមុខងារនៃប្រព័ន្ធលូឬបណ្តាញលូដោយបង្កការរំខាន ដូចជាបង្កើនចន្លោះលំហូរ ឬកាត់បន្ថយចន្លោះលំហូរទឹកកខ្វក់ចូលទៅក្នុងប្រព័ន្ធលូឬបណ្តាញលូ។

២- ការរំលោភបទប្បញ្ញត្តិបច្ចេកទេស ក្នុងការសាងសង់ ការជួសជុល ការថែទាំ និងការការពារហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទឹកកខ្វក់និង/ឬប្រព័ន្ធលូ។

៣- ការជីកគាស់ ឬជីកកកាយ ឬចោះខួង ផ្លាស់ប្តូរឬកែប្រែសំណង់សិល្បការ្យទឹកកខ្វក់ឬហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទឹកកខ្វក់។

៤- ការសាងសង់អ្វីមួយពីលើ ឬសង្កត់ពីខាងលើប្រព័ន្ធលូ ដែលសំណង់ទាំងនោះអាចធ្វើឱ្យរាំងស្ទះចន្លោះលំហូរទឹកកខ្វក់តាមផ្នែកខ្លះ ឬរាំងស្ទះទាំងស្រុងនៃប្រព័ន្ធលូ ឬបណ្តាញលូ។

៥- ការដាក់សម្ភារៈ កម្ទេចកម្ទីចូលទៅក្នុងអណ្តូងលូតាមប្រព័ន្ធលូឬបណ្តាញលូ។

៦- ការកែប្រែផ្ទៃដីខាងលើនៃប្រព័ន្ធលូ ដែលជាហេតុធ្វើឱ្យបែកធ្លាយដំណើរការបង្ហូរទឹកចូលទៅក្នុងបណ្តុំបែងចែកឬអណ្តូងលូ។

៧- ការធ្វើឱ្យខូចខាតដោយចេតនាដល់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទឹកកខ្វក់ ដូចជាការធ្វើឱ្យបែកបាក់ឬបាក់ស្រុតប្រព័ន្ធលូឬបណ្តាញលូ។

៨- ការតភ្ជាប់ឬកែប្រែប្រព័ន្ធលូ និងប្រើប្រាស់សម្ភារៈបរិក្ខារនិងគ្រឿងបង្គុំលូ គ្មានការយល់ព្រមនិងគ្មានការអនុញ្ញាតពីភ្នាក់ងារមានសមត្ថកិច្ច ឬវិស្វករទទួលបន្ទុក ឬអ្នកបច្ចេកទេស។

៩- ការរំខាន ឬរារាំងដល់ការងារត្រួតពិនិត្យហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទឹកកខ្វក់និង/ឬប្រព័ន្ធលូរបស់ភ្នាក់ងារមានសមត្ថកិច្ចឬវិស្វករទទួលបន្ទុកឬអ្នកបច្ចេកទេស។

១០- ការសាងសង់អាងស្តុកទឹកកខ្វក់គ្មានលក្ខណៈបច្ចេកទេសត្រឹមត្រូវនិងបង្កផលប៉ះពាល់ដល់សុខភាពសាធារណៈឬបរិស្ថាន។

១១- ការបញ្ចេញទឹកសំណល់ឬទឹកកខ្វក់មានសារធាតុមិនបានបំពេញត្រឹមត្រូវតាមកម្រិតស្តង់ដាបញ្ចេញសំណល់ឬទឹកកខ្វក់ ចូលនៅក្នុងប្រព័ន្ធលូឬបណ្តាញលូ។

ផ្នែកទី៤
ការសាងសង់និងការជួសជុលអាងសិបទិក

មាត្រា៥៧ .-

បុគ្គលដែលជាម្ចាស់ទីតាំង ត្រូវសាងសង់ឬដំឡើងអាងសិបទិកសម្រាប់ស្តុកនិងច្រោះទឹកកខ្វក់ក្នុងករណីណាមួយ ដូចខាងក្រោម៖

១- តំបន់ឬទីតាំងមានទីធ្លាចង្អៀតឬគ្មានទីធ្លាសម្រាប់រៀបចំបណ្តាញលូ។

២- តំបន់ឬទីតាំងមានបណ្តាញលូទ្រុឌទ្រោមដែលមានបរិមាណទឹកច្រើនលើសលប់។

៣- តំបន់ឬទីតាំងមានសណ្ឋានដីងាយជ្រាបទឹកខ្លាំង ដែលកម្រិតប្រសិទ្ធភាពនៃការធ្វើប្រព្រឹត្តកម្ម មិនអាចទប់ទល់នឹងការជ្រាបទឹកចូលក្នុងដី។

៤- តំបន់ឬទីតាំងមិនឱ្យជ្រាបទឹកចូលឬតំបន់ស្រទាប់ថ្មដែលការពារការជ្រាបទឹកចូល។

៥- តំបន់ឬទីតាំងមានស្រទាប់ដីស្តើងមិនសក្តិសមសម្រាប់បង្ហូរទឹកកខ្វក់។

៦- តំបន់ឬទីតាំងបរិស្ថានវេទយិតមិនអាចសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទឹកកខ្វក់បាន ដាច់ខាត។

មាត្រា៥៨ .-

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់មិនតម្រូវឱ្យបុគ្គលដែលជាម្ចាស់ទីតាំងសាងសង់ឬដំឡើងអាងសិបទិកក្នុងតំបន់ឬទីតាំងដែលមានហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទឹកកខ្វក់គ្រប់គ្រាន់ ក្នុងករណីពិនិត្យឃើញថាការបញ្ចេញទឹកកខ្វក់ក្នុងតំបន់ឬទីតាំងនោះមិនប៉ះពាល់ដល់បណ្តាញលូ ឬបង្កការកកស្ទះ ឬរំខានចរន្តលំហូរទឹកតាមបណ្តាញលូ។

មាត្រា៥៩ .-

រាល់ការសាងសង់ឬការដំឡើង ការជួសជុលនិងការកែប្រែអាងសិបទិក ត្រូវធានាឱ្យបាននូវគុណភាព សមត្ថភាពតាមរចនាសម្ព័ន្ធ និងមុខងារចម្រោះទឹកកខ្វក់ដែលងាយស្រួលបូមស្តារ លាងសម្អាត និងថែទាំ។ ការសាងសង់ឬការដំឡើង ការជួសជុល និងការកែប្រែអាងសិបទិក ត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសប្រព័ន្ធទឹកកខ្វក់ ដូចមានចែងក្នុងមាត្រា៧០នៃច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

លក្ខខណ្ឌតម្រូវនៃការសាងសង់ឬការដំឡើង ការជួសជុល និងការកែប្រែអាងសិបទិក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ផ្នែកទី៥
ការគ្រប់គ្រងនិងកែច្នៃសំណល់កក់

មាត្រា៦០ .-

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ត្រូវធ្វើប្រតិបត្តិការបូមស្តារនិងសម្អាតសំណល់កក់ ជាអាទិ៍ក្នុងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ ស្ថានីយបូម ប្រព័ន្ធលូ សំណង់សិល្បការទឹកកខ្វក់ផ្សេងទៀតយ៉ាងតិច១(មួយ)ឆ្នាំម្តង ដើម្បីការពារហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទឹកកខ្វក់ឱ្យបានល្អនិងសមស្របតាមអាយុកាលបច្ចេកទេស។

រាល់ការបូមស្តារនិងសម្អាតសំណល់កក់ ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ត្រូវបញ្ចៀសការកកស្ទះចរន្តបញ្ចេញទឹកប្រើប្រាស់ប្រចាំថ្ងៃក្នុងតំបន់ដែលត្រូវបង្ហូរទឹកកខ្វក់ចូលតាមបណ្តាញលូ និងចៀសវាងបង្កផលប៉ះពាល់ដល់សុខភាពរបស់មនុស្ស សត្វ និងខូចខាតដល់បរិស្ថាននៅក្នុងតំបន់នោះ។

លក្ខណៈបច្ចេកទេសនៃការបូមស្តារនិងការសម្អាតសំណល់កក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា៦១ .-

ការប្រមូលដឹកជញ្ជូន ការធ្វើប្រព្រឹត្តកម្ម ការកែច្នៃប្រើប្រាស់ និងការរក្សាទុកឬស្តុកសំណល់កក់ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១- រក្សាទុកនិងធ្វើប្រព្រឹត្តកម្ម ឬកែច្នៃសំណល់ភក់នៅទីតាំងដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ច ឬក្រសួង ស្ថាប័នមានសមត្ថកិច្ច និងហាមឃាត់ដាច់ខាតការចាក់ចោលសំណល់ភក់ដែលមិនទាន់បានឆ្លងកាត់ធ្វើប្រព្រឹត្តកម្មនៅតំបន់ទឹកសាធារណៈ និងទីលានសាធារណៈ ឬឯកជន។

២- ធ្វើប្រព្រឹត្តកម្មសំណល់ភក់តាមវិធីសាស្ត្របច្ចេកទេសដែលមានការទទួលស្គាល់ពីសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

៣- កែច្នៃសំណល់ភក់និងប្រើប្រាស់ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៤- រៀបចំឱ្យមានរចនាសម្ព័ន្ធ ចំនួនអាងស្តុក សមត្ថភាពអាងស្តុក ម៉ាស៊ីនកូរ អាងទប់ក្លិននិងអាងបំបាត់ក្លិន ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

លក្ខខណ្ឌបច្ចេកទេសនៃការប្រមូលដឹកជញ្ជូនការធ្វើប្រព្រឹត្តកម្ម ការកែច្នៃប្រើប្រាស់ និងការរក្សាទុកឬស្តុកសំណល់ភក់ ត្រូវកំណត់ដោយអនុក្រឹត្យ។

ជំពូកទី៨
ការថែទាំប្រព័ន្ធទឹកកខ្វក់

មាត្រា៦២ .-

ការថែទាំប្រព័ន្ធទឹកកខ្វក់ត្រូវធ្វើជាទៀងទាត់និងត្រូវបែងចែកជាការថែទាំខួប ការថែទាំប្រចាំ និងការជួសជុលបន្ទាន់។

មាត្រា៦៣ .-

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ត្រូវធ្វើការថែទាំប្រព័ន្ធទឹកកខ្វក់ឱ្យបានត្រឹមត្រូវដើម្បីធានាឱ្យប្រព័ន្ធទឹកកខ្វក់មានដំណើរការល្អ ចៀសវាងការកើតមានហានិភ័យដល់សុខភាពសាធារណៈ និងប៉ះពាល់ដល់គុណភាពទឹកនៃតំបន់ទឹកសាធារណៈ។

រាល់ការថែទាំប្រព័ន្ធទឹកកខ្វក់ត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសប្រព័ន្ធទឹកកខ្វក់ដូចមានចែងក្នុងមាត្រា៧០នៃច្បាប់នេះ និងត្រូវធ្វើការត្រួតពិនិត្យជាប្រចាំនូវសមាសភាគហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទឹកកខ្វក់។

បែបបទនិងនីតិវិធីនៃការថែទាំប្រព័ន្ធទឹកកខ្វក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា៦៤ .-

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ត្រូវធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនៃប្រព័ន្ធទឹកកខ្វក់យ៉ាងទៀងទាត់ ក្នុងរយៈពេលយ៉ាងយូរ៣(បី)ឆ្នាំម្តង ដើម្បីត្រួតពិនិត្យនិងវាយតម្លៃគុណភាពនិងមុខងារនិងដំណើរការនៃប្រព័ន្ធទឹកកខ្វក់ ដែលស្ថិតក្រោមសមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន។

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ត្រូវរៀបចំគម្រោងប្លង់និងផែនការជួសជុល ថែទាំ ឬធ្វើឱ្យប្រសើរឡើងប្រព័ន្ធទឹកកខ្វក់ដែលរងការខូចខាត បន្ទាប់ពីទទួលបានលទ្ធផលនៃការត្រួតពិនិត្យលក្ខណៈបច្ចេកទេសដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ។

លក្ខខណ្ឌនៃការត្រួតពិនិត្យនិងការវាយតម្លៃគុណភាពនិងមុខងារនីមួយៗនៃប្រព័ន្ធទឹកកខ្វក់ ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៦៥ .-

ពល់គម្រោងថែទាំប្រព័ន្ធទឹកកខ្វក់ដែលបានទទួលការឯកភាពជាគោលការណ៍ពីរាជរដ្ឋាភិបាល អាចត្រូវបានអនុវត្តដោយសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ដោយខ្លួនឯង ឬអនុញ្ញាតឱ្យវិស័យឯកជនចូលរួមអនុវត្ត ស្របតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងត្រូវអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា៦៦ .-

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់អាចប្រគល់ភារកិច្ចក្នុងការត្រួតពិនិត្យនិងវាយតម្លៃគុណភាពនិងមុខងារនីមួយៗនៃប្រព័ន្ធទឹកកខ្វក់ឱ្យវិស្វករដែលបានចុះបញ្ជីទទួលស្គាល់ពីគណៈវិស្វករកម្ពុជា។

ក្នុងករណីហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទឹកកខ្វក់ស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងស្ថាប័នណាមួយជាអ្នកទទួលខុសត្រូវ ក្រសួងស្ថាប័ននោះ អាចប្រគល់ភារកិច្ចក្នុងការងារត្រួតពិនិត្យនិងវាយតម្លៃគុណភាពនិងមុខងារនីមួយៗនៃប្រព័ន្ធទឹកកខ្វក់ឱ្យវិស្វករដែលបានចុះបញ្ជីទទួលស្គាល់ពីគណៈវិស្វករកម្ពុជា។

មាត្រា៦៧ .-

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ឬប្រតិបត្តិករ អាចប្រគល់ភារកិច្ច ថែទាំបណ្តាញលូ ផ្លាស់ប្តូរ ឬកែប្រែសម្ភារៈបរិក្ខារនិងគ្រឿងបង្ហុំលូ ឱ្យអ្នកបច្ចេកទេសដែលបានឆ្លងកាត់ការបណ្តុះបណ្តាលបច្ចេកទេសនិងមានការទទួលស្គាល់ជាផ្លូវការពីក្រសួងសាធារណការនិងដឹកជញ្ជូន។

បែបបទនិងនីតិវិធីនៃការបណ្តុះបណ្តាលអ្នកបច្ចេកទេសថែទាំបណ្តាញលូ ផ្លាស់ប្តូរ ឬកែប្រែសម្ភារៈបរិក្ខារនិងគ្រឿងបង្ហុំលូ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា៦៨ .-

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ត្រូវរក្សាទុកឯកសារនិងកត់ត្រាទុកក្នុងប្រព័ន្ធព័ត៌មានវិទ្យា ឬប្រព័ន្ធឌីជីថលនូវទិន្នន័យអំពីសំណង់សិល្បការ្យទឹកកខ្វក់ សម្ភារៈបរិក្ខារនិងគ្រឿងបង្ហុំលូដែលបានផ្លាស់ប្តូរ ថែទាំ បរិមាណ និងគុណភាពនៃការបញ្ជូនទឹកកខ្វក់ចូលលូ ឬបញ្ចេញទឹកក្រោយប្រព្រឹត្តកម្មរួចពីប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ ឬអាងចម្រោះទឹកកខ្វក់។

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ត្រូវរៀបចំគំនូរប្លង់បង្ហាញប្រព័ន្ធលូឬបណ្តាញលូនៅលើផែនទីតាមតំបន់នីមួយៗ ដោយត្រូវបិទផ្សាយជាសាធារណៈនៅក្នុងការិយាល័យរបស់ខ្លួន។

ព័ត៌មានដែលត្រូវបិទផ្សាយជាសាធារណៈ មានដូចខាងក្រោម៖

១- ព្រំកំណត់ខ្សែប្រព័ន្ធលូឬបណ្តាញលូឱ្យបានច្បាស់លាស់នៅក្នុងទីតាំងនីមួយៗ។

២- ទីតាំងភូមិសាស្ត្រនិងផ្ទៃក្រឡានៃប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ឬស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ ឬអាងចម្រោះទឹកកខ្វក់ អណ្តូងលូ និងចំណុចតភ្ជាប់ជាមួយប្រព័ន្ធលូឬបណ្តាញលូ និងទីតាំងបញ្ចេញទឹកកខ្វក់ដែលបានធ្វើប្រព្រឹត្តកម្មរួចរាល់។

៣- កាលបរិច្ឆេទនៃការថែទាំនិងជួសជុល រួមទាំងការប្រើប្រាស់សម្ភារៈបរិក្ខារនិងគ្រឿងបង្ហុំលូ និងការបញ្ចេញទឹកកខ្វក់។

៤- ព័ត៌មានផ្សេងទៀតដែលជាតម្រូវការចាំបាច់ក្នុងការគ្រប់គ្រង ការពារ និងថែទាំហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទឹកកខ្វក់ក្នុងតំបន់នោះ។

មាត្រា៦៩ .-

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ត្រូវចាត់ភ្នាក់ងារមានសមត្ថកិច្ចឱ្យទទួលខុសត្រូវក្នុងការតាមដាន និងត្រួតពិនិត្យមើលតាមតំបន់នីមួយៗ ដូចមានចែងក្នុងចំណុចទី១និងចំណុចទី២នៃកថាខណ្ឌទី៣ នៃមាត្រា៦៨នៃច្បាប់នេះ ដើម្បីធ្វើការផ្សព្វផ្សាយនិងអប់រំណែនាំប្រជាពលរដ្ឋឱ្យចូលរួមថែទាំហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទឹកកខ្វក់ និងចាត់វិធានការទប់ស្កាត់ក្នុងករណីពិនិត្យឃើញមានសកម្មភាពត្រូវបានហាមឃាត់ដូចមានចែងក្នុងមាត្រា៥៦នៃច្បាប់នេះ។

ជំពូកទី៩
បទប្បញ្ញត្តិបច្ចេកទេសប្រព័ន្ធទឹកកខ្វក់

មាត្រា៧០ .-

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវរៀបចំបង្កើតបទប្បញ្ញត្តិបច្ចេកទេសប្រព័ន្ធទឹកកខ្វក់ឱ្យស្រប នឹងបច្ចេកវិទ្យាថ្មីៗ និងការតម្រូវបច្ចេកទេសផ្សេងទៀតឆ្លើយតបនឹងបទប្បញ្ញត្តិបច្ចេកទេសអន្តរជាតិ ដើម្បីបម្រើឱ្យការងារប្រព័ន្ធទឹកកខ្វក់ និងប្រតិបត្តិការប្រព័ន្ធទឹកកខ្វក់។

បទប្បញ្ញត្តិបច្ចេកទេសប្រព័ន្ធទឹកកខ្វក់ មានជាអាទិ៍៖

- បទប្បញ្ញត្តិបច្ចេកទេសគំនូររចនាប្លង់ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់
- បទប្បញ្ញត្តិបច្ចេកទេសគំនូររចនាប្លង់ប្រព័ន្ធលូ
- បទប្បញ្ញត្តិបច្ចេកទេសសំណង់ឋបនីយកណ្ដទឹកកខ្វក់
- បទប្បញ្ញត្តិបច្ចេកទេសសាងសង់លូមេ
- បទប្បញ្ញត្តិបច្ចេកទេសអណ្ដូងលូ
- បទប្បញ្ញត្តិបច្ចេកទេសការតភ្ជាប់លូ
- បទប្បញ្ញត្តិបច្ចេកទេសសាងសង់ឬដំឡើងអាងសិបទិក
- បទប្បញ្ញត្តិបច្ចេកទេសគម្របអណ្ដូងលូនិងចម្រឹងអណ្ដូងលូ
- បទប្បញ្ញត្តិបច្ចេកទេសផ្សេងទៀតដែលពាក់ព័ន្ធនឹងប្រព័ន្ធទឹកកខ្វក់។

បទប្បញ្ញត្តិបច្ចេកទេសប្រព័ន្ធទឹកកខ្វក់នីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ជំពូកទី១០
ប្រតិបត្តិការអាជីវកម្មប្រព័ន្ធទឹកកខ្វក់
ផ្នែកទី១
ការប្រកបអាជីវកម្មប្រព័ន្ធទឹកកខ្វក់

មាត្រា៧១ .-

បុគ្គលដែលប្រកបអាជីវកម្មប្រព័ន្ធទឹកកខ្វក់ ត្រូវមានលិខិតអនុញ្ញាតឬអាជ្ញាបណ្ណប្រកបអាជីវកម្មប្រព័ន្ធទឹកកខ្វក់ដែលចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូននិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា៧២ .-

លក្ខខណ្ឌនិងនីតិវិធីនៃការផ្ដល់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណប្រកបអាជីវកម្មប្រព័ន្ធទឹកកខ្វក់ ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៧៣ .-

ការស្នើសុំប្រកបអាជីវកម្មប្រព័ន្ធទឹកកខ្វក់ ត្រូវបង់កម្រៃសេវាសាធារណៈ។

កម្រៃសេវាសាធារណៈនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា៧៤ .-

រាល់ការប្រកបអាជីវកម្មប្រព័ន្ធទឹកកខ្វក់ ត្រូវមានអ្នកបច្ចេកទេសដែលបានទទួលការបណ្តុះបណ្តាល មានគ្រឿងឧបករណ៍តាមមុខងារគ្រប់គ្រាន់មានវិធានប្រតិបត្តិការប្រកបដោយសុវត្ថិភាពនិងមានយន្តបករណ៍បច្ចេកទេសគ្រប់គ្រាន់។

ដោយឡែកការកែច្នៃយានយន្តសម្រាប់ប្រើប្រាស់ការងារបូមស្តារនិងដឹកជញ្ជូន ត្រូវអនុលោមតាមបទប្បញ្ញត្តិត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា៧៥ .-

គោលការណ៍ណែនាំស្តីពីលក្ខខណ្ឌចាំបាច់និងវិធានការសុវត្ថិភាពសម្រាប់ប្រតិបត្តិការអាជីវកម្មបូមស្តារនិងដឹកជញ្ជូន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូននិងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

មាត្រា៧៦ .-

បុគ្គលដែលប្រកបអាជីវកម្មបូមស្តារនិងដឹកជញ្ជូន ត្រូវមានកាតព្វកិច្ចចំពោះកម្មករ និយោជិតរបស់ខ្លួនដូចខាងក្រោម៖

១- ផ្តល់ការបណ្តុះបណ្តាលអំពីវិធានសុវត្ថិភាពក្នុងការបូមស្តារ ការដឹកជញ្ជូននិងការបញ្ចេញចោលទឹកកខ្វក់ ទៅក្នុងកន្លែងឬទីតាំងកំណត់របស់ភ្នាក់ងារមានសមត្ថកិច្ច។

២- ផ្តល់ឧបករណ៍សុវត្ថិភាពដល់បុគ្គលិកប្រតិបត្តិការបូមស្តារនិងដឹកជញ្ជូនផ្ទាល់។

៣- ផ្តល់ការណែនាំអំពីបទដ្ឋានសម្រាប់ប្រើប្រាស់ឧបករណ៍បូមស្តារនិងដឹកជញ្ជូន និងឧបករណ៍ការពារសុវត្ថិភាព។

៤- ផ្តល់ការណែនាំអំពីវិធីត្រួតពិនិត្យ និងថែទាំឧបករណ៍ប្រើប្រាស់បូមស្តារនិងដឹកជញ្ជូនជាប្រចាំ។

គោលការណ៍ណែនាំស្តីពីការប្រើប្រាស់ឧបករណ៍សុវត្ថិភាព ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា៧៧ .-

ក្នុងការបញ្ចេញឬបង្ហូរចោលទឹកកខ្វក់និង/ឬសំណល់កក់ ដែលបានមកពីការបូមស្តារនិងដឹកជញ្ជូន បុគ្គលដែលប្រកបអាជីវកម្មប្រព័ន្ធទឹកកខ្វក់ត្រូវអនុវត្តតាមវិធានដូចខាងក្រោម៖

១- ត្រូវបញ្ចេញឬបង្ហូរចោលទឹកកខ្វក់និង/ឬសំណល់កក់ នៅទីតាំងដែលមានការអនុញ្ញាតពីក្រសួង ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចនៅតាមមូលដ្ឋាននីមួយៗនិងត្រូវគោរពតាមលក្ខខណ្ឌ ដែលតម្រូវដោយក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចនៅតាមទីតាំងនោះ។

២- ចំពោះការបញ្ចេញទឹកកខ្វក់ពីយានយន្តដឹកជញ្ជូនទឹកកខ្វក់ បញ្ចូលទៅក្នុងប្រព័ន្ធលូ ត្រូវមានការអនុញ្ញាតពីសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ជាមុន។

មាត្រា៧៨ .–

បុគ្គលដែលប្រកបអាជីវកម្មបូមស្តារនិងដឹកជញ្ជូនទឹកកខ្វក់និង/ឬសំណល់កក់ដែលបានបូមស្តារទឹកកខ្វក់ ឬបូមស្តារនិងសម្អាតសំណល់កក់ ត្រូវបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី១នៃកថាខណ្ឌទី១នៃមាត្រា៦១នៃច្បាប់នេះ និងត្រូវអនុវត្តតាមវិធានដូចមានចែងក្នុងចំណុចទី១នៃមាត្រា៧៧នៃច្បាប់នេះ។

ផ្នែកទី២
សិទ្ធិនិងកាតព្វកិច្ចរបស់ប្រតិបត្តិករនិងអ្នកប្រើប្រាស់

មាត្រា៧៩ .–

ប្រតិបត្តិករដែលទទួលបានសិទ្ធិគ្រប់គ្រង ថែទាំ និងប្រតិបត្តិការប្រព័ន្ធទឹកកខ្វក់ មានសិទ្ធិដូចខាងក្រោម៖

- គ្រប់គ្រងនិងប្រតិបត្តិការប្រព័ន្ធទឹកកខ្វក់តាមកិច្ចព្រមព្រៀងវិនិយោគ
- អាចលើកសំណើកែសម្រួលលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងារប្រតិបត្តិការប្រព័ន្ធទឹកកខ្វក់ជូនសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ពិនិត្យនិងសម្រេច
- ចូលរួមពិភាក្សា និងផ្តល់យោបល់លើផែនការអភិវឌ្ឍន៍ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់និង/ឬប្រព័ន្ធលូក្នុងដែនរដ្ឋបាលដែលខ្លួនបានវិនិយោគ
- ប្រមូលកម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ
- ទទួលបានសំណងរាល់ការខូចខាតដែលបង្កឡើងដោយភាគីពាក់ព័ន្ធ ដែលបានប្រព្រឹត្តផ្ទុយនឹងកិច្ចព្រមព្រៀងវិនិយោគ ឬផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ
- សិទ្ធិផ្សេងទៀតដែលចែងក្នុងកិច្ចព្រមព្រៀងវិនិយោគនិងស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ប្រតិបត្តិករដែលទទួលបានសិទ្ធិគ្រប់គ្រង ថែទាំ និងប្រតិបត្តិការប្រព័ន្ធទឹកកខ្វក់ មានកាតព្វកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងទ្រព្យសម្បត្តិតាមកិច្ចព្រមព្រៀងវិនិយោគ
- អនុវត្តតាមនីតិវិធីនិងវិធាននានាដែលមានចែងក្នុងច្បាប់នេះ
- ដោះស្រាយឧបទ្ទវហេតុដែលកើតមានក្នុងកំឡុងពេលវិនិយោគ រហូតដល់បញ្ចប់កិច្ចព្រមព្រៀង
- រៀបចំគម្រោងគិតថ្លៃសេវាប្រើប្រាស់ប្រព័ន្ធលូជូនទៅសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ធ្វើការពិនិត្យនិងសម្រេច
- បង្កើតទិន្នន័យលំនៅឋាន និងទីតាំងនានាដែលតភ្ជាប់បំពង់លូនិងបង្ហូរទឹកកខ្វក់ចូលក្នុងប្រព័ន្ធលូដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន
- សហការជាមួយអង្គភាពរដ្ឋាករទឹក ឬអ្នកផ្គត់ផ្គង់ទឹកស្អាតដើម្បីប្រមូលកម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ
- ផ្តល់ព័ត៌មានស្តីពីកិច្ចសន្យាតភ្ជាប់ជាមួយប្រព័ន្ធលូ តាមការស្នើសុំរបស់សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់
- ការធានាសំណង់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទឹកកខ្វក់ឱ្យបានត្រឹមត្រូវ សុវត្ថិភាព ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងកិច្ចព្រមព្រៀងវិនិយោគ

- ទូទាត់សំណងនៅពេលបង្កការខូចខាតដល់អ្នកប្រើប្រាស់ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- រាយការណ៍អំពីសកម្មភាពការងារតាមពេលវេលាកំណត់ដូចមានចែងក្នុងកិច្ចព្រមព្រៀងវិនិយោគជូនសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់
- គោរពនិងបំពេញកាតព្វកិច្ចផ្សេងទៀតតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា៨០ .-

អ្នកប្រើប្រាស់ប្រព័ន្ធលូ មានសិទ្ធិដូចខាងក្រោម៖
- ទទួលបានសេវាប្រើប្រាស់ប្រព័ន្ធលូតាមកិច្ចសន្យា
- ស្នើសុំឱ្យសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ឬប្រតិបត្តិករ ដោះស្រាយការតភ្ជាប់បំពង់លូជាមួយនឹងបណ្ដាញលូឱ្យបានឆាប់រហ័ស
- ទទួលបានព័ត៌មានទៀងទាត់ដែលពាក់ព័ន្ធនឹងការប្រើប្រាស់និងកម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូរបស់ខ្លួនពីសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ឬប្រតិបត្តិករ
- ប្ដឹងតវ៉ានិងទាមទារសំណងខូចខាតពីសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ឬប្រតិបត្តិករដែលបំពាននឹងកិច្ចសន្យា ឬអនុវត្តផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- សិទ្ធិផ្សេងទៀតដែលបានកំណត់ក្នុងកិច្ចសន្យានិងស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

អ្នកប្រើប្រាស់ប្រព័ន្ធលូ មានកាតព្វកិច្ចដូចខាងក្រោម៖
- បង់កម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូឱ្យបានទៀងទាត់និងទាន់ពេលវេលា
- បង្ហូរទឹកកខ្វក់ចូលក្នុងប្រព័ន្ធលូ ដោយគោរពតាមកិច្ចសន្យា បទប្បញ្ញត្តិនៃច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ផ្ដល់ព័ត៌មានជាបន្ទាន់ដល់សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ឬប្រតិបត្តិករ អំពីឧបទ្ទវហេតុ ឬបាតុភាពដែលអាចបង្កឱ្យខូចខាតប្រព័ន្ធលូ
- តភ្ជាប់បំពង់លូពីលំនៅឋាន និង/ឬទីតាំងរបស់ខ្លួនជាមួយបណ្ដាញលូ ដូចមានចែងក្នុងកិច្ចសន្យានិងស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ
- សងរាល់ការខូចខាតដែលកើតចេញពីការប្រព្រឹត្តផ្ទុយនឹងកិច្ចសន្យា បទប្បញ្ញត្តិនៃច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- បំពេញកាតព្វកិច្ចផ្សេងទៀតដែលមានចែងក្នុងកិច្ចសន្យានិងស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ជំពូកទី១១
កម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ

មាត្រា៨១ .-

កម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ ត្រូវកំណត់ដោយផ្អែកតាមគោលការណ៍ ដូចខាងក្រោម៖
- អនុលោមតាមដំណាក់កាលអភិវឌ្ឍសង្គម សេដ្ឋកិច្ច សង្គតិភាពនឹងកម្រិតវិនិយោគ កែលម្អគុណភាពសេវា ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រង ប្រតិបត្តិការ និងថែទាំប្រព័ន្ធទឹកកខ្វក់
- លើកកម្ពស់ប្រសិទ្ធភាពសេដ្ឋកិច្ច ឧត្តមភាពផលចំណេញ ដើម្បីបង្កើនការវិនិយោគ និងធានាប្រសិទ្ធភាពនៃការអនុវត្តបទប្បញ្ញត្តិច្បាប់

- លើកកម្ពស់ផលប្រយោជន៍សាធារណៈនិងដាក់ចេញនូវក្របខ័ណ្ឌប្រតិបត្តិការប្រកបដោយសមធម៌សម្រាប់អតិថិជនក្រីក្រនិងក្រុមជនងាយរងគ្រោះ
- អាជីវកម្មមានប្រាក់ចំណូលគ្រប់គ្រាន់ ដើម្បីធានាដល់ការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព តម្លាភាព សាមញ្ញ និងចំណាយតិច
- រដ្ឋបំពេញបង្គ្រប់ថ្លៃចំណាយលើការគ្រប់គ្រង ប្រតិបត្តិការ និងថែទាំ ក្នុងករណីដែលចំណូលកម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូទទួលបានទាបជាងថ្លៃចំណាយជាក់ស្តែង ដោយអនុលោមតាមច្បាប់ជាធរមាន។

មាត្រា៨២ .-

ការកំណត់អត្រាកម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ អាចត្រូវបានកែសម្រួលក្នុងករណីដូចខាងក្រោម៖

១- នៅពេលមានការផ្លាស់ប្តូរការវិនិយោគលើបច្ចេកទេសនិងបច្ចេកវិទ្យាថ្មីៗនៃការធ្វើប្រព្រឹត្តកម្មទឹកកខ្វក់ និងគុណភាពសេវា។

២- ការផ្លាស់ប្តូរយន្តការនិងគោលនយោបាយរបស់រដ្ឋ។

៣- លក្ខខណ្ឌអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់ប្រទេសជាតិតំបន់ទីប្រជុំជននិងកំណើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋកាន់តែល្អប្រសើរឡើង។

៤- ការធ្លាក់ចុះឬឡើងថ្លៃវត្ថុធាតុដើមនៅលើទីផ្សារសកល តំបន់ និងក្នុងប្រទេស។

៥- វិបត្តិសេដ្ឋកិច្ចឬហិរញ្ញវត្ថុសកលឬក្នុងប្រទេស ឬករណីប្រធានសក្តិផ្សេងទៀត ដែលធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ។

រាល់សំណើកែសម្រួលអត្រាកម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូខាងលើ ត្រូវស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល។

មាត្រា៨៣ .-

ការគណនាអត្រានៃកម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ ត្រូវអនុវត្តដូចខាងក្រោម៖

១- ចំពោះការបញ្ចេញទឹកកខ្វក់ពីលំនៅឋាន ត្រូវគណនាអនុលោមតាមសមាមាត្រនៃបរិមាណប្រើប្រាស់ទឹកស្អាត។

២- ចំពោះការបញ្ចេញទឹកកខ្វក់ពីប្រភពផ្សេងទៀតក្រៅពីលំនៅឋាន ត្រូវគណនាអនុលោមតាមសមាមាត្រនៃបរិមាណប្រើប្រាស់ទឹកស្អាតនិងកម្រិតសារធាតុបំពុលនៃទឹកកខ្វក់ដែលបញ្ចូលទៅប្រព័ន្ធលូ។

៣- វិធីសាស្ត្រផ្សេងទៀតដែលកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

អត្រានៃកម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា៨៤ .-

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ត្រូវសហការជាមួយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ដើម្បីប្រមូលតម្លៃសេវាប្រើប្រាស់ប្រព័ន្ធលូ។

តម្លៃសេវាប្រើប្រាស់ប្រព័ន្ធលូដែលប្រមូលបាន ត្រូវប្រើប្រាស់សម្រាប់ទូទាត់តាមកិច្ចសន្យាគ្រប់គ្រងប្រតិបត្តិការ និងពង្រឹងសមត្ថភាពវិនិយោគក្នុងការអភិវឌ្ឍ ការសាងសង់ ការជួសជុល ការថែទាំប្រព័ន្ធទឹកកខ្វក់តាមស្តង់ដារបច្ចេកទេស និងបច្ចេកវិទ្យាថ្មីៗ។

បែបបទ និងនីតិវិធីនៃការប្រមូលកម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូត្រូវកំណត់ដោយអនុក្រឹត្យ។

ជំពូកទី១២
ថវិកាសាងសង់និងថែទាំប្រព័ន្ធទឹកកខ្វក់

មាត្រា៨៥ .-

ថវិកាសាងសង់និងថែទាំប្រព័ន្ធទឹកកខ្វក់ មានប្រភពធនធានមកពី៖

- ថវិកាជាតិ
- ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍនានា
- ហិរញ្ញប្បទានពីវិស័យឯកជន
- អំណោយសប្បុរសធម៌ពីសប្បុរសជន អង្គការជាតិ អង្គការអន្តរជាតិ សមាគម ឬសហគមន៍
- ផលចំណេញពីការវិនិយោគនិងការផ្តល់សេវាអាជីវកម្មស្របច្បាប់លើប្រព័ន្ធទឹកកខ្វក់
- ចំណូលពីប្រភពស្របច្បាប់ផ្សេងទៀត។

មាត្រា៨៦ .-

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិនិត្យលទ្ធភាពផ្តល់កញ្ចប់ថវិកាឱ្យបានគ្រប់គ្រាន់ទៅដល់សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ដើម្បីគាំទ្រការអភិវឌ្ឍ ការសាងសង់ ការជួសជុល ការថែទាំ និងការគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

មាត្រា៨៧ .-

ការគ្រប់គ្រងនិងការបែងចែកថវិកាសម្រាប់ការអភិវឌ្ឍ ការសាងសង់ ការជួសជុល និងការថែទាំប្រព័ន្ធទឹកកខ្វក់ ត្រូវកំណត់ដោយអនុក្រឹត្យ។

ជំពូកទី១៣
អធិការកិច្ចប្រព័ន្ធទឹកកខ្វក់

មាត្រា៨៨ .-

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវតែងតាំងមន្ត្រីអធិការកិច្ចប្រព័ន្ធទឹកកខ្វក់ ដើម្បីតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការងារសាងសង់ ដំឡើង កែប្រែ ជួសជុល ថែទាំ តភ្ជាប់ និងប្រតិបត្តិការប្រព័ន្ធទឹកកខ្វក់ និងសកម្មភាពផ្សេងទៀតដែលពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទឹកកខ្វក់ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។ សិទ្ធិនិងភារកិច្ចរបស់មន្ត្រីអធិការកិច្ចប្រព័ន្ធទឹកកខ្វក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មន្ត្រីអធិការកិច្ចប្រព័ន្ធទឹកកខ្វក់ ត្រូវទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ដើម្បីពិនិត្យបទល្មើសដូចមានចែងក្នុងច្បាប់នេះ ដោយអនុលោមតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ក្នុងពេលប្រតិបត្តិការពិនិត្យបទល្មើស មន្ត្រីអធិការកិច្ចប្រព័ន្ធទឹកកខ្វក់ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវអនុវត្តភារកិច្ចដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ចំពោះមន្ត្រីអធិការកិច្ចប្រព័ន្ធទឹកកខ្វក់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា៨៩ .-

មន្ត្រីអធិការកិច្ចប្រព័ន្ធទឹកកខ្វក់ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ មានសិទ្ធិនិងភារកិច្ចដូចខាងក្រោម៖

- ចូលទៅក្នុងទីតាំងសាងសង់ដើម្បីតាមដាន ពិនិត្យ និងប្រតិបត្តិការងារតាមសមត្ថកិច្ច ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ
- ចាត់វិធានការផ្អាកឬបញ្ឈប់ជាបណ្ដោះអាសន្នចំពោះការបញ្ចេញទឹកកខ្វក់មិនត្រឹមត្រូវតាមស្តង់ដាបញ្ចេញទឹកកខ្វក់ និងការតភ្ជាប់បណ្ដាញលូគ្មានលិខិតអនុញ្ញាតឬមិនត្រឹមត្រូវតាមបទប្បញ្ញត្តិបច្ចេកទេសប្រព័ន្ធទឹកកខ្វក់
- សហការជាមួយមន្ត្រីមានសមត្ថកិច្ចជំនាញរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចដើម្បីទប់ស្កាត់ការបង្ហូរនិងការបញ្ចេញទឹកកខ្វក់គ្មានការអនុញ្ញាតឬមិនអនុលោមតាមកម្រិតស្តង់ដាបញ្ចេញទឹកកខ្វក់
- អនុវត្តការពិន័យអន្តរការណ៍ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ
- ចាត់វិធានការផ្សេងទៀតនៅក្នុងក្របខ័ណ្ឌនៃការអនុវត្តបទប្បញ្ញត្តិនៃច្បាប់នេះ។

បែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចប្រព័ន្ធទឹកកខ្វក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា៩០ .-

មន្ត្រីអធិការកិច្ចប្រព័ន្ធទឹកកខ្វក់ អាចចូលទៅក្នុងទីតាំងសាងសង់ ដំឡើង កែប្រែ ជួសជុល ថែទាំ តភ្ជាប់ និងប្រតិបត្តិការប្រព័ន្ធទឹកកខ្វក់ និងសកម្មភាពផ្សេងទៀតដែលពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទឹកកខ្វក់ ដើម្បីបំពេញភារកិច្ចរបស់ខ្លួន ដោយគ្មានការជូនដំណឹងឬជូនដំណឹងជាលាយលក្ខណ៍អក្សរតាមកាលបរិច្ឆេទកំណត់។

មន្ត្រីអធិការកិច្ចប្រព័ន្ធទឹកកខ្វក់ មានសិទ្ធិស្នើសុំជំនួយសហការពីក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនិងអាជ្ញាធរដែនដី ដើម្បីចូលរួមទប់ស្កាត់និងបង្ក្រាបបទល្មើស ដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ។

មាត្រា៩១ .-

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចប្រព័ន្ធទឹកកខ្វក់ ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ ព្រមទាំងមានលិខិតអនុញ្ញាតឱ្យបំពេញបេសកកម្ម។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចប្រព័ន្ធទឹកកខ្វក់ ត្រូវកំណត់ដោយអនុក្រឹត្យ។

ជំពូកទី១៤
ទោសប្បញ្ញត្តិ

មាត្រា៩២ .-

ទណ្ឌកម្មនៅក្នុងច្បាប់នេះ រួមមានទណ្ឌកម្មរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌ។

មាត្រា៩៣ .-

ទណ្ឌកម្មរដ្ឋបាល រួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ

- ការផ្អាកជាបណ្តោះអាសន្ន
- ការតម្រូវឱ្យកែលម្អ
- ការតម្រូវឱ្យផ្លាស់ប្តូរសម្ភារៈបរិក្ខារឬគ្រឿងបង្គុំលូ
- ការតម្រូវឱ្យរៀបចំអាងប្រមូលផ្តុំរួមឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ផ្ទាល់ខ្លួន
- ការតម្រូវឱ្យធ្វើបដិទានឡើងវិញ
- ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណដែលបានផ្តល់អនុលោមតាមច្បាប់នេះ។

អំពើផ្សេងទៀតដែលត្រូវរងទណ្ឌកម្មរដ្ឋបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល ជាសមត្ថកិច្ចរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចអំពីទណ្ឌកម្មរដ្ឋបាល ក្រៅពីការព្រមានជាលាយលក្ខណ៍អក្សរ ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ មានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរ ទៅរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលសេចក្តីសម្រេច។ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវសម្រេចលើពាក្យប្តឹងតវ៉ានេះក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យប្តឹងតវ៉ា។ បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន លើពាក្យប្តឹងតវ៉ា មានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ចតាមនីតិវិធីក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច។ ការដាក់ពាក្យប្តឹងតវ៉ារបស់បុគ្គលខាងលើ មិនមានអានុភាពផ្អាកការអនុវត្តសេចក្តីសម្រេចអំពីទណ្ឌកម្មរដ្ឋបាលនោះទេ។

មាត្រា៩៤ .-

ទណ្ឌកម្មព្រហ្មទណ្ឌ រួមមាន៖

- ពិន័យអន្តរការណ៍
- ពិន័យជាប្រាក់
- ទោសដាក់ពន្ធនាគារ។

បទល្មើសដែលត្រូវពិន័យអន្តរការណ៍ស្របតាមច្បាប់នេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

ការសម្រេចដាក់ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចប្រព័ន្ធទឹកកខ្វក់ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌។

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យបណ្តឹងអាជ្ញារលត់។ ការបង់ប្រាក់ពិន័យអន្តរការណ៍មិនមែនជាឧបសគ្គដល់ការអនុវត្តទណ្ឌកម្មរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងច្បាប់ព្រហ្មទណ្ឌជាធរមានផ្សេងទៀតឡើយ។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចប្រព័ន្ធទឹកកខ្វក់ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវកសាងសំណុំរឿងនៃបទល្មើសហើយបញ្ជូនទៅតុលាការតាម

[illegible]និងនីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យអន្តរការណ៍ ការគ្រប់គ្រងបង្កាន់ដៃ

បង់ប្រាក់ពិន័យអន្តរការណ៍ និងការចាត់ចែងប្រាក់ចំណូលដែលបានពីការពិន័យអន្តរការណ៍ ចំពោះអំពើល្មើស ដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រាជរដ្ឋាភិបាល អាចផ្តល់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើស ដូចមានចែងក្នុងច្បាប់នេះ។

មាត្រា៩៦ .-

មន្ត្រីអធិការកិច្ចប្រព័ន្ធទឹកកខ្វក់ឬមន្ត្រីមានសមត្ថកិច្ចដែលអនុវត្តបំពានបទប្បញ្ញត្តិនៃច្បាប់នេះ និង បទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងទៀតក្នុងការអនុវត្តការកិច្ចរបស់ខ្លួនត្រូវទទួលខុសត្រូវផ្នែករដ្ឋបាលនេះ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។ ការទទួលខុសត្រូវផ្នែករដ្ឋបាល មិនមែន ជាឧបសគ្គសម្រាប់ការចោទប្រកាន់ ការផ្តន្ទាទោសព្រហ្មទណ្ឌ ព្រមទាំងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ស្របតាមច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀតឡើយ។

មាត្រា៩៧ .-

ជនណាដែលទទួលបានសិទ្ធិក្នុងការអភិវឌ្ឍ ការសាងសង់ ការស្តារឡើងវិញ ឬការពង្រីកប្រព័ន្ធ ទឹកកខ្វក់ មិនអនុវត្តតាមគម្រោងប្លង់សាងសង់និងកិច្ចសន្យានិងបទប្បញ្ញត្តិបច្ចេកទេសប្រព័ន្ធទឹកកខ្វក់ ដូចមានចែងក្នុងមាត្រា១៧នៃច្បាប់នេះ ត្រូវតម្រូវឱ្យកែលម្អឡើងវិញជាបន្ទាន់។

ក្នុងករណីរឹងទទឹង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជា ប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៨ ០០០ ០០០(ប្រាំបីលាន)រៀល។

មាត្រា៩៨ .-

ជនណាដែលអនុវត្តគម្រោងសាងសង់ មិនគោរពតាមបទប្បញ្ញត្តិសុវត្ថិភាពការងារ ឬវិធានការ សុវត្ថិភាពចរាចរណ៍ ដូចមានចែងក្នុងមាត្រា១៨នៃច្បាប់នេះ បណ្តាលឱ្យមានរងរបួសដល់អ្នកដទៃហើយ បណ្តាលឱ្យអ្នករងគ្រោះអសមត្ថភាពធ្វើការងារក្នុងរយៈពេលស្មើឬលើសពី៨(ប្រាំបី)ថ្ងៃ គិតពីថ្ងៃកើតហេតុ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំនិងពិន័យជាប្រាក់ពី៤០០ ០០០(បួនសែន)រៀល ទៅ៤ ០០០ ០០០(បួនលាន)រៀល។

អំពើល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០(បួនលាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល ក្នុងករណីណាមួយដូចខាងក្រោម៖

- បណ្តាលឱ្យបាត់បង់ជីវិតអ្នកដទៃ
- បណ្តាលឱ្យមានរបួសមនុស្សច្រើននាក់
- បណ្តាលឱ្យអ្នកដទៃមានពិការភាពជាអចិន្ត្រៃយ៍។

មាត្រា៩៩ .-

ជនណាដែលមិនសាងសង់បណ្តាញលូញែក ក្នុងតំបន់អភិវឌ្ឍន៍ថ្មី ដូចមានចែងក្នុងមាត្រា២៥នៃ ច្បាប់នេះ ត្រូវតម្រូវឱ្យកែលម្អធ្វើឡើងវិញ។

ក្នុងករណីរឹងទទឹង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៨ ០០០ ០០០(ប្រាំបីលាន)រៀល។

មាត្រា១០០ .-

មន្ត្រីអធិការកិច្ចប្រព័ន្ធទឹកកខ្វក់ ឬមន្ត្រីមានសមត្ថកិច្ចណាដែលនៅក្នុងក្របខ័ណ្ឌមុខងារឬក្នុងឱកាសបំពេញមុខងាររបស់ខ្លួន ដែលបានដកហូតយកលិខិតអនុញ្ញាតឬអាជ្ញាបណ្ណប្រកបអាជីវកម្មប្រព័ន្ធទឹកកខ្វក់ ដោយគ្មានមូលហេតុច្បាស់លាស់ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ថ្ងៃ ទៅ១(មួយ)ខែ និងពិន័យជាប្រាក់ពី១០០ ០០០(មួយសែន)រៀល ទៅ៤០០ ០០០(បួនសែន)រៀល។

ក្នុងករណីដែលអំពើល្មើសខាងលើបណ្ដាលឱ្យមានការខូចខាតឬខាតបង់អាជីវកម្ម អង្គភាពសាមីត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតឬខាតបង់នោះ ស្របតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីនិងច្បាប់ជាធរមានផ្សេងទៀត។

ក្នុងករណីមន្ត្រីអធិការកិច្ចប្រព័ន្ធទឹកកខ្វក់ឬមន្ត្រីមានសមត្ថកិច្ចដែលប្រើសិទ្ធិអំណាចរំលោភដោយទទួលបានអត្ថប្រយោជន៍ក្នុងការបំពេញមុខងាររបស់ខ្លួនឬក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួននូវអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវផ្ដន្ទាទោសតាមបញ្ញត្តិនៃមាត្រា៣៥(បទរំលោភអំណាច)នៃច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ ដែលជាបទល្មើសពុករលួយនិងត្រូវស្ថិតនៅក្រោមសមត្ថកិច្ចតែមួយគត់របស់អង្គភាពប្រឆាំងអំពើពុករលួយ ក្នុងការស៊ើបអង្កេតនិងកសាងសំណុំរឿងពុករលួយទៅតុលាការ។

អង្គភាពនិងបុគ្គលដទៃទៀតដែលបានដឹងពីបទល្មើសពុករលួយ ដែលមានចែងនៅក្នុងច្បាប់នេះ និងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ត្រូវប្ដឹងទៅអង្គភាពឬការិយាល័យរាជធានី ខេត្តប្រឆាំងអំពើពុករលួយ អំពីរឿងហេតុនៃបទល្មើសទាំងនេះ។

មាត្រា១០១ .-

ជនណាដែលកែប្រែបណ្ដាញលូនិងគម្របអណ្ដូងលូដែលមិនគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រា៣១នៃច្បាប់នេះ ត្រូវតម្រូវឱ្យកែលម្អឬផ្លាស់ប្ដូរសម្ភារៈបរិក្ខាឬគ្រឿងបង្គុំលូទាំងនោះចេញ។

ក្នុងករណីរឹងទទឹង ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី៤០០ ០០០(បួនសែន)រៀល ទៅ៤ ០០០ ០០០(បួនលាន)រៀល។

មាត្រា១០២ .-

ជនណាដែលរំខានឬបង្អាក់ដំណើរការនៃការតភ្ជាប់បណ្ដាញលូណាមួយដោយគ្មានការអនុញ្ញាតដូចមានចែងក្នុងមាត្រា៣៤នៃច្បាប់នេះ ត្រូវតម្រូវឱ្យផ្អាកជាបណ្ដោះអាសន្ន។

ក្នុងករណីរឹងទទឹង ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី៤០០ ០០០(បួនសែន)រៀល ទៅ៤ ០០០ ០០០(បួនលាន)រៀល។

មាត្រា១០៣ .-

ជនណាដែលតភ្ជាប់បណ្ដាញលូពីតំបន់សេដ្ឋកិច្ចពិសេស សួនឧស្សាហកម្ម ឬសួននវានុវត្តន៍ជាមួយបណ្ដាញលូដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៣៩នៃច្បាប់នេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី៤០០ ០០០ (បួនសែន)រៀល ទៅ៤ ០០០ ០០០ (បួនលាន)រៀល។

មាត្រា១០៤ .-

ជនណាដែលជីកកប់ ជីកគាស់ ជីកលុង ឬចោះខួងផ្លូវថ្នល់ ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៨៤នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី៤០០ ០០០(បួនសែន)រៀល ទៅ៤ ០០០ ០០០(បួនលាន)រៀល។

មាត្រា១០៥ .-

ជនណាដែលបញ្ចេញទឹកកខ្វក់ពីប្រភពផ្សេងទៀតក្រៅពីលំនៅឋាន មិនអនុវត្តតាមចំណុចទី២-ក កថាខណ្ឌទី១នៃមាត្រា៤៨នៃច្បាប់នេះ ត្រូវតម្រូវឱ្យរៀបចំអាងប្រមូលផ្តុំរួមឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ផ្ទាល់ខ្លួនជាបន្ទាន់។

ក្នុងករណីរឹងទទឹង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី៤០០ ០០០(បួនសែន)រៀល ទៅ៤ ០០០ ០០០(បួនលាន)រៀល។

មាត្រា១០៦ .-

ជនណាដែលបំផ្លិចបំផ្លាញ ឬធ្វើឱ្យខូចខាតដោយចេតនានូវមុខងារនៃប្រព័ន្ធលូ ឬបណ្តាញលូ ដោយបង្កការរំខាន ឬរំលោភបទប្បញ្ញត្តិបច្ចេកទេសក្នុងការសាងសង់ ការជួសជុល ការថែទាំ និងការការពារហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទឹកកខ្វក់ និង/ឬប្រព័ន្ធលូ ដូចមានចែងនឹងចំណុចទី១ឬចំណុចទី២នៃមាត្រា៥៦នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៨ ០០០ ០០០(ប្រាំបីលាន)រៀល។

មាត្រា១០៧ .-

ជនណាដែលធ្វើប្រព្រឹត្តកម្ម កែច្នៃ ឬរក្សាទុកសំណល់កក់ មិនអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី១នៃកថាខណ្ឌទី១នៃមាត្រា៦១នៃច្បាប់នេះ ត្រូវតម្រូវឱ្យកែលម្អឡើងវិញជាបន្ទាន់។

ក្នុងករណីរឹងទទឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី៤០០ ០០០(បួនសែន)រៀល ទៅ៤ ០០០ ០០០(បួនលាន)រៀល។

មាត្រា១០៨ .-

ចំពោះជនណាដែលប្រព្រឹត្តបទល្មើសដែលមានចែងក្នុងកថាខណ្ឌទី២នៃមាត្រា៩៧ មាត្រា៩៨ កថាខណ្ឌទី២នៃមាត្រា៩៩ កថាខណ្ឌទី២នៃមាត្រា១០១ កថាខណ្ឌទី២នៃមាត្រា១០២ មាត្រា១០៣ មាត្រា១០៤ កថាខណ្ឌទី២នៃមាត្រា១០៥ មាត្រា១០៦ និងកថាខណ្ឌទី២នៃមាត្រា១០៧នៃច្បាប់នេះ តុលាការអាចប្រកាសទោសបន្ថែមមួយឬច្រើន ដូចមានចែងក្នុងមាត្រា៥៣(ប្រភេទទោសបន្ថែម)នៃក្រមព្រហ្មទណ្ឌ។

ខ្លឹមសារ បែបបទ និងនីតិវិធីសម្រាប់ការអនុវត្តទោសបន្ថែមទាំងនេះ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។

មាត្រា១០៩ .-

នីតិបុគ្គលអាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងចាប់ពីមាត្រា៩៧ ដល់មាត្រា៩៩ និងពីមាត្រា១០១ ដល់មាត្រា១០៧នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ២០០ ០០០ ០០០(ពីររយលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

មាត្រា១១០ .-

ការអនុវត្តបទប្បញ្ញត្តិនៃជំពូកទី១៤នៃច្បាប់នេះ មិនរារាំងដល់ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត ក្នុងករណីដែលអំពើដែលកំណត់ថាជាបទល្មើសដែលមានចែងក្នុងច្បាប់នេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

ជំពូកទី១៥
អន្តរប្បញ្ញត្តិ

មាត្រា១១១ .-

លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងប្រព័ន្ធទឹកកខ្វក់ ត្រូវមានសុពលភាពរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស អនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

មាត្រា១១២ .-

បុគ្គលដែលប្រកបអាជីវកម្មប្រព័ន្ធទឹកកខ្វក់ត្រូវស្នើសុំលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្នុងរយៈពេល១(មួយ)ឆ្នាំ បន្ទាប់ពីច្បាប់នេះចូលជាធរមាន។

ជំពូកទី១៦
អវសានប្បញ្ញត្តិ

មាត្រា១១៣ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

ថ្ងៃ សុក្រ ៧កើត ខែ កត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០២៤

នស/រកម/១១២៤/០២៦

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

ប៉េង ពោធិ៍នា

៣២/ ៣២

ឧបសម្ព័ន្ធនៃច្បាប់ស្ដីពីប្រព័ន្ធទឹកកខ្វក់

សទ្ទានុក្រម

១- **ការកែប្រែ** សំដៅដល់ការផ្លាស់ប្ដូរ ឬកែសម្រួលផ្នែកណាមួយពីរចនាសម្ព័ន្ធដើមក្នុងគម្រោងប្លង់ រួមមានការបង្កើតបន្ថែម ការដកចេញនូវគ្រឿងបង្គុំសំណង់ណាមួយ។

២- **ការងារប្រព័ន្ធទឹកកខ្វក់** សំដៅដល់ការងារដែលពាក់ព័ន្ធនឹងវិស្វកម្មនៃការសិក្សាលើគម្រោងប្លង់ ការសាងសង់ ការស្ដារឡើងវិញ ការពង្រីក ការកែប្រែ ការដំឡើង ការជួសជុល និងការថែទាំប្រព័ន្ធទឹកកខ្វក់។

៣- **កម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ** សំដៅដល់ការបង់ថ្លៃសម្រាប់ថែទាំ ជួសជុល ស្ដារ ពង្រីកអណ្ដូងលូ បណ្ដាញលូ ប្រឡាយចំហ អាងស្តុក និងដំណើរការស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់។

៤- **ការបូមស្ដារនិងដឹកជញ្ជូនទឹកកខ្វក់** សំដៅដល់ការដឹកជញ្ជូនទឹកសំណល់រាវនិងសំណល់ភក់ ដែលបានបូមប្រមូល ស្ដារយកចេញពីបង្គន់ អណ្ដូងលូ អាងសិបទិក ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ឬស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ អាងប្រព្រឹត្តកម្មទឹកកខ្វក់ ឬអាងចម្រោះទឹកកខ្វក់ តាមមធ្យោបាយដឹកជញ្ជូនផ្សេងៗ។

៥- **ការធ្វើតេស្តគុណភាពទឹក** សំដៅដល់ការផ្ទៀងផ្ទាត់គុណភាពទឹកកខ្វក់តាមកម្រិតស្ដង់ដាតម្រូវដែលបង្ហូរចូលតាមប្រព័ន្ធលូ ឬបញ្ចេញពីប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ឬស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ អាងប្រព្រឹត្តកម្មទឹកកខ្វក់ឬអាងចម្រោះទឹកកខ្វក់ ទៅក្នុងតំបន់ទឹកសាធារណៈ។

៦- **ការប្រកបអាជីវកម្មប្រព័ន្ធទឹកកខ្វក់** សំដៅដល់បុគ្គលដែលប្រកបអាជីវកម្មពាក់ព័ន្ធនឹងការងារសាងសង់ ការស្ដារឡើងវិញ ការពង្រីក ការជួសជុល និងការថែទាំប្រព័ន្ធទឹកកខ្វក់ ព្រមទាំងប្រតិបត្តិការបូមស្ដារ និងដឹកជញ្ជូនទឹកកខ្វក់ ឬសំណល់ភក់។

៧- **បរិក្ខារទឹកកខ្វក់** សំដៅដល់អាងប្រព្រឹត្តកម្មទឹកកខ្វក់ និងគ្រឿងឧបករណ៍នានាដែលបានដំឡើង ឬសាងសង់ឡើងសម្រាប់ប្រមូល បញ្ជូន ធ្វើប្រព្រឹត្តកម្ម និងបញ្ចេញទឹកកខ្វក់ពីអគារ ឬបញ្ចេញទឹកសំណល់ឧស្សាហកម្ម ទៅចំណុចតភ្ជាប់របស់ប្រព័ន្ធលូ។

៨- **តំណភ្ជាប់** សំដៅដល់ការតភ្ជាប់បណ្ដាញលូនានាជាមួយប្រព័ន្ធលូ។

៩- **តំបន់ទឹកសាធារណៈ** សំដៅដល់ប្រភពទឹកសម្រាប់ប្រើប្រាស់ជាសាធារណៈ ដូចជាទន្លេ ដៃទន្លេ ស្ទឹង ព្រែក អូរ បឹង ស្រះ ត្រពាំង សមុទ្រ ដៃសមុទ្រ ពាម ប្រព័ន្ធប្រឡាយ ធារាសាស្ត្រ ទឹកក្រោមដី។ល។

១០-**ទឹកកខ្វក់** សំដៅដល់ទឹកដែលបានប្រែប្រួលលក្ខណៈដើមដោយសារសកម្មភាពរបស់មនុស្សដែលបញ្ចេញពីទីតាំងនានាចូលទៅក្នុងបណ្ដាញលូ ឬតំបន់ទឹកសាធារណៈ រួមទាំងទឹកភ្លៀងដែលហូរតាមបណ្ដាញលូរួម។

១១-**ទឹកសំណល់** សំដៅដល់ទឹកកខ្វក់ដែលបង្ហូរចេញពីទីតាំងចូលទៅក្នុងប្រព័ន្ធលូនិងទឹកកខ្វក់ដែលបានធ្វើប្រព្រឹត្តកម្មរួច ហើយបង្ហូរចេញពីស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ ឬអាងចម្រោះទឹកកខ្វក់ និងឧបករណ៍សម្អាតទឹកសំណល់ផ្សេងទៀត។

១២-**ទីតាំង** សំដៅដល់ទីសាធារណៈ អគារសាធារណៈ លំនៅឋាន លំនៅឋានប្រមូលផ្ដុំ បុរីលំនៅឋាន អគារអាជីវកម្មនិងផលិតកម្ម ទីក្រុងរណប រមណីយដ្ឋាន មណ្ឌលកម្សាន្ត ឬទីតាំងប្រហាក់ប្រហែលផ្សេងទៀត។

១៣-ទីសាធារណៈ សំដៅដល់សារមន្ទីរ កន្លែងពិព័រណ៍ពាណិជ្ជកម្ម សាលសន្និសីទឬសាលប្រជុំ គ្រឹះស្ថានសិក្សា មណ្ឌលកម្សាន្ត សួនសាធារណៈ ទីសក្ការគោរពបូជា ឬទីកន្លែងផ្សេងទៀតសម្រាប់មនុស្សប្រមូលផ្ដុំ ឬជួបជុំគ្នា។

១៤-ទីក្រុងរណប សំដៅដល់តំបន់អភិវឌ្ឍន៍ចម្រុះដែលមានលំនៅឋានទំនើប បុរី អាផាតមិន អគារខុនដូ សាលារៀន ផ្សារទំនើប សណ្ឋាគារ ភោជនីយដ្ឋាន អគារពាណិជ្ជកម្ម អគារសេវាកម្ម មណ្ឌលកម្សាន្ត ព្រមទាំងសំណង់ប្រហាក់ប្រហែលផ្សេងទៀត។

១៥-ទីលានគ្រប់គ្រងសំណល់កក់ សំដៅដល់ទីតាំងរក្សាទុកឬស្តុកសំណល់កក់ ដែលប្រមូលយកចេញពីប្រព័ន្ធលូ ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ អាងប្រព្រឹត្តកម្មទឹកកខ្វក់ អាងសិបទិក និងទីតាំងអាជីវកម្ម ផលិតកម្ម សម្រាប់កែច្នៃប្រើប្រាស់ឡើងវិញ។

១៦-ទឹកកខ្វក់ប្រើប្រាស់ឡើងវិញ សំដៅដល់ទឹកដែលបានធ្វើប្រព្រឹត្តកម្មឬចម្រោះរួច និងមានគុណភាពស្របតាមស្តង់ដាតម្រូវដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន និងអាចប្រើប្រាស់ឡើងវិញសម្រាប់ វិស័យឧស្សាហកម្ម សិប្បកម្ម កសិកម្ម ឬប្រើប្រាស់ក្នុងគោលបំណងផ្សេងទៀត។

១៧-បណ្តាញលូ សំដៅដល់បណ្តាញលូរួមនិងបណ្តាញលូញែក។

១៨-បណ្តាញលូរួម សំដៅដល់បណ្តាញលូដែលប្រមូលនិងបញ្ជូន ឬបង្ហូរទឹកកខ្វក់ និងទឹកភ្លៀងជាមួយគ្នា។

១៩-បណ្តាញលូញែក សំដៅដល់បណ្តាញលូដែលប្រមូលនិងបញ្ជូន ឬបង្ហូរទឹកកខ្វក់ និងទឹកភ្លៀងញែកដាច់ផ្សេងពីគ្នា។

២០-បណ្តាញលូមេ សំដៅដល់បណ្តាញលូរួម និងបណ្តាញលូញែកដែលតភ្ជាប់ទៅនឹងអាងស្តុកទឹកកខ្វក់ ស្ថានីយបូម ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ ឬអាងចម្រោះទឹកកខ្វក់។

២១-បណ្តាញលូមេរង សំដៅដល់បណ្តាញលូរួមនិងបណ្តាញលូញែកដែលតភ្ជាប់ទៅនឹងបណ្តាញលូមេ ដើម្បីប្រមូលនិងទទួលទឹកកខ្វក់និង/ឬទឹកភ្លៀងពីបណ្តាញលូខ្នែង។

២២-បណ្តាញលូខ្នែង សំដៅដល់បណ្តាញលូរួមនិងបណ្តាញលូញែកដែលតភ្ជាប់ទៅនឹងបណ្តាញលូមេ ឬ បណ្តាញលូមេរង។

២៣-បណ្តាញលូខ្នែងរង សំដៅដល់បណ្តាញលូរួមនិងបណ្តាញលូញែកដែលតភ្ជាប់ទៅនឹងបណ្តាញលូខ្នែង និងទទួលទឹកកខ្វក់ពីទីតាំងឬប្រភពបញ្ចេញ។

២៤-បណ្តាញលូស្ពាត់ សំដៅដល់បណ្តាញលូដែលបានសាងសង់ឡើងដើម្បីស្ទាក់បរិមាណទឹកកខ្វក់ចូលទៅក្នុងអាងស្តុកទឹកកខ្វក់ ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ ឬអាងចម្រោះទឹកកខ្វក់ និង/ឬបង្វែរទឹកចូលអាងស្តុកទឹកធម្មជាតិ ឬតំបន់ទឹកសាធារណៈដោយផ្ទាល់។

២៥-ប្រព័ន្ធលូ សំដៅដល់ប្រព័ន្ធលូសាធារណៈ និងប្រព័ន្ធលូឯកជន ដែលមានជាអាទិ៍បណ្តាញលូរួមនិង/ឬ បណ្តាញលូញែក បណ្តាញលូមេ បណ្តាញលូមេរង បណ្តាញលូខ្នែង បណ្តាញ លូខ្នែងរង បណ្តាញលូ [illegible] អណ្តូងលូ។

២៦-ប្រព័ន្ធលូសាធារណៈ សំដៅដល់ប្រព័ន្ធលូដែលបានអភិវឌ្ឍ សាងសង់ ស្តារឡើងវិញ ដំឡើង ជួសជុល ថែទាំ និង/ឬគ្រប់គ្រងដោយសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់។

២៧-**ប្រព័ន្ធលូឯកជន** សំដៅដល់បណ្តាញលូដែលបានសាងសង់ ដំឡើង ជួសជុល ថែទាំ និងប្រតិបត្តិការដោយការវិនិយោគពីវិស័យឯកជន។

២៨-**ប្រព័ន្ធទឹកកខ្វក់** សំដៅដល់ប្រព័ន្ធលូ ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ឬស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ ទីលានគ្រប់គ្រងសំណល់កក់ ការងារប្រព័ន្ធទឹកកខ្វក់ សំណង់សិល្បការទឹកកខ្វក់ ឬឋបនីយកណ្ដទឹកកខ្វក់ និងសកម្មភាពពាក់ព័ន្ធនឹងទឹកកខ្វក់ផ្សេងទៀត។

២៩-**ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់** សំដៅដល់អាងស្តុកទឹកឬស្រះ ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ ឬអាងចម្រោះទឹកកខ្វក់ ស្ថានីយបូម ប្រឡាយចំហ បណ្តាញលូមេ បណ្តាញលូមេរង និងសំណង់សិល្បការទឹកកខ្វក់ដែលរៀបចំឡើងតាមលក្ខណៈបច្ចេកវិទ្យា ឬលក្ខណៈធម្មជាតិ។

៣០-**ប្រតិបត្តិករ** សំដៅដល់អង្គភាពដែលត្រូវបង្កើតឡើងដោយរដ្ឋឬក្រុមហ៊ុនឯកជនដែលទទួលបានសិទ្ធិគ្រប់គ្រង ថែទាំ និងប្រតិបត្តិការប្រព័ន្ធទឹកកខ្វក់ស្របតាមច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៣១-**បទប្បញ្ញត្តិបច្ចេកទេសប្រព័ន្ធទឹកកខ្វក់** សំដៅដល់បទដ្ឋានបច្ចេកទេស ឬស្តង់ដាបច្ចេកទេស ឬវិធានបច្ចេកទេសនានាសម្រាប់ អនុវត្តការងារប្រព័ន្ធទឹកកខ្វក់ ដែលត្រូវបានរៀបចំនិងដាក់ឱ្យប្រើប្រាស់កំណត់ដោយក្រសួងសាធារណការនិងដឹកជញ្ជូន។

៣២-**ភ្នាក់ងារមានសមត្ថកិច្ច** សំដៅដល់មន្ត្រីដែលត្រូវចាត់តាំងដោយសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ឱ្យចុះតាមដានត្រួតពិនិត្យមើលព្រំកំណត់ខ្សែប្រព័ន្ធលូឬបណ្តាញលូ ទីតាំងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ឬស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ ឬអាងចម្រោះទឹកកខ្វក់ អណ្តូងលូ ចំណុចតភ្ជាប់ និងសកម្មភាពពាក់ព័ន្ធផ្សេងទៀត។

៣៣-**លូ** សំដៅដល់លូបិទ និងលូចំហឬប្រឡាយចំហ ដែលមានមុខងារសម្រាប់ប្រមូលនិងបញ្ជូនឬបង្ហូរទឹកកខ្វក់និង/ឬទឹកភ្លៀង។

៣៤-**លំនៅឋាន** សំដៅដល់ផ្ទះស្នាក់នៅជាលក្ខណៈឯកជនផ្ទាល់ខ្លួន។

៣៥-**សំណង់សិល្បការទឹកកខ្វក់** សំដៅដល់ប្រឡាយបង្ហូរ របាំងទំនប់បង្ហូរ ជញ្ជាំងអាងស្តុកទឹកកខ្វក់ គ្រឿងបង្គុំ ឧបករណ៍ធ្វើប្រព្រឹត្តកម្មទឹកកខ្វក់ និងសម្ភារៈបរិក្ខារផ្សេងទៀតដែលបម្រើឱ្យដំណើរការប្រព្រឹត្តកម្មទឹកកខ្វក់។

៣៦-**ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់** សំដៅដល់បណ្តុំអាងប្រព្រឹត្តកម្មទឹកកខ្វក់រួម ដែលធ្វើប្រព្រឹត្តកម្មទឹកសំណល់មុននឹងបង្ហូរចេញ។

៣៧-**សំណល់ភក់** សំដៅដល់កាកសំណល់ពីអាងសិបទិក ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងអាងចម្រោះទឹកកខ្វក់។

៣៨-**សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់** សំដៅដល់ក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

៣៩-**អណ្តូងលូ** សំដៅដល់អណ្តូងដែលសាងសង់នៅលើបណ្តាញលូ សម្រាប់ជាច្រកចេញចូល ដើម្បីត្រួតពិនិត្យ ជួសជុលថែទាំ សម្អាត និង/ឬបូមស្តារសំណល់ភក់ដែលកកស្ទះក្នុងបណ្តាញលូ។ អណ្តូង

លូជាចំណុច ខ្សែង បំបែកចេញពីបណ្ដាញលូ អាចប្រែប្រួលតាមអង្កត់ផ្ចិត ទំហំ បរិមាត្រ កម្រិតកម្ពស់ ទិសដៅ និងមានប្រវែងជួរត្រង់តាមចន្លោះគម្លាតសមស្រប។

៤០-**អាងប្រព្រឹត្តកម្មទឹកកខ្វក់** សំដៅដល់ឋបនីយកណ្ដាលដែលធ្វើប្រព្រឹត្តកម្មឬច្រោះទឹកកខ្វក់បឋមចេញពីប្រភពលំនៅឋាន អគារឬមណ្ឌលអាជីវកម្មនិងផលិតកម្ម ឬទីតាំងណាមួយ មុននឹងបង្ហូរចូលបណ្ដាញលូ។

៤១-**អាងសិបទិក** សំដៅដល់អាងទទួលទឹកកខ្វក់ពីបង្គន់អនាម័យនិងបន្ទប់ទឹក ដើម្បីស្តុក និងបំបែកសំណល់សរីរាង្គក្នុងទឹកកខ្វក់ មុនការហូរចេញទៅក្នុងបណ្ដាញលូ។

៤២-**អាងចម្រោះទឹកកខ្វក់** សំដៅដល់អាងស្តុកទឹកកខ្វក់សាធារណៈ និងអាងចម្រោះតាមបែបធម្មជាតិ។

៤៣-**អាងស្តុកទឹកកខ្វក់** សំដៅដល់អាងស្តុកទឹកសំណល់ចម្រុះ ដូចជាសំណល់ទឹកភ្លៀង ទឹកសំណល់ចេញពីលំនៅឋាន សំណល់ទឹកកសិដ្ឋាន និងសំណល់ទឹកឧស្សាហកម្មដែលបានបង្កើតឡើងយ៉ាងពិសេស ដើម្បីបម្រើដល់ការធ្វើប្រព្រឹត្តកម្មទឹកកខ្វក់។

៤៤-**អាងចម្រោះតាមបែបធម្មជាតិ** សំដៅដល់អាងច្រោះសម្អាតទឹកកខ្វក់តាមដំណាក់ៗ និងមានលំហូរតាមបែបធម្មជាតិ ដោយស្តុកទឹកទុកក្នុងរយៈពេលមួយ ដើម្បីប្រើពន្លឺព្រះអាទិត្យ ខ្យល់ ឬខ្យល់អាកាសមេកានិក និងបាក់តេរីធម្មជាតិ ក្នុងការធ្វើសំយោគទឹកសំណល់ដើម្បីបំបាត់ចោលនូវអតិសុខុមប្រាណមានក្នុងទឹកសំណល់ មុនបញ្ចេញទៅតំបន់ទឹកសាធារណៈ។

៤៥-**អ្នកបច្ចេកទេស** សំដៅដល់អ្នកបច្ចេកទេសការងារប្រព័ន្ធទឹកកខ្វក់ ដែលមានការបណ្ដុះបណ្ដាល និងទទួលបានវិញ្ញាបនបត្រត្រឹមត្រូវ ដែលទទួលស្គាល់ពីក្រសួងសាធារណការនិងដឹកជញ្ជូន។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ព្រះរាជក្រម

នស/រកម/១១២៤/០០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃកិច្ចព្រមព្រៀងស្តីពីការទទួលយកបទប្បញ្ញត្តិបច្ចេកទេសរួមនៃអង្គការសហប្រជាជាតិសម្រាប់យានយន្ត បរិក្ខារ និងគ្រឿងបន្លាស់ ដែលអាចបំពាក់និង/ឬប្រើប្រាស់ទៅលើយានយន្ត និងលក្ខខណ្ឌសម្រាប់ការទទួលស្គាល់ទៅវិញទៅមកនៃការផ្តល់អនុលោមភាពដោយឈរលើមូលដ្ឋាននៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៤ នាសម័យប្រជុំព្រឹទ្ធសភាលើកទី២ នីតិកាលទី៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

១/២

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃកិច្ចព្រមព្រៀង ស្តីពីការទទួលយកបទប្បញ្ញត្តិបច្ចេកទេសរួមនៃអង្គការសហប្រជាជាតិ សម្រាប់យានយន្ត បរិក្ខារ និងគ្រឿងបន្លាស់ ដែលអាចបំពាក់ និង/ឬប្រើប្រាស់ នៅលើយានយន្ត និងលក្ខខណ្ឌសម្រាប់ការទទួលស្គាល់ទៅវិញទៅមកនៃ ការផ្តល់អនុលោមភាពដោយឈរលើមូលដ្ឋាននៃបទប្បញ្ញត្តិ អង្គការសហប្រជាជាតិ

មាត្រា១ .-

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃកិច្ចព្រមព្រៀងស្តីពីការទទួលយកបទប្បញ្ញត្តិបច្ចេកទេសរួមនៃអង្គការសហប្រជាជាតិសម្រាប់យានយន្ត បរិក្ខារ និងគ្រឿងបន្លាស់ ដែលអាចបំពាក់ និង/ឬប្រើប្រាស់ទៅលើយានយន្ត និងលក្ខខណ្ឌសម្រាប់ការទទួលស្គាល់ទៅវិញទៅមកនៃការផ្តល់អនុលោមភាពដោយឈរលើមូលដ្ឋាននៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ដែលបានធ្វើនៅទីក្រុងហ្សឺណែវប្រទេសស្វ៊ីស នាថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៥៨ និងបានធ្វើវិសោធនកម្មបន្តបន្ទាប់ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

មាត្រា២ .-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តពលរ់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

ថ្ងៃ សុក្រ ៧រោច ខែ កត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០២៤

នស/រកម/១១២៤/០៤៧

នរោត្តម សីហមុនី

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
អគ្គលេខាធិការរដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

ប៉េង ពោធិ៍នា

២/២

កិច្ចព្រមព្រៀង
ស្តីពី
ការទទួលយកបទប្បញ្ញត្តិបច្ចេកទេសរួមនៃអង្គការសហប្រជាជាតិសម្រាប់យានយន្ត បរិក្ខារ និងគ្រឿងបន្លាស់ ដែលអាចបំពាក់ និង/ឬប្រើប្រាស់នៅលើយានយន្ត និងលក្ខខណ្ឌសម្រាប់ការទទួលស្គាល់ទៅវិញទៅមកនៃការផ្តល់អនុលោមភាពដោយឈរលើមូលដ្ឋាននៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិ

បុព្វកថា

ភាគីនៃកិច្ចព្រមព្រៀង

*ដោយបានសម្រេច*ធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងស្តីពីការទទួលយកលក្ខខណ្ឌរួមនៃប្រព័ន្ធអនុលោមភាព និងការទទួលស្គាល់ទៅវិញទៅមកនៃប្រព័ន្ធអនុលោមភាពសម្រាប់យានយន្ត បរិក្ខារ និងគ្រឿងបន្លាស់ ធ្វើឡើងនៅទីក្រុងហ្សឺណែវ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៥៨ និងបានធ្វើវិសោធនកម្មនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៥។

*ដោយមានបំណង*កាត់បន្ថយរបាំងបច្ចេកទេសចំពោះការធ្វើពាណិជ្ជកម្មអន្តរជាតិ ដោយកំណត់នូវបទប្បញ្ញត្តិបច្ចេកទេសរួមនៃអង្គការសហប្រជាជាតិ ដែលនឹងសមស្របសម្រាប់យានយន្ត បរិក្ខារ និងគ្រឿងបន្លាស់ ដើម្បីបំពេញឱ្យបានតាមបទប្បញ្ញត្តិទាំងនោះ ក្នុងគោលបំណងយកទៅប្រើប្រាស់នៅក្នុងប្រទេសជាភាគីឬនៅក្នុងតំបន់។

*ដោយទទួលស្គាល់*អំពីសារៈសំខាន់នៃសុវត្ថិភាព ការការពារបរិស្ថាន ប្រសិទ្ធភាពថាមពល និងមុខងារប្រឆាំងចោរកម្មនៃយានយន្ត បរិក្ខារ និងគ្រឿងបន្លាស់ ដែលអាចបំពាក់និង/ឬប្រើប្រាស់ទៅលើយានយន្តសម្រាប់ការរៀបចំបទប្បញ្ញត្តិ ដែលអាចអនុវត្តបានក្នុងន័យបច្ចេកទេសនិងសេដ្ឋកិច្ច និងសម្របតាមការវិវឌ្ឍនៃបច្ចេកទេស។

*ដោយមានបំណង*អនុវត្តបទប្បញ្ញត្តិទាំងឡាយនៃអង្គការសហប្រជាជាតិ នៅក្នុងប្រទេសភាគីឬនៅក្នុងតំបន់ នៅពេលដែលសមស្រប។

*ដោយមានបំណង*ដើម្បីសម្របសម្រួលការទទួលយកនៅក្នុងប្រទេសរបស់ខ្លួននូវយានយន្ត បរិក្ខារ និងគ្រឿងបន្លាស់ ដែលត្រូវបានអនុម័តស្របតាមបទប្បញ្ញត្តិនានារបស់អង្គការសហប្រជាជាតិ ដែលចេញដោយអាជ្ញាធរផ្តល់អនុលោមភាពនៃភាគីកិច្ចព្រមព្រៀងមួយផ្សេងទៀត។

*ដោយមានបំណង*បង្កើត**កម្មវិធីប្រព័ន្ធអនុលោមភាពជាអន្តរជាតិចំពោះប្រភេទលើយានយន្តទាំងមូល** នៅក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះ ដើម្បីបង្កើនឧត្តមភាពនៃបទប្បញ្ញត្តិដោយឡែករបស់អង្គការសហប្រជាជាតិ ដែលមាននៅក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ និងបង្កើតនូវកាលានុវត្តភាពដើម្បីធ្វើសាមញ្ញកម្មដល់ការអនុវត្តដោយភាគីនៃកិច្ចព្រមព្រៀង និងពង្រីកការអនុម័តឱ្យកាន់តែទូលំទូលាយចំពោះការទទួលស្គាល់ទៅវិញទៅមកបដិកានៃប្រព័ន្ធអនុលោមភាពចំពោះប្រភេទលើយានយន្តទាំងមូល។

*ដោយមានបំណង*បង្កើនចំនួនភាគីនៃកិច្ចព្រមព្រៀងនេះ ដោយធ្វើឱ្យប្រសើរលើការប្រព្រឹត្តទៅនិងភាពជឿទុកចិត្តបានរបស់កិច្ចព្រមព្រៀងនេះ និងធានាថា កិច្ចព្រមព្រៀងនេះនឹងនៅតែជាក្របខ័ណ្ឌអន្តរជាតិគន្លឹះសម្រាប់ការធ្វើសុខដុមនីយកម្មនៃបទដ្ឋានបច្ចេកទេសក្នុងវិស័យយានយន្ត។

១/៤៤

បានព្រមព្រៀង ដូចខាងក្រោម៖

មាត្រា១ ..

១- ភាគីនៃកិច្ចព្រមព្រៀងនេះត្រូវបង្កើតបទប្បញ្ញត្តិអង្គការសហប្រជាជាតិសម្រាប់យានយន្ត បរិក្ខារ និងគ្រឿងបន្លាស់ ដែលអាចបំពាក់និង/ឬប្រើប្រាស់ទៅលើយានយន្ត តាមរយៈគណៈកម្មាធិការរដ្ឋបាលដែលកើតចេញពីភាគីទាំងអស់នៃកិច្ចព្រមព្រៀងនេះ ស្របតាមគោលការណ៍នៃនីតិវិធីដែលបានចែងក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ និងឈរលើគោលការណ៍នៃមាត្រានិងកថាខណ្ឌខាងក្រោម។ លក្ខខណ្ឌសម្រាប់ការផ្ដល់ប្រព័ន្ធអនុលោមភាពចំពោះប្រភេទនិងការទទួលស្គាល់គ្នាទៅវិញទៅមកនឹងត្រូវបានបញ្ចូលសម្រាប់ប្រើប្រាស់ដោយភាគីកិច្ចព្រមព្រៀងដែលជ្រើសរើសអនុវត្តបទប្បញ្ញត្តិតាមរយៈប្រព័ន្ធអនុលោមភាពចំពោះប្រភេទ។

ចំពោះគោលបំណងនៃកិច្ចព្រមព្រៀងនេះ៖

ពាក្យ **"យានយន្ត បរិក្ខារ និងគ្រឿងបន្លាស់"** សំដៅលើយានយន្ត បរិក្ខារ និងគ្រឿងបន្លាស់ ដែលលក្ខណៈរបស់វាពាក់ព័ន្ធទៅនឹងសុវត្ថិភាពយានយន្ត ការការពារបរិស្ថាន ការសន្សំសំចៃថាមពល និងមុខងារនៃបច្ចេកវិទ្យាប្រឆាំងចោរកម្ម។

ពាក្យ **"ប្រព័ន្ធអនុលោមភាពចំពោះប្រភេទស្របតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិ"** សំដៅលើនីតិវិធីរដ្ឋបាលមួយដែលអាជ្ញាធរផ្ដល់អនុលោមភាពនៃភាគីកិច្ចព្រមព្រៀងមួយប្រកាសថា ប្រភេទនៃយានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់ ដែលរោងចក្រផលិតដាក់ជូនពិនិត្យ បានអនុលោមតាមលក្ខខណ្ឌតម្រូវដែលបានកំណត់ក្នុងបទប្បញ្ញត្តិអង្គការសហប្រជាជាតិដាក់លាក់ណាមួយ បន្ទាប់ពីបានផ្ទៀងផ្ទាត់ចាំបាច់នានា។ បន្ទាប់ពីនេះ រោងចក្រផលិតត្រូវបញ្ជាក់ថា យានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់នីមួយៗដែលបានដាក់លើទីផ្សារត្រូវបានផលិតដោយមានលក្ខណៈដូចគ្នាទៅនឹងផលិតផលដែលទទួលបានអនុលោមភាព។

ពាក្យ **"ប្រព័ន្ធអនុលោមភាពចំពោះប្រភេទលើយានយន្តទាំងមូល"** សំដៅលើប្រព័ន្ធអនុលោមភាពចំពោះប្រភេទដែលបានផ្ដល់ស្របតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ដែលសមស្របសម្រាប់យានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់ ដែលត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធអនុលោមភាពចំពោះប្រភេទនៃយានយន្តទាំងមូល ស្របតាមបញ្ញត្តិរដ្ឋបាលនៃកម្មវិធីប្រព័ន្ធអនុលោមភាពជាអន្តរជាតិចំពោះប្រភេទលើយានយន្តទាំងមូល

ពាក្យ **"កំណែនៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិមួយ"** សំដៅលើបទប្បញ្ញត្តិអង្គការសហប្រជាជាតិមួយបន្ទាប់ពីតាក់តែងរួចនិងអនុម័តឱ្យប្រើប្រាស់ អាចត្រូវធ្វើវិសោធនកម្ម ដោយស្របតាមនីតិវិធីដូចមានរៀបរាប់នៅក្នុងកិច្ចព្រមព្រៀងនេះ ជាពិសេសនៅក្នុងមាត្រា១២។ បទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលពុំបានធ្វើវិសោធនកម្ម និងបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលបានធ្វើវិសោធនកម្មរួច ត្រូវចាត់ទុកជាកំណែដាច់ដោយឡែកពីបទប្បញ្ញត្តិអង្គការសហប្រជាជាតិនោះ។

ពាក្យ **"ការអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ"** សំដៅលើបទប្បញ្ញត្តិមួយនៃអង្គការសហប្រជាជាតិដែលបានចូលជាធរមានសម្រាប់ឱ្យភាគីកិច្ចព្រមព្រៀងមួយអនុវត្ត។ ប៉ុន្តែនៅពេលអនុវត្តនោះភាគីនៃកិច្ចព្រមព្រៀងនៅតែមានលទ្ធភាពបន្តអនុវត្តបទប្បញ្ញត្តិជាតិឬក្នុងតំបន់របស់ខ្លួនបានដដែល។ ភាគីទាំងនោះក៏អាចប្រើប្រាស់លក្ខខណ្ឌ តម្រូវនៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលខ្លួនកំពុងអនុវត្តជំនួសឱ្យបទប្បញ្ញត្តិជាតិឬតំបន់របស់ខ្លួនបាន ប្រសិនបើភាគីនោះមានបំណងអនុវត្តកិច្ចព្រមព្រៀងនេះមិនចង់ជាកាតព្វកិច្ចឱ្យភាគីទាំងនោះត្រូវតែ អនុវត្តបែបនេះទេ។ ទោះជាយ៉ាងនេះក្ដី ភាគីកិច្ចព្រមព្រៀងត្រូវទទួលយកប្រព័ន្ធអនុលោមភាពចំពោះប្រភេទរបស់អង្គការ

H8
VL

សហប្រជាជាតិ ដែលបានផ្តល់ជូនស្របតាមកំណែចុងក្រោយបង្អស់នៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ទុកជាជម្រើសមួយលើផ្នែកដែលពាក់ព័ន្ធនឹងបទប្បញ្ញត្តិជាតិឬតំបន់ សម្រាប់អនុវត្តក្នុងប្រទេសឬតំបន់របស់ខ្លួន។ សិទ្ធិនិងកាតព្វកិច្ចនៃភាគីកិច្ចព្រមព្រៀងដែលអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ មានចែងលម្អិតនៅក្នុងមាត្រានានានៃកិច្ចព្រមព្រៀងនេះ។

ការអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិអាចមាននីតិវិធីរដ្ឋបាលផ្សេងៗទៀត ដែលអាចជំនួសលើប្រព័ន្ធអនុលោមភាពចំពោះប្រភេទ។ នីតិវិធីជំនួសតែមួយដែលត្រូវបានទទួលស្គាល់និងអនុវត្តជាទូទៅនៅក្នុងបណ្តារដ្ឋមួយចំនួនជាភាគីរបស់គណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប គឺការធ្វើស្វ័យបញ្ជាក់អនុលោមភាពដោយរោងចក្រផលិតចេញបញ្ជាក់ថា ផលិតផលយានយន្តនីមួយៗដែលបានដាក់លើទីផ្សារស្របតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលកំណត់ បើទោះបីជាពុំបានឆ្លងកាត់ការត្រួតពិនិត្យរដ្ឋបាលបឋមក៏ដោយ។ អាជ្ញាធររដ្ឋបាលមានសមត្ថកិច្ចអាចធ្វើការផ្ទៀងផ្ទាត់បញ្ជាក់ថាផលិតផលដែលទទួលបានស្វ័យបញ្ជាក់ អនុលោមតាមលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិ តាមរយៈវិធីសាស្ត្រជ្រើសរើសគំរូចៃដន្យនៅលើទីផ្សារ។

២- គណៈកម្មាធិការរដ្ឋបាលត្រូវបានបង្កើតឡើងដោយមានសមាសភាពពីគ្រប់ភាគីកិច្ចព្រមព្រៀង ស្របទៅនឹងវិធាននៃនីតិវិធីដែលបានចែងនៅក្នុងឧបសម្ព័ន្ធ។

បទប្បញ្ញត្តិអង្គការសហប្រជាជាតិមួយ បន្ទាប់ពីត្រូវបានបង្កើតស្របតាមនីតិវិធីដែលបានចែងក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ ត្រូវបញ្ជូនដោយគណៈកម្មាធិការរដ្ឋបាលទៅកាន់អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ដែលតទៅនេះហៅថា "អគ្គលេខាធិការ"។ បន្ទាប់ពីនេះ អគ្គលេខាធិការត្រូវជូនដំណឹងអំពីបទប្បញ្ញត្តិអង្គការសហប្រជាជាតិនោះ ទៅកាន់ភាគីនៃកិច្ចព្រមព្រៀង។

បទប្បញ្ញត្តិអង្គការសហប្រជាតិនឹងត្រូវចាត់ទុកថាបានអនុម័ត លើកលែងតែក្នុងកំឡុងពេល៦ខែ គិតចាប់ពីការជូនដំណឹងដោយអគ្គលេខាធិការ មានភាគីកិច្ចព្រមព្រៀងច្រើនជាង១/៥ បានជូនដំណឹងដល់អគ្គលេខាធិការអំពីការជំទាស់របស់ខ្លួនលើបទប្បញ្ញត្តិរបស់អង្គការសហប្រជាជាតិនោះ។

បទប្បញ្ញត្តិអង្គការសហប្រជាជាតិត្រូវមានវិសាលភាពលើ៖

ក- យានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់ពាក់ព័ន្ធ។

ខ- លក្ខខណ្ឌតម្រូវបច្ចេកទេសដែលត្រូវផ្តោតលើសមត្ថភាពមុខងារនិងមិនមានការរឹតត្បិតលើការរចនា ដែលផ្តល់នូវការពិចារណាលើភាពជាក់ស្តែងចំពោះបច្ចេកវិទ្យាដែលមាន ថ្លៃដើម និងអត្ថប្រយោជន៍ រួមទាំងជម្រើសផ្សេងៗទៀត។

គ- វិធីសាស្ត្រធ្វើតេស្តនានា ដែលក្នុងនោះលក្ខខណ្ឌតម្រូវលើសមត្ថភាពមុខងារត្រូវបានបង្ហាញ។

ឃ- លក្ខខណ្ឌសម្រាប់ការផ្តល់ប្រព័ន្ធអនុលោមភាពចំពោះប្រភេទនិងការទទួលស្គាល់ទៅវិញទៅមកនៃលក្ខខណ្ឌទាំងនោះ រួមមានបញ្ញត្តិរដ្ឋបាល សញ្ញាសម្គាល់អនុលោមភាពផ្សេងៗ និងលក្ខខណ្ឌធានាចំពោះអនុលោមភាពនៃផលិតកម្ម។

ង- កាលបរិច្ឆេទដែលបទប្បញ្ញត្តិអង្គការសហប្រជាជាតិចូលជាធរមាន រួមទាំងកាលបរិច្ឆេទនៅពេលដែលភាគីកិច្ចព្រមព្រៀងអនុវត្ត អាចផ្តល់អនុលោមភាពស្របទៅនឹងបទប្បញ្ញត្តិអង្គការសហប្រជាជាតិនោះ និងកាលបរិច្ឆេទគិតចាប់ពីពេលដែលភាគីកិច្ចព្រមព្រៀងត្រូវឯកភាពទទួលយកចំពោះអនុលោមភាព (ប្រសិនបើខុសគ្នា)។

ច- ឯកសារព័ត៌មានដែលត្រូវផ្តល់ដោយរោងចក្រផលិត។

ប្រសិនបើចាំបាច់ បទប្បញ្ញត្តិអង្គការសហប្រជាជាតិអាចដាក់បញ្ចូលនូវព័ត៌មានអំពីមន្ទីរពិសោធន៍នានាដែលចុះបញ្ជីទទួលស្គាល់ដោយអាជ្ញាធរផ្តល់ប្រព័ន្ធអនុលោមភាពដែលបានធ្វើតេស្តទទួលស្គាល់លើប្រភេទនៃយានយន្ត បរិក្ខារ និងគ្រឿងបន្លាស់ដែលដាក់ស្នើសុំការបញ្ជាក់អនុលោមភាពនោះ។

បន្ថែមលើបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលបានលើកឡើងខាងលើ កិច្ចព្រមព្រៀងនេះក៏អនុញ្ញាតឱ្យមានការបង្កើតឡើងនូវបទប្បញ្ញត្តិអង្គការសហប្រជាជាតិបន្ថែមមួយទៀត ដើម្បីដាក់ចេញនូវ**ប្រព័ន្ធអនុលោមភាពចំពោះប្រភេទលើយានយន្តទាំងមូល**។ បទប្បញ្ញត្តិអង្គការសហប្រជាជាតិនេះត្រូវកំណត់វិសាលភាព នីតិវិធីរដ្ឋបាល និងលក្ខខណ្ឌតម្រូវបច្ចេកទេសដែលអាចរួមបញ្ចូលនូវកម្រិតផ្សេងៗគ្នានៃភាពតឹងរ៉ឹង នៅក្នុងកំណែមួយនៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលបានលើកឡើង។

ទោះបីជាមានបញ្ញត្តិផ្សេងៗទៀតនៃមាត្រា១និងមាត្រា១២ក៏ដោយ ក៏ភាគីកិច្ចព្រមព្រៀងដែលអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិស្តីពីកម្មវិធីប្រព័ន្ធអនុលោមភាពជាអន្តរជាតិចំពោះប្រភេទលើយានយន្តទាំងមូលត្រូវមានកាតព្វកិច្ចទទួលយកតែអនុលោមភាពចំពោះប្រភេទទាំងឡាយណាដែលបានចេញដោយភាគីកិច្ចព្រមព្រៀងដទៃទៀត ដោយយោងទៅតាមភាពតឹងរ៉ឹងខ្ពស់បំផុតនៃកំណែចុងក្រោយរបស់បទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលបានលើកឡើងខាងលើតែប៉ុណ្ណោះ។

កិច្ចព្រមព្រៀងនេះរួមបញ្ចូលនូវបទប្បញ្ញត្តិបន្ថែមនៃបញ្ញត្តិផ្នែករដ្ឋបាលនិងនីតិវិធី ដែលអនុវត្តចំពោះគ្រប់បទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលមាននៅក្នុងកិច្ចព្រមព្រៀងនេះ និងចំពោះគ្រប់ភាគីនៃកិច្ចព្រមព្រៀងដែលអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិមួយឬច្រើន។

៣- នៅពេលដែលបទប្បញ្ញត្តិអង្គការសហប្រជាជាតិត្រូវបានអនុម័ត អគ្គលេខាធិការត្រូវជូនដំណឹងជាការប្រញាប់ដល់ភាគីកិច្ចព្រមព្រៀងទាំងអស់ ដោយបញ្ជាក់អំពីភាគីណាមួយជំទាស់ឬយល់ព្រមទទួលយក ប៉ុន្តែមិនទាន់មានបំណងចាប់ផ្តើមអនុវត្តបទប្បញ្ញត្តិនោះនៅកាលបរិច្ឆេទចូលជាធរមាននោះទេ ហើយក្នុងករណីនេះ បទប្បញ្ញត្តិនោះនឹងមិនត្រូវបានចូលជាធរមានចំពោះភាគីទាំងនោះ។

៤- បទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលបានអនុម័តរួចនឹងត្រូវចូលជាធរមានតាមកាលបរិច្ឆេទដែលបានកំណត់ ជាបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលមាននៅក្នុងកិច្ចព្រមព្រៀងនេះ ចំពោះរាល់ភាគីណាដែលមិនបានជូនដំណឹងអំពីការជំទាស់ឬបំណងក្នុងការមិនអនុវត្តតាមកាលបរិច្ឆេទ។

៥- នៅពេលដាក់តម្កល់លិខិតុបករណ៍សុំចូលជាភាគី ភាគីកិច្ចព្រមព្រៀងថ្មីណាមួយអាចប្រកាសថា ខ្លួននឹងមិនអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិជាក់លាក់ណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ឬថា ខ្លួននឹងមិនអនុវត្តរាល់បទប្បញ្ញត្តិណាទាំងអស់។ ប្រសិនបើកំឡុងពេលនោះ នីតិវិធីដែលបានចែងក្នុងកថាខណ្ឌទី២ ទី៣ និងទី៤នៃមាត្រានេះកំពុងស្ថិតនៅក្នុងដំណាក់កាលជាសេចក្តីព្រាងឬជាបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលបានអនុម័តរួច អគ្គលេខាធិការត្រូវជូនដំណឹងអំពីសេចក្តីព្រាងនោះ ទៅកាន់ភាគីកិច្ចព្រមព្រៀងថ្មី ហើយបទប្បញ្ញត្តិនោះនឹងក្លាយជាបទប្បញ្ញត្តិអង្គការសហប្រជាជាតិជាធរមានសម្រាប់ភាគីកិច្ចព្រមព្រៀងថ្មីនោះ ប្រសិនបើភាគីកិច្ចព្រមព្រៀងថ្មីនេះមិនបានជូនដំណឹងអំពីការជំទាស់របស់ខ្លួនលើបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលត្រូវបានអនុម័ត ក្នុង ,កំឡុងពេល៦ខែ បន្ទាប់ពីការដាក់លិខិតុបករណ៍សុំចូលជាភាគីរបស់ខ្លួន។ អគ្គលេខាធិការត្រូវជូនដំណឹងដល់ភាគីកិច្ចព្រមព្រៀងទាំងអស់អំពីកាលបរិច្ឆេទនៃការចូលជាធរមាននេះ។ អគ្គលេខាធិការត្រូវជូនដំណឹងដល់ភាគីកិច្ចព្រមព្រៀងទាំងអស់នូវរាល់សេចក្តីប្រកាសទាក់ទងនឹងការមិនអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិរបស់ភាគីកិច្ចព្រមព្រៀងណាមួយ ដោយស្របតាមលក្ខខណ្ឌនៃកថាខណ្ឌនេះ។

៦- នៅគ្រប់ពេលទាំងអស់ រាល់ភាគីកិច្ចព្រមព្រៀងដែលកំពុងអនុវត្តបទប្បញ្ញត្តិណាមួយរបស់អង្គការសហប្រជាជាតិ អាចជូនដំណឹងទៅអគ្គលេខាធិការឱ្យបានមុនមួយឆ្នាំ អំពីបំណងបញ្ឈប់ការអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិនោះ។ អគ្គលេខាធិការត្រូវជូនដំណឹងនេះទៅបណ្តាភាគីកិច្ចព្រមព្រៀងដទៃទៀត។

អនុលោមភាពដែលបានផ្តល់ពីមុនស្របតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិដោយភាគីកិច្ចព្រមព្រៀងនោះ ត្រូវតែនៅមានសុពលភាព លើកលែងតែការផ្តល់អនុលោមភាពទាំងនោះត្រូវបានដកចេញ ស្របតាមបញ្ញត្តិនៃមាត្រា៤។

ប្រសិនបើភាគីកិច្ចព្រមព្រៀងមួយបញ្ឈប់ការផ្តល់អនុលោមភាពលើបទប្បញ្ញត្តិអង្គការសហប្រជាជាតិណាមួយ ភាគីនោះ ត្រូវ៖

ក- រក្សាការត្រួតពិនិត្យឱ្យបានត្រឹមត្រូវទៅលើអនុលោមភាពផលិតកម្មនៃផលិតផលដែលខ្លួនបានផ្តល់អនុលោមភាពចំពោះប្រភេទកន្លងមក។

ខ- ចាត់វិធានការចាំបាច់នានាដែលមានចែងក្នុងមាត្រា៤ នៅពេលដែលទទួលបានការជូនដំណឹងអំពីផលិតផលដែលមិនមានអនុលោមភាពរបស់ភាគីកិច្ចព្រមព្រៀងមួយដែលបន្តអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ។

គ- បន្តការជូនដំណឹងទៅបណ្តាភាគីកិច្ចព្រមព្រៀងដទៃទៀតអំពីការដកចេញនៃការផ្តល់អនុលោមភាព ដូចមានចែងក្នុងមាត្រា៥។

ឃ- បន្តផ្តល់ការពន្យារលើសុពលភាពចំពោះអនុលោមភាពដែលមានស្រាប់។

៧- នៅគ្រប់ពេលភាគីកិច្ចព្រមព្រៀងដែលមិនបានអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិណាមួយ អាចជូនដំណឹងទៅអគ្គលេខាធិការថា ខ្លួនមានបំណងចាប់អនុវត្តបទប្បញ្ញត្តិនោះពីពេលនេះតទៅ ហើយបទប្បញ្ញត្តិអង្គការសហប្រជាជាតិនោះនឹងចូលជាធរមានសម្រាប់ភាគីនេះ ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ បន្ទាប់ពីការជូនដំណឹង។ អគ្គលេខាធិការត្រូវជូនដំណឹងដល់ភាគីកិច្ចព្រមព្រៀងទាំងអស់នូវរាល់ការចូលជាធរមាននូវបទប្បញ្ញត្តិអង្គការសហប្រជាជាតិណាមួយចំពោះភាគីកិច្ចព្រមព្រៀងថ្មីមួយ ដែលស្របតាមលក្ខខណ្ឌនៃកថាខណ្ឌនេះ។

៨- ភាគីកិច្ចព្រមព្រៀងដែលទទួលយកបទប្បញ្ញត្តិអង្គការសហប្រជាជាតិមួយចូលជាធរមានសម្រាប់ខ្លួន តទៅហៅថា "ភាគីកិច្ចព្រមព្រៀងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ"។

មាត្រា២ ..

១- ភាគីកិច្ចព្រមព្រៀងនីមួយៗដែលអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ភាគច្រើនតាមរយៈប្រព័ន្ធអនុលោមភាពចំពោះប្រភេទ ត្រូវផ្តល់អនុលោមភាពចំពោះប្រភេទនិងសញ្ញាសម្គាល់អនុលោមភាពដែលមានចែងក្នុងបទប្បញ្ញត្តិអង្គការសហប្រជាជាតិនានា លើប្រភេទនៃយានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់ ដែលស្ថិតក្រោមបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ដរាបណាខ្លួនមានសមត្ថភាពបច្ចេកទេសនិងយល់ថា ដំណើរការរៀបចំដើម្បីធានាឱ្យបាននូវអនុលោមភាពនៃផលិតផលស្របតាមប្រភេទដែលទទួលបានអនុលោមភាពនោះ បានបំពេញតាមលក្ខខណ្ឌត្រឹមត្រូវ។

ភាគីកិច្ចព្រមព្រៀងនីមួយៗដែលផ្តល់ប្រព័ន្ធអនុលោមភាពចំពោះប្រភេទ ត្រូវចាត់វិធានការចាំបាច់ដូចមានចែងក្នុងបទប្បញ្ញត្តិបន្ថែមទី១ ដែលមាននៅក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ ដើម្បីផ្ទៀងផ្ទាត់ថាមានដំណើរការរៀបចំគ្រប់គ្រាន់ និងធានាថា យានយន្ត បរិក្ខារ និងគ្រឿងបន្លាស់ ត្រូវបានផលិតដោយគោរពតាមប្រភេទដែលទទួលបានអនុលោមភាព។

៥/៤៤

២- ភាគីកិច្ចព្រមព្រៀងនីមួយៗដែលផ្តល់ប្រព័ន្ធអនុលោមភាពចំពោះប្រភេទស្របតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ត្រូវកំណត់អំពីអាជ្ញាធរផ្តល់អនុលោមភាពចំពោះបទប្បញ្ញត្តិអង្គការសហប្រជាជាតិនោះ។ អាជ្ញាធរផ្តល់អនុលោមភាពនោះ ត្រូវទទួលខុសត្រូវទៅលើគ្រប់ទិដ្ឋភាពនៃការផ្តល់ប្រព័ន្ធអនុលោមភាពចំពោះប្រភេទដែលស្របទៅនឹងបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលបានលើកឡើងនោះ។ អាជ្ញាធរផ្តល់អនុលោមភាពអាចចាត់តាំងអង្គភាពបច្ចេកទេស ដើម្បីអនុវត្តកិច្ចការតំណាងឱ្យខ្លួនទៅលើការធ្វើតេស្តនិងការត្រួតពិនិត្យចាំបាច់នានាដើម្បីផ្ទៀងផ្ទាត់បញ្ជាក់ ដែលបានកំណត់ក្នុងកថាខណ្ឌទី១នៃមាត្រានេះ។ ភាគីទាំងអស់ត្រូវធានាថា អង្គភាពបច្ចេកទេសត្រូវបានវាយតម្លៃ ចាត់តាំង និងជូនដំណឹងស្របទៅតាមលក្ខខណ្ឌតម្រូវដែលបានចែងក្នុងបទប្បញ្ញត្តិបន្ថែមទី២នៃកិច្ចព្រមព្រៀងនេះ។

៣- ប្រព័ន្ធអនុលោមភាពចំពោះប្រភេទ សញ្ញាសម្គាល់អនុលោមភាព សញ្ញាសម្គាល់អត្តសញ្ញាណសម្រាប់ប្រភេទយានយន្ត បរិក្ខារ និងគ្រឿងបន្លាស់ ត្រូវកំណត់ក្នុងបទប្បញ្ញត្តិអង្គការសហប្រជាជាតិ និងត្រូវផ្តល់ឱ្យស្របតាមនីតិវិធីដូចមានចែងក្នុងបទប្បញ្ញត្តិបន្ថែមទី៣ដល់ទី៥នៃកិច្ចព្រមព្រៀងនេះ។

៤- ភាគីនៃកិច្ចព្រមព្រៀងនីមួយៗដែលអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ត្រូវបដិសេធការផ្តល់អនុលោមភាពចំពោះប្រភេទនិងសញ្ញាសម្គាល់អនុលោមភាព ដែលស្ថិតក្រោមបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ប្រសិនបើលក្ខខណ្ឌខាងលើមិនត្រូវបានគោរពតាម។

មាត្រា៣ ._

១- យានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់ដែលត្រូវបានផ្តល់ប្រព័ន្ធអនុលោមភាពចំពោះប្រភេទ ដោយភាគីនៃកិច្ចព្រមព្រៀងស្របតាមមាត្រា២នៃកិច្ចព្រមព្រៀងនេះត្រូវចាត់ទុកថា មានអនុលោមភាពជាមួយនឹងផ្នែកពាក់ព័ន្ធនៃបទដ្ឋានគតិយុត្តជាតិនៃភាគីកិច្ចព្រមព្រៀងទាំងអស់ដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិនោះ។

២- តាមរយៈការទទួលស្គាល់គ្នាទៅវិញទៅមក ភាគីកិច្ចព្រមព្រៀងដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ត្រូវទទួលស្គាល់ប្រព័ន្ធអនុលោមភាពចំពោះប្រភេទដែលផ្តល់ស្របទៅតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិសម្រាប់ដាក់ចរាចរណ៍នៅក្នុងទីផ្សាររបស់ខ្លួន ដែលស្របតាមបញ្ញត្តិនៃមាត្រា១ មាត្រា៨ និងមាត្រា១២ ព្រមទាំងបញ្ញត្តិពិសេសទាំងឡាយនៅក្នុងបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ដោយមិនតម្រូវឱ្យមានការធ្វើតេស្តម្តងទៀត ការរៀបចំចងក្រងឯកសារ លិខិតបញ្ជាក់ ឬសញ្ញាសម្គាល់ទាក់ទងនឹងប្រព័ន្ធអនុលោមភាពចំពោះប្រភេទឡើយ។

មាត្រា៤ ._

១- ប្រសិនបើភាគីកិច្ចព្រមព្រៀងដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិរកឃើញថា យានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់ជាក់លាក់ណាមួយដែលមានសញ្ញាសម្គាល់អនុលោមភាពដែលបានផ្តល់ដោយភាគីកិច្ចព្រមព្រៀងដទៃទៀតស្របតាមបទបុបញ្ញត្តិអង្គការសហប្រជាជាតិដែលបានលើកឡើង មិនបានគោរពតាមប្រភេទដែលបានឯកភាពឬលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិខាងលើទេនោះ ភាគីកិច្ចព្រមព្រៀងខាងដើមត្រូវជូនដំណឹងទៅកាន់អាជ្ញាធរផ្តល់អនុលោមភាពនៃភាគីម្ខាងទៀតដែលបានផ្តល់អនុលោមភាពនោះ។

ភាគីដែលបានផ្តល់អនុលោមភាពនោះត្រូវចាត់វិធានការចាំបាច់នានាដើម្បីធានាថា ភាពមិនអនុលោមនោះត្រូវបានកែតម្រូវ។

២- នៅពេលដែលភាពមិនអនុលោមកើតឡើង ដោយសារតែការមិនគោរពតាមលក្ខខណ្ឌតម្រូវបច្ចេកទេសដែលមានចែងក្នុងបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ដូចមានបញ្ជាក់ក្នុងមាត្រា១ កថាខណ្ឌទី២ ចំណុចខ ភាគីកិច្ចព្រមព្រៀងដែលបានចេញអនុលោមភាពត្រូវជូនដំណឹងជាបន្ទាន់ទៅគ្រប់ភាគីកិច្ចព្រមព្រៀងដទៃទៀតអំពីស្ថានភាព

នោះ និងត្រូវផ្តល់ការណែនាំឱ្យបានទៀងទាត់ទៅកាន់បណ្តាភាគីកិច្ចព្រមព្រៀង នូវជំហានដែលខ្លួនបាននិងកំពុងអនុវត្ត ដែលរួមមានទាំងការដកហូតនូវអនុលោមភាពផងដែរ ប្រសិនបើចាំបាច់។

បន្ទាប់ពីបានពិចារណាទៅលើផលប៉ះពាល់ដែលអាចកើតមានឡើងទៅលើសុវត្ថិភាពយានយន្ត ការការពារបរិស្ថាន ការសន្សំសំចៃថាមពល ឬសមត្ថភាពមុខងារនៃបច្ចេកវិទ្យាប្រឆាំងចោរកម្ម ភាគីកិច្ចព្រមព្រៀងទាំងឡាយអាចធ្វើការហាមឃាត់ចំពោះការលក់និងការប្រើប្រាស់នូវយានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់ទាំងនោះ នៅក្នុងដែនដីរបស់ខ្លួនរហូតដល់មានការកែតម្រូវចំពោះភាពមិនអនុលោមនោះ។ ក្នុងករណីបែបនេះ ភាគីនៃកិច្ចព្រមព្រៀងទាំងនោះត្រូវជូនដំណឹងទៅលេខាធិការដ្ឋាននៃគណៈកម្មាធិការរដ្ឋបាល អំពីវិធានការទាំងឡាយដែលខ្លួនបានធ្វើ។ នីតិវិធីចែងក្នុងមាត្រា១០ កថាខណ្ឌទី៤ ត្រូវយកមកអនុវត្តចំពោះដំណោះស្រាយវិវាទរវាងភាគីនៃកិច្ចព្រមព្រៀង។

៣- ទោះបីជាមានបញ្ញត្តិក្នុងកថាខណ្ឌទី១នៃមាត្រានេះក៏ដោយ ប្រសិនបើផលិតផលមួយដែលមិនមានអនុលោមភាពដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ មិនត្រូវបានកែតម្រូវក្នុងរយៈពេល៣ខែនោះទេ ភាគីកិច្ចព្រមព្រៀងដែលទទួលខុសត្រូវលើការផ្តល់អនុលោមភាពត្រូវដកការផ្តល់អនុលោមភាពនេះជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍។ ក្នុងករណីលើកលែង រយៈពេលកែតម្រូវនេះអាចត្រូវបានពន្យារដោយមិនឱ្យលើសពី៣ខែបន្ថែម ប្រសិនបើភាគីនៃកិច្ចព្រមព្រៀងមួយឬច្រើនដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ មិនមានការជំទាស់ទេ។ នៅកំឡុងពេលសម្រាប់ការកែតម្រូវត្រូវបានពន្យារ ភាគីកិច្ចព្រមព្រៀងដែលបានផ្តល់អនុលោមភាពនោះត្រូវជូនដំណឹងក្នុងកំឡុងពេលបីខែដំបូង ទៅដល់ភាគីកិច្ចព្រមព្រៀងទាំងអស់ដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលពាក់ព័ន្ធនូវបំណងដើម្បីពន្យារពេលដែលត្រូវកែតម្រូវភាពមិនអនុលោមនោះ ក៏ដូចជាផ្តល់ជូននូវហេតុផលសម្រាប់ការពន្យារនោះផងដែរ។

៤- នៅពេលដែលភាពមិនអនុលោមកើតឡើងដោយសារតែការមិនគោរពតាមបញ្ញត្តិរដ្ឋបាល សញ្ញាសម្គាល់អនុលោមភាព លក្ខខណ្ឌនៃអនុលោមភាពផលិតកម្មឬឯកសារព័ត៌មាន ដែលមានចែងក្នុងបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ដូចបានលើកឡើងក្នុងមាត្រា១ កថាខណ្ឌទី២ ចំណុច"ឃ" និងមាត្រា១ កថាខណ្ឌទី២ ចំណុច"ច" ភាគីកិច្ចព្រមព្រៀងដែលចេញអនុលោមភាព ត្រូវដកហូតនូវអនុលោមភាពនោះជាបណ្តោះអាសន្នឬជាអចិន្ត្រៃយ៍ ប្រសិនបើភាពមិនអនុលោមនោះមិនទាន់បានកែតម្រូវក្នុងរយៈពេល៦ខែ។

៥- កថាខណ្ឌ១ដល់៤នៃមាត្រានេះ ក៏អនុវត្តនៅក្នុងស្ថានភាពដែលភាគីកិច្ចព្រមព្រៀងទទួលបន្ទុកលើការផ្តល់អនុលោមភាពរកឃើញដោយខ្លួនឯងថា យានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់ដែលមានសញ្ញាសម្គាល់អនុលោមភាពមិនគោរពតាមប្រភេទដែលទទួលបានអនុលោមភាពឬលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិ។

មាត្រា៥ .-

១- អាជ្ញាធរផ្តល់អនុលោមភាពនៃភាគីកិច្ចព្រមព្រៀងនីមួយៗដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ត្រូវធ្វើនូវបញ្ជីនៃយានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់ ដែលខ្លួនបានបដិសេធមិនផ្តល់ ឬដកអនុលោមភាព ក្នុងករណីមានការស្នើសុំពីបណ្តាភាគីកិច្ចព្រមព្រៀងដទៃទៀត។

២- បន្ថែមពីនេះ នៅពេលទទួលបានសំណើពីភាគីកិច្ចព្រមព្រៀងមួយទៀតដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ភាគីកិច្ចព្រមព្រៀងនោះត្រូវប្រញាប់បញ្ជូនទៅកាន់ភាគីកិច្ចព្រមព្រៀងម្ខាងទៀត ដោយស្របតាមបទប្បញ្ញត្តិបន្ថែមទី៥នៅក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ នូវព័ត៌មានពាក់ព័ន្ធទាំងអស់ដែលខ្លួនបានយកជាមូលដ្ឋានក្នុងការសម្រេចចិត្តលើការផ្តល់ បដិសេធ ឬក៏ដកហូតអនុលោមភាពនៃយានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់ ដែលយោងតាមបទប្បញ្ញត្តិរបស់អង្គការសហប្រជាជាតិ។

៧/៤៤

៣- ច្បាប់ចម្លងជាក្រដាស អាចត្រូវបានជំនួសដោយឯកសារអេឡិចត្រូនិក ស្របទៅតាមបទប្បញ្ញត្តិបន្ថែមទី៥ នៃកិច្ចព្រមព្រៀងនេះ។

មាត្រា៦ .-

១- ភាគីនៃកិច្ចព្រមព្រៀងនេះអាចជាប្រទេសសមាជិកនៃគណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប ប្រទេសជាភាគីពិគ្រោះយោបល់នៃគណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប ស្របតាមកថាខណ្ឌទី៨នៃលក្ខន្តិកៈរបស់គណៈកម្មការនេះ និងអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដែលត្រូវបានបង្កើតឡើងដោយប្រទេសសមាជិកនៃគណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប ហើយប្រទេសសមាជិកទាំងនោះបានផ្ទេរសិទ្ធិឱ្យចំពោះវិស័យដែលស្ថិតក្រោមកិច្ចព្រមព្រៀងនេះ ដោយរួមបញ្ចូលនូវសិទ្ធិក្នុងការសម្រេចរួមដែលបង្កើតជាអានុភាពគតិយុត្តចំពោះរដ្ឋសមាជិក។

សម្រាប់ការកំណត់ចំនួនសំឡេងឆ្នោតដូចមានចែងក្នុងមាត្រា១ កថាខណ្ឌទី២ និងមាត្រា១២ កថាខណ្ឌទី២ អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់មានចំនួនសំឡេងឆ្នោតស្មើនឹងចំនួននៃរដ្ឋសមាជិកដែលជាភាគីនៃគណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប។

២- ភាគីនៃកិច្ចព្រមព្រៀងនេះក៏អាចជារដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ ដែលអាចចូលរួមក្នុងសកម្មភាពជាក់លាក់មួយចំនួននៃគណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប ស្របតាមកថាខណ្ឌទី១១នៃលក្ខន្តិកៈរបស់គណៈកម្មការនោះ រួមទាំងអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់នៃប្រទេសទាំងនោះ ដែលប្រទេសទាំងនោះបានផ្ទេរសិទ្ធិឱ្យខ្លួនចំពោះវិស័យដែលស្ថិតក្រោមកិច្ចព្រមព្រៀងនេះ ដោយរួមបញ្ចូលនូវសិទ្ធិក្នុងការសម្រេចរួមដែលបង្កើតជាអានុភាពគតិយុត្តចំពោះរដ្ឋសមាជិក។

សម្រាប់ការកំណត់ចំនួនសំឡេងឆ្នោតដូចមានចែងក្នុងមាត្រា១ កថាខណ្ឌទី២ និងមាត្រា១២ កថាខណ្ឌទី២ អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់មានចំនួនសំឡេងឆ្នោតស្មើនឹងចំនួននៃរដ្ឋសមាជិកដែលជាភាគីនៃអង្គការសហប្រជាជាតិ។

៣- ក្រោយពីការចូលជាធរមាននៃកិច្ចព្រមព្រៀងឆ្នាំ១៩៥៨ ភាគីកិច្ចព្រមព្រៀងថ្មីដែលមិនមែនជាភាគីនៃកិច្ចព្រមព្រៀងឆ្នាំ១៩៥៨ អាចចូលជាភាគីនៃកិច្ចព្រមព្រៀងនេះ បន្ទាប់ពីដាក់តម្កល់លិខិតុបករណ៍ស្នើសុំចូលជាសមាជិកទៅអគ្គលេខាធិការ។

មាត្រា៧ .-

១- កិច្ចព្រមព្រៀងនេះត្រូវចាត់ទុកថាចូលជាធរមានក្នុងរយៈពេល៩ខែ បន្ទាប់ពីអគ្គលេខាធិការបញ្ជូនឯកសារទៅកាន់ភាគីកិច្ចព្រមព្រៀងឆ្នាំ១៩៥៨ទាំងអស់។

២- កិច្ចព្រមព្រៀងនេះមិនត្រូវចូលជាធរមានឡើយ ប្រសិនបើមានការជំទាស់ណាមួយពីភាគីកិច្ចព្រមព្រៀងឆ្នាំ១៩៥៨ ត្រូវបានលើកឡើងក្នុងរយៈពេល៦ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការបញ្ជូនកិច្ចព្រមព្រៀងនេះទៅកាន់ភាគីនៃកិច្ចព្រមព្រៀងដោយអគ្គលេខាធិការ។

៣- ភាគីថ្មីនឹងក្លាយជាសមាជិកនៃកិច្ចព្រមព្រៀងនេះ បន្ទាប់ពីបានតម្កល់លិខិតុបករណ៍ស្នើសុំចូលជាសមាជិកក្នុងរយៈពេល៦០ថ្ងៃ។

មាត្រា៨ .-

១- ភាគីណាមួយនៃកិច្ចព្រមព្រៀងនេះអាចប្រកាសដកខ្លួនចេញពីកិច្ចព្រមព្រៀងនេះ ដោយជូនដំណឹងទៅអគ្គលេខាធិការ។

២- ការប្រកាសដកខ្លួននេះមានប្រសិទ្ធភាពជាធរមានក្នុងរយៈពេល១២ខែ បន្ទាប់ពីអគ្គលេខាធិការទទួលបាននូវការជូនដំណឹងអំពីការដកខ្លួននេះ។

៣- អនុលោមភាពចំពោះប្រភេទណាមួយដែលត្រូវបានផ្ដល់ដោយភាគីនៃកិច្ចព្រមព្រៀងនោះ ត្រូវរក្សាសុពលភាពរយៈពេល១២ខែ បន្ទាប់ពីការប្រកាសដកខ្លួននោះចូលជាធរមាន ដូចមានចែងក្នុងមាត្រា៨ កថាខណ្ឌទី២។

មាត្រា៩ ._

១- ភាគីណាមួយនៃកិច្ចព្រមព្រៀងដូចមានចែងក្នុងមាត្រា៦ អាចធ្វើការប្រកាសតាមរយៈសេចក្ដីជូនដំណឹងទៅកាន់អគ្គលេខាធិការថា កិច្ចព្រមព្រៀងនេះត្រូវពង្រីកវិសាលភាពទៅកាន់ដែនដីទាំងអស់ឬដែនដីណាមួយដែលខ្លួនទទួលខុសត្រូវលើកិច្ចការទំនាក់ទំនងអន្តរជាតិ។ កិច្ចព្រមព្រៀងនេះត្រូវពង្រីកវិសាលភាពទៅកាន់ដែនដីឬបណ្ដាដែនដីដែលបានកំណត់ឈ្មោះនៅក្នុងសេចក្ដីជូនដំណឹង គិតចាប់ពីថ្ងៃទី៦០បន្ទាប់ពីអគ្គលេខាធិការទទួលបាននូវការជូនដំណឹងនោះ។

២- ភាគីណាមួយនៃកិច្ចព្រមព្រៀង ដូចមានចែងក្នុងមាត្រា៦នៃកិច្ចព្រមព្រៀងនេះ ដែលបានប្រកាសស្របតាមកថាខណ្ឌទី១នៃមាត្រានេះដើម្បីពង្រីកវិសាលភាពនៃកិច្ចព្រមព្រៀងទៅកាន់ដែនដីណាមួយដែលខ្លួនទទួលខុសត្រូវលើកិច្ចការទំនាក់ទំនងអន្តរជាតិ អាចប្រកាសឈប់អនុវត្តកិច្ចព្រមព្រៀងនេះដោយឡែកចំពោះដែនដីនោះ ដោយយោងតាមបញ្ញត្តិនៃមាត្រា៨។

មាត្រា១០ ._

១- វិវាទរវាងភាគីកិច្ចព្រមព្រៀងពីរឬច្រើន ចំពោះការបកស្រាយឬការអនុវត្តកិច្ចព្រមព្រៀងនេះ ត្រូវដោះស្រាយដោយការចរចារវាងភាគីពាក់ព័ន្ធនឹងវិវាទ តាមដែលអាចធ្វើទៅបាន។

២- វិវាទណាមួយដែលមិនអាចដោះស្រាយបានតាមរយៈការចរចា ត្រូវបញ្ជូនទៅមជ្ឈត្តការ ប្រសិនបើភាគីកិច្ចព្រមព្រៀងណាមួយនៅក្នុងវិវាទធ្វើសំណើសុំ ហើយត្រូវបញ្ជូនទៅកាន់មជ្ឈត្តករមួយឬច្រើនដែលត្រូវបានជ្រើសរើសដោយការព្រមព្រៀងរវាងភាគីទាំងអស់នៅក្នុងវិវាទ។ ប្រសិនបើក្នុងកំឡុងពេល៣ខែ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់សំណើទៅកាន់មជ្ឈត្តកម្ម ភាគីនៃវិវាទមិនអាចឈានដល់ការព្រមព្រៀងលើការជ្រើសរើសមជ្ឈត្តករមួយឬច្រើនបានទេ នោះភាគីនៃវិវាទទាំងអស់នោះអាចរៀបចំសំណើទៅអគ្គលេខាធិការ ដើម្បីចាត់តាំងមជ្ឈត្តករតែមួយគត់ដែលអាចសម្រេចនូវមជ្ឈត្តវិនិច្ឆ័យទៅលើវិវាទនោះ។

៣- មជ្ឈត្តវិនិច្ឆ័យនៃមជ្ឈត្តករមួយឬច្រើនដែលត្រូវបានចាត់តាំង ស្របតាមកថាខណ្ឌទី២នៃមាត្រានេះ ត្រូវមានអានុភាពអនុវត្តចំពោះគ្រប់ភាគីនៃវិវាទ។

៤- វិវាទរវាងភាគីកិច្ចព្រមព្រៀងពីរឬច្រើន ដែលទាក់ទងទៅនឹងការបកស្រាយឬការអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិនៃកិច្ចព្រមព្រៀងនេះ ត្រូវដោះស្រាយដោយការចរចា ស្របតាមនីតិវិធីដែលបានចែងនៅក្នុងបទប្បញ្ញត្តិបន្ថែមទី៦នៃកិច្ចព្រមព្រៀងនេះ។

មាត្រា១១ ._

១- ភាគីកិច្ចព្រមព្រៀងណាមួយអាចប្រកាសថា ខ្លួនមិនមានកាតព្វកិច្ចអនុវត្តតាមបទប្បញ្ញត្តិនៃកថាខណ្ឌទី១ដល់ទី៣នៃមាត្រា១០ នៃកិច្ចព្រមព្រៀងនេះទេ នៅពេលចូលជាភាគីនៃកិច្ចព្រមព្រៀងនេះ។ ភាគីកិច្ចព្រមព្រៀងដទៃទៀត ក៏មិនមានកាតព្វកិច្ចអនុវត្តកថាខណ្ឌទី១ដល់ទី៣នៃមាត្រា១០នេះដែរ ជាមួយនឹងភាគីកិច្ចព្រមព្រៀងដែលប្រកាសដកខ្លួនពីការអនុវត្ត។

២- ភាគីកិច្ចព្រមព្រៀងណាដែលបានអនុវត្តខរក្សាសិទ្ធិដូចមានចែងនៅក្នុងកថាខណ្ឌទី១នៃមាត្រានេះ អាចដកខ្លួនចេញពីខរក្សាសិទ្ធិទាំងនោះគ្រប់ពេល តាមរយៈការជូនដំណឹងទៅអគ្គលេខាធិការ។

៣- មិនមានខរក្សាសិទ្ធិណាផ្សេងទៀតចំពោះកិច្ចព្រមព្រៀងនេះ ឧបសម្ព័ន្ធ បទប្បញ្ញត្តិបន្ថែម និងបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ត្រូវបានអនុញ្ញាតឱ្យអនុវត្តនោះទេ ប៉ុន្តែដោយស្របតាមលក្ខខណ្ឌនៃមាត្រា១ កថាខណ្ឌទី៥ ភាគីកិច្ចព្រមព្រៀងណាក៏អាចធ្វើការប្រកាសថា ខ្លួនមិនមានបំណងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិជាក់លាក់ណាមួយឬរាល់បទប្បញ្ញត្តិទាំងអស់។

មាត្រា១២ .-

បទប្បញ្ញត្តិអង្គការសហប្រជាជាតិនៅក្នុងកិច្ចព្រមព្រៀងនេះអាចត្រូវធ្វើវិសោធនកម្មដោយស្របទៅនឹងនីតិវិធី ដូចខាងក្រោម៖

១- ការធ្វើវិសោធនកម្មចំពោះបទប្បញ្ញត្តិអង្គការសហប្រជាជាតិត្រូវរៀបចំឡើងដោយគណៈកម្មាធិការរដ្ឋបាល ដូចមានចែងក្នុងមាត្រា១ កថាខណ្ឌទី២ និងស្របទៅនឹងនីតិវិធីមានចែងក្នុងឧបសម្ព័ន្ធ។

បន្ទាប់ពីបានរៀបចំហើយ គណៈកម្មាធិការរដ្ឋបាលត្រូវធ្វើការជូនដំណឹងទៅលេខាធិការប្រតិបត្តិនៃគណៈកម្មការសេដ្ឋកិច្ចនៃអង្គការសហប្រជាជាតិសម្រាប់អឺរ៉ុបអំពីការធ្វើវិសោធនកម្មទៅលើបទប្បញ្ញត្តិអង្គការសហប្រជាជាតិ។ បន្ទាប់ពីនេះទៅ លេខាធិការប្រតិបត្តិនៃគណៈកម្មការសេដ្ឋកិច្ចនៃអង្គការសហប្រជាជាតិសម្រាប់អឺរ៉ុប ត្រូវប្រញាប់ជូនដំណឹងអំពីការធ្វើវិសោធនកម្មនេះទៅភាគីកិច្ចព្រមព្រៀងដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិនិងអគ្គលេខាធិការ។

២- ការធ្វើវិសោធនកម្មទៅលើបទប្បញ្ញត្តិអង្គការសហប្រជាជាតិមួយនឹងត្រូវចាត់ទុកថាទទួលបានការអនុម័ត ប្រសិនបើមិនមានភាគីកិច្ចព្រមព្រៀងច្រើនជាងមួយភាគប្រាំដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិបានលើកការជំទាស់របស់ខ្លួនទៅកាន់អគ្គលេខាធិការ ក្នុងកំឡុងពេលប្រាំមួយខែបន្ទាប់ពីលេខាធិការប្រតិបត្តិនៃគណៈកម្មការសេដ្ឋកិច្ចអង្គការសហប្រជាជាតិសម្រាប់អឺរ៉ុបបានធ្វើការជូនដំណឹងអំពីការធ្វើវិសោធនកម្មនោះទេ។ នៅពេលការធ្វើវិសោធនកម្មទៅលើបទប្បញ្ញត្តិអង្គការសហប្រជាជាតិណាមួយត្រូវបានអនុម័ត អគ្គលេខាធិការត្រូវប្រកាសជាប្រញាប់ថា វិសោធនកម្មនោះត្រូវទទួលបានការអនុម័តនិងមានអានុភាពអនុវត្តចំពោះភាគីកិច្ចព្រមព្រៀងដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ។

៣- វិសោធនកម្មនានាទៅលើបទប្បញ្ញត្តិអង្គការសហប្រជាជាតិមួយអាចរាប់បញ្ចូលនូវអន្តរប្បញ្ញត្តិទាក់ទងនឹងការចូលជាធរមាននៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលបានធ្វើវិសោធនកម្ម កាលបរិច្ឆេទចុងក្រោយដែលភាគីកិច្ចព្រមព្រៀងទាំងឡាយត្រូវឯកភាពយកអនុលោមភាពដែលស្របនឹងកំណែមុននៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិ និងកាលបរិច្ឆេទដែលកំណត់ថា ចាប់ពីពេលនេះតទៅ ភាគីកិច្ចព្រមព្រៀងទាំងឡាយគ្មានកាតព្វកិច្ចទទួលយកនូវអនុលោមភាពចំពោះប្រភេទដែលបានផ្តល់ស្របតាមកំណែមុននៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលបានធ្វើវិសោធនកម្មនោះ។

៤- ទោះបីជាមានអន្តរប្បញ្ញត្តិនៅក្នុងកំណែណាមួយនៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិអាចត្រូវបានចែងផ្សេងក៏ដោយ ក៏ភាគីកិច្ចព្រមព្រៀងដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិទាំងអស់នៅតែអាចផ្តល់អនុលោមភាពចំពោះប្រភេទ ស្របតាមកំណែមុនៗនៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ដោយស្របតាមបញ្ញត្តិទាំងឡាយនៃមាត្រា២។ ទោះបីយ៉ាងនេះក្តី យោងតាមកថាខណ្ឌទី៣នៃមាត្រានេះ ភាគីកិច្ចព្រមព្រៀងទាំងឡាយ

ដែលអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិមិនមានកាតព្វកិច្ចទទួលយកអនុលោមភាពចំពោះប្រភេទដែលផ្តល់ស្របតាមកំណែមុនៗទាំងនោះទេ។

៥- ភាគីកិច្ចព្រមព្រៀងទាំងអស់ដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិមួយត្រូវទទួលយកអនុលោមភាពដែលបានផ្តល់ស្របទៅតាមកំណែថ្មីបំផុតនៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិនោះ លើកលែងតែភាគីកិច្ចព្រមព្រៀងណាដែលបានជូនដំណឹងទៅអគ្គលេខាធិការ នូវបំណងរបស់ខ្លួនក្នុងការបញ្ឈប់ការអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិនោះ។ ក្នុងកំឡុងពេលមួយឆ្នាំនៃការជូនដំណឹង ដូចមានចែងនៅក្នុងកថាខណ្ឌទី៦នៃមាត្រា១ ភាគីកិច្ចព្រមព្រៀងណាមួយដែលបានជូនដំណឹងដល់អគ្គលេខាធិការនូវបំណងរបស់ខ្លួនក្នុងការបញ្ឈប់ការអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិនោះ ត្រូវទទួលយកអនុលោមភាពដែលបានផ្តល់ស្របទៅតាមកំណែណាមួយនៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលអនុវត្តចំពោះភាគីកិច្ចព្រមព្រៀងនោះ នៅខណៈដែលខ្លួនបានជូនដំណឹងទៅកាន់អគ្គលេខាធិការ។

៦- ភាគីកិច្ចព្រមព្រៀងមួយដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិអាចផ្តល់នូវអនុលោមភាពអនុគ្រោះ ស្របតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិ សម្រាប់ប្រភេទមួយនៃយានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់ណាមួយដែលផ្អែកលើបច្ចេកវិទ្យាថ្មី នៅពេលដែលបច្ចេកវិទ្យាថ្មីនេះមិនត្រូវបានកំណត់នៅក្នុងបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលកំពុងមានជាធរមាន និងមានវិសមិតភាពជាមួយលក្ខខណ្ឌតម្រូវមួយឬច្រើននៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិនេះ។ ក្នុងករណីបែបនេះ នីតិវិធីដែលមានចែងក្នុងបទប្បញ្ញត្តិបន្ថែមទី៧ ក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ នឹងត្រូវយកមកអនុវត្ត។

៧- ប្រសិនបើភាគីកិច្ចព្រមព្រៀងថ្មីមួយចូលជាភាគីនៃកិច្ចព្រមព្រៀងនៅចន្លោះពេលការជូនដំណឹងអំពីការធ្វើវិសោធនកម្មទៅលើបទប្បញ្ញត្តិអង្គការសហប្រជាជាតិមួយ ដោយលេខាធិការប្រតិបត្តិនៃគណៈកម្មាធិការសេដ្ឋកិច្ចអង្គការសហប្រជាជាតិសម្រាប់អឺរ៉ុប និងពេលចូលជាធរមាននៃបទប្បញ្ញត្តិនេះ វាក៏ត្រូវចូលជាធរមានសម្រាប់ភាគីកិច្ចព្រមព្រៀងនោះផងដែរ ប្រសិនបើភាគីនៃកិច្ចព្រមព្រៀងថ្មីនោះមិនបានលើកការជំទាស់របស់ខ្លួនចំពោះការធ្វើវិសោធនកម្មក្នុងរយៈពេល៦ខែ គិតចាប់ពីពេលដែលអគ្គលេខាធិការបានជូនដំណឹងអំពីការចូលជាសមាជិកនៃកិច្ចព្រមព្រៀង។

មាត្រា១៣ .-

អត្ថបទនៃកិច្ចព្រមព្រៀងនេះនិងឧបសម្ព័ន្ធអាចត្រូវបានធ្វើវិសោធនកម្ម ស្របតាមនីតិវិធី ដូចខាងក្រោម៖

១- ភាគីកិច្ចព្រមព្រៀងណាមួយអាចលើកសំណើសុំធ្វើវិសោធនកម្មមួយឬច្រើនទៅលើកិច្ចព្រមព្រៀងនេះនិងឧបសម្ព័ន្ធ។ អត្ថបទនៃវិសោធនកម្មដែលបានស្នើឡើងចំពោះកិច្ចព្រមព្រៀងនិងឧបសម្ព័ន្ធត្រូវបញ្ជូនទៅអគ្គលេខាធិការដែលជាអ្នកត្រូវបញ្ជូនបន្តនូវវិសោធនកម្មដែលបានស្នើឡើងនោះទៅកាន់ភាគីកិច្ចព្រមព្រៀងទាំងអស់ និងជូនដំណឹងដល់បណ្តាប្រទេសដទៃទៀត ដោយបានចែងនៅក្នុងកថាខណ្ឌទី១នៃមាត្រា៦ អំពីការធ្វើវិសោធនកម្មនោះ។

២- វិសោធនកម្មណាមួយដែលស្នើឡើង ដោយបានជូនដំណឹងស្របតាមកថាខណ្ឌទី១នៃមាត្រានេះ ត្រូវចាត់ទុកថាបានឯកភាពទទួលយក ប្រសិនបើគ្មានភាគីកិច្ចព្រមព្រៀងណាមួយជំទាស់ ក្នុងកំឡុងពេលប្រាំបួនខែបន្ទាប់ពីកាលបរិច្ឆេទនៃការផ្សព្វផ្សាយនូវវិសោធនកម្មដែលបានស្នើនោះដោយអគ្គលេខាធិការ។

៣- អគ្គលេខាធិការត្រូវប្រញាប់ជូនដំណឹងដល់ភាគីកិច្ចព្រមព្រៀងទាំងអស់អំពីវិសោធនកម្មដែលបានស្នើឡើងមានការជំទាស់ឬទេ។ ប្រសិនបើវិសោធនកម្មដែលបានស្នើឡើងមានការជំទាស់ វិសោធនកម្មនោះត្រូវបានចាត់ទុកថាមិនត្រូវបានទទួលយកនិងមិនត្រូវមានអានុភាពអនុវត្តទេ។ ប្រសិនបើមិនមានការជំទាស់ទេ សេចក្តីព្រាងវិសោធនកម្ម

នោះត្រូវចូលជាធរមានចំពោះភាគីកិច្ចព្រមព្រៀងទាំងអស់ក្នុងរយៈពេល៣ខែ បន្ទាប់ពីផុតកំឡុងពេល៩ខែ ដែលបានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ។

មាត្រា១៣ .. ស្នូន

១- បទប្បញ្ញត្តិបន្ថែមស្តីពីបញ្ញត្តិរដ្ឋបាលនិងនីតិវិធី នៅក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះអាចត្រូវបានធ្វើវិសោធនកម្ម ស្របតាមនីតិវិធី ដូចខាងក្រោម៖

១.១- ការធ្វើវិសោធនកម្មទៅលើបទប្បញ្ញត្តិបន្ថែមស្តីពីបញ្ញត្តិរដ្ឋបាលនិងនីតិវិធី ត្រូវរៀបចំឡើងដោយគណៈកម្មាធិការរដ្ឋបាល ដូចមានចែងនៅក្នុងមាត្រា១ កថាខណ្ឌទី១ និងស្របតាមនីតិវិធីដែលមានបញ្ជាក់នៅក្នុងមាត្រា៧ ក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ។

១.២- គណៈកម្មាធិការរដ្ឋបាលត្រូវជូនដំណឹងទៅកាន់អគ្គលេខាធិការអំពីការធ្វើវិសោធនកម្មទៅលើបទប្បញ្ញត្តិបន្ថែមស្តីពីបញ្ញត្តិរដ្ឋបាលនិងនីតិវិធី។ បន្ទាប់មក អគ្គលេខាធិការត្រូវប្រញាប់ជូនដំណឹងអំពីការធ្វើវិសោធនកម្មនេះទៅកាន់បណ្តាភាគីកិច្ចព្រមព្រៀងដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិមួយឬច្រើន។

២- ការធ្វើវិសោធនកម្មទៅលើបទប្បញ្ញត្តិបន្ថែមស្តីពីបញ្ញត្តិរដ្ឋបាលនិងនីតិវិធី នឹងត្រូវចាត់ទុកថាបានអនុម័តរួច ប្រសិនបើនៅក្នុងកំឡុងពេល៦ខែ គិតចាប់ពីការជូនដំណឹងដោយអគ្គលេខាធិការ មិនមានភាគីកិច្ចព្រមព្រៀងណាដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិមួយឬច្រើនបានជូនដំណឹងទៅអគ្គលេខាធិការអំពីការជំទាស់របស់ខ្លួនទៅនឹងការធ្វើវិសោធនកម្មនោះ។

៣- អគ្គលេខាធិការត្រូវប្រញាប់ជូនដំណឹងដល់ភាគីកិច្ចព្រមព្រៀងទាំងអស់ថា តើវិសោធនកម្មដែលបានស្នើឡើងមានការជំទាស់ឬទេ។ ប្រសិនបើវិសោធនកម្មដែលបានស្នើឡើងមានការជំទាស់ វិសោធនកម្មនោះត្រូវបានចាត់ទុកថាមិនត្រូវបានទទួលយកនិងមិនត្រូវមានអានុភាពអនុវត្តទេ។ ប្រសិនបើមិនមានការជំទាស់ទេ សេចក្តីព្រាងវិសោធនកម្មនោះ ត្រូវចូលជាធរមានចំពោះភាគីកិច្ចព្រមព្រៀងទាំងអស់ក្នុងរយៈពេល៣ខែ បន្ទាប់ពីផុតកំឡុងពេល៦ខែ ដែលបានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ។

៤- បទប្បញ្ញត្តិបន្ថែមថ្មីមួយត្រូវបានចាត់ទុកជាវិសោធនកម្មលើបទប្បញ្ញត្តិបន្ថែមស្តីពីបញ្ញត្តិរដ្ឋបាលនិងនីតិវិធីនោះ ហេតុនេះបទប្បញ្ញត្តិបន្ថែមថ្មីនោះត្រូវបានបង្កើតឡើងស្របតាមនីតិវិធីដូចគ្នាទៅនឹងនីតិវិធីដែលបានចែងក្នុងមាត្រានេះ។

មាត្រា១៤ ..

១- ស្របតាមបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ អគ្គលេខាធិការត្រូវជូនដំណឹងទៅភាគីកិច្ចព្រមព្រៀងទាំងអស់អំពី៖

ក- ការចូលជាភាគី ស្របតាមមាត្រា៦។

ខ- កាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ស្របតាមមាត្រា៧។

គ- ការដកខ្លួនចេញពីកិច្ចព្រមព្រៀង ស្របតាមមាត្រា៨។

ឃ- សេចក្តីជូនដំណឹងដែលទទួលបាន ស្របតាមមាត្រា៩។

ង- សេចក្តីប្រកាសនិងសេចក្តីជូនដំណឹងដែលទទួលបាន ស្របតាមកថាខណ្ឌទី១និងទី២នៃមាត្រា១១។

ច- ការចូលជាធរមាននៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិថ្មីណាមួយនិងវិសោធនកម្មលើបទប្បញ្ញត្តិនានារបស់អង្គការសហប្រជាជាតិដែលមានជាធរមាន ដោយស្របតាមកថាខណ្ឌទី២ ទី៣ ទី៥ និងទី៧នៃមាត្រា១ និងកថាខណ្ឌទី២នៃមាត្រា១២។

ឆ- ការចូលជាធរមាននៃវិសោធនកម្មលើកិច្ចព្រមព្រៀងឬឧបសម្ព័ន្ធ ស្របតាមកថាខណ្ឌទី៣ នៃមាត្រា១៣ ឬវិសោធនកម្មលើបទប្បញ្ញត្តិបន្ថែមស្ដីពីបញ្ញត្តិរដ្ឋបាលនិងនីតិវិធីស្របតាម កថាខណ្ឌទី៣នៃមាត្រា១៣ស្ទួន។

ជ- ការបញ្ឈប់ការអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិដោយភាគីកិច្ចព្រមព្រៀងស្របតាម កថាខណ្ឌទី៦នៃមាត្រា១។

២- ស្របទៅតាមបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះនិងបទប្បញ្ញត្តិបន្ថែមស្ដីពីបញ្ញត្តិរដ្ឋបាលនិងនីតិវិធីដែលមាននៅក្នុងឧបសម្ព័ន្ធ លេខាធិការប្រតិបត្តិនៃគណៈកម្មការសេដ្ឋកិច្ចរបស់អង្គការសហប្រជាជាតិសម្រាប់អឺរ៉ុបត្រូវជូនដំណឹងទៅ៖

ក- អគ្គលេខាធិការនិងភាគីកិច្ចព្រមព្រៀងទាំងឡាយអំពីការរៀបចំធ្វើវិសោធនកម្មលើបទប្បញ្ញត្តិ អង្គការសហប្រជាជាតិ ដោយស្របតាមកថាខណ្ឌទី២នៃមាត្រា១២។

ខ- ភាគីកិច្ចព្រមព្រៀងទាំងឡាយ អំពីសេចក្ដីសម្រេចដែលធ្វើឡើងដោយគណៈកម្មាធិការរដ្ឋបាល ទៅលើការស្នើសុំផ្ដល់អនុលោមភាពអនុគ្រោះ ហើយបន្ទាប់មក អំពីការទទួលយកនូវសំណើសុំ ផ្ដល់អនុលោមភាពអនុគ្រោះខាងលើ ដោយស្របតាមកថាខណ្ឌទី៥នៃបទប្បញ្ញត្តិបន្ថែមទី៧។

មាត្រា១៥ .-

១- ប្រសិនបើនៅកាលបរិច្ឆេទដែលបញ្ញត្តិខាងលើត្រូវចូលជាធរមាន ហើយនីតិវិធីដែលមានចែងក្នុងមាត្រា១ កថាខណ្ឌទី៣និងទី៤ នៃកំណែមុននៃកិច្ចព្រមព្រៀងនេះកំពុងស្ថិតក្នុងដំណើរការសុំការអនុម័តលើបទប្បញ្ញត្តិអង្គការ សហប្រជាជាតិថ្មីមួយ បទប្បញ្ញត្តិអង្គការសហប្រជាជាតិថ្មីនោះត្រូវចូលជាធរមានស្របតាមបញ្ញត្តិនៃកថាខណ្ឌទី៤ នៃមាត្រាដែលបានលើកឡើងខាងលើ។

២- ប្រសិនបើនៅកាលបរិច្ឆេទដែលបញ្ញត្តិខាងលើត្រូវចូលជាធរមាន ហើយនីតិវិធីដែលមានចែងក្នុងមាត្រា១២ កថាខណ្ឌទី១នៃកំណែមុននៃកិច្ចព្រមព្រៀងនេះកំពុងស្ថិតក្នុងដំណើរការសុំការអនុម័តលើវិសោធនកម្មមួយនៃ បទប្បញ្ញត្តិអង្គការសហប្រជាជាតិ វិសោធនកម្មនោះត្រូវចូលជាធរមាន ស្របតាមបញ្ញត្តិទាំងឡាយនៃមាត្រាខាងលើ។

៣- ប្រសិនបើភាគីនៃកិច្ចព្រមព្រៀងទាំងអស់ឯកភាព បទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលត្រូវបានអនុម័ត ស្របតាមលក្ខខណ្ឌនៃកំណែមុននៃកិច្ចព្រមព្រៀងអាចចាត់ទុកថាជាបទប្បញ្ញត្តិដែលបានអនុម័តរួច ស្របតាម លក្ខខណ្ឌនៃបញ្ញត្តិនានាខាងលើ។

មាត្រា១៦ .-

កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងនៅទីក្រុងហ្សឺណែវ ជាច្បាប់ចម្លងតែមួយជាភាសាអង់គ្លេស បារាំង និងរុស្ស៊ី ដែលអត្ថបទនីមួយៗមានតម្លៃស្មើគ្នា។

១៣/៤៤

ឧបសម្ព័ន្ធ
សមាសភាព និងវិធាននៃនីតិវិធីរបស់គណៈកម្មាធិការរដ្ឋបាល

មាត្រា១

គណៈកម្មាធិការរដ្ឋបាល ត្រូវមានសមាសភាពចេញពីគ្រប់ភាគីនៃកិច្ចព្រមព្រៀងដែលបានធ្វើវិសោធនកម្ម។

មាត្រា២

លេខាធិការប្រតិបត្តិនៃគណៈកម្មការសេដ្ឋកិច្ចរបស់អង្គការសហប្រជាជាតិសម្រាប់អឺរ៉ុបត្រូវដើរតួនាទីជាលេខាធិការនៃគណៈកម្មាធិការនេះ។

មាត្រា៣

នៅសម័យប្រជុំដំបូង ជារៀងរាល់ឆ្នាំ គណៈកម្មាធិការនេះត្រូវបោះឆ្នោតជ្រើសរើសប្រធានមួយរូប និងអនុប្រធានមួយរូបរបស់ខ្លួន។

មាត្រា៤

អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវកោះប្រជុំគណៈកម្មាធិការ ក្រោមការគាំទ្រពីគណៈកម្មការសេដ្ឋកិច្ចសម្រាប់អឺរ៉ុប នៅពេលដែលមានតម្រូវការឱ្យមានការបង្កើតបទប្បញ្ញត្តិអង្គការសហប្រជាជាតិថ្មីណាមួយ ការធ្វើវិសោធនកម្មលើបទប្បញ្ញត្តិអង្គការសហប្រជាជាតិមួយ ការជូនដំណឹងស្របទៅតាមនីតិវិធីអនុលោមភាពអនុគ្រោះសម្រាប់បច្ចេកវិទ្យាថ្មីៗ (ដូចមានចែងក្នុងបទប្បញ្ញត្តិបន្ថែមទី៧) ឬការធ្វើវិសោធនកម្មលើបទប្បញ្ញត្តិបន្ថែមនៃបញ្ញត្តិស្តីពីរដ្ឋបាលនិងនីតិវិធី។

មាត្រា៥

បទប្បញ្ញត្តិអង្គការសហប្រជាជាតិថ្មីដែលស្នើឡើង ត្រូវឆ្លងកាត់ការបោះឆ្នោត។ ប្រទេសនីមួយៗដែលជាភាគីនៃកិច្ចព្រមព្រៀងនេះត្រូវមានសំឡេងឆ្នោតមួយសំឡេង។ រាល់ការធ្វើសេចក្តីសម្រេច ត្រូវមានចំនួនកូរ៉ុមមិនតិចជាងពាក់កណ្តាលនៃចំនួនភាគីកិច្ចព្រមព្រៀងសរុប។ ក្នុងការកំណត់ចំនួនកូរ៉ុម អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ដែលជាភាគីនៃកិច្ចព្រមព្រៀងនេះ ធ្វើការបោះឆ្នោតទៅតាមចំនួននៃសំឡេងរដ្ឋជាសមាជិករបស់ខ្លួន។ តំណាងនៃអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់អាចធ្វើការបោះឆ្នោតជំនួសឱ្យបណ្តាប្រទេសជាសមាជិកចំណុះរបស់ខ្លួន។ សេចក្តីព្រាងថ្មីនៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ត្រូវបានបង្កើតឡើងដោយសំឡេងភាគច្រើន៤/៥(បួនភាគប្រាំ) នៃបណ្តាប្រទេសដែលមានវត្តមាននិងបានចូលរួមបោះឆ្នោត។

មាត្រា៦

ការធ្វើវិសោធនកម្មនៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិថ្មីដែលស្នើឡើង ត្រូវឆ្លងកាត់ការបោះឆ្នោត។ ប្រទេសនីមួយៗនៃភាគីកិច្ចព្រមព្រៀងដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ត្រូវមានសំឡេងឆ្នោតមួយសំឡេង។ រាល់ការធ្វើសេចក្តីសម្រេច ត្រូវមានចំនួនកូរ៉ុមមិនតិចជាងពាក់កណ្តាលនៃចំនួនភាគីកិច្ចព្រមព្រៀងដែលកំពុងអនុវត្ត បទប្បញ្ញត្តិអង្គការសហប្រជាជាតិ។ ក្នុងការកំណត់ចំនួនកូរ៉ុម អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ដែលជាភាគីនៃកិច្ចព្រមព្រៀងនេះ ធ្វើការបោះឆ្នោតទៅតាមចំនួនសំឡេងនៃរដ្ឋជាសមាជិករបស់ខ្លួន។ តំណាងនៃអង្គការ សមាហរណកម្មសេដ្ឋកិច្ចតំបន់ អាចធ្វើការបោះឆ្នោតជំនួសឱ្យបណ្តាប្រទេសជាសមាជិកដែលកំពុងអនុវត្តបទប្បញ្ញត្តិ អង្គការសហប្រជាជាតិបាន។ សេចក្តីព្រាងវិសោធនកម្មនៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ត្រូវបានបង្កើតឡើងដោយសំឡេងភាគច្រើ៤/៥(បួនភាគប្រាំ)នៃបណ្តាប្រទេសដែលមានវត្តមាននិងបានចូលរួមបោះឆ្នោត។

១៤/៤៤

មាត្រា៧

សេចក្តីព្រាងវិសោធនកម្មដែលស្នើឡើងនៃបទប្បញ្ញត្តិបន្ថែមស្តីពីបញ្ញត្តិរដ្ឋបាលនិងនីតិវិធីនៅក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ ត្រូវឆ្លងកាត់ការបោះឆ្នោត។ ប្រទេសនីមួយៗនៃភាគីកិច្ចព្រមព្រៀងដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិមួយឬច្រើន ត្រូវមានសំឡេងឆ្នោតមួយសំឡេង។ រាល់ការធ្វើសេចក្តីសម្រេច ត្រូវមានចំនួនកូរ៉ុមមិនតិចជាងពាក់កណ្តាលនៃចំនួនភាគីកិច្ចព្រមព្រៀងដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិមួយឬច្រើន។ ក្នុងការកំណត់ចំនួនកូរ៉ុម អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ដែលជាភាគីនៃកិច្ចព្រមព្រៀងនេះ ធ្វើការបោះឆ្នោតទៅតាមចំនួនសំឡេងនៃរដ្ឋជាសមាជិករបស់ខ្លួន។ តំណាងនៃអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់អាចធ្វើការបោះឆ្នោតជំនួសឱ្យបណ្តាប្រទេសជាសមាជិកដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិមួយឬច្រើន។ សេចក្តីព្រាងវិសោធនកម្មនៃបទប្បញ្ញត្តិបន្ថែមស្តីពីបញ្ញត្តិរដ្ឋបាលនិងនីតិវិធី ត្រូវបានបង្កើតឡើងដោយសំឡេងឆ្នោតជាឯកច្ឆន្ទនៃបណ្តាប្រទេសដែលមានវត្តមាននិងបានចូលរួមបោះឆ្នោត។

មាត្រា៨

ការស្នើសុំពីសំណាក់ភាគីកិច្ចព្រមព្រៀងមួយនូវសិទ្ធិក្នុងការសម្រេចផ្តល់អនុលោមភាពអនុគ្រោះពាក់ព័ន្ធនឹងបច្ចេកវិទ្យាថ្មីៗ ត្រូវឆ្លងកាត់ការបោះឆ្នោត។ ភាគីនៃកិច្ចព្រមព្រៀងនីមួយៗដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិត្រូវមានសំឡេងឆ្នោតមួយសំឡេង។ រាល់ការធ្វើសេចក្តីសម្រេចត្រូវមានចំនួនកូរ៉ុមមិនតិចជាងពាក់កណ្តាលនៃចំនួនភាគីកិច្ចព្រមព្រៀងដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ។ ក្នុងការកំណត់ចំនួនកូរ៉ុម អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ដែលជាភាគីនៃកិច្ចព្រមព្រៀងនេះ ធ្វើការបោះឆ្នោតទៅតាមចំនួនសំឡេងនៃរដ្ឋជាសមាជិករបស់ខ្លួន។ តំណាងនៃអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់អាចធ្វើការបោះឆ្នោតជំនួសឱ្យបណ្តាប្រទេសជាសមាជិកដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ។ សិទ្ធិក្នុងការសម្រេចផ្តល់អនុលោមភាពអនុគ្រោះសម្រាប់ភាគីកិច្ចព្រមព្រៀងខាងលើ ត្រូវបានបង្កើតឡើងដោយសំឡេងភាគច្រើន៤/៥(បួនភាគប្រាំ)នៃបណ្តាប្រទេសដែលមានវត្តមាននិងបានចូលរួមបោះឆ្នោត។

បទប្បញ្ញត្តិបន្ថែមស្តីពីបញ្ញត្តិរដ្ឋបាលនិងនីតិវិធី

បទប្បញ្ញត្តិបន្ថែមស្តីពីបញ្ញត្តិរដ្ឋបាលនិងនីតិវិធី ត្រូវបានដាក់ជាឧបសម្ព័ន្ធកិច្ចព្រមព្រៀងឆ្នាំ១៩៥៨ និងកំណត់អំពីបញ្ញត្តិរដ្ឋបាលនិងនីតិវិធីដែលអនុវត្តលើបទប្បញ្ញត្តិអង្គការសហប្រជាជាតិទាំងអស់ នៅក្នុងឧបសម្ព័ន្ធកិច្ចព្រមព្រៀងឆ្នាំ១៩៥៨ ដូចខាងក្រោម៖

បទប្បញ្ញត្តិបន្ថែមទី១	នីតិវិធី ភាពអនុលោមនៃផលិតកម្ម
បទប្បញ្ញត្តិបន្ថែមទី២	ផ្នែកទី១ : ការវាយតម្លៃ ការចាត់តាំង និងការជូនដំណឹងពីអង្គភាពបច្ចេកទេស ផ្នែកទី២ : ស្តង់ដាដែលត្រូវគោរពតាមសម្រាប់អង្គភាពបច្ចេកទេស ដូចមានកំណត់ក្នុងផ្នែកទី១នៃបទប្បញ្ញត្តិបន្ថែមនេះ ផ្នែកទី៣ : នីតិវិធីសម្រាប់ការវាយតម្លៃអង្គភាពបច្ចេកទេស
បទប្បញ្ញត្តិបន្ថែមទី៣	នីតិវិធីសម្រាប់អនុលោមភាពចំពោះប្រភេទនៃអង្គការសហប្រជាជាតិ
បទប្បញ្ញត្តិបន្ថែមទី៤	ការផ្តល់លេខសម្គាល់អនុលោមភាពចំពោះប្រភេទនៃអង្គការសហប្រជាជាតិ
បទប្បញ្ញត្តិបន្ថែមទី៥	ការផ្សព្វផ្សាយឯកសារអនុលោមភាព
បទប្បញ្ញត្តិបន្ថែមទី៦	នីតិវិធីសម្រាប់ការដោះស្រាយបញ្ហាលើការបកស្រាយចំពោះការអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ និងការផ្តល់អនុលោមភាពស្របតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិទាំងនេះ
បទប្បញ្ញត្តិបន្ថែមទី៧	នីតិវិធីនៃការផ្តល់អនុលោមភាពអនុគ្រោះចំពោះបច្ចេកវិទ្យាថ្មីៗ
បទប្បញ្ញត្តិបន្ថែមទី៨	លក្ខខណ្ឌទូទៅសម្រាប់វិធីសាស្ត្រការធ្វើតេស្តនិម្មិត

បទប្បញ្ញត្តិបន្ថែមទី១
នីតិវិធី ភាពអនុលោមនៃផលិតកម្ម

គោលបំណង

នីតិវិធី ភាពអនុលោមនៃផលិតកម្ម មានគោលបំណងដើម្បីធានាថា យានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់នីមួយៗដែលបានផលិត ត្រូវគោរពតាមប្រភេទដែលទទួលបានអនុលោមភាព។

នីតិវិធីទាំងអស់ រួមមានការវាយតម្លៃប្រព័ន្ធគ្រប់គ្រងគុណភាព ហៅថា "ការវាយតម្លៃបឋម" និងការផ្ទៀងផ្ទាត់លើគំរូអនុលោមភាពនិងលើការត្រួតពិនិត្យលើផលិតផល ហៅថា "ការរៀបចំអនុលោមភាពផលិតផល"។ នីតិវិធីទាំងពីរនេះត្រូវអនុវត្តរួមគ្នាដោយមិនអាចកាត់ផ្ដាច់ចេញពីគ្នាបាន។

១- ការវាយតម្លៃបឋម

១.១- អាជ្ញាធរផ្ដល់អនុលោមភាពនៃភាគីកិច្ចព្រមព្រៀងមួយ មុននឹងផ្ដល់អនុលោមភាពចំពោះប្រភេទ ត្រូវបញ្ជាក់ថា ដំណើរការនិងនីតិវិធីសមស្របត្រូវបានរៀបចំឡើង ក្នុងគោលបំណងធានាឱ្យបាននូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ដើម្បីឱ្យយានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់ គោរពទៅតាមប្រភេទដែលទទួលបានអនុលោមភាពក្នុងដំណាក់កាលផលិតកម្ម។

១.២- គោលការណ៍ណែនាំសម្រាប់ការវាយតម្លៃមាននៅក្នុងស្តង់ដាអន្តរជាតិ ISO 19011:2011 - គោលការណ៍ណែនាំសម្រាប់សវនកម្មលើប្រព័ន្ធគ្រប់គ្រង។

១.៣- លក្ខខណ្ឌតម្រូវនៅក្នុងកថាខណ្ឌ១.១ ត្រូវផ្ទៀងផ្ទាត់បញ្ជាក់ទៅតាមលក្ខខណ្ឌរបស់អាជ្ញាធរដែលផ្ដល់អនុលោមភាពចំពោះប្រភេទ។

ការវាយតម្លៃបឋមនិងការរៀបចំអនុលោមភាពចំពោះផលិតផល ក្នុងផ្នែកទី២ខាងក្រោម ត្រូវបំពេញតាមលក្ខខណ្ឌនៃអាជ្ញាធរផ្ដល់អនុលោមភាព ដែលផ្ដល់អនុលោមភាពចំពោះប្រភេទរបស់អង្គការសហប្រជាជាតិ។ ការបំពេញតាមលក្ខខណ្ឌផ្ដល់អនុលោមភាពត្រូវគិតគូរជាចាំបាច់ទៅលើដំណើរការរៀបចំយ៉ាងតិចមួយក្នុងចំណោមដំណើរការរៀបចំនានា ឬដាក់បញ្ចូលគ្នាទាំងមូល ឬដោយផ្នែកនូវដំណើរការរៀបចំ ដែលមានចែងចាប់ពីកថាខណ្ឌ១.៣.១ ដល់១.៣.៣ តាមស្ថានភាពសមស្រប។

១.៣.១- ការវាយតម្លៃបឋមជាក់ស្តែង និង/ឬការផ្ទៀងផ្ទាត់បញ្ជាក់នៃដំណើរការរៀបចំភាពអនុលោមផលិតផល ត្រូវអនុវត្តដោយអាជ្ញាធរផ្ដល់អនុលោមភាពចំពោះប្រភេទរបស់អង្គការសហប្រជាជាតិ ឬដោយអង្គភាពបច្ចេកទេស ដែលបានចាត់តាំងបំពេញកិច្ចក្នុងនាមអាជ្ញាធរផ្ដល់អនុលោមភាព។

១.៣.១.១- នៅពេលពិចារណាលើវិសាលភាពនៃការវាយតម្លៃបឋមដែលត្រូវអនុវត្ត អាជ្ញាធរផ្ដល់អនុលោមភាពអាចពិចារណាលើព័ត៌មានដែលមានស្រាប់ពាក់ព័ន្ធទៅលើ៖

- ក- វិញ្ញាបនបត្ររោងចក្រផលិត ដែលមានចែងក្នុងកថាខណ្ឌ១.៣.៣ ខាងក្រោម ដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឬមិនត្រូវបានទទួលស្គាល់ ដូចមានចែងក្នុងកថាខណ្ឌខាងលើ។
- ខ- ក្នុងករណីដែលការផ្ដល់អនុលោមភាពចំពោះប្រភេទរបស់អង្គការសហប្រជាជាតិលើបរិក្ខារឬគ្រឿងបន្លាស់ ត្រូវបានធ្វើឡើងនៅក្នុងបរិវេណនៃរោងចក្រផលិតយានយន្តអនុលោមភាពចំពោះប្រភេទការវាយតម្លៃប្រព័ន្ធគុណភាពទៅលើបរិក្ខារឬគ្រឿងបន្លាស់នោះដោយយោងទៅលើយថាប្រភេទមួយឬច្រើននៃផ្នែកឧស្សាហកម្មនោះដែលបំពេញតាមលក្ខខណ្ឌតម្រូវនៃស្តង់ដាអន្តរជាតិ ISO 9001:2008។

១៧/៤៤

១.៣.២- ការវាយតម្លៃបឋមជាក់ស្តែង និង/ឬការផ្ទៀងផ្ទាត់បញ្ជាក់លើដំណើរការរៀបចំភាពអនុលោមផលិតផល ក៏អាចត្រូវបានអនុវត្តដោយអាជ្ញាធរផ្តល់អនុលោមភាពចំពោះប្រភេទនៃភាគីកិច្ចព្រមព្រៀងដទៃ ឬ ដោយអង្គភាពបច្ចេកទេសដែលត្រូវបានចាត់តាំងដោយអាជ្ញាធរផ្តល់អនុលោមភាពនោះ ក្នុងករណីភាគីកិច្ចព្រមព្រៀងនោះអនុវត្តយ៉ាងហោចណាស់បទប្បញ្ញត្តិអង្គការសហប្រជាជាតិដូចគ្នាទៅនឹង បទប្បញ្ញត្តិជាមូលដ្ឋានក្នុងការផ្តល់អនុលោមភាពចំពោះប្រភេទ។

១.៣.២.១- ក្នុងករណីបែបនេះ អាជ្ញាធរផ្តល់អនុលោមភាពរបស់ភាគីកិច្ចព្រមព្រៀងដទៃទៀតត្រូវរៀបចំសេចក្តីថ្លែងការណ៍នៃភាពអនុលោម ដែលបញ្ជាក់ពីផ្នែក ទីកន្លែង និងសម្ភារៈបរិក្ខារផលិតកម្មដែលខ្លួនមានវិសាលភាពគ្របដណ្តប់ពាក់ព័ន្ធទៅនឹងផលិតផល ដើម្បីទទួលបានអនុលោមភាពលើប្រភេទ និងបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ដែលយកជាបទប្បញ្ញត្តិក្នុងការផ្តល់អនុលោមភាព។

១.៣.២.២- នៅពេលដែលទទួលបានពាក្យស្នើសុំសេចក្តីថ្លែងការណ៍នៃភាពអនុលោមពីអាជ្ញាធរផ្តល់អនុលោមភាពរបស់ភាគីកិច្ចព្រមព្រៀងដែលផ្តល់អនុលោមភាពចំពោះប្រភេទរបស់អង្គការសហប្រជាជាតិនោះ អាជ្ញាធរផ្តល់អនុលោមភាពរបស់ភាគីកិច្ចព្រមព្រៀងដទៃទៀត ត្រូវធ្វើសេចក្តីថ្លែងការណ៍នៃភាពអនុលោមជាបន្ទាន់ ឬផ្តល់យោបល់ថា ខ្លួនមិនមានតួនាទីផ្តល់សេចក្តីថ្លែងការណ៍នោះទេ។

១.៣.២.៣- សេចក្តីថ្លែងការណ៍នៃភាពអនុលោម យ៉ាងហោចណាស់ ត្រូវដាក់បញ្ចូលនូវព័ត៌មាន ដូចខាងក្រោម៖

- ក- ក្រុមឬក្រុមហ៊ុន(ឧទាហរណ៍ ក្រុមហ៊ុនរថយន្ត)។
- ខ- ស្ថាប័នសាមី(ឧទាហរណ៍ អង្គភាពប្រចាំតំបន់) ។
- គ- រោងចក្រផលិត/ទីតាំង(ឧទាហរណ៍ រោងចក្រផលិតម៉ាស៊ីន១(នៅក្នុងប្រទេសក) - រោងចក្រផលិតយានយន្ត២(នៅក្នុងប្រទេសខ)។
- ឃ- ប្រភេទយានយន្ត/គ្រឿងបង្គុំ(ឧទាហរណ៍ ប្រភេទM1គ្រប់ប្រភេទ)។
- ង- ផ្នែកត្រូវបានវាយតម្លៃ(ឧទាហរណ៍ ទីតាំងដំឡើងម៉ាស៊ីន ទីតាំងដំឡើងតួ ទីតាំងដំឡើងយានយន្ត)។
- ច- ឯកសារដែលបានពិនិត្យ(ឧទាហរណ៍ សៀវភៅណែនាំនិងនីតិវិធីអំពីគុណភាពនៃក្រុមហ៊ុននិងទីតាំង)។
- ឆ- កាលបរិច្ឆេទនៃការវាយតម្លៃ(ឧទាហរណ៍ ការធ្វើសវនកម្មធ្វើឡើងចាប់ពីថ្ងៃ ខែ ឆ្នាំ ទៅដល់ថ្ងៃ ខែ ឆ្នាំ)។
- ជ- ការចុះត្រួតពិនិត្យដែលបានគ្រោងទុក(ឧទាហរណ៍ ខែ ឆ្នាំ)។

១.៣.៣- អាជ្ញាធរផ្តល់អនុលោមភាព ក៏អាចទទួលយកលិខិតបញ្ជាក់របស់រោងចក្រផលិត/ក្រុមហ៊ុនផលិតទៅលើស្តង់ដាអន្តរជាតិ ISO 9001:2008 (វិសាលភាពនៃលិខិតបញ្ជាក់នេះត្រូវមានអានុភាពគ្របដណ្តប់លើផលិតផលដែលត្រូវផ្តល់អនុលោមភាព) ឬស្តង់ដាទទួលស្គាល់ដែលមានតម្លៃសមមូលដែលបំពេញនូវលក្ខខណ្ឌតម្រូវនៃការវាយតម្លៃបឋមនៃកថាខណ្ឌ១.១។ រោងចក្រផលិតត្រូវផ្តល់ការបញ្ជាក់លម្អិត ហើយត្រូវជូនដំណឹងដល់អាជ្ញាធរផ្តល់អនុលោមភាពអំពីការកែប្រែណាមួយចំពោះសុពលភាពឬវិសាលភាពនៃលិខិតបញ្ជាក់នោះ។

១.៤- សម្រាប់គោលបំណងនៃប្រព័ន្ធអនុលោមភាពជាអន្តរជាតិចំពោះប្រភេទលើយានយន្តទាំងមូល ការវាយតម្លៃបឋមដែលអនុវត្តចំពោះការផ្តល់អនុលោមភាពរបស់អង្គការសហប្រជាជាតិទៅលើបរិក្ខារនិងគ្រឿងបន្លាស់នានានៃយានយន្ត មិនទាមទារឱ្យធ្វើឡើងវិញម្តងទៀតទេ ប៉ុន្តែត្រូវបំពេញបញ្ចប់ដោយការវាយតម្លៃមួយ ដោយគ្របដណ្តប់លើផ្នែកដែលមិនបានធ្វើឡើងកាលពីការវាយតម្លៃលើកមុន ជាពិសេសទាក់ទងនឹងការដំឡើងយានយន្តទាំងមូល។

២- ការរៀបចំភាពអនុលោមផលិតផល

២.១- រាល់យានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់ដែលបានអនុលោមស្របតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ដែលមានក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងឆ្នាំ១៩៥៨ ត្រូវផលិតឱ្យស្របទៅតាមប្រភេទដែលបានទទួលអនុលោមភាព ដោយឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិបន្ថែមនេះ និងបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលបានលើកឡើង។

២.២- អាជ្ញាធរផ្ដល់អនុលោមភាពរបស់ភាគីកិច្ចព្រមព្រៀងមួយដែលផ្ដល់អនុលោមភាពចំពោះប្រភេទស្របតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលមានក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងឆ្នាំ១៩៥៨ ត្រូវបញ្ជាក់ពីអត្ថិភាពនៃការរៀបចំដែលមានលក្ខណៈគ្រប់គ្រាន់ និងផែនការគ្រប់គ្រងត្រួតពិនិត្យជាលាយលក្ខណ៍អក្សរ ដោយស្របទៅនឹងរោងចក្រផលិត/ក្រុមហ៊ុនផលិតសម្រាប់ការផ្ដល់អនុលោមភាពនីមួយៗ ដើម្បីអនុវត្តនៅចន្លោះពេលជាក់លាក់ណាមួយ នូវការធ្វើតេស្តទាំងនោះ ឬការត្រួតពិនិត្យពាក់ព័ន្ធចាំបាច់ដើម្បីផ្ទៀងផ្ទាត់បញ្ជាក់លើការរក្សាបាននូវភាពអនុលោមនៃប្រភេទដែលបានទទួលអនុលោមភាព ដោយរាប់បញ្ចូលទាំងការធ្វើតេស្តពិសេស ដែលអាចអនុវត្តបាននូវការធ្វើតេស្តដែលមានបញ្ជាក់នៅក្នុងបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលបានលើកឡើង។

២.៣- អ្នកកាន់កាប់អនុលោមភាពចំពោះប្រភេទនៃអង្គការសហប្រជាជាតិចាំបាច់ត្រូវ៖

២.៣.១- ធានានូវអត្ថិភាពនិងការអនុវត្តនូវនីតិវិធីសម្រាប់ការត្រួតពិនិត្យភាពអនុលោមប្រកបដោយប្រសិទ្ធភាពលើផលិតផល(យានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់) ទៅតាមប្រភេទដែលបានទទួលអនុលោមភាព។

២.៣.២- មានលទ្ធភាពធ្វើតេស្ត ឬឧបករណ៍ត្រួតពិនិត្យចាំបាច់សមស្របផ្សេងទៀត សម្រាប់ត្រួតពិនិត្យអំពីភាពអនុលោមនៃប្រភេទដែលបានទទួលអនុលោមភាពនីមួយៗ។

២.៣.៣- ធានាថា ទិន្នន័យនៃលទ្ធផលតេស្តឬការត្រួតពិនិត្យត្រូវបានកត់ត្រា និងធានាថា ឯកសារភ្ជាប់នានានៅតែអាចប្រើប្រាស់បានសម្រាប់រយៈពេលដែលត្រូវបានកំណត់នៅក្នុងការព្រមព្រៀងជាមួយអាជ្ញាធរផ្ដល់អនុលោមភាព។ រយៈពេលនេះមិនត្រូវលើសពី១០ឆ្នាំឡើយ។

២.៣.៤- វិភាគអំពីលទ្ធផលតេស្តនៃប្រភេទនីមួយៗឬការត្រួតពិនិត្យ ក្នុងគោលបំណងដើម្បីផ្ទៀងផ្ទាត់និងធានានូវស្ថិរភាពនៃលក្ខណៈទ្រង់ទ្រាយផលិតផល និងផ្ដល់ការអនុញ្ញាតសម្រាប់ប្រភេទផ្សេងៗនៃផលិតកម្មឧស្សាហកម្ម។

២.៣.៥- ធានាថា គ្រប់ប្រភេទផលិតផលនីមួយៗ យ៉ាងហោចណាស់ ត្រូវឆ្លងកាត់ការត្រួតពិនិត្យដែលមានចែងក្នុងបទប្បញ្ញត្តិបន្ថែមនេះ និងការធ្វើតេស្តដែលបានចែងក្នុងបទប្បញ្ញត្តិអង្គការសហប្រជាជាតិ។

២.៣.៦- ធានាថា សំណុំនៃគំរូឬបំណែកតេស្តណាមួយដែលផ្ដល់ភស្តុតាងនៃភាពមិនអនុលោមតាមប្រភេទនៃការធ្វើតេស្តនៅក្នុងសំណួរនោះ ត្រូវផ្ដល់នូវគំរូនិងការធ្វើតេស្តបន្ថែមទៀត។ រាល់ជំហានចាំបាច់នឹងត្រូវធ្វើឡើងដើម្បីស្ដារឡើងវិញនូវភាពអនុលោមនៃផលិតកម្មដែលត្រូវគ្នា។

៣- ការរៀបចំការផ្ទៀងផ្ទាត់បន្ត

៣.១- អាជ្ញាធរដែលបានផ្ដល់អនុលោមភាពចំពោះប្រភេទរបស់អង្គការសហប្រជាជាតិ អាចផ្ទៀងផ្ទាត់បញ្ជាក់គ្រប់ពេលវេលាអំពីវិធីសាស្ត្រត្រួតពិនិត្យអនុលោមភាពដែលត្រូវបានអនុវត្តនៅក្នុងរោងចក្រផលិតនីមួយៗ។

៣.១.១- ការរៀបចំទូទៅ ត្រូវតាមដានប្រសិទ្ធភាពបន្តនៃនីតិវិធីដែលមានចែងក្នុងកថាខណ្ឌ១និង២(ការវាយតម្លៃបឋមនិងការរៀបចំភាពអនុលោមផលិតផល) នៃបទប្បញ្ញត្តិបន្ថែមនេះ។

៣.១.១.១- សកម្មភាពឃ្លាំមើលដែលធ្វើឡើងដោយអង្គភាពបច្ចេកទេស(មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឬត្រូវបានទទួលស្គាល់តាមលក្ខខណ្ឌក្នុងកថាខណ្ឌ១.៣.១និង១.៣.២) ត្រូវបានទទួលយកជាការបំពេញនូវលក្ខខណ្ឌតម្រូវនៃកថាខណ្ឌ៣.១.១ ទាក់ទងនឹងនីតិវិធីដែលបានបង្កើតឡើងនៅពេលវាយតម្លៃដំបូង។

៣.១.១.២- ភាពញឹកញាប់ជាទូទៅ នៃការផ្ទៀងផ្ទាត់ដោយអាជ្ញាធរផ្តល់អនុលោមភាព (ក្រៅពីការផ្ទៀងផ្ទាត់ដែលមានចែងនៅក្នុងកថាខណ្ឌ៣.១.១.១) ដើម្បីធានាថា រាល់ការត្រួតពិនិត្យទាំងអស់ដែលយោងតាមកថាខណ្ឌ១និង២នៃបទប្បញ្ញត្តិបន្ថែមនេះ ត្រូវបានត្រួតពិនិត្យនៅកំឡុងពេលទៀងទាត់ ដោយឈរលើវិធីសាស្ត្រវាយតម្លៃហានិភ័យដែលស្របជាមួយនឹងស្តង់ដាអន្តរជាតិ ISO 31000:2009 (គោលការណ៍និងការណែនាំការគ្រប់គ្រងហានិភ័យ) ដោយយ៉ាងហោចណាស់រៀងរាល់បីឆ្នាំម្តង។ វិធីសាស្ត្រនេះត្រូវពិចារណាជាពិសេសទៅលើភាពមិនអនុលោមណាមួយដែលបានលើកឡើងដោយភាគីកិច្ចព្រមព្រៀង ដូចមានចែងក្នុងមាត្រា៤ នៃកិច្ចព្រមព្រៀងឆ្នាំ១៩៥៨។

៣.២- រាល់ការពិនិត្យឡើងវិញ កំណត់ត្រានៃការធ្វើតេស្តនិងការត្រួតពិនិត្យ និងកំណត់ត្រាផលិតកម្ម ត្រូវប្រគល់ជូនអធិការកិច្ច ជាពិសេសកំណត់ត្រានៃការធ្វើតេស្តឬការត្រួតពិនិត្យទាំងនោះ ដែលបានចងក្រងជាឯកសារដូចដែលបានចែងក្នុងកថាខណ្ឌ២.២។

៣.៣- អធិការកិច្ចអាចជ្រើសរើសសំណាកចៃដន្យ ដើម្បីតេស្តនៅក្នុងមន្ទីរពិសោធន៍របស់រោងចក្រផលិត/ក្រុមហ៊ុន ឬនៅមជ្ឈមណ្ឌលនៃអង្គភាពបច្ចេកទេស។ នៅក្នុងករណីបែបនេះ មានតែការធ្វើតេស្តជាក់ស្តែងប៉ុណ្ណោះត្រូវបានធ្វើឡើង។ ចំនួនអប្បបរមានៃសំណាកអាចត្រូវបានកំណត់ដោយយោងទៅតាមលទ្ធផលនៃការផ្ទៀងផ្ទាត់បញ្ជាក់ដោយរោងចក្រផលិត។

៣.៤- នៅពេលដែលកម្រិតនៃការត្រួតពិនិត្យមិនបានបំពេញតាមលក្ខខណ្ឌតម្រូវ ឬនៅពេលដែលមានភាពចាំបាច់ដើម្បីផ្ទៀងផ្ទាត់សុពលភាពនៃការធ្វើតេស្តដែលបានអនុវត្តនៅក្នុងកថាខណ្ឌ៣.៣ អធិការកិច្ចត្រូវជ្រើសរើសសំណាក ដើម្បីបញ្ជូនទៅអង្គភាពបច្ចេកទេសសម្រាប់ធ្វើតេស្តជាក់ស្តែង។

៣.៥- នៅពេលដែលរកឃើញថាលទ្ធផលមិនបានបំពេញតាមលក្ខខណ្ឌ នៅកំឡុងពេលធ្វើអធិការកិច្ច ឬតាមដានត្រួតពិនិត្យ អាជ្ញាធរផ្តល់អនុលោមភាពត្រូវធានាថា រាល់ជំហានចាំបាច់នានាត្រូវបានធ្វើឡើងដើម្បីស្តារអនុលោមភាពនៃផលិតកម្មឱ្យបានលឿនតាមដែលអាចធ្វើទៅបាន។

បទប្បញ្ញត្តិបន្ថែមទី២

ផ្នែកទី១ ការវាយតម្លៃ ការចាត់តាំង និងការជូនដំណឹងចំពោះអង្គភាពបច្ចេកទេស

១- ការចាត់តាំងអង្គភាពបច្ចេកទេស

១.១- នៅពេលទទួលបានការចាត់តាំងពីអាជ្ញាធរផ្តល់អនុលោមភាព អង្គភាពបច្ចេកទេសត្រូវអនុលោមទៅតាមបញ្ញត្តិដែលមានចែងនៅក្នុងបទប្បញ្ញត្តិបន្ថែមនេះ។

១.២- អង្គភាពបច្ចេកទេសត្រូវអនុវត្តដោយខ្លួនឯងឬត្រួតពិនិត្យរាល់តេស្តដែលចាំបាច់ ដើម្បីទទួលបានការផ្តល់អនុលោមភាពឬការធ្វើអធិការកិច្ច ដូចមានចែងនៅក្នុងបទប្បញ្ញត្តិអង្គការសហប្រជាជាតិលើកលែងតែមាននីតិវិធីជំនួសណាមួយត្រូវបានអនុញ្ញាត។ អង្គភាពបច្ចេកទេសមិនអាចធ្វើតេស្តឬធ្វើអធិការកិច្ចណាដែលខ្លួនមិនត្រូវបានចាត់តាំងឱ្យធ្វើនោះឡើយ។

ការអនុវត្តរបស់អង្គភាពបច្ចេកទេស និងគុណភាពនៃការធ្វើតេស្តនិងអធិការកិច្ចដែលអង្គភាពបច្ចេកទេសកំពុងអនុវត្ត ត្រូវធានាថា ផលិតផលដែលបានស្នើសុំអនុលោមភាពចំពោះប្រភេទត្រូវបានផ្ទៀងផ្ទាត់សមស្របជាមួយនឹងលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិណាមួយដែលអង្គភាពបច្ចេកទេសនោះត្រូវបានចាត់តាំងឱ្យអនុវត្ត។

១.៣- អង្គភាពបច្ចេកទេសត្រូវបានចាត់តាំង ដោយយោងតាមប្រភេទសកម្មភាពមួយឬច្រើនក្នុងចំណោមបួនដូចខាងក្រោម អាស្រ័យទៅលើសមត្ថភាពជំនាញរបស់ពួកគេ៖

- ក- ប្រភេទក ៖ អង្គភាពបច្ចេកទេសដែលត្រូវអនុវត្តការធ្វើតេស្តដែលបានចែងនៅក្នុងបទប្បញ្ញត្តិអង្គការសហប្រជាជាតិ នៅក្នុងទីតាំងរបស់ពួកគេ។
- ខ- ប្រភេទខ ៖ អង្គភាពបច្ចេកទេសដែលត្រួតពិនិត្យលើការធ្វើតេស្តដែលបានចែងនៅក្នុងបទប្បញ្ញត្តិអង្គការសហប្រជាជាតិ អាចអនុវត្តនៅក្នុងទីតាំងរបស់រោងចក្រផលិតឬនៅក្នុងទីតាំងរបស់ភាគីទីបី។
- គ- ប្រភេទគ ៖ អង្គភាពបច្ចេកទេសដែលវាយតម្លៃនិងតាមដានជាប្រចាំនូវនីតិវិធីរបស់រោងចក្រផលិតក្នុងការគ្រប់គ្រងភាពអនុលោមនៃផលិតកម្ម។
- ឃ- ប្រភេទឃ ៖ អង្គភាពបច្ចេកទេសដែលត្រួតពិនិត្យ ឬធ្វើតេស្ត ឬធ្វើអធិការកិច្ចនៅក្នុងក្របខ័ណ្ឌនៃការឃ្លាំមើលភាពអនុលោមនៃផលិតកម្ម។

១.៤- អង្គភាពបច្ចេកទេសត្រូវបង្ហាញពីជំនាញសមស្រប ចំណេះដឹងបច្ចេកទេសជាក់លាក់ និងបទពិសោធសម្បូរបែបនៅក្នុងវិស័យដែលមានចែងក្នុងបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ដែលអង្គភាពបច្ចេកទេសនោះត្រូវបានចាត់តាំងឱ្យអនុវត្ត។

លើសពីនេះទៀត អង្គភាពបច្ចេកទេសត្រូវអនុវត្តតាម ប៉ុន្តែមិនចាំបាច់ត្រូវបានអនុម័តឬទទួលស្គាល់ដោយអនុលោមតាមស្តង់ដាដែលមានរាយក្នុងផ្នែកទី២នៃបទប្បញ្ញត្តិបន្ថែមនេះ ដែលពាក់ព័ន្ធទៅនឹងប្រភេទនៃសកម្មភាព ដែលអង្គភាពបច្ចេកទេសត្រូវបានចាត់តាំងឱ្យអនុវត្ត។

អង្គភាពបច្ចេកទេសត្រូវធានាថា ខ្លួនមិនស្ថិតក្រោមការត្រួតពិនិត្យនិងមិនទទួលរងឥទ្ធិពលពីសំណាក់ភាគីពាក់ព័ន្ធណាមួយ ដែលអាចមានផលប៉ះពាល់ជាអវិជ្ជមានដល់សុចរិតភាព និងគុណភាពនៃការធ្វើតេស្ត និងអធិការកិច្ច។

២១/៨៨

អង្គភាពបច្ចេកទេសត្រូវមានលទ្ធភាពប្រើប្រាស់បរិក្ខារតេស្តនិងឧបករណ៍វាស់ស្ទង់ចាំបាច់នានា ដើម្បីធ្វើការត្រួតពិនិត្យ ឬអនុវត្តការធ្វើតេស្ត ឬអធិការកិច្ច ដូចមានចែងនៅក្នុងបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ដែលអង្គភាពបច្ចេកទេសនោះត្រូវបានចាត់តាំងឱ្យអនុវត្ត។

១.៥- អាជ្ញាធរផ្តល់អនុលោមភាពអាចដើរតួជាអង្គភាពបច្ចេកទេសសម្រាប់សកម្មភាពមួយឬច្រើន ដូចមានចែងក្នុងកថាខណ្ឌ១.៣។ បញ្ញត្តិនៃបទប្បញ្ញត្តិបន្ថែមឬវិធានដែលមានតម្លៃស្មើទៅនឹងបញ្ញត្តិនៃកថាខណ្ឌ១ ២ និង៣.៤នៃបទប្បញ្ញត្តិបន្ថែមនេះ ត្រូវអនុវត្តតាម នៅក្នុងករណីដែលអាជ្ញាធរផ្តល់អនុលោមភាពដើរតួជាអង្គភាពបច្ចេកទេស ហើយត្រូវបានតែងតាំងដោយច្បាប់ជាតិនៃភាគីកិច្ចព្រមព្រៀងមួយ និងត្រូវបានផ្តល់ហិរញ្ញប្បទានដោយភាគីកិច្ចព្រមព្រៀងនោះ។ វិធានសមមូលទាំងនោះត្រូវធានានូវភាពស្មើគ្នានៃកម្រិតការងារនិងឯករាជ្យភាព។

១.៦- ទោះបីមានកថាខណ្ឌ៣.៣ ក៏រោងចក្រផលិតឬតំណាងដែលដើរតួជំនួស អាចត្រូវបានចាត់តាំងជាអង្គភាពបច្ចេកទេស សម្រាប់សកម្មភាពនានាដែលស្ថិតក្នុងប្រភេទសកម្មភាព ក និងសម្រាប់តែបទប្បញ្ញត្តិអង្គការសហប្រជាជាតិណាដែលបង្កើតជាបញ្ញត្តិសម្រាប់ការចាត់តាំងនោះប៉ុណ្ណោះ។ ក្នុងករណីនេះ និងមិនគិតពីកថាខណ្ឌ១.៤ អង្គភាពបច្ចេកទេសនឹងត្រូវទទួលស្គាល់ដោយអនុលោមតាមស្តង់ដាដែលមានចែងក្នុងកថាខណ្ឌ១នៃផ្នែកទី២នៃបទប្បញ្ញត្តិបន្ថែមនេះ។

១.៧- អង្គភាពដែលយោងក្នុងកថាខណ្ឌ១.៥និង១.៦ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃកថាខណ្ឌ១។

២- ការវាយតម្លៃលើជំនាញនៃអង្គភាពបច្ចេកទេស

២.១- ជំនាញនានាដែលបានចែងក្នុងកថាខណ្ឌ១ ត្រូវបង្ហាញនៅក្នុងរបាយការណ៍វាយតម្លៃដែលរៀបចំឡើងដោយអាជ្ញាធរមានសមត្ថកិច្ច។ ជំនាញនេះអាចរួមបញ្ចូលនូវវិញ្ញាបនបត្រនៃការទទួលស្គាល់ ដែលចេញដោយស្ថាប័នទទួលស្គាល់គុណភាព។

២.២- ការវាយតម្លៃដែលចែងក្នុងកថាខណ្ឌ២.១ ត្រូវរៀបចំឡើងដោយយោងតាមបញ្ញត្តិនានាក្នុងផ្នែកទី៣នៃបទប្បញ្ញត្តិបន្ថែមនេះ។

របាយការណ៍វាយតម្លៃត្រូវពិនិត្យឡើងវិញ យ៉ាងយូរបំផុតរយៈពេលបីឆ្នាំ។

២.៣- របាយការណ៍វាយតម្លៃ ត្រូវបញ្ជូនទៅលេខាធិការដ្ឋាននៃគណៈកម្មការសេដ្ឋកិច្ចអង្គការសហប្រជាជាតិសម្រាប់អឺរ៉ុប និងបញ្ជូនទៅភាគីកិច្ចព្រមព្រៀង បើសិនមានការស្នើសុំ។

២.៤- អាជ្ញាធរផ្តល់អនុលោមភាព ដែលដើរតួជាអង្គភាពបច្ចេកទេស ត្រូវបង្ហាញភាពអនុលោមតាមរយៈភស្តុតាងជាឯកសារ។

ភស្តុតាងទាំងនេះ រួមមានការវាយតម្លៃដែលត្រូវរៀបចំឡើងដោយសវនករឯករាជ្យពីសកម្មភាពនានាដែលត្រូវបានវាយតម្លៃ។ សវនករទាំងនេះអាចមកពីអង្គភាពតែមួយ ក្នុងករណីដែលពួកគេមានឯករាជ្យភាពពីបុគ្គលិកអនុវត្តសកម្មភាពដែលទទួលការវាយតម្លៃ។

២.៥- រោងចក្រផលិតឬតំណាងដែលត្រូវបានចាត់តាំងជាអង្គភាពបច្ចេកទេស ត្រូវគោរពតាមបញ្ញត្តិពាក់ព័ន្ធក្នុងកថាខណ្ឌ២។

៣- នីតិវិធីនៃការជូនដំណឹង

៣.១- ភាគីកិច្ចព្រមព្រៀងត្រូវជូនដំណឹងទៅលេខាធិការដ្ឋាននៃគណៈកម្មការសេដ្ឋកិច្ចអង្គការសហប្រជាជាតិសម្រាប់អឺរ៉ុបនូវឈ្មោះ អាសយដ្ឋាន រួមទាំងអ៊ីមែល និងប្រភេទសកម្មភាពនៃអង្គភាពបច្ចេកទេស

នីមួយៗដែលបានចាត់តាំង។ ភាគីកិច្ចព្រមព្រៀងក៏ត្រូវជូនដំណឹងដល់លេខាធិការដ្ឋាននៃគណៈកម្មការសេដ្ឋកិច្ចអង្គការសហប្រជាជាតិសម្រាប់អឺរ៉ុបអំពីការកែប្រែនូវព័ត៌មាន ដូចបានរៀបរាប់ខាងលើជាបន្តបន្ទាប់ផងដែរ។

ការជូនដំណឹងត្រូវបញ្ជាក់ថា តើបទប្បញ្ញត្តិអង្គការសហប្រជាជាតិណាមួយដែលអង្គភាពបច្ចេកទេសត្រូវបានកំណត់ឱ្យអនុវត្ត។

៣.២- អង្គភាពបច្ចេកទេសអាចអនុវត្តសកម្មភាពដែលមានចែងនៅក្នុងកថាខណ្ឌ១ ក្នុងគោលបំណងនៃការស្នើសុំអនុលោមភាពចំពោះប្រភេទរបស់អង្គការសហប្រជាជាតិ តែក្នុងករណីណាដែលអង្គភាពនោះបានជូនដំណឹងទៅលេខាធិការដ្ឋាននៃគណៈកម្មការសេដ្ឋកិច្ចអង្គការសហប្រជាជាតិសម្រាប់អឺរ៉ុបប៉ុណ្ណោះ។

៣.៣- អង្គភាពបច្ចេកទេសតែមួយអាចត្រូវបានចាត់តាំងនិងជូនដំណឹងដោយភាគីនៃកិច្ចព្រមព្រៀងលើសពីមួយ ដោយមិនគិតពីប្រភេទសកម្មភាពដែលអង្គភាពនោះអនុវត្ត។

៣.៤- លេខាធិការដ្ឋាននៃគណៈកម្មការសេដ្ឋកិច្ចអង្គការសហប្រជាជាតិសម្រាប់អឺរ៉ុប ត្រូវផ្សព្វផ្សាយបញ្ជីរាយនាមនិងព័ត៌មានទំនាក់ទំនងរបស់អាជ្ញាធរផ្តល់អនុលោមភាព និងអង្គភាពបច្ចេកទេសនៅលើគេហទំព័ររបស់ខ្លួន។

ផ្នែកទី២ ស្តង់ដាដែលត្រូវគោរពតាម សម្រាប់អង្គភាពបច្ចេកទេសដែលបានកំណត់ក្នុងផ្នែកទី១នៃបទប្បញ្ញត្តិបន្ថែមនេះ

១- សកម្មភាពនានានៃការធ្វើតេស្តសម្រាប់ការផ្តល់អនុលោមភាពចំពោះប្រភេទស្របតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិ

១.១- ប្រភេទ ក (ការធ្វើតេស្តនៅទីតាំងផ្ទាល់ខ្លួន)

ស្តង់ដា ISO/IEC 17025:2005 ស្តីពីលក្ខខណ្ឌតម្រូវទូទៅចំពោះសមត្ថភាពនៃមន្ទីរពិសោធន៍តេស្ត និងព្យាសកម្ម។

អង្គភាពបច្ចេកទេសដែលទទួលបានការចាត់តាំងសម្រាប់ប្រភេទសកម្មភាព ក អាចអនុវត្តឬត្រួតពិនិត្យការធ្វើតេស្ត ដោយយោងតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ដែលអង្គភាពនោះត្រូវបានចាត់តាំងឱ្យអនុវត្ត នៅក្នុងទីតាំងនៃរោងចក្រផលិតឬទីតាំងនៃតំណាងរបស់ខ្លួន។

១.២- ប្រភេទ ខ (ត្រួតពិនិត្យការធ្វើតេស្តដែលធ្វើឡើងនៅក្នុងទីតាំងនៃរោងចក្រផលិតឬនៃតំណាងរបស់ខ្លួន)

ស្តង់ដា ISO/IEC 17020:2012 ស្តីពីលក្ខណវិនិច្ឆ័យទូទៅ ចំពោះប្រតិបត្តិការនៃប្រភេទអង្គភាពផ្សេងៗគ្នា ដែលអនុវត្តការធ្វើអធិការកិច្ច។

មុនពេលអនុវត្តឬត្រួតពិនិត្យតេស្តនានា នៅក្នុងទីតាំងនៃរោងចក្រផលិតឬនៃតំណាងរបស់ខ្លួន អង្គភាពបច្ចេកទេសត្រូវបញ្ជាក់ថា បរិក្ខារធ្វើតេស្តនិងឧបករណ៍វាស់វែងនានា អនុលោមតាមលក្ខខណ្ឌតម្រូវសមស្របដូចមានចែងក្នុងកថាខណ្ឌ១.១។

២- សកម្មភាពទាក់ទងទៅនឹងភាពអនុលោមនៃផលិតកម្ម

២.១- ប្រភេទ គ (នីតិវិធីក្នុងការវាយតម្លៃដំបូងនិងសវនកម្មឃ្លាំមើលនៃប្រព័ន្ធគ្រប់គ្រងគុណភាពរោងចក្រផលិត)

ស្តង់ដា ISO/IEC 17021:2015 ស្តីពីលក្ខខណ្ឌតម្រូវចំពោះអង្គភាពផ្តល់សវនកម្មនិងវិញ្ញាបនបត្រនៃប្រព័ន្ធគ្រប់គ្រង។

២.២- ប្រភេទ ឃ (ការធ្វើអធិការកិច្ច ឬការធ្វើតេស្តលើសំណាកផលិតកម្ម ឬការត្រួតពិនិត្យលើការធ្វើតេស្តនោះ)

ស្តង់ដា ISO/IEC 17020:2012 ស្តីពីលក្ខណវិនិច្ឆ័យទូទៅចំពោះប្រតិបត្តិការនៃប្រភេទអង្គភាពផ្សេងៗគ្នាដែលអនុវត្តការធ្វើអធិការកិច្ច។

ផ្នែកទី៣ នីតិវិធីសម្រាប់ការវាយតម្លៃអង្គភាពបច្ចេកទេស

១- គោលបំណង

១.១- ផ្នែកនេះនៃបទប្បញ្ញត្តិបន្ថែមទី២ បង្កើតឱ្យមាននូវលក្ខខណ្ឌដែលអាជ្ញាធរមានសមត្ថកិច្ចរៀបចំនីតិវិធីវាយតម្លៃចំពោះអង្គភាពបច្ចេកទេស ដូចមានចែងក្នុងកថាខណ្ឌ២ ក្នុងផ្នែក១នៃបទប្បញ្ញត្តិបន្ថែមនេះ។

១.២- លក្ខខណ្ឌតម្រូវទាំងនេះត្រូវអនុវត្តចំពោះអង្គភាពបច្ចេកទេសដោយមិនគិតពីបុគ្គលិកលក្ខណៈគតិយុត្តរបស់ស្ថាប័នទាំងនោះ (ស្ថាប័នឯករាជ្យ រោងចក្រផលិត ឬអាជ្ញាធរផ្តល់អនុលោមភាពដែលដើរតួជាអង្គភាពបច្ចេកទេស) នៅពេលចាំបាច់។

២- គោលការណ៍ក្នុងការវាយតម្លៃ

ការវាយតម្លៃត្រូវបានកំណត់ដោយផ្អែកលើគោលការណ៍មួយចំនួន ដូចខាងក្រោម៖

ក- ឯករាជ្យភាពដែលជាមូលដ្ឋានសម្រាប់ភាពមិនលំអៀង និងវត្ថុវិស័យភាពនៃការសន្និដ្ឋាន។

ខ- អភិក្រមត្រូវផ្អែកលើភស្តុតាងដែលធានាលើការសន្និដ្ឋានដែលអាចជឿទុកចិត្តនិងអាចធ្វើឡើងវិញបាន។

សវនករទាំងឡាយត្រូវបង្ហាញសេចក្តីជឿទុកចិត្តនិងសុចរិតភាព ហើយត្រូវរក្សាការសម្ងាត់និងឆន្ទានុសិទ្ធិ។ សវនករទាំងនោះត្រូវរាយការណ៍អំពីលទ្ធផលនិងការសន្និដ្ឋានប្រកបដោយសច្ចភាពនិងសុក្រឹតភាព។

៣- ជំនាញរបស់សវនករ

៣.១- ការវាយតម្លៃត្រូវធ្វើឡើងដោយសវនករដែលមានចំណេះដឹងផ្នែកបច្ចេកទេស និងរដ្ឋបាលចាំបាច់នានាសម្រាប់ការវាយតម្លៃនោះ។

៣.២- សវនករទាំងឡាយត្រូវទទួលបានការបណ្តុះបណ្តាល ជាពិសេសសម្រាប់សកម្មភាពវាយតម្លៃនានា។ លើសពីនេះទៀត សវនករទាំងនោះត្រូវមានចំណេះដឹងបច្ចេកទេសជាក់លាក់ ពាក់ព័ន្ធនឹងសកម្មភាពនានាដែលអង្គភាពបច្ចេកទេសត្រូវអនុវត្ត។

៣.៣- ទោះបីមានចែងក្នុងកថាខណ្ឌ៣.១ និង ៣.២ ក៏ដោយ ការវាយតម្លៃចែងក្នុងកថាខណ្ឌ២.៥នៃផ្នែកទី១នៃបទប្បញ្ញត្តិបន្ថែមនេះ ត្រូវធ្វើឡើងដោយសវនករដែលឯករាជ្យពីសកម្មភាពដែលខ្លួនវាយតម្លៃ។

៤- ការស្នើសុំក្នុងការទទួលបានការចាត់តាំង

៤.១- អ្នកតំណាងដែលមានការអនុញ្ញាតត្រឹមត្រូវនៃអង្គភាពបច្ចេកទេស ត្រូវដាក់ពាក្យស្នើសុំជាផ្លូវការទៅអាជ្ញាធរមានសមត្ថកិច្ច។ ពាក្យសុំត្រូវរួមបញ្ចូលយ៉ាងហោចណាស់នូវព័ត៌មាន ដូចខាងក្រោម៖

ក- លក្ខណៈទូទៅនៃអង្គភាពបច្ចេកទេស រួមមានអង្គភាពសាជីវកម្ម ឈ្មោះ អាសយដ្ឋាន បុគ្គលិកលក្ខណៈគតិយុត្ត ធនធានមនុស្ស និងបច្ចេកទេស។

ខ- ព័ត៌មានលម្អិត រួមមានប្រវត្តិរូបសង្ខេបរបស់បុគ្គលិកទទួលបន្ទុកលើការធ្វើតេស្ត និង/ឬការធ្វើអធិការកិច្ច និងបុគ្គលិកគ្រប់គ្រងដែលមានជំនាញ ការអប់រំ និងវិជ្ជាជីវៈ។

គ- បន្ថែមពីនេះ អង្គភាពបច្ចេកទេសដែលប្រើប្រាស់វិធីសាស្ត្រធ្វើតេស្តនិម្មិត ត្រូវមានសមត្ថភាពក្នុងការបំពេញការងារដោយប្រើប្រាស់កុំព្យូទ័រ។

ឃ- ព័ត៌មានទូទៅទាក់ទងនឹងអង្គភាពបច្ចេកទេស ដូចជាសកម្មភាពការងារនិងទំនាក់ទំនងផ្ទាល់នៅក្នុងក្រុមហ៊ុនសាជីវកម្មធំៗ ប្រសិនបើមាន និងអាសយដ្ឋាន ទីតាំងនានាដែលស្ថិតនៅក្រោមវិសាលភាពនៃការចាត់តាំង។

ង- ការព្រមព្រៀងដើម្បីបំពេញនូវលក្ខខណ្ឌតម្រូវនានាសម្រាប់ការចាត់តាំងនិងកាតព្វកិច្ចនៃអង្គភាពបច្ចេកទេសដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលពាក់ព័ន្ធ។

ច- ការពិពណ៌នានៃសេវាវាយតម្លៃលើភាពអនុលោមដែលអង្គភាពបច្ចេកទេសត្រូវបំពេញតាមក្របខ័ណ្ឌនៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលពាក់ព័ន្ធ និងបញ្ជីនៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលអង្គភាពបច្ចេកទេសដាក់ស្នើសុំដើម្បីទទួលបានការចាត់តាំង រួមទាំងកម្រិតសមត្ថភាពដែលអាចអនុវត្តបាន។

ឆ- ច្បាប់ចម្លងនៃសៀវភៅណែនាំស្តីពីការធានាគុណភាពឬវិធានប្រតិបត្តិការប្រហាក់ប្រហែលនៃអង្គភាពបច្ចេកទេស។

៤.២- អាជ្ញាធរមានសមត្ថកិច្ចត្រូវពិនិត្យចំពោះភាពគ្រប់គ្រាន់នៃព័ត៌មាន ដែលផ្តល់ជូនដោយអង្គភាពបច្ចេកទេស។

៤.៣- អង្គភាពបច្ចេកទេសត្រូវជូនដំណឹងទៅអាជ្ញាធរផ្តល់អនុលោមភាពអំពីការកែតម្រូវណាមួយទៅលើព័ត៌មានដែលបានផ្តល់ ស្របតាមកថាខណ្ឌ៤.១។

៥- ការពិនិត្យលើធនធាន

អាជ្ញាធរមានសមត្ថកិច្ចត្រូវពិនិត្យលើសមត្ថភាពក្នុងការវាយតម្លៃទៅលើអង្គភាពបច្ចេកទេស រួមមានគោលនយោបាយរបស់ខ្លួន ទាំងសមត្ថភាព សវនករ និងអ្នកជំនាញឱ្យបានសមស្រប។

៦- អនុកិច្ចសន្យាចំពោះសកម្មភាពវាយតម្លៃ

៦.១- អាជ្ញាធរមានសមត្ថកិច្ចអាចប្រគល់ផ្នែកមួយចំនួននៃការងារវាយតម្លៃបន្តទៅកាន់អាជ្ញាធរដែលទទួលបានការចាត់តាំងដទៃទៀត ឬស្នើសុំការគាំទ្រពីអ្នកជំនាញបច្ចេកទេសដែលផ្តល់ជូនដោយអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត។ អ្នកទទួលយកអនុកិច្ចសន្យានិងអ្នកជំនាញការទាំងនោះ ត្រូវមានការឯកភាពពីអង្គភាពបច្ចេកទេសដែលដាក់ពាក្យស្នើសុំ។

៦.២- អាជ្ញាធរមានសមត្ថកិច្ចត្រូវពិចារណាលើវិញ្ញាបនបត្រទទួលស្គាល់គុណភាព ជាមួយនឹងវិសាលភាពសមស្រប ដើម្បីអាចបំពេញការវាយតម្លៃជាសកលចំពោះអង្គភាពបច្ចេកទេស។

៧- ការត្រៀមរៀបចំសម្រាប់ការវាយតម្លៃ

៧.១- អាជ្ញាធរមានសមត្ថកិច្ចត្រូវរៀបចំក្រុមវាយតម្លៃមួយជាផ្លូវការ។ អាជ្ញាធរនោះត្រូវធានាថា អ្នកជំនាញឯកទេសដែលត្រូវបានប្រគល់កិច្ចការឱ្យ មានសមត្ថភាពសមស្របក្នុងការបំពេញកិច្ចការនីមួយៗ។ ជាពិសេស ក្រុមការងារទាំងមូល៖

ក- ត្រូវមានចំណេះជំនាញជាក់លាក់សមស្រប ជាពិសេសលើវិសាលភាពនៃការជ្រើសតាំងអង្គភាពបច្ចេកទេស។

ខ- ត្រូវមានការយល់ដឹងគ្រប់គ្រាន់ ដើម្បីវាយតម្លៃប្រកបដោយភាពជឿទុកចិត្តចំពោះសមត្ថភាពនៃអង្គភាពបច្ចេកទេសដែលបំពេញការងារក្នុងវិសាលភាពនៃការជ្រើសតាំង។

៧.២- អាជ្ញាធរមានសមត្ថកិច្ចត្រូវកំណត់ឱ្យច្បាស់នូវកិច្ចការដែលបានប្រគល់ឱ្យក្រុមវាយតម្លៃ។ ភារកិច្ចរបស់ក្រុមវាយតម្លៃ គឺត្រួតពិនិត្យនូវឯកសារដែលប្រមូលបានពីបេក្ខភាពនៃអង្គភាពបច្ចេកទេសដែលដាក់ពាក្យស្នើសុំ និងដើម្បីធ្វើការវាយតម្លៃនៅនឹងកន្លែង។

៧.៣- អាជ្ញាធរមានសមត្ថកិច្ចត្រូវព្រមព្រៀងជាមួយអង្គភាពបច្ចេកទេស និងក្រុមវាយតម្លៃដែលបានកំណត់នូវកាលបរិច្ឆេទនិងកាលវិភាគសម្រាប់ការវាយតម្លៃ។ យ៉ាងណាក៏ដោយ អាជ្ញាធរមានសមត្ថកិច្ចនៅតែទទួលខុសត្រូវ ក្នុងការសម្រេចជ្រើសរើសយកកាលបរិច្ឆេទណាមួយ ដោយយោងតាមផែនការឃ្លាំមើល និងវាយតម្លៃឡើងវិញ។

៧.៤- អាជ្ញាធរមានសមត្ថកិច្ចត្រូវធានាថា ក្រុមវាយតម្លៃត្រូវបានផ្តល់ជូននូវសំណុំឯកសារវិនិច្ឆ័យសមស្របរបាយការណ៍វាយតម្លៃពីមុន និងឯកសារកំណត់ត្រាពាក់ព័ន្ធនៃអង្គភាពបច្ចេកទេស។

៨- ការវាយតម្លៃនៅនឹងកន្លែង

ក្រុមវាយតម្លៃត្រូវរៀបចំការវាយតម្លៃលើអង្គភាពបច្ចេកទេស នៅក្នុងបរិវេណរបស់អង្គភាពដែលជាទីកន្លែងអនុវត្តសកម្មភាពសំខាន់ៗមួយឬច្រើន ហើយត្រូវធ្វើការវាយតម្លៃដោយផ្ទាល់ភ្នែកនៅទីតាំងដែលបានជ្រើសរើសដទៃទៀត ជាទីកន្លែងដែលអង្គភាពបច្ចេកទេសដំណើរការការងាររបស់ខ្លួន។

៩- ការវិភាគលើលទ្ធផលនិងរបាយការណ៍វាយតម្លៃ

៩.១- ក្រុមវាយតម្លៃត្រូវវិភាគរាល់ព័ត៌មាននិងភស្តុតាងពាក់ព័ន្ធទាំងឡាយដោយពិនិត្យមើលលើឯកសារកំណត់ត្រា និងការវាយតម្លៃនៅនឹងកន្លែង។ ការវិភាគនេះត្រូវមានលក្ខណៈគ្រប់គ្រាន់ដើម្បីឱ្យក្រុមវាយតម្លៃអាចកំណត់វិសាលភាពនៃសមត្ថភាពនិងអនុលោមភាពនៃអង្គភាពបច្ចេកទេសទៅនឹងលក្ខខណ្ឌតម្រូវសម្រាប់ការជ្រើសតាំង។

៩.២- នីតិវិធីនៃការរាយការណ៍របស់អាជ្ញាធរមានសមត្ថកិច្ចត្រូវធានាថា លក្ខខណ្ឌខាងក្រោមត្រូវបានបំពេញ។

៩.២.១- កិច្ចប្រជុំមួយត្រូវធ្វើឡើងរវាងក្រុមវាយតម្លៃនិងអង្គភាពបច្ចេកទេស មុនពេលចាកចេញពីកន្លែងវាយតម្លៃនោះ។ នៅក្នុងកិច្ចប្រជុំនេះ ក្រុមវាយតម្លៃត្រូវផ្តល់ជូននូវរបាយការណ៍ជាលាយលក្ខណ៍អក្សរ និង/ឬផ្ទាល់មាត់អំពីលទ្ធផលដែលទទួលបានពីការវិភាគនោះ។ អង្គភាពបច្ចេកទេសត្រូវមានឱកាសចោទសួរអំពីលទ្ធផលទាំងនោះ រួមទាំងភាពមិនអនុលោម បើមាន និងអំណះអំណាង។

៩.២.២- របាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីលទ្ធផលនៃការវាយតម្លៃ ត្រូវប្រគល់ជូនភ្លាមៗដល់អង្គភាពបច្ចេកទេស។ របាយការណ៍វាយតម្លៃត្រូវផ្តល់មតិយោបល់ទៅលើសមត្ថភាពនិងអនុលោមភាព និងកំណត់នូវភាពមិនអនុលោម បើមាន ដើម្បីដោះស្រាយឱ្យស្របតាមលក្ខខណ្ឌតម្រូវទាំងអស់នៃការចាត់តាំង។

៩.២.៣- អង្គភាពបច្ចេកទេសត្រូវបានអញ្ជើញឱ្យឆ្លើយតបលើរបាយការណ៍វាយតម្លៃ និងរៀបរាប់អំពីសកម្មភាពជាក់លាក់ដែលបានធ្វើឬគ្រោងនឹងធ្វើដើម្បី ដោះស្រាយភាពមិនអនុលោមណាមួយដែលបានរកឃើញក្នុងរយៈពេលជាក់លាក់ណាមួយ។

៩.៣- អាជ្ញាធរមានសមត្ថកិច្ចត្រូវធានាថា ការឆ្លើយតបរបស់អង្គភាពបច្ចេកទេសមានលក្ខណៈគ្រប់គ្រាន់ និងមានប្រសិទ្ធភាពក្នុងការដោះស្រាយភាពមិនអនុលោម។ ប្រសិនបើការឆ្លើយតបរបស់អង្គភាពបច្ចេកទេសមិនមានលក្ខណៈគ្រប់គ្រាន់ ព័ត៌មានបន្ថែមនឹងត្រូវបានស្នើសុំ។ លើសពីនេះទៀត ភស្តុតាងនៃប្រសិទ្ធភាពនៃការអនុវត្តសកម្មភាពអាចត្រូវបានស្នើសុំ ឬការវាយតម្លៃតាមដានបន្តអាចត្រូវបានធ្វើឡើង ដើម្បីផ្ទៀងផ្ទាត់ប្រសិទ្ធភាពនៃការអនុវត្តសកម្មភាពកែតម្រូវ។

៩.៤- របាយការណ៍វាយតម្លៃ ត្រូវមាន៖

- ក- ការកំណត់អត្តសញ្ញាណពិសេសផ្ទាល់ខ្លួននៃអង្គភាពបច្ចេកទេស។
- ខ- កាលបរិច្ឆេទនៃការវាយតម្លៃនៅនឹងកន្លែង។
- គ- ឈ្មោះនៃសវនករនិង/ឬអ្នកជំនាញពាក់ព័ន្ធនឹងការវាយតម្លៃ។
- ឃ- ការកំណត់អត្តសញ្ញាណពិសេសនៃទីតាំងអង្គភាពបច្ចេកទេស។
- ង- វិសាលភាពនៃតួនាទីដែលត្រូវបានវាយតម្លៃ។
- ច- សេចក្តីថ្លែងការណ៍ស្តីពីដំណើរការរៀបចំនិងនីតិវិធីផ្ទៃក្នុងមានភាពគ្រប់គ្រាន់ដែលត្រូវបានអនុម័តដោយអង្គភាពបច្ចេកទេស ដែលបង្ហាញការគាំទ្រដល់សមត្ថភាពរបស់អង្គភាពបច្ចេកទេស ដូចបានចែងនៅក្នុងលក្ខខណ្ឌតម្រូវសម្រាប់កំណត់តួនាទី។
- ឆ- ព័ត៌មានស្តីពីការដោះស្រាយភាពមិនអនុលោមទាំងអស់។
- ជ- អនុសាសន៍ថា តើអង្គភាពបច្ចេកទេសដែលបានដាក់ពាក្យស្នើសុំគួរតែត្រូវបានចាត់តាំង ឬបញ្ជាក់ថាជាអង្គភាពបច្ចេកទេសពេញសិទ្ធិ និងវិសាលភាពនៃតួនាទី។

១០- ការផ្តល់/ការបញ្ជាក់លើការចាត់តាំង

១០.១- អាជ្ញាធរផ្តល់អនុលោមភាពត្រូវធ្វើការសម្រេចភ្លាមៗថា តើត្រូវផ្តល់ បញ្ជាក់ ពង្រីកការចាត់តាំងដោយយោងលើរបាយការណ៍នានានិងព័ត៌មានពាក់ព័ន្ធដទៃផ្សេងទៀត។

១០.២- អាជ្ញាធរផ្តល់អនុលោមភាពត្រូវផ្តល់វិញ្ញាបនបត្រទៅកាន់អង្គភាពបច្ចេកទេស។ វិញ្ញាបនបត្រនេះត្រូវកំណត់ព័ត៌មាន ដូចខាងក្រោម៖

- ក- អត្តសញ្ញាណនិងឡូហ្គោរបស់អាជ្ញាធរផ្តល់អនុលោមភាព។
- ខ- អត្តសញ្ញាណផ្ទាល់ខ្លួននៃអង្គភាពបច្ចេកទេសដែលទទួលបានការចាត់តាំង។
- គ- កាលបរិច្ឆេទចូលជាធរមាននៃការចាត់តាំងនិងកាលបរិច្ឆេទផុតកំណត់។
- ឃ- ការចង្អុលបង្ហាញដោយសង្ខេបឬឯកសារយោងអំពីវិសាលភាពនៃការចាត់តាំង (បទប្បញ្ញត្តិអង្គការសហប្រជាជាតិពាក់ព័ន្ធឬផ្នែកនៃបទប្បញ្ញត្តិនោះ)។
- ង- សេចក្តីថ្លែងការណ៍នៃភាពអនុលោមនិងឯកសារយោងទៅលើបទប្បញ្ញត្តិបន្ថែមនេះ។

១១- ការវាយតម្លៃឡើងវិញនិងការឃ្លាំមើល

១១.១- ការវាយតម្លៃឡើងវិញ មានលក្ខណៈស្រដៀងគ្នាទៅនឹងការវាយតម្លៃបឋម លើកលែងតែបទពិសោធដែលទទួលបានក្នុងកំឡុងពេលវាយតម្លៃមុនៗ ត្រូវយកមកពិចារណា។ ការវាយតម្លៃនៅនឹងកន្លែងទៅលើការឃ្លាំមើលមានវិសាលភាពតូចជាងការវាយតម្លៃឡើងវិញ។

១១.២- អាជ្ញាធរមានសមត្ថកិច្ចត្រូវរៀបចំផែនការរបស់ខ្លួនសម្រាប់ការវាយតម្លៃឡើងវិញ និងការឃ្លាំមើលចំពោះអង្គភាពបច្ចេកទេសនីមួយៗដែលបានចាត់តាំង ដើម្បីធានាថា សំណាកគំរូនៃវិសាលភាពតួនាទីត្រូវបានវាយតម្លៃជាប្រចាំ។

មិនថាជាការវាយតម្លៃឡើងវិញឬការឃ្លាំមើល ចន្លោះពេលជាក់លាក់រវាងការវាយតម្លៃនៅនឹងកន្លែងនីមួយៗ គឺអាស្រ័យលើកស្ថុតាងនៃស្ថិរភាពរបស់អង្គភាពបច្ចេកទេស។

១១.៣- នៅពេលភាពមិនអនុលោមត្រូវបានរកឃើញ នៅកំឡុងពេលឃ្លាំមើលឬវាយតម្លៃឡើងវិញ អាជ្ញាធរមានសមត្ថកិច្ចត្រូវកំណត់ពេលវេលាជាក់លាក់សម្រាប់អនុវត្តសកម្មភាពកែតម្រូវ។

១១.៤- នៅពេលសកម្មភាពកែតម្រូវឬកែលម្អទាំងឡាយមិនទាន់ត្រូវបានធ្វើឡើងតាមពេលវេលាកំណត់ដែលបានព្រមព្រៀងឬមិនទាន់ចាត់ទុកថាគ្រប់គ្រាន់ អាជ្ញាធរមានសមត្ថកិច្ចត្រូវអនុម័តចាត់វិធានការសមស្រប ដូចជាធ្វើការវាយតម្លៃបន្ថែម ព្យួរ ឬដកហូតការចាត់តាំងចំពោះសកម្មភាពមួយឬច្រើនដែលអង្គភាពបច្ចេកទេសទទួលបានការចាត់តាំងឱ្យធ្វើកន្លងមក។

១១.៥- នៅពេលអាជ្ញាធរមានសមត្ថកិច្ចសម្រេចថាត្រូវព្យួរឬដកហូតតួនាទីនៃអង្គភាពបច្ចេកទេស អាជ្ញាធរនោះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអង្គភាពបច្ចេកទេសនោះ និងត្រូវជូនដំណឹងទៅលេខាធិការដ្ឋានគណៈកម្មការសេដ្ឋកិច្ចអង្គការសហប្រជាជាតិសម្រាប់អឺរ៉ុប អំពីករណីនោះផងដែរ។ ក្នុងករណីណាក៏ដោយ អាជ្ញាធរមានសមត្ថកិច្ចត្រូវអនុម័តរាល់វិធានការចាំបាច់នានាដើម្បីធានាថាគ្រប់សកម្មភាពដែលបាន និងកំពុងអនុវត្តដោយអង្គភាពត្រួតពិនិត្យបច្ចេកទេសនឹងនៅតែអាចបន្តទៅមុខបាន។

១២- កំណត់ត្រាលើអង្គភាពបច្ចេកទេសដែលបានចាត់តាំង

១២.១- អាជ្ញាធរមានសមត្ថកិច្ចត្រូវរក្សាទុកនូវកំណត់ត្រាចំពោះអង្គភាពបច្ចេកទេស ដើម្បីបង្ហាញថា លក្ខខណ្ឌតម្រូវដើម្បីទទួលបានការចាត់តាំង រួមមានសមត្ថភាពការងារជាដើម ត្រូវបានបំពេញប្រកបដោយប្រសិទ្ធភាព។

១២.២- អាជ្ញាធរមានសមត្ថកិច្ចត្រូវរក្សាទុកកំណត់ត្រានៃអង្គភាពបច្ចេកទេសឱ្យមានសុវត្ថិភាពដើម្បីជានារក្សាការសម្ងាត់។

១២.៣- កំណត់ត្រានៃអង្គភាពបច្ចេកទេស ត្រូវមានៈ

- ក- ការឆ្លើយតបដែលពាក់ព័ន្ធ។
- ខ- កំណត់ត្រានិងរបាយការណ៍នៃការវាយតម្លៃ។
- គ- ច្បាប់ចម្លងវិញ្ញាបនបត្រនៃការចាត់តាំង។

២៩/៤៤

បទប្បញ្ញត្តិបន្ថែមទី៣
នីតិវិធីនៃការទទួលបានអនុលោមភាពចំពោះប្រភេទរបស់អង្គការសហប្រជាជាតិ

១- ការស្នើសុំនិងដំណើរការរៀបចំអនុលោមភាពចំពោះប្រភេទរបស់អង្គការសហប្រជាជាតិ

១.១- ការស្នើសុំសម្រាប់អនុលោមភាពចំពោះប្រភេទរបស់អង្គការសហប្រជាជាតិ ត្រូវដាក់ជូនទៅអាជ្ញាធរផ្តល់អនុលោមភាពនៃភាគីកិច្ចព្រមព្រៀង ដោយរោងចក្រផលិតឬតំណាង(តទៅនេះហៅថា "បេក្ខភាព")។

១.២- មានការស្នើសុំតែមួយគត់ដែលអាចដាក់ស្នើសុំសម្រាប់ប្រភេទយានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់ជាក់លាក់ណាមួយ ហើយការស្នើសុំនោះត្រូវដាក់ជូនទៅភាគីកិច្ចព្រមព្រៀងតែមួយគត់ដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ស្របទៅនឹងអនុលោមភាពចំពោះប្រភេទរបស់អង្គការសហប្រជាជាតិដែលបានស្នើសុំនោះ។ ការស្នើសុំដាច់ដោយឡែកមួយច្បាប់ ត្រូវដាក់ពាក្យស្នើសុំ ដើម្បីទទួលបានអនុលោមភាពទៅលើប្រភេទនីមួយៗ។

១.៣- ការស្នើសុំអនុលោមភាពចំពោះប្រភេទត្រូវភ្ជាប់មកជាមួយនូវព័ត៌មានដូចមានចែងក្នុងបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ស្របទៅនឹងអនុលោមភាពដែលបានស្នើសុំ។ ព័ត៌មានទាំងនេះត្រូវរៀបរាប់លម្អិតទៅលើប្រភេទដែលស្នើសុំអនុលោមភាព រួមមានទាំងការគំនូសប្លង់ ដ្យាក្រាម និងរូបភាពនានាដែលចាំបាច់។

១.៤- នៅពេលមានសំណូមពរសមស្របណាមួយ អាជ្ញាធរផ្តល់អនុលោមភាពអាចស្នើឱ្យបេក្ខភាពផ្តល់នូវព័ត៌មានបន្ថែមចាំបាច់ ដើម្បីអាចធ្វើការសម្រេចលើតេស្តផ្តល់អនុលោមភាពដែលតម្រូវឬសម្រួលដល់ការធ្វើតេស្តទាំងនោះ។

១.៥- បេក្ខភាពត្រូវផ្តល់ជូនអាជ្ញាធរផ្តល់អនុលោមភាពនូវយានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់តាមការចាំបាច់សម្រាប់ការធ្វើតេស្តដែលតម្រូវដោយបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ស្របទៅនឹងអនុលោមភាពដែលបានស្នើសុំនោះ។

១.៦- ភាពអនុលោមតាមលក្ខខណ្ឌតម្រូវដែលមានចែងក្នុងបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ត្រូវបង្ហាញតាមរយៈមធ្យោបាយនៃការធ្វើតេស្តសមស្របនានាទៅលើយានយន្ត បរិក្ខារ និងគ្រឿងបន្លាស់ដែលតំណាងឱ្យប្រភេទដែលស្នើសុំអនុលោមភាព។

អាជ្ញាធរផ្តល់អនុលោមភាពត្រូវអនុវត្តគោលការណ៍ "ករណីកម្រិតទាបបំផុត" ដោយជ្រើសរើសយកប្រភេទផ្សេងៗគ្នា ឬកំណែណាមួយពីប្រភេទដែលបានកំណត់សម្រាប់ធ្វើតេស្ត ដែលនឹងតំណាងឱ្យប្រភេទដែលដាក់ស្នើសុំផ្តល់អនុលោមភាពនៅក្រោមលក្ខខណ្ឌកម្រិតទាបបំផុត។ ការសម្រេចចិត្តរួមជាមួយហេតុផលសមស្របផង នឹងត្រូវកត់ត្រានៅក្នុងឯកសារផ្តល់អនុលោមភាព។

ទោះយ៉ាងណាក៏ដោយ បន្ទាប់ពីមានការឯកភាពគ្នាជាមួយអាជ្ញាធរផ្តល់អនុលោមភាព បេក្ខភាពអាចជ្រើសរើសយានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់ ដែលមិនតំណាងឱ្យប្រភេទដែលស្នើសុំអនុលោមភាព រួមបញ្ចូលគ្នានូវគ្រឿងបង្គុំមួយចំនួនដែលមានលក្ខណៈមិនសមស្របទៅនឹងកម្រិតនៃសមត្ថភាពមុខងារ ដែលតម្រូវដោយបទប្បញ្ញត្តិអង្គការសហប្រជាជាតិ(ករណីកម្រិតទាបបំផុត)។ វិធីសាស្ត្រធ្វើតេស្តនិម្មិត អាចត្រូវបានប្រើប្រាស់ដើម្បីជាជំនួយដល់ការសម្រេចចិត្តជ្រើសរើសនៃករណីកម្រិតទាបបំផុត។

៣០/៤៤

១.៧- តេស្តផ្តល់អនុលោមភាព នឹងត្រូវបានធ្វើឡើងឬត្រួតពិនិត្យដោយអង្គភាពបច្ចេកទេស។ នីតិវិធីនៃការធ្វើតេស្ត និងគ្រឿងឧបករណ៍បរិក្ខារដែលត្រូវប្រើប្រាស់ ត្រូវតែមានកំណត់ក្នុងបទប្បញ្ញត្តិអង្គការសហប្រជាជាតិ។

១.៨- ជំនួសឱ្យនីតិវិធីនៃការធ្វើតេស្តដែលបានលើកឡើងក្នុងកថាខណ្ឌ១.៦ និង១.៧ខាងលើ តេស្តនិម្មិតអាចត្រូវបានធ្វើឡើងទៅតាមសំណូមពរនៃបេក្ខភាព នៅក្នុងកម្រិតមួយដែលការធ្វើតេស្តនោះនៅតែអនុលោមតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិ និងអាស្រ័យលើការបំពេញតាមលក្ខខណ្ឌទូទៅដែលបានចែងក្នុងបទប្បញ្ញត្តិបន្ថែមទី៨ នៅក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងឆ្នាំ១៩៥៨។

១.៩- ភាគីកិច្ចព្រមព្រៀងត្រូវផ្តល់នូវអនុលោមភាពចំពោះប្រភេទ តែក្នុងករណីណាដែលគោរពតាមលក្ខខណ្ឌតម្រូវសម្រាប់ភាពអនុលោមនៃផលិតកម្មនៅក្នុងបទប្បញ្ញត្តិបន្ថែមទី១ ចែងក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងឆ្នាំ១៩៥៨តែប៉ុណ្ណោះ។

១.១០- នៅពេលដែលតេស្តផ្តល់អនុលោមភាពបង្ហាញថា ប្រភេទនោះគោរពតាមលក្ខខណ្ឌតម្រូវផ្នែកបច្ចេកទេសនៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិ អនុលោមភាពមួយនឹងត្រូវបានផ្តល់ជូនជាមួយនឹងការកំណត់នូវលេខសម្គាល់អនុលោមភាពសម្រាប់ប្រភេទផលិតផលនោះ ដោយយោងទៅតាមបទប្បញ្ញត្តិបន្ថែមទី៤ នៅក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងឆ្នាំ១៩៥៨ ហើយសញ្ញាសម្គាល់អនុលោមភាពត្រូវកំណត់ចំពោះប្រភេទនីមួយៗ យោងទៅតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលពាក់ព័ន្ធ។

១.១១- អាជ្ញាធរផ្តល់អនុលោមភាពត្រូវធានាថា ឯកសារផ្តល់អនុលោមភាពមានដាក់បញ្ចូលនូវព័ត៌មានដូចខាងក្រោម៖

ក- កំណត់ត្រាលើការជ្រើសរើសទៅលើករណីកម្រិតទាបបំផុត និងអំណះអំណាងដែលអាចយកពីព័ត៌មានដែលផ្តល់ជូនដោយរោងចក្រផលិតផងដែរ។

ខ- កំណត់ត្រានៃការបកស្រាយលក្ខណៈបច្ចេកទេសសំខាន់ៗណាមួយ រួមទាំងវិធីសាស្ត្រនៃការធ្វើតេស្តផ្សេងៗដែលបានអនុវត្ត និងបច្ចេកវិទ្យាថ្មីដែលយកមកប្រើប្រាស់។

គ- របាយការណ៍នៃការធ្វើតេស្តពីអង្គភាពបច្ចេកទេសដែលរួមមានតួលេខទទួលបានដែលបានកត់ត្រាទុកសម្រាប់ធ្វើការវាស់វែង និងតេស្តដែលតម្រូវដោយបទប្បញ្ញត្តិអង្គការសហប្រជាជាតិ។

ឃ- ឯកសារព័ត៌មានពីរោងចក្រផលិត ដែលមានបញ្ជាក់ត្រឹមត្រូវអំពីស្ថានលក្ខណៈនៃប្រភេទដែលស្នើសុំអនុលោមភាព។

ង- សេចក្តីថ្លែងការណ៍នៃភាពអនុលោមចំពោះលក្ខខណ្ឌតម្រូវសម្រាប់ភាពអនុលោមនៃផលិតកម្មក្នុងបទប្បញ្ញត្តិបន្ថែមទី១ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងឆ្នាំ១៩៥៨ ដោយពណ៌នាជាលម្អិតថា តើការរៀបចំណាមួយដែលចែងក្នុងកថាខណ្ឌ ១.៣ នៃបទប្បញ្ញត្តិបន្ថែមទី១ ត្រូវបានធ្វើជាមូលដ្ឋានសម្រាប់ការវាយតម្លៃបឋម រួមទាំងកាលបរិច្ឆេទនៃការវាយតម្លៃបឋមនោះនិងសកម្មភាពឃ្លាំមើលផ្សេងៗផងដែរ។

ច- វិញ្ញាបនបត្របញ្ជាក់អនុលោមភាពចំពោះប្រភេទ។

២- ការធ្វើវិសោធនកម្មលើអនុលោមភាពចំពោះប្រភេទ

២.១- រោងចក្រផលិតដែលមានអនុលោមភាពចំពោះប្រភេទសម្រាប់យានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់ត្រូវជូនដំណឹងជាបន្ទាន់មកកាន់ភាគីកិច្ចព្រមព្រៀងដែលចេញអនុលោមភាពចំពោះប្រភេទ អំពីការ

កែប្រែនានាទៅលើព័ត៌មានលម្អិតនៃប្រភេទ ដូចដែលបានកត់ត្រាក្នុងព័ត៌មានដែលបានចែងក្នុងកថាខណ្ឌ១.៣។

២.២- ភាគីកិច្ចព្រមព្រៀងត្រូវសម្រេចថាគួរអនុវត្តតាមនីតិវិធីណាមួយរវាងនីតិវិធីពីរក្នុងការធ្វើវិសោធនកម្មលើអនុលោមភាពចំពោះប្រភេទ ដូចដែលមានចែងក្នុងកថាខណ្ឌ២.៥ និង២.៦។ ក្នុងករណីចាំបាច់ ដោយពិគ្រោះយោបល់ជាមួយរោងចក្រផលិត ភាគីកិច្ចព្រមព្រៀងអាចធ្វើការសម្រេចចិត្តថា តើនឹងត្រូវផ្តល់អនុលោមភាពចំពោះប្រភេទថ្មីមួយទៀតដែរឬទេ។

២.៣- ការស្នើសុំធ្វើវិសោធនកម្មអនុលោមភាពចំពោះប្រភេទ អាចដាក់ស្នើជូនតែចំពោះភាគីកិច្ចព្រមព្រៀងដែលចេញអនុលោមភាពចំពោះប្រភេទជាច្បាប់ដើមប៉ុណ្ណោះ។

២.៤- ភាគីកិច្ចព្រមព្រៀងត្រូវជូនដំណឹងដល់រោងចក្រផលិត ករណីដែលភាគីនោះគិតថាចាំបាច់ត្រូវធ្វើអធិការកិច្ច ឬធ្វើតេស្តណាមួយដើម្បីធ្វើវិសោធនកម្មលើអនុលោមភាពចំពោះប្រភេទ។

២.៥- នៅពេលដែលព័ត៌មានលម្អិតនៃប្រភេទផលិតផលដែលបានកត់ត្រានៅក្នុងឯកសារព័ត៌មាន និងរបាយការណ៍តេស្តមានការប្រែប្រួល ហើយភាគីកិច្ចព្រមព្រៀងគិតថា ការប្រែប្រួលនោះមិនប៉ះពាល់អវិជ្ជមានដល់ប្រព័ន្ធសុវត្ថិភាពបរិស្ថាននិង/ឬមុខងារ និងទោះក្នុងករណីណាក៏ដោយ ប្រភេទនោះនៅតែអនុលោមតាមលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលពាក់ព័ន្ធ នោះការកែប្រែនៃអនុលោមភាពចំពោះប្រភេទនោះត្រូវបានកំណត់ជា"ការកែសម្រួលឡើងវិញ" ។

ក្នុងករណីបែបនេះ ភាគីកិច្ចព្រមព្រៀងត្រូវផ្តល់ទំព័រដែលបានកែសម្រួលឡើងវិញនៅក្នុងឯកសារព័ត៌មាននិងក្នុងរបាយការណ៍ធ្វើតេស្តតាមការចាំបាច់ ដោយមានគូសសម្គាល់លើទំព័រកែសម្រួលនីមួយៗដើម្បីបង្ហាញអោយច្បាស់អំពីលក្ខណៈនៃការកែប្រែនិងកាលបរិច្ឆេទនៃការផ្តល់ឱ្យឡើងវិញ។ កំណែនៃឯកសារព័ត៌មាន និងរបាយការណ៍ធ្វើតេស្តដែលបានរួមបញ្ចូលគ្នានិងធ្វើបច្ចុប្បន្នកម្ម អមដោយការពណ៌នាលម្អិតអំពីការកែប្រែ ត្រូវបានចាត់ទុកថាបានបំពេញតាមលក្ខខណ្ឌតម្រូវ។

២.៦- ការធ្វើវិសោធនកម្មទៅលើអនុលោមភាពចំពោះប្រភេទ ត្រូវបានកំណត់ថាជា "ផ្នែកបន្ថែម" ប្រសិនបើបន្ថែមពីលើការកែប្រែលើទិន្នន័យដែលបានកត់ត្រាក្នុងឯកសារព័ត៌មានៈ

ក- ត្រូវធ្វើអធិការកិច្ចឬធ្វើតេស្តបន្ថែម។

ខ- មានការប្រែប្រួលចំពោះព័ត៌មានទាំងឡាយដែលនៅក្នុងឯកសារទំនាក់ទំនង (លើកលែងតែឯកសារភ្ជាប់)។

គ- ការផ្តល់អនុលោមភាពទៅលើការធ្វើវិសោធនកម្មក្រោយៗត្រូវបានស្នើឡើង បន្ទាប់ពីវិសោធនកម្មនោះចូលជាធរមាន ដែលអាចត្រូវបានផ្តល់ជូន ក្នុងករណីដែលការធ្វើវិសោធនកម្មក្រោយៗនោះបានបំពេញតាមលក្ខខណ្ឌតម្រូវ។

២.៧- រាល់ការសម្រេចថាត្រូវទទួលយកឬបដិសេធសំណើសុំធ្វើវិសោធនកម្មលើអនុលោមភាពចំពោះប្រភេទ ដោយមានបញ្ជាក់ពីចំណុចដែលបានកែប្រែ ត្រូវជូនដំណឹងទៅភាគីកិច្ចព្រមព្រៀងឆ្នាំ១៩៥៨ ដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ តាមរយៈមធ្យោបាយទំនាក់ទំនងណាមួយ។ បន្ថែមពីនេះ បញ្ជីនៃឯកសារព័ត៌មាននិងរបាយការណ៍ធ្វើតេស្តដែលមានភ្ជាប់មកជាមួយឯកសារទំនាក់ទំនង ត្រូវធ្វើវិសោធនកម្មទៅតាមអនុលោមភាពចំពោះប្រភេទនោះ ដើម្បីបង្ហាញពីកាលបរិច្ឆេទនៃការកែប្រែឡើងវិញ និងផ្នែកបន្ថែមថ្មីៗចុងក្រោយបង្អស់។

២.៨- អាជ្ញាធរផ្តល់អនុលោមភាពចំពោះប្រភេទ ដែលផ្តល់នូវផ្នែកបន្ថែមនៃអនុលោមភាព ត្រូវធ្វើបច្ចុប្បន្នកម្មទៅលើលេខសម្គាល់អនុលោមភាព ស្របទៅនឹងចំនួននៃផ្នែកបន្ថែមដែលកើនឡើងនោះ ដោយយោងទៅតាមចំនួនផ្នែកបន្ថែមបន្តបន្ទាប់ដែលបានផ្តល់កន្លងមក ស្របតាមបទប្បញ្ញត្តិបន្ថែមទី៤ នៅក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងឆ្នាំ១៩៥៨ និងត្រូវផ្តល់នូវទម្រង់ជូនដំណឹងដែលបានកែប្រែឡើងវិញ ដែលកំណត់ដោយលេខនៃផ្នែកបន្ថែម។

បទប្បញ្ញត្តិបន្ថែមទី៤
ការដាក់លេខសម្គាល់សម្រាប់អនុលោមភាពចំពោះប្រភេទរបស់អង្គការសហប្រជាជាតិ

១- ដោយគិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងឆ្នាំ១៩៥៨ ភាគីកិច្ចព្រមព្រៀងទាំងឡាយត្រូវចេញលេខសម្គាល់អនុលោមភាពចំពោះប្រភេទ ដោយយោងតាមកថាខណ្ឌ១.១០ និង២.៨ នៃបទប្បញ្ញត្តិបន្ថែមទី៣ សម្រាប់អនុលោមភាពចំពោះប្រភេទ និងផ្នែកបន្ថែមថ្មីនីមួយៗនៃការផ្តល់អនុលោមភាពនោះ។

២- ដោយគិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងឆ្នាំ១៩៥៨ និងទោះបីជាបញ្ញត្តិស្តីពីសញ្ញាសម្គាល់អនុលោមភាពមាននៅក្នុងកំណែណាមួយនៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិអាចត្រូវបានចែងខុសពីនេះក៏ដោយ ក៏រោងចក្រផលិតត្រូវភ្ជាប់នូវសញ្ញាសម្គាល់អនុលោមភាពនៅពេលមានការស្នើសុំ ដោយស្របតាមបញ្ញត្តិនានានៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិពាក់ព័ន្ធ ដោយប្រើប្រាស់តួលេខពីរខ្ទង់ដំបូងនៃផ្នែកទី២ និងតួលេខនានានៃផ្នែកទី៣នៃលេខសម្គាល់អនុលោមភាពដែលមានចែងក្នុងបទប្បញ្ញត្តិបន្ថែមនេះ គឺជាលេខសម្គាល់អនុលោមភាពចំពោះយានយន្ត បរិក្ខារ និងគ្រឿងបន្លាស់នីមួយៗ ដែលការផ្តល់អនុលោមភាពថ្មីត្រូវបានផ្តល់ជូនឬត្រូវបានបន្ថែម។ ទោះបីយ៉ាងណាក៏ដោយ បញ្ញត្តិនេះមិនត្រូវបានអនុវត្តឡើយ នៅក្នុងករណីដែលបទប្បញ្ញត្តិអង្គការសហប្រជាជាតិមួយតម្រូវឱ្យមានលេខកូដអនុលោមភាពឬលេខកូដកំណត់អត្តសញ្ញាណ ដើម្បីប្រើប្រាស់នៅក្នុងគំនូសសម្គាល់អនុលោមភាព ជំនួសឱ្យលេខសម្គាល់អនុលោមភាព។ លេខសូន្យពីមុខនៃផ្នែកទី៣អាចត្រូវបានលុបចេញ។

៣- លេខសម្គាល់អនុលោមភាពមួយត្រូវបានរៀបចំផ្តល់ឱ្យប្រភេទនីមួយៗដែលបានទទួលអនុលោមភាព។ លេខសម្គាល់អនុលោមភាពចំពោះប្រភេទត្រូវចែកចេញជា៤ផ្នែក ដោយផ្នែកនីមួយៗត្រូវបានញែកដាច់ពីគ្នាដោយសញ្ញា '*' ។

ផ្នែកទី១ : អក្សរ E បន្ទាប់មក លេខសម្គាល់នៃភាគីកិច្ចព្រមព្រៀងដែលផ្តល់នូវអនុលោមភាពចំពោះប្រភេទ

ផ្នែកទី២ : លេខសម្គាល់បទប្បញ្ញត្តិអង្គការសហប្រជាជាតិពាក់ព័ន្ធ បន្ទាប់មក អក្សរ និងឈរជាប់ពីក្រោយដោយ៖

- ក- តួលេខ២ខ្ទង់(នាំមុខដោយ00) សម្គាល់ស៊េរីនៃការធ្វើវិសោធនកម្ម ដែលមានបញ្ចូលនូវបញ្ញត្តិបច្ចេកទេសនៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិអនុវត្តចំពោះការផ្តល់អនុលោមភាព(00 សម្រាប់បទប្បញ្ញត្តិអង្គការសហប្រជាជាតិនៅក្នុងទម្រង់ដើម)។
- ខ- សញ្ញាចែក "/" និងតួលេខ២ខ្ទង់(នាំមុខដោយ00) សម្គាល់លេខបំពេញបន្ថែមទៅលើស៊េរីនៃការធ្វើវិសោធនកម្មអនុវត្តចំពោះការផ្តល់អនុលោមភាព (00 សម្រាប់ស៊េរីនៃការធ្វើវិសោធនកម្មនៅក្នុងទម្រង់ដើម)។
- គ- សញ្ញាចែក "/" និងតួអក្សរមួយឬពីរ សម្រាប់សម្គាល់ដំណាក់កាលនៃការអនុវត្ត បើពាក់ព័ន្ធ។

ផ្នែកទី៣ : លេខបួនខ្ទង់តាមលំដាប់(នាំមុខដោយ0000)។ លំដាប់លេខត្រូវចាប់ផ្តើមពី0001។

ផ្នែកទី៤ : លេខពីរខ្ទង់តាមលំដាប់(អាចជាលេខ 0 ពីមុខ) តំណាងឱ្យផ្នែកបន្ថែម។ លំដាប់លេខត្រូវចាប់ផ្តើមពី00។ តួលេខគ្រប់ខ្ទង់ទាំងអស់ត្រូវតែជាលេខអារ៉ាប់។

៤- ភាគីកិច្ចព្រមព្រៀងតែមួយមិនត្រូវផ្តល់លេខសម្គាល់ដូចគ្នាទៅលើអនុលោមភាពផ្សេងៗទៀតឡើយ។

ឧទាហរណ៍

ឧទាហរណ៍នៃផ្នែកបន្ថែមលើកទី២ សម្រាប់អនុលោមភាពចំពោះប្រភេទទី៤ ដែលចេញដោយប្រទេសហូឡង់ ដោយយោងតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិលេខ៥៨ ជាកំណែដើម :

E4*58R00/00*0004*02

ឧទាហរណ៍នៃផ្នែកបន្ថែមលើកទី១ សម្រាប់អនុលោមភាពចំពោះប្រភេទទី២៤៣៩ ចេញដោយចក្រភពអង់គ្លេសនិងអៀរឡង់ខាងជើងសម្រាប់ការផ្តល់អនុលោមភាពចំពោះយានយន្ត ដោយយោងទៅតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិលេខ៨៣ ស៊េរីទី៣នៃការធ្វើវិសោធនកម្ម កំណែសម្រាប់យានយន្តប្រភេទM ថ្នាក់N1 I ដែលពាក់ព័ន្ធនឹងការបំភាយឧស្ម័នពុល ស្របតាមលក្ខខណ្ឌតម្រូវនៃប្រេងឥន្ធនៈសម្រាប់ម៉ាស៊ីនៈ

E11*83R03/00/J*2439*01

បទប្បញ្ញត្តិបន្ថែមទី៥
ការផ្សព្វផ្សាយឯកសារផ្តល់អនុលោមភាព

១- ករណីដែលអាជ្ញាធរផ្តល់អនុលោមភាពត្រូវបានទាមទារឱ្យឬទទួលបានការស្នើសុំផ្តល់ច្បាប់ចម្លងនៃការផ្តល់អនុលោមភាពនិងឯកសារភ្ជាប់ អាជ្ញាធរនោះត្រូវផ្ញើឯកសាក្នុងទម្រង់ច្បាប់ចម្លងជាក្រដាស ឬក្នុងទម្រង់សារអេឡិចត្រូនិក ឬទិន្នន័យអ៊ីនធឺណិតដែលមានសុវត្ថិភាព ដែលត្រូវបានបង្កើតឡើងដោយគណៈកម្មការសេដ្ឋកិច្ចរបស់អង្គការសហប្រជាជាតិសម្រាប់អឺរ៉ុប។

២- ឯកសារដែលរក្សាទុកនៅក្នុងទិន្នន័យអ៊ីនធឺណិតដែលមានសុវត្ថិភាព ត្រូវមានយ៉ាងហោចណាស់ឯកសារដែលបានចែងនៅក្នុងបទប្បញ្ញត្តិអង្គការសហប្រជាជាតិនីមួយៗ។ ឯកសារទាំងនេះត្រូវរួមបញ្ចូលទាំងឯកសារដែលបានបញ្ជូនទៅភាគីកិច្ចព្រមព្រៀងស្តីពីសេចក្តីជូនដំណឹងអំពីការផ្តល់អនុលោមភាព ផ្នែកបន្ថែម ការបដិសេធ ឬការដកហូតអនុលោមភាព ឬនៅពេលផលិតកម្មត្រូវបានបញ្ឈប់ទាំងស្រុង ចំពោះប្រភេទណាមួយនៃយានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់ យោងទៅតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិ។

៣- ប្រសិនបើអនុលោមភាពចំពោះប្រភេទអនុវត្តចំពោះយានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់ត្រូវបានដាក់នៅក្នុងទិន្នន័យអ៊ីនធឺណិតដែលមានសុវត្ថិភាព នោះសញ្ញាសម្គាល់អនុលោមភាព តម្រូវដោយបទប្បញ្ញត្តិអង្គការសហប្រជាជាតិ នឹងអាចត្រូវជំនួសដោយកូដពិសេស ឈរពីមុខដោយសញ្ញា (UI) លុះត្រាតែមានការចែងផ្សេងពីនេះនៅក្នុងបទប្បញ្ញត្តិអង្គការសហប្រជាជាតិ។ កូដពិសេសបែបនេះត្រូវបានបង្កើតឡើងដោយទិន្នន័យនោះជាស្វ័យប្រវត្ត។

៤- ភាគីកិច្ចព្រមព្រៀងទាំងអស់ដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ត្រូវទទួលបាននូវព័ត៌មានសម្រាប់បទប្បញ្ញត្តិអង្គការសហប្រជាជាតិនោះដែលបានផ្ទុកនៅក្នុងបណ្តុំទិន្នន័យដោយប្រើប្រាស់កូដពិសេស ហើយមុខងារនេះនឹងផ្តល់លទ្ធភាពដើម្បីទទួលបានព័ត៌មានពាក់ព័ន្ធទៅនឹងការផ្តល់អនុលោមភាពជាក់លាក់ទាំងឡាយ។

៥- បទប្បញ្ញត្តិអង្គការសហប្រជាជាតិមានចែងនៅក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងឆ្នាំ១៩៥៨ អាចតម្រូវឱ្យមានការផ្សព្វផ្សាយនៃអនុលោមភាពចំពោះប្រភេទ តាមរយៈសំណៅថតចម្លងអេឡិចត្រូនិកដោយប្រើប្រាស់ទិន្នន័យអ៊ីនធឺណិតដែលមានសុវត្ថិភាពនៅពេលចាំបាច់ សម្រាប់ដំណើរការផ្តល់អនុលោមភាពប្រកបដោយប្រសិទ្ធភាព អាស្រ័យលើលទ្ធភាពទទួលបានព័ត៌មានដែលកំណត់ដោយភាគីកិច្ចព្រមព្រៀង។

បទប្បញ្ញត្តិបន្ថែមទី៦
នីតិវិធីសម្រាប់ដោះស្រាយបញ្ហាទៅលើការបកស្រាយទាក់ទងនឹងការអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ និងការផ្តល់អនុលោមភាពស្របតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិ

១- បញ្ហានៃការបកស្រាយមុនពេលដែលអនុលោមភាពចំពោះប្រភេទរបស់អង្គការប្រជាជាតិត្រូវបានផ្តល់ជូន

នៅពេលមានការស្នើសុំអនុលោមភាពចំពោះប្រភេទរបស់អង្គការសហប្រជាជាតិ តម្រូវឱ្យអាជ្ញាធរផ្តល់អនុលោមភាពធ្វើការបកស្រាយចាំបាច់លើការអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ឬប្រសិនបើមានសំណើពីបេក្ខភាពសុំអនុលោមភាព អាជ្ញាធរផ្តល់អនុលោមភាពត្រូវជូនដំណឹងនិងស្វែងរកការណែនាំពីអាជ្ញាធរផ្តល់អនុលោមភាពផ្សេងទៀតមុនពេលធ្វើការសម្រេចចិត្ត។

អាជ្ញាធរផ្តល់អនុលោមភាពដែលពាក់ព័ន្ធ ត្រូវជូនដំណឹងដល់អាជ្ញាធរផ្តល់អនុលោមភាពផ្សេងទៀតដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ អំពីបញ្ហានិងដំណោះស្រាយដែលបានលើកឡើងសម្រាប់ការបកស្រាយ ដោយរួមមានទាំងព័ត៌មានគាំទ្រពីរោងចក្រផលិត។ យោងទៅបទប្បញ្ញត្តិទូទៅ បញ្ហានេះគួរតែត្រូវបានធ្វើឡើងតាមរយៈប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក។ អាជ្ញាធរផ្តល់អនុលោមភាពផ្សេងដទៃទៀត ត្រូវធ្វើការឆ្លើយតបក្នុងកំឡុងពេល១៤(ដប់បួន)ថ្ងៃ។

- ក- អាជ្ញាធរផ្តល់អនុលោមភាពត្រូវផ្តល់អនុលោមភាពស្របតាមការបកស្រាយថ្មីនេះ បន្ទាប់ពីបានពិចារណាលើរាល់មតិយោបល់។
- ខ- ប្រសិនបើមិនអាចធ្វើការសម្រេចចិត្តតាមមតិយោបល់ដែលទទួលបាននោះទេ អាជ្ញាធរផ្តល់អនុលោមភាពត្រូវស្វែងរកការបំភ្លឺបន្ថែមទៀត តាមមធ្យោបាយនៃនីតិវិធីដែលមានចែងក្នុងកថាខណ្ឌ៣ ដូចខាងក្រោម។

២- បញ្ហានៃការបកស្រាយ បន្ទាប់ពីការផ្តល់អនុលោមភាពចំពោះប្រភេទ

ក្នុងស្ថានភាពដែលមានការបកស្រាយខុសគ្នាកើតឡើងរវាងភាគីកិច្ចព្រមព្រៀង ប៉ុន្តែការបកស្រាយនោះកើតឡើងក្រោយពីបានផ្តល់អនុលោមភាព នោះនីតិវិធីខាងក្រោមនឹងត្រូវអនុវត្ត។

នៅក្នុងឧទាហរណ៍ទីមួយ ភាគីកិច្ចព្រមព្រៀងដែលពាក់ព័ន្ធត្រូវស្វែងរកដំណោះស្រាយចំពោះបញ្ហាដោយការព្រមព្រៀងទៅវិញទៅមក។ ភាគីកិច្ចព្រមព្រៀងតម្រូវឱ្យមានទំនាក់ទំនងនិងធ្វើការពិនិត្យឡើងវិញនូវនីតិវិធីដែលត្រូវបានប្រើក្នុងការធ្វើតេស្ត និងផ្តល់អនុលោមភាពលើយានយន្តបរិក្ខារ និងគ្រឿងបន្លាស់ដែលជាកម្មវត្ថុនៃការខ្វែងគំនិតលើការបកស្រាយ។

នីតិវិធីខាងក្រោមនឹងត្រូវយកមកអនុវត្តៈ

- ក- ក្នុងករណីដែលកំហុសមួយត្រូវបានទទួលស្គាល់ដោយអាជ្ញាធរផ្តល់អនុលោមភាព អាជ្ញាធរនោះត្រូវចាត់វិធានការស្របតាមបញ្ញត្តិនៃកិច្ចព្រមព្រៀងឆ្នាំ១៩៥៨ និងជាពិសេសមាត្រា៤។
- ខ- នៅពេលឈានដល់ការព្រមព្រៀងដែលទាមទារឱ្យមានការបកស្រាយថ្មីឬការបកស្រាយផ្សេងគ្នានៃការអនុវត្តដែលមានជាធរមាន(ដោយភាគីកិច្ចព្រមព្រៀងណាមួយ) ការបកស្រាយនេះត្រូវបញ្ជូនទៅភាគីកិច្ចព្រមព្រៀងដែលកំពុងអនុវត្ត

៣៧/៤៤

បទប្បញ្ញត្តិអង្គការសហប្រជាជាតិពាក់ព័ន្ធ ជាកិច្ចការបន្ទាន់។ ភាគីដទៃទៀតមានរយៈពេល១៤ថ្ងៃដើម្បីផ្តល់មតិយោបល់លើសេចក្តីសម្រេចនេះ ហើយបន្ទាប់ពីធ្វើការពិចារណាលើរាល់មតិយោបល់ដែលទទួលបាន អាជ្ញាធរផ្តល់អនុលោមភាពអាចផ្តល់អនុលោមភាពចំពោះប្រភេទ ដោយស្របតាមការបកស្រាយថ្មីនោះ។

គ- នៅពេលមិនអាចឈានដល់ការព្រមព្រៀង ភាគីកិច្ចព្រមព្រៀងដែលពាក់ព័ន្ធ ត្រូវស្នើសុំការពិនិត្យបន្ថែមទៀត តាមរយៈដំណើរការមជ្ឈត្តការដែលមានចែងក្នុងកថាខណ្ឌ៣ ខាងក្រោម។

ឃ- ក្នុងករណីណាក៏ដោយ បញ្ហានេះនឹងត្រូវជូនដំណឹងដល់ក្រុមការងារមានសមត្ថកិច្ចដែលចំណុះឱ្យ "វេទិកាពិភពលោកសម្រាប់ការធ្វើសុខដុមនីយកម្មនៃបទប្បញ្ញត្តិយានយន្ត"(WP.29)។ ប្រសិនបើយល់ថាចាំបាច់ ក្រុមការងារចំណុះនោះត្រូវដាក់សំណើទៅ WP.29 នូវការធ្វើវិសោធនកម្មលើបទប្បញ្ញត្តិសមស្របដែលសំដៅដោះស្រាយភាពខុសគ្នានៃការបកស្រាយនោះ។

៣- ដំណើរការមជ្ឈត្តការតាមរយៈ WP.29 និងអនុក្រុមការងារនានារបស់ខ្លួន

ប្រធាននៃអនុក្រុមការងារត្រូវកំណត់បញ្ហាដែលកើតឡើងពីការបកស្រាយខុសៗគ្នារវាងភាគីកិច្ចព្រមព្រៀងទាក់ទងនឹងការអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ និងការផ្តល់អនុលោមភាពចំពោះប្រភេទ ដោយអនុលោមតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ជាមួយនឹងទស្សនៈក្នុងការដាក់ចេញនូវវិធានការនានាឱ្យបានឆាប់បំផុត ចំពោះការដោះស្រាយលើការបកស្រាយខុសគ្នាទាំងនោះ។

ប្រធាននៃអនុក្រុមការងារនឹងរៀបចំបង្កើតនីតិវិធីសមស្របក្នុងការដោះស្រាយបញ្ហាលើការបកស្រាយខុសៗគ្នា ដើម្បីបង្ហាញដល់WP.29 ថា៖

ក- ត្រូវពិចារណាយ៉ាងល្អិតល្អន់លើមតិខុសៗគ្នារបស់អាជ្ញាធរផ្តល់អនុលោមភាពនៃភាគីកិច្ចព្រមព្រៀងដែលពាក់ព័ន្ធ ព្រមទាំងភាគីកិច្ចព្រមព្រៀងដទៃទៀតដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ។

ខ- ការសម្រេចចិត្ត គឺផ្អែកលើការណែនាំផ្នែកបច្ចេកទេសសមស្រប ដោយពិចារណាយ៉ាងពេញលេញទៅលើផ្នែកដែលពាក់ព័ន្ធ។

គ- ការសម្រេចចិត្តជាឯកច្ឆន្ទត្រូវបានធ្វើឡើង នៅពេលដែលអាចធ្វើទៅបាន។

ឃ- នីតិវិធីទាំងឡាយ គឺមានតម្លាភាពនិងអាចធ្វើសវនកម្មបាន។

ប្រសិនបើចាំបាច់ដើម្បីដោះស្រាយបញ្ហា ប្រធានអាចដាក់បញ្ចូលរបៀបវារៈថ្មីចំពោះបញ្ហានេះ ទៅសម័យប្រជុំបន្ទាប់នៃអនុក្រុមការងារ ដោយពុំចាំបាច់សុំការព្រមព្រៀងជាមុនពី WP.29 នោះទេ។ ក្នុងកាលៈទេសៈបែបនេះ ប្រធានត្រូវរាយការណ៍អំពីវឌ្ឍនភាពទៅកាន់ WP.29 ឱ្យបានឆាប់បំផុត។

នៅចុងបញ្ចប់នៃដំណើរការមជ្ឈត្តការ ប្រធានត្រូវផ្តល់របាយការណ៍មួយទៅកាន់ WP.29។

៣.១- ករណីដែលបញ្ហាអាចត្រូវបានដោះស្រាយ នៅក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិដែលមានធរមាន : ការបកស្រាយបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ដូចដែលបានព្រមព្រៀងនៅក្នុងក្រុមការងារ ត្រូវបានអនុវត្ត ហើយអាជ្ញាធរផ្តល់អនុលោមភាពត្រូវចេញអនុលោមភាពចំពោះប្រភេទតាមនោះដែរ។

៣.២- ករណីដែលបញ្ហាមិនអាចដោះស្រាយបាន នៅក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិបច្ចុប្បន្ននោះទេ : WP.29 នឹងត្រូវទទួលបានដំណឹងអំពីកិច្ចការនេះ ហើយត្រូវស្នើសុំក្រុមការងារឱ្យចាត់ទុកបញ្ហានេះ ជាបញ្ហាអាទិភាពនៅសម័យប្រជុំបន្ទាប់។ របៀបវារៈនៃសម័យប្រជុំនឹងត្រូវកែប្រែ ទៅតាមនោះដែរ។

អនុក្រុមការងារត្រូវពិចារណាលើសំណើផ្សេងៗអំពីបញ្ហានៃការបកស្រាយ និងត្រូវដាក់សំណើជាផ្លូវការទៅកាន់WP.29 ដើម្បីធ្វើវិសោធនកម្មបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលបានលើកឡើងដោយអនុវត្តតាមនីតិវិធីសមស្រប។ WP.29 ត្រូវចាត់ទុកបញ្ហានេះជាបញ្ហាអាទិភាពមួយនៅសម័យប្រជុំបន្ទាប់។

បទប្បញ្ញត្តិបន្ថែមទី៧
នីតិវិធីសម្រាប់ការផ្ដល់អនុលោមភាពអនុគ្រោះពាក់ព័ន្ធនឹងបច្ចេកវិទ្យាថ្មីៗ

១- តាមការស្នើសុំដោយរោងចក្រផលិត ភាគីកិច្ចព្រមព្រៀងដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ អាចផ្ដល់អនុលោមភាពអនុគ្រោះ ដោយអនុលោមតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិពាក់ព័ន្ធនឹងយានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់ណាមួយ ដែលរួមបញ្ចូលនូវបច្ចេកវិទ្យាថ្មីៗដែលមិនស្របនឹងលក្ខខណ្ឌតម្រូវមួយឬច្រើននៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិនោះ ដែលគណៈកម្មាធិការរដ្ឋបាលនៃកិច្ចព្រមព្រៀងឆ្នាំ១៩៥៨ ផ្ដល់ជូនតាមនីតិវិធីដូចមានចែងក្នុងកថាខណ្ឌ២ដល់១២នៃបទប្បញ្ញត្តិបន្ថែមនេះ។

២- នៅពេលរង់ចាំការសម្រេច សម្រាប់ការផ្ដល់អនុលោមភាពអនុគ្រោះនេះថាត្រូវបានផ្ដល់ជូនឬយ៉ាងណានោះ ភាគីកិច្ចព្រមព្រៀងដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ អាចផ្ដល់អនុលោមភាពជាបណ្ដោះអាសន្នសម្រាប់តែក្នុងដែនដីរបស់ខ្លួនតែប៉ុណ្ណោះ។ ភាគីកិច្ចព្រមព្រៀងដទៃទៀតដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ អាចសម្រេចចិត្តទទួលយកអនុលោមភាពនេះជាបណ្ដោះអាសន្ននៅក្នុងដែនដីរៀងៗខ្លួន។

៣- ភាគីកិច្ចព្រមព្រៀងដែលផ្ដល់អនុលោមភាពបណ្ដោះអាសន្ន ដូចមានចែងក្នុងកថាខណ្ឌ២នៃបទប្បញ្ញត្តិបន្ថែមនេះ ត្រូវជូនដំណឹងដល់គណៈកម្មាធិការរដ្ឋបាលអំពីការសម្រេចចិត្តរបស់ខ្លួន និងត្រូវភ្ជាប់ឯកសារដូចខាងក្រោម៖

ក- មូលហេតុអ្វីខ្លះដែលបច្ចេកវិទ្យាថ្មីៗឬគោលគំនិតបានលើកឡើង ធ្វើឱ្យយានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់ មិនស្របនឹងលក្ខខណ្ឌតម្រូវនានានៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិ។

ខ- ការរៀបរាប់ពីសុវត្ថិភាព ការការពារបរិស្ថាន ឬការពិចារណាផ្សេងៗទៀត និងវិធានការដែលបានអនុវត្ត។

គ- ការរៀបរាប់ពីការធ្វើតេស្តនិងលទ្ធផលដែលបង្ហាញថា យ៉ាងហោចណាស់សមមូលនឹងកម្រិតសុវត្ថិភាព និងការការពារបរិស្ថាន ត្រូវបានធានា ដោយប្រៀបធៀបនឹងលក្ខខណ្ឌតម្រូវនានាដែលមានចែង។

ឃ- ការស្នើសុំការអនុញ្ញាតផ្ដល់អនុលោមភាពអនុគ្រោះចំពោះបទប្បញ្ញត្តិអង្គការសហប្រជាជាតិសម្រាប់ប្រភេទយានយន្ត បរិក្ខារ ឬគ្រឿងបន្លាស់។

៤- គណៈកម្មាធិការរដ្ឋបាលត្រូវពិចារណាលើការជូនដំណឹង ស្របតាមកថាខណ្ឌ៣នៃបទប្បញ្ញត្តិបន្ថែមនេះនៅក្នុងសម័យប្រជុំបន្ទាប់ ក្រោយពីទទួលបានការជូនដំណឹងយ៉ាងតិចបីខែមុនសម័យប្រជុំ។ បន្ទាប់ពីពិចារណាលើការជូនដំណឹង គណៈកម្មាធិការរដ្ឋបាលអាចសម្រេចផ្ដល់សិទ្ធិឬបដិសេធការផ្ដល់អនុលោមភាពអនុគ្រោះ ឬបញ្ជូនបញ្ហានេះទៅឱ្យអនុក្រុមការងារដែលមានសមត្ថកិច្ច។

៥- សេចក្ដីសម្រេចរបស់គណៈកម្មាធិការរដ្ឋបាលត្រូវបានធ្វើឡើងស្របតាមនីតិវិធីដែលមានចែងនៅក្នុងឧបសម្ព័ន្ធនៃមាត្រា៨។

៦- ស្របតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ដូចមានចែងក្នុងកថាខណ្ឌ៣នៃបទប្បញ្ញត្តិបន្ថែមនេះ ការស្នើសុំអនុលោមភាពអនុគ្រោះនឹងត្រូវបានចាត់ទុកថាបានផ្ដល់ការអនុញ្ញាត លើកលែងតែច្រើន

ជាងមួយភាគប្រាំនៃភាគីកិច្ចព្រមព្រៀងដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ នៅខណៈពេលនៃការជូនដំណឹង បានជម្រាបជូនដល់លេខាធិការប្រតិបត្តិនៃគណៈកម្មការសេដ្ឋកិច្ចរបស់អង្គការសហប្រជាជាតិសម្រាប់អឺរ៉ុប អំពីការជំទាស់របស់ខ្លួនទៅលើការអនុញ្ញាតនៃអនុលោមភាពអនុគ្រោះនោះ ក្នុងកំឡុងពេលមួយខែ គិតចាប់ពីការជូនដំណឹងរបស់លេខាធិការប្រតិបត្តិនៃគណៈកម្មការសេដ្ឋកិច្ចរបស់អង្គការសហប្រជាជាតិសម្រាប់អឺរ៉ុប នៃការសម្រេចចិត្តលើការអនុញ្ញាតរបស់គណៈកម្មាធិការរដ្ឋបាល។

៧- នៅពេលដែលការអនុញ្ញាតផ្តល់អនុលោមភាពអនុគ្រោះត្រូវបានអនុម័ត លេខាធិការប្រតិបត្តិនៃគណៈកម្មការសេដ្ឋកិច្ចអង្គការសហប្រជាជាតិសម្រាប់អឺរ៉ុបត្រូវប្រញាប់ជូនដំណឹងដល់ភាគីកិច្ចព្រមព្រៀងដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិដទៃទៀត ឱ្យបានលឿនតាមដែលអាចធ្វើទៅបាន។

គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹង ភាគីកិច្ចព្រមព្រៀងដែលបានចែងក្នុងកថាខណ្ឌ៣នៃបទប្បញ្ញត្តិបន្ថែមនេះអាចផ្តល់អនុលោមភាពអនុគ្រោះ ដោយស្របតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិ។ អនុលោមភាពអនុគ្រោះត្រូវបានទទួលយកដោយភាគីកិច្ចព្រមព្រៀងដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ លើកលែងតែភាគីណាបានជូនដំណឹង ជំទាស់ ឬការមិនទទួលយកអនុលោមភាពអនុគ្រោះនោះភ្លាមៗ ទៅលេខាធិការប្រតិបត្តិនៃគណៈកម្មការសេដ្ឋកិច្ចរបស់អង្គការសហប្រជាជាតិសម្រាប់អឺរ៉ុប។ ភាគីណាដែលបានជូនដំណឹង ជំទាស់ ឬការមិនទទួលយកអនុលោមភាពអនុគ្រោះភ្លាមៗនោះទេ អាចទទួលយកអនុលោមភាពអនុគ្រោះនោះនៅពេលក្រោយបាន ដោយមានការអនុញ្ញាតពីគណៈកម្មាធិការរដ្ឋបាល និងត្រូវជូនដំណឹងទៅលេខាធិការប្រតិបត្តិនៃគណៈកម្មការសេដ្ឋកិច្ចរបស់អង្គការសហប្រជាជាតិសម្រាប់អឺរ៉ុបអំពីការសម្រេចចិត្តរបស់ខ្លួន។

៨- គណៈកម្មាធិការរដ្ឋបាលត្រូវកំណត់ឱ្យបានច្បាស់លាស់នៅក្នុងសេចក្តីសម្រេចលើការអនុញ្ញាតដែលមានរយៈពេលមិនតិចជាង៣៦(សាមសិបប្រាំមួយ)ខែឡើយ។ ភាគីកិច្ចព្រមព្រៀងដែលកំពុងអនុវត្តបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ត្រូវទទួលយកអនុលោមភាពអនុគ្រោះ យ៉ាងហោចណាស់ រហូតដល់ផុតរយៈពេលកំណត់នោះ ប្រសិនបើមាន ឬនៅពេលដែលបទប្បញ្ញត្តិអង្គការសហប្រជាជាតិ នោះត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់ ស្របតាមកថាខណ្ឌ៩និង១០នៃបទប្បញ្ញត្តិបន្ថែមនេះដើម្បីដាក់បញ្ចូលនូវបច្ចេកវិទ្យាថ្មីដែលបានចែងក្នុងអនុលោមភាពអនុគ្រោះនោះ។ ភាគីកិច្ចព្រមព្រៀង អាចបដិសេធចំពោះអនុលោមភាពលើកំណែមុននៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិនោះ និងត្រូវទទួលយកអនុលោមភាពអនុគ្រោះនោះ រហូតដល់កាលបរិច្ឆេទណាមួយមកដល់មុន។

ភាគីកិច្ចព្រមព្រៀងដែលត្រូវបានអនុញ្ញាតឱ្យផ្តល់អនុលោមភាពអនុគ្រោះ ត្រូវធានាថា រោងចក្រផលិតគោរពតាមការកំណត់ទាំងអស់ដែលទាក់ទងនឹងអនុលោមភាពនេះយ៉ាងខ្ជាប់ខ្ជួន និងធានាថាទម្រង់នៃការជូនដំណឹងត្រូវផ្អែកលើការអនុគ្រោះដែលបានអនុញ្ញាតដោយគណៈកម្មាធិការរដ្ឋបាល។

៩- ក្នុងពេលជាមួយគ្នានេះដែរ គណៈកម្មាធិការរដ្ឋបាលត្រូវជូនដំណឹងដល់អនុក្រុមការងារដែលទទួលបន្ទុកចំពោះបទប្បញ្ញត្តិអង្គការសហប្រជាជាតិអំពីការអនុញ្ញាតផ្តល់អនុលោមភាពអនុគ្រោះនោះ។

៤១/៤៤

ភាគីកិច្ចព្រមព្រៀងដែលត្រូវបានអនុញ្ញាតឱ្យផ្តល់អនុលោមភាពអនុគ្រោះ ត្រូវបញ្ជូនទៅអនុក្រុមការងារទទួលបន្ទុកលើបទប្បញ្ញត្តិអង្គការសហប្រជាជាតិនូវសំណើសុំធ្វើវិសោធនកម្មទៅលើបទប្បញ្ញត្តិអង្គការសហប្រជាជាតិ ដែលអនុលោមភាពអនុគ្រោះត្រូវបានស្នើសុំ ក្នុងគោលបំណងដើម្បីសម្របទៅនឹងការវិវឌ្ឍនៃបច្ចេកវិទ្យា។ ការដាក់ស្នើនេះត្រូវធ្វើឡើងយ៉ាងយូរត្រឹមសម័យប្រជុំបន្ទាប់របស់អនុក្រុមការងារ ក្រោយពីការជូនដំណឹងពីសេចក្តីសម្រេចស្តីពីការអនុញ្ញាតរបស់គណៈកម្មាធិការរដ្ឋបាល ស្របតាមកថាខណ្ឌ៦នៃបទប្បញ្ញត្តិបន្ថែមនេះ។

១០- នៅពេលដែលបទប្បញ្ញត្តិអង្គការសហប្រជាជាតិត្រូវបានធ្វើវិសោធនកម្មដាក់បញ្ចូលនូវបច្ចេកវិទ្យាថ្មីដែលអនុលោមភាពអនុគ្រោះនោះត្រូវបានផ្តល់ឱ្យ និងបានចូលជាធរមានភ្លាម រោងចក្រត្រូវបានអនុញ្ញាតឱ្យដាក់ស្នើសុំអនុលោមភាពចំពោះប្រភេទ ដោយយោងតាមបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលបានធ្វើវិសោធនកម្មថ្មី ដោយជំនួសទៅលើអនុលោមភាពអនុគ្រោះចំពោះបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលបានផ្តល់ជូនពីមុន។ អាជ្ញាធរផ្តល់អនុលោមភាពដែលផ្តល់អនុលោមភាពចំពោះប្រភេទ ត្រូវដកហូតអនុលោមភាពអនុគ្រោះឬជូនដំណឹងដល់អាជ្ញាធរផ្តល់អនុលោមភាពដែលបានផ្តល់អនុលោមភាពអនុគ្រោះថា អនុលោមភាពអនុគ្រោះនេះនឹងត្រូវបានដកហូត ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

១១- ប្រសិនបើនីតិវិធីក្នុងការធ្វើវិសោធនកម្មបទប្បញ្ញត្តិអង្គការសហប្រជាជាតិមិនត្រូវបានបញ្ចប់មុនពេលផុតសុពលភាពនៃរយៈពេលកំណត់ដែលបានចែងនៅក្នុងកថាខណ្ឌ៨ នៃបទប្បញ្ញត្តិបន្ថែមនេះ សុពលភាពនៃអនុលោមភាពអនុគ្រោះអាចត្រូវបានពន្យារ ទៅតាមសំណើរបស់ភាគីកិច្ចព្រមព្រៀងដែលបានផ្តល់អនុលោមភាពអនុគ្រោះនោះ ដែលសេចក្តីសម្រេចបានអនុម័តស្របតាមនីតិវិធីដែលមានចែងនៅក្នុងកថាខណ្ឌ២និង៣នៃបទប្បញ្ញត្តិបន្ថែមនេះ។ ទោះបីយ៉ាងនេះក្តី ប្រសិនបើភាគីកិច្ចព្រមព្រៀងដែលត្រូវបានអនុញ្ញាតឱ្យផ្តល់អនុលោមភាពអនុគ្រោះ ខកខានក្នុងការដាក់សំណើសុំធ្វើវិសោធនកម្មបទប្បញ្ញត្តិអង្គការសហប្រជាជាតិមុនកាលកំណត់ដែលបានចែងនៅក្នុងកថាខណ្ឌ៩នៃបទប្បញ្ញត្តិបន្ថែមនេះ ភាគីកិច្ចព្រមព្រៀងនោះត្រូវដកហូតភ្លាមៗនូវអនុលោមភាពអនុគ្រោះនោះ តែត្រូវពិចារណាលើរយៈពេលកំណត់ ដូចមានចែងក្នុងកថាខណ្ឌ៨នៃបទប្បញ្ញត្តិបន្ថែមនេះ។ ភាគីកិច្ចព្រមព្រៀងដែលបានដកហូតអនុលោមភាពអនុគ្រោះ ត្រូវជូនដំណឹងដល់គណៈកម្មាធិការរដ្ឋបាលអំពីការដកហូតនេះនៅសម័យប្រជុំបន្ទាប់។

១២- ប្រសិនបើគណៈកម្មាធិការរដ្ឋបាលសម្រេចបដិសេធការផ្តល់អនុលោមភាពអនុគ្រោះ ភាគីកិច្ចព្រមព្រៀងដែលផ្តល់អនុលោមភាពបណ្តោះអាសន្ន ដូចមានចែងនៅក្នុងកថាខណ្ឌ២នៃបទប្បញ្ញត្តិបន្ថែមនេះ អាចដកហូតអនុលោមភាពបណ្តោះអាសន្ននេះ។ ក្នុងករណីនេះ ភាគីកិច្ចព្រមព្រៀងត្រូវជូនដំណឹងជាបន្ទាន់ដល់អ្នកទទួលបានអនុលោមភាពបណ្តោះអាសន្ននេះថា អនុលោមភាពបណ្តោះអាសន្នដែលបានផ្តល់ជូនស្របតាមកថាខណ្ឌ២នៃបទប្បញ្ញត្តិបន្ថែមនេះនឹងត្រូវដកហូតវិញក្នុងរយៈពេល ៦(ប្រាំមួយ)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចដកហូត តែត្រូវពិចារណាថា អនុលោមភាពបណ្តោះអាសន្នត្រូវមានសុពលភាពអនុវត្តយ៉ាងតិចរយៈពេល១២(ដប់ពីរ)ខែ ដោយគិតចាប់ពីថ្ងៃដែលបានផ្តល់ជូន រហូតដល់ថ្ងៃដកហូត។

៤២/៤៤

បទប្បញ្ញត្តិបន្ថែមទី៨
លក្ខខណ្ឌទូទៅសម្រាប់វិធីសាស្ត្រធ្វើតេស្តនិម្មិត

១- លំនាំនៃតេស្តនិម្មិត

ការពិពណ៌នានិងការធ្វើតេស្តនិម្មិតត្រូវមានទម្រង់មូលដ្ឋាន ដូចខាងក្រោម៖

- គោលបំណង
- គំរូនៃបង្គុំ
- លក្ខខណ្ឌព្រំដែននៃការគណនា
- ការប៉ាន់ស្មានលើទម្ងន់ផ្ទុក
- ការគណនា
- ការវាយតម្លៃ
- ការចងក្រងឯកសារ។

២- មូលដ្ឋានគ្រឹះនៃដំណើរការពិសោធន៍ក្នុងកុំព្យូទ័រនិងការគណនា

២.១- ម៉ូដែលគណិតសាស្ត្រ

ម៉ូដែលគណិតសាស្ត្រត្រូវផ្តល់ដោយរោងចក្រផលិត ហើយត្រូវឆ្លុះបញ្ចាំងអំពីទ្រង់ទ្រាយនៃបង្គុំយានយន្ត ឧបករណ៍ និងគ្រឿងបន្លាស់ ដែលត្រូវធ្វើតេស្តស្របតាមលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិដែលពាក់ព័ន្ធ និងលក្ខខណ្ឌព្រំដែននៃការគណនា។

បញ្ញត្តិដូចគ្នានេះត្រូវប្រើប្រាស់គោលការណ៍អនុវត្តដូចគ្នា សម្រាប់ការធ្វើតេស្តគ្រឿងបង្គុំដោយឡែកពីយានយន្ត។

២.២- ដំណើរការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃម៉ូដែលគណិតសាស្ត្រ

ម៉ូដែលគណិតសាស្ត្រត្រូវផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ ដោយប្រៀបធៀបជាមួយលក្ខខណ្ឌតេស្តជាក់ស្តែង។

ចំពោះលទ្ធផលនោះ ការធ្វើតេស្តជាក់ស្តែងត្រូវធ្វើឡើងឱ្យបានសមស្រប សម្រាប់គោលបំណងនៃការប្រៀបធៀបលទ្ធផលដែលទទួលបាននៅពេលប្រើម៉ូដែលគណិតសាស្ត្រជាមួយនឹងលទ្ធផលនៃការធ្វើតេស្តជាក់ស្តែង។ ភាពជាក់ស្តែងនៃលទ្ធផលតេស្តនឹងត្រូវបានបង្ហាញ។ របាយការណ៍ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ ត្រូវរៀបចំឡើងដោយរោងចក្រផលិតឬដោយអង្គភាពបច្ចេកទេស និងត្រូវបញ្ជូនទៅអាជ្ញាធរផ្តល់អនុលោមភាព។

រាល់ការផ្លាស់ប្តូរដែលបានធ្វើឡើងចំពោះម៉ូដែលគណិតសាស្ត្រឬចំពោះកម្មវិធី ដែលនឹងធ្វើឱ្យទៅជាមោឃៈនូវរបាយការណ៍ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ ត្រូវជូនដំណឹងទៅអាជ្ញាធរផ្តល់អនុលោមភាពដែលទាមទារឱ្យមានការរៀបចំដំណើរការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវឡើងវិញ។

២.៣- ការចងក្រងឯកសារ

ទិន្នន័យនិងឧបករណ៍ជំនួយដែលត្រូវបានប្រើសម្រាប់ដំណើរការពិសោធក្នុងកុំព្យូទ័រ និងការគណនា ត្រូវរៀបចំនិងចងក្រងដោយរោងចក្រផលិតក្នុងទម្រង់សមស្របមួយសម្រាប់អង្គភាពបច្ចេកទេស។

៣- ឧបករណ៍និងការគាំទ្រ

រោងចក្រផលិតត្រូវផ្គត់ផ្គង់ឬផ្តល់ជូននូវសិទ្ធិប្រើប្រាស់ឧបករណ៍ រួមទាំងកម្មវិធីសមស្របតាមការស្នើសុំរបស់អាជ្ញាធរផ្តល់អនុលោមភាពឬអង្គភាពបច្ចេកទេស។

លើសពីនេះទៀត រោងចក្រផលិតត្រូវផ្តល់ការគាំទ្រសមស្របដល់អាជ្ញាធរផ្តល់អនុលោមភាព ឬអង្គភាពបច្ចេកទេស។

ទោះបីជាមានការផ្តល់សិទ្ធិក្នុងការប្រើប្រាស់និងការគាំទ្រចំពោះអង្គភាពបច្ចេកទេសក៏ដោយ កាតព្វកិច្ចនានានៃអង្គភាពបច្ចេកទេសនៅតែរក្សាដដែលទាក់ទងនឹងជំនាញរបស់បុគ្គលិក ការទូទាត់លើសិទ្ធិអាជ្ញាបណ្ណ និងការរក្សាការសម្ងាត់។

E/ECE/TRANS/505/Rev.3

20 October 2017

Agreement

Concerning the Adoption of Harmonized Technical United Nations Regulations for Wheeled Vehicles, Equipment and Parts which can be Fitted and/or be Used on Wheeled Vehicles and the Conditions for Reciprocal Recognition of Approvals Granted on the Basis of these United Nations Regulations*

Revision 3

(Including the amendments which entered into force on 14 September 2017)

This document is meant purely as documentation tool. The authentic and legal binding text is: ECE/TRANS/WP.29/2016/2.

UNITED NATIONS

* Former titles of the Agreement:
Agreement concerning the Adoption of Uniform Conditions of Approval and Reciprocal Recognition of Approval for Motor Vehicle Equipment and Parts, done at Geneva on 20 March 1958 (original version);
Agreement concerning the Adoption of Uniform Technical Prescriptions for Wheeled Vehicles, Equipment and Parts which can be Fitted and/or be Used on Wheeled Vehicles and the Conditions for Reciprocal Recognition of Approvals Granted on the Basis of these Prescriptions, done at Geneva on 5 October 1995 (Revision 2).

Agreement concerning the Adoption of Harmonized Technical United Nations Regulations for Wheeled Vehicles, Equipment and Parts which can be Fitted and/or be Used on Wheeled Vehicles and the Conditions for Reciprocal Recognition of Approvals Granted on the Basis of these United Nations Regulations[1]

Preamble

THE CONTRACTING PARTIES,

HAVING DECIDED to amend the Agreement Concerning the Adoption of Uniform Conditions of Approval and Reciprocal Recognition of Approval for Motor Vehicle Equipment and Parts, done at Geneva on 20 March 1958, as amended on 16 October 1995, and

DESIRING to reduce technical barriers to international trade by defining harmonized technical UN Regulations that it will suffice for certain wheeled vehicles, equipment and parts to fulfil in order to be used in their countries or regions,

RECOGNIZING the importance of safety, environmental protection, energy efficiency and anti-theft performance of wheeled vehicles, equipment and parts, which can be fitted and/or be used on wheeled vehicles for the development of regulations that are technically and economically feasible and adapted to technical progress,

DESIRING to apply these UN Regulations whenever possible in their countries or regions,

DESIRING to facilitate the acceptance in their countries of the vehicles, equipment and parts, where approved according to these UN Regulations by the approval authorities of another Contracting Party,

DESIRING to establish an International Whole Vehicle Type Approval scheme (IWVTA) within the framework of the Agreement to increase the advantages of individual UN Regulations annexed to the Agreement and so create opportunities to simplify implementation by Contracting Parties and the wider adoption of mutual recognition of type approvals for whole vehicles, and,

DESIRING to increase the number of Contracting Parties to the Agreement by improving its functioning and reliability, and thus ensure that it remains the key international framework for the harmonization of technical regulations in the automotive sector,

HAVE AGREED as follows:

---

[1] Former titles of the Agreement:
Agreement concerning the Adoption of Uniform Conditions of Approval and Reciprocal Recognition of Approval for Motor Vehicle Equipment and Parts, done at Geneva on 20 March 1958 (original version);
Agreement concerning the Adoption of Uniform Technical Prescriptions for Wheeled Vehicles, Equipment and Parts which can be Fitted and/or be Used on Wheeled Vehicles and the Conditions for Reciprocal Recognition of Approvals Granted on the Basis of these Prescriptions, done at Geneva on 5 October 1995 (Revision 2).

Article 1

1. The Contracting Parties shall establish, through an Administrative Committee made up of all the Contracting Parties in conformity with the rules of procedure set out in the Appendix to this Agreement and on the basis of the following articles, paragraphs, UN Regulations for wheeled vehicles, equipment and parts which can be fitted and/or be used on wheeled vehicles. Conditions for granting type approvals and their reciprocal recognition will be included for use by Contracting Parties which choose to implement Regulations through type approval.

For the purposes of this Agreement:

The term "wheeled vehicles, equipment and parts" shall include any wheeled vehicles, equipment and parts whose characteristics have a bearing on vehicle safety, protection of the environment, energy saving and the performance of anti-theft technology.

The term "type approval pursuant to a UN Regulation" indicates an administrative procedure by which the approval authorities of one Contracting Party declare, after carrying out the required verifications that a type of vehicle, equipment or part submitted by the manufacturer conforms to the requirements of the given UN Regulation. Afterwards the manufacturer certifies that each vehicle, equipment or parts put on the market were produced to be identical with the approved product.

The term "whole vehicle type approval" indicates that type approvals granted pursuant to applicable UN Regulations for wheeled vehicles, equipment and parts of a vehicle are integrated into an approval of the whole vehicle according to the provisions of the administrative IWVTA system.

The term "version of a UN Regulation" indicates that a UN Regulation, following its adoption and establishment, may subsequently be amended following the procedures described in this Agreement, in particular Article 12. The unamended UN Regulation as well as the UN Regulation, after integration of subsequent amendment(s), are considered to be separate versions of that UN Regulation.

The term "applying a UN Regulation" indicates that a UN Regulation enters into force for a Contracting Party. When doing so, Contracting Parties have the possibility to keep their own national/regional legislation. If they wish, they may substitute their national/regional legislation by the requirements of the UN Regulations they are applying, but they are not bound by the Agreement to do so. However, Contracting Parties shall accept, as an alternative to the relevant part of their national/regional legislation, UN type approvals granted pursuant to the latest version of UN Regulations applied in their country/region. The rights and obligations of Contracting Parties applying a UN Regulation are detailed in the various articles of this Agreement.

For the application of the UN Regulations there could be various administrative procedures alternative to type approval. The only alternative procedure generally known and applied in certain member States of the Economic Commission for Europe is the self-certification by which the manufacturer certifies, without any preliminary administrative control, that each product put on the market conforms to the given UN Regulation; the competent administrative authorities may verify by random sampling on the market that the self-certified products comply with the requirements of the given UN Regulation.

2. The Administrative Committee shall be composed of all the Contracting Parties in accordance with the rules of procedure set out in the Appendix.

A UN Regulation, after having been established in accordance with the procedure indicated in the Appendix, shall be communicated by the Administrative

Committee to the Secretary-General of the United Nations, hereinafter called "Secretary-General". As soon as possible thereafter, the Secretary-General shall give notification of this UN Regulation to the Contracting Parties.

The UN Regulation will be considered as adopted unless, within a period of six months from its notification by the Secretary-General, more than one-fifth of the Contracting Parties at the time of notification have informed the Secretary-General of their disagreement with the UN Regulation.

The UN Regulation shall cover the following:

(a) Wheeled vehicles, equipment or parts concerned;

(b) Technical requirements, which shall be performance oriented wherever appropriate and not design-restrictive, that give objective consideration to available technologies, costs and benefits as appropriate, and may include alternatives;

(c) Test methods by which any performance requirements are to be demonstrated;

(d) Conditions for granting type approval and their reciprocal recognition including administrative provisions, any approval markings and conditions for ensuring conformity of production;

(e) The date(s) on which the UN Regulation enters into force, including the date when Contracting Parties applying it can issue approvals pursuant to that UN Regulation, and the date from which they shall accept approvals (if different);

(f) An information document to be provided by the manufacturer.

The UN Regulation may, if needed, include references to the laboratories accredited by the approval authorities where acceptance tests of the types of wheeled vehicles, equipment or parts submitted for approval shall be carried out.

In addition to the above-mentioned UN Regulations, this Agreement provides for establishing a UN Regulation to introduce a system of Whole Vehicle Type Approval. This UN Regulation shall set the scope, administrative procedures, and technical requirements that can include different levels of stringency in one version of the said UN Regulation.

Notwithstanding other provisions of Article 1 and Article 12, a Contracting Party applying the UN Regulation on IWVTA shall only be obliged to accept those type approvals granted pursuant to the highest level of stringency of the latest version of the said UN Regulation.

This Agreement also includes Schedules of Administrative and Procedural Provisions applicable to all UN Regulations annexed to this Agreement and to all Contracting Parties applying one or more UN Regulations.

3. When a UN Regulation has been adopted, the Secretary-General shall so notify as soon as possible all the Contracting Parties, specifying which Contracting Parties have objected, or have notified their agreement but intention not to begin applying the UN Regulation at the date of entry into force, and in respect of which the UN Regulation shall not enter into force.

4. The adopted UN Regulation shall enter into force on the date(s) specified therein as a UN Regulation annexed to this Agreement for all Contracting Parties which have not notified either their disagreement, or their intention not to apply it on that date.

5. When depositing its instrument of accession, any new Contracting Party may declare that it will not apply certain UN Regulations then annexed to this Agreement or that it will not apply any of them. If, at that time, the procedure laid down in paragraphs 2, 3, and 4 of this Article is in progress for a draft or adopted UN Regulation, the Secretary-General shall communicate such draft or adopted UN Regulation to the new Contracting Party and it shall enter into force as a UN Regulation for the new Contracting Party unless this Contracting Party notifies its disagreement with the adopted UN Regulation within a period of six months after the deposit of its instrument of accession. The Secretary-General shall notify all the Contracting Parties of the date of such entry into force. The Secretary-General shall also communicate to them all declarations concerning the non-application of certain UN Regulations that any Contracting Party may make in accordance with the terms of this paragraph.

6. Any Contracting Party applying a UN Regulation may at any time notify the Secretary-General, subject to one year's notice, about its intention to cease applying that UN Regulation. Such notification shall be communicated by the Secretary-General to the other Contracting Parties.

Approvals previously granted pursuant to that UN Regulation by that Contracting Party shall remain valid unless they are withdrawn in accordance with the provisions of Article 4.

If a Contracting Party ceases to issue approvals to a UN Regulation it shall:

(a) Maintain proper supervision on conformity of production of products for which it previously granted type approval;

(b) Take the necessary steps set out in Article 4 when advised of non-conformity by a Contracting Party that continues to apply the UN Regulation;

(c) Continue to notify the other Contracting Parties of withdrawal of approvals as set out in Article 5;

(d) Continue to grant extensions to existing approvals.

7. Any Contracting Party not applying a UN Regulation may at any time notify the Secretary-General that it intends henceforth to apply it and the UN Regulation will then enter into force for this Party on the sixtieth day after this notification. The Secretary-General shall notify all the Contracting Parties of every entry into force of a UN Regulation for a new Contracting Party affected in accordance with the terms of this paragraph.

8. The Contracting Parties for which a UN Regulation is in force shall hereinafter be referred to as "the Contracting Parties applying a UN Regulation".

Article 2

1. Each Contracting Party applying UN Regulations largely through type approval shall grant the type approvals and approval markings described in any UN Regulation for the types of wheeled vehicles, equipment or parts covered by the UN Regulation, provided that it has the technical competence and is satisfied with the arrangements for ensuring conformity of the product with the approved type. Each Contracting Party which grants type approval shall take the necessary measures as set out in Schedule 1 annexed to this Agreement to verify that adequate arrangements have been made to ensure that wheeled vehicles, equipment and parts are manufactured in conformity with the approved type.

2. Each Contracting Party issuing type approvals pursuant to a UN Regulation shall specify an approval authority for the UN Regulation. The approval authority shall have the responsibility for all aspects of type approval pursuant to the said UN Regulation. This approval authority may designate technical services to carry out on its behalf the testing and inspections necessary for the verifications required in paragraph 1 of this article. Contracting Parties shall ensure that technical services are assessed, designated and notified in accordance with the requirements set out in Schedule 2 annexed to this Agreement.

3. The type approvals, approval markings and identifiers for the types of wheeled vehicles, equipment and parts shall be specified in the UN Regulation and granted in accordance with the procedures set out in Schedules 3 to 5 annexed to this Agreement.

4. Each Contracting Party applying a UN Regulation shall refuse to grant the type approvals and approval markings covered by the UN Regulation if the above-mentioned conditions are not complied with.

Article 3

1. Wheeled vehicles, equipment or parts for which type approvals have been issued by a Contracting Party in accordance with Article 2 of this Agreement, shall be held to be in conformity with the relevant part of the national legislation of all the Contracting Parties applying the said UN Regulation.

2. Contracting Parties applying UN Regulations shall, by mutual recognition, accept for the placement in their markets, and subject to the provisions of Articles 1, 8 and 12 as well as any special provisions within these UN Regulations, type approvals granted pursuant to these UN Regulations, without requiring any further testing, documentation, certification or marking concerning these type approvals.

Article 4

1. Should a Contracting Party applying a UN Regulation find that certain wheeled vehicles, equipment or parts bearing approval markings issued under the said UN Regulation by one of the Contracting Parties, do not conform to the approved types or the requirements of the said UN Regulation, they shall advise the approval authority of the Contracting Party which issued the approval.

The Contracting Party that issued the approval shall take the necessary steps to ensure that the non-conformity is rectified.

2. When the non-conformity is due to non-compliance with the technical requirements specified in a UN Regulation, as referred to in Article 1.2.(b), the Contracting Party that issued the approval shall immediately inform all other Contracting Parties about the situation and shall provide regular advice to Contracting Parties of the steps it is taking, which may include, if necessary, the withdrawal of the approval.

After having considered the potential impact on vehicle safety, protection of the environment, energy saving or the performance of anti-theft technology, Contracting Parties may prohibit the sale and use of such wheeled vehicles, equipment or parts in their territory until this non-conformity is rectified. In such a case, these Contracting Parties shall inform the secretariat of the Administrative Committee of the measures taken. For resolution of disputes between the Contracting Parties, the procedure provided in Article 10.4 shall apply.

3. Notwithstanding the provisions of paragraph 1 of this Article, if a non-conforming product, as referred to in paragraph 2 of this Article, has not been brought into conformity within a period of three months, the Contracting Party responsible for the approval shall temporarily or permanently withdraw the approval. By exception, this period may be extended by a period not exceeding three months unless one or more Contracting

Parties applying the concerned UN Regulation object. When the period is being extended, the Contracting Party that issued the approval shall, within the initial three-month period, notify all Contracting Parties applying the concerned UN Regulation of their intention to extend the period in which the non-conformity shall be rectified and provide a justification for such extension.

4. When the non-conformity is due to non-compliance with the administrative provisions, approval markings, conditions for conformity of production or the information document specified in a UN Regulation, as referred to in Article 1.2.(d) and 1.2.(f), the Contracting Party that issued the approval shall temporarily or permanently withdraw the approval if the non-conformity has not been rectified within a period of six months.

5. Paragraphs 1 to 4 of this Article also apply in the situation where the Contracting Party responsible for issuing of the approval itself finds that certain wheeled vehicles, equipment or parts bearing approval markings do not conform to the approved types or the requirements of a UN Regulation.

Article 5

1. The approval authorities of each Contracting Party applying UN Regulations shall send upon the request from the other Contracting Parties, a list of the wheeled vehicles, equipment or parts, of which it has refused to grant or has withdrawn approvals.
